**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បរិវត្តកម្មឌីជីថលលើការចុះបញ្ជី កម្មសិទ្ធិអចលនវត្ថុនៅកម្ពុជា

(Digital Transformation on Initial Registration of Immovable Property Ownership in Cambodia)

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លោក ខន្យ វ៉ាឃីម**

ណែនាំដោយ
សាស្ត្រាចារ្យបណ្ឌិត **ហាប់ ផល្លី**

ថ្នាក់**បរិញ្ញាបត្រនីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បរិវត្តកម្មឌីជីថលលើការចុះបញ្ជី
# កម្មសិទ្ធិអចលនវត្ថុនៅកម្ពុជា

(Digital Transformation on Initial Registration

of Immovable Property Ownership in Cambodia)

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក. ខឲ្យ រ៉ាឃីម**

ណែនាំដោយ

សាស្ត្រាចារ្យបណ្ឌិត **ហាប់ ផល្លី**


ថ្នាក់**បរិញ្ញាបត្រនីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# ការឧទ្ទិសស្នាដៃ

ខ្ញុំបាទសូមឧទ្ទិសស្នាដៃនេះជូន **លោកតាជាទីស្រលាញ់ ថាវ ស៊ីណារ៉េត និងលោកឪពុក វង្ស វិចិត្រ** ដែលលោកទាំងពីរបានលះបង់ពេលវេលាអស់ពេញមួយជីវិត ក្នុងការមើលថែកូនចៅតាំងពីកុមារភាព ចំណាយកម្លាំងកាយចិត្ត ប្រាជ្ញា និងស្មារតីព្រហ្មវិហារធម៌ទាំង ៤ ក្នុងការណែនាំជាកូន ជាចៅម្នាក់នេះឱ្យដើរទៅរកផ្លូវត្រឹមត្រូវ ជាពលរដ្ឋល្អដែលសង្គមត្រូវការ និងជាបញ្ញាវន្តសំខាន់ដែលប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់នាអនាគត។

ខ្ញុំបាទពិតជាមានសេចក្តីរន្ធត់ក្រៃលែងក្រោយពីទទួលបានដំណឹងថា លោកតាបានទទួលមរណភាពកាលពីវេលាម៉ោង ១០៖៥៥ នាទីព្រឹក នាថ្ងៃសីល ថ្ងៃសៅរ៍ ៨រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងជន្មាយុ ៨៣ឆ្នាំ ដោយជរាពាធ។ និងលោកឪពុក បានទទួលមរណភាពកាលពីឆ្នាំ ២០០៨ ដោយរោគាពាធ។

កន្លងមក លោកតាបានដឹកដៃចៅទៅសាលារៀន បង្ហាត់បង្រៀន បៀនប្រដៅដ៏មានអត្ថន័យ រហូតដល់ចៅធំដឹងក្តី និងមានតម្លៃដែលមិនអាចធ្វើការកាត់ថ្លៃបាន។ អ្វីដែលលោកតាចង់បាន និងមើលឃើញ គឺសង្ឃឹមលើចៅម្នាក់នេះដែលអាចជាទីពឹងពាក់ទៅដល់ក្រុមគ្រួសារ និងសង្គមជាតិនាពេលខាងមុខ។

ខ្ញុំបាទ សូមគោរពបួងសួងឱ្យវិញ្ញាណក្ខន្ធរបស់ **លោកតាជាទីស្រលាញ់ ថាវ ស៊ីណារ៉េត និងលោកឪពុក វង្ស វិចិត្រ** ឱ្យបានទៅកាន់សុគតិភពជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ វង្ស វ៉ាឃីម ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់២៤ ឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងឱកាសទទួលបានការរៀបរៀងសារណាបទ ក្រោមប្រធានបទស្តីពី "**បរិវត្តកម្មឌីជីថលលើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុនៅកម្ពុជា**" ឱ្យលេចជារូបរាងឡើង ដើម្បីបញ្ជាក់ពីការស្រាវជ្រាវបញ្ចប់ថ្នាក់សិក្សាបរិញ្ញាបត្រ។

ឆ្លៀតឱកាសនេះ កូនសូមគោរពលំឱនកាយក្រាបថ្វាយបង្គំ ដោយកិច្ចប្រណិប័តន៍សម្តែងកិច្ចកតញ្ញូយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះគុណបំបាច់ធំធេងរបស់ **ម៉ាក់យាយ ពុធ ម៉ឺនសុវណ្ណរេខា និងអ្នកម្តាយ ថាវ សោភណ្ឌ** ដែលបានផ្តល់កំណើតដល់រូបកូនចៅ ចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់ អប់រំទូន្មានកូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានផ្គត់ផ្គង់ទំនុកបម្រុង និងធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានសិក្សារៀនសូត្រចាប់តាំងពីថ្នាក់មត្តេយ្យសិក្សា រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ដោយគុណូបការៈ គុណយ៉ាងអនេកប្បការ ដោយកូនទទួលបានចំណេះដឹងដ៏ថ្លៃថ្លា និងពុំអាចកាត់ថ្លៃបាន របស់លោកអ្នកមានគុណទាំងទ្វេព្រមទាំងក្រុមគ្រួសារ។

សូមគោរពថ្លែងអំណរគុណ **ម្តាយមីង ថាច់ ច័ន្ទលក្ខិណា** ដែលបានផ្តល់ឱកាស និងទំនុកបម្រុងថវិកាដល់ការសិក្សារៀនសូត្រគ្រប់ពេលវេលា ដើម្បីឱ្យក្មួយប្រុសបានរៀនចេះដឹងខ្ពង់ខ្ពស់ ជាពិសេស ជួយដាស់តឿនដល់ក្មួយជានិច្ចឱ្យខិតខំប្រឹងប្រែង រៀនដោះស្រាយបញ្ហា ធ្វើខ្លួនជាពលរដ្ឋល្អ និងជាបញ្ញាវន្តនៅក្នុងសង្គម។

សូមគោរពថ្លែងអំណរគុណ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្របសម្រួលខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ជាចំណេះដឹងដល់រូបខ្ញុំ ព្រមទាំងបំណិនជីវិតផ្សេងៗក្នុងរយៈពេលបួនឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រកន្លងមកនេះ និងរួមទាំងគណៈកម្មការវាយតម្លៃដែលបានផ្តល់យោបល់ណែនាំដ៏ល្អទាក់ទងនឹងសារណាបទមួយនេះ។

សូមគោរពថ្លែងអំណរគុណជ្រាលជ្រៅជូនចំពោះ ***សាស្ត្រាចារ្យបណ្ឌិត ហាប់ ផល្វី សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច*** ដែលបានផ្តល់ឱកាសដល់រូបខ្ញុំបាទ ក្នុងការផ្តល់ពីភាពជឿជាក់ និងទំនុកចិត្តឱ្យធ្វើហាត់ការរយៈពេល ១ ឆ្នាំពេញប្រតិទិន គិតចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ១ ខែសីហា ឆ្នាំ ២០២៣ ដែលជួយបង្កើនចំណេះដឹង, បំពេញចន្លោះខ្វះខាតផ្នែកច្បាប់ ជាពិសេសផ្តោតសំខាន់លើវិស័យដីធ្លីនិងភូមិបាល, ផ្តល់ជាទីកន្លែងសិក្សាស្រាវជ្រាវ, ចងក្រងស្នាដៃ, ឯកសារពាក់ព័ន្ធនានា និងរួមចំណែកក្នុងការចងក្រងស្នាដៃនេះឡើងផងដែរ។ ម្យ៉ាងវិញ លោកក៏ជា **សាស្ត្រាចារ្យដឹកនាំ** នៃកិច្ចការសារណាបទដល់រូបខ្ញុំយ៉ាងទំនុកចិត្តខ្ពង់ខ្ពស់បំផុត។ លោកបានតម្រាយតម្រង់ផ្លូវ-គោលដៅធ្វើយ៉ាងណាឱ្យស្នាដៃមួយនេះ ឈានចូលដល់ការសម្រេចបានការតាក់តែងជាកិច្ចការសារណាបទនេះ និងដើម្បីអាចទទួលបានការ

ការពារដោយជោគជ័យ ជាស្នូលគុណប្រយោជន៍បម្រើដល់វិស័យពាក់ព័ន្ធនានា ក្នុងសង្គមអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើនបន្ថែមមួយកម្រិតទៀត។

សូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមបណ្ឌិត មាស បូរ៉ា** ដែលបានណែនាំដោយប្រយោលទៅលើអត្ថន័យ ខ្លឹមសារ និងយុទ្ធវិធីដល់ការកំណត់ពីទម្រង់បញ្ហា និងដំណោះស្រាយស្រាវជ្រាវជារួម។

សូមគោរពថ្លែងអំណរគុណជូនចំពោះ **សាស្ត្រាចារ្យជំនួយបណ្ឌិត ព្រុំ រិទ្ធី** ដែលបានចូលរួមផ្តល់ជាមតិទូទៅសំខាន់ៗ ផ្តល់ជាអនុសាសន៍ ការតម្រាយតម្រង់ផ្លូវជាយុទ្ធសាស្ត្រ និងយុទ្ធវិធីទៅលើចំណុចខ្លឹមស្រាវជ្រាវជាគន្លឹះមិនអាចខ្វះបានលើថ្នាលស្រាវជ្រាវរបស់ខ្ញុំបាទ។

សូមគោរពថ្លែងអំណរគុណជូនចំពោះ **សាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សកក្កដា** បានចូលរួមផ្តល់គន្លឹះនៃមាគ៌ាដ៏សំខាន់ៗ ដល់ការសរសេរស្នាដៃនេះឱ្យមានរបៀបរៀបរយ និងបានផ្តល់ជាឱកាសដល់ខ្ញុំបាទក្នុងការសាកល្បងស្រាវជ្រាវបឋម ទៅលើប្រធានបទនេះដោយសង្ខេបតូចមួយ និងបានការពារបទបង្ហាញលក្ខណៈកិច្ចការស្រាវជ្រាវនៅក្នុងថ្នាក់រៀនប្រកបទៅដោយភាពរលូន និងជោគជ័យ។

ខ្ញុំបាទសូមអរគុណ **មេធាវី ឃាន ហ៊្គិចហ័ង** ដែលបានចូលរួមជាមតិយោបល់ ការអង្កេត វិភាគ ត្រិះរិះ ផ្តល់ជាទំនុកឯកសារ បកប្រែភាសាចិន អនុសាសន៍នានា និងជួយសម្របសម្រួលដល់កិច្ចការសារណាបទនេះរហូតបានបញ្ចប់ទៅយ៉ាងមានគុណវុឌ្ឍិភាព និងប្រសិទ្ធភាព។

សូមអរគុណ **សិស្សច្បង និងមិត្តភក្តិបណ្តាជំនាញផ្សេងៗ** ដែលបានលើកទឹកចិត្ត ចូលរួមជាមតិយោបល់ផ្តល់ជាឯកសារស្រាវជ្រាវសំខាន់ៗ សម្របសម្រួលដល់កិច្ចការសារណាបទនេះរហូតបានបញ្ចប់ទៅយ៉ាងរលូនប្រកបដោយជោគជ័យ។ ទៀតសោត រួមទាំង **អ៊ំ ពូមីង បងប្អូន អ្នកភូមិ មេភូមិ ឃុំ ស្រុក រាជធានី ខេត្ត** ទាំង០៥មួយចំនួន នៃរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល ដែលបានចូលរួមផ្តល់ជាអនុសាសន៍ក្នុងរបាយការណ៍ស្ទង់មតិ ដើម្បីជួសគុណតម្លៃក្នុងអំណះអំណាងដ៏ល្អប្រសើរដល់ការសិក្សាស្រាវជ្រាវ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមលើកហត្ថាប្រណម្យបួងសួង សូមជូនពរដល់អស់លោកអ្នកមានគុណ ឯកឧត្តមលោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាលា វិទ្យាស្ថានគ្រប់ជាន់ថ្នាក់ វរកងទ័ពដ៏អង់អាចអ្នកស្នេហាជាតិនៅគ្រប់ស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងប្រជាជនខ្មែរទាំងអស់ ឱ្យបានជួបប្រទះទៅនឹងសេចក្តីសុខសេចក្តីចម្រើន សុខសុភមង្គល សុខភាពមាំមួនល្អបរិបូណ៌គ្រប់ទិនទិវនាកាល និងបានជួបចតុពុទ្ធិពរគឺ អាយុវណ្ណៈ សុខៈ និងពលៈ ព្រមបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាសារវន្តទៅដល់ការស្រាវជ្រាវ គឺអាចនឹងជួបពាក្យពេចន៍ថ្មីៗមួយចំនួន ដែលពាក្យខ្លះមានជាស្រេចនៅក្នុងវចនានុក្រមនៃព្រះរាជាណាចក្រកម្ពុជា ពាក្យមួយចំនួនត្រូវបានបង្កើតឡើង ប្រើសំនៀងបែបថ្មី និងការកម្ចីពាក្យពីបរទេស ភាគច្រើនជាពាក្យបច្ចេកទេសលំអោនទៅនឹងការអនុវត្តជាក់ស្តែង និងជាភារកិច្ចរបស់រាជបណ្ឌិត្យ-សភាកម្ពុជានៃនាយកដ្ឋានអក្សរសាស្ត្រខ្មែរ ក៏ដូចជាអាស្រ័យតាមក្រសួង ស្ថាប័នសាមី ដែលបានអនុវត្ត និង/ឬតាមរយៈព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ជាអាទិ៍ ដែលបញ្ចូលទៅក្នុងផ្នែកសទ្ទានុក្រម។ ពាក្យដែលបម្រើឱ្យការស្រាវជ្រាវនេះ នឹងមាននៅតាមចំណុចសម្គាល់នីមួយៗ ដែលភ្ជាប់ក្នុងការពន្យល់តាមផ្នែក និងប្រភពឯកសារ។

បញ្ហាគន្លឹះក្នុងការតាក់តែងគឺផ្តោតសំខាន់លើកត្តាដើមហេតុនៃវិវាទដីធ្លី ដែលកើតមានជារឿយៗក្នុងសង្គមកម្ពុជាអំពីភាពផកល្វែងនៃការចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុ។ ជាការឆ្លើយតបគួរកត់សម្គាល់ (១) ព្រឹត្តិហេតុនៃការវិភាគដីធ្លី (២) វាយតម្លៃយន្តការស្រាវជ្រាវលើបេត់សង្គម និងការស្រូបយកឌីជីថលូបនីយកម្ម (៣) ការផ្តល់ជាយោបល់ដំណោះស្រាយ និងលើកទិសដៅគាំពារជំរុញបរិវត្តកម្មឌីជីថល។ ការសិក្សាពិចារណាតែចំពោះកម្មសិទ្ធិចម្បងលើអចលនវត្ថុនៃការចុះបញ្ជីដំបូងនៅកម្ពុជា។ ដោយបង្ហាញថា ប្រជាពលរដ្ឋភាគច្រើននៅពុំទាន់មានកិច្ចធានាស្របច្បាប់គ្រប់គ្រាន់ឡើយលើកម្មសិទ្ធិអចលនវត្ថុ, គេចវេសពីការចុះបញ្ជីដី ក្រោមហេតុផលនានា, និងការផ្តល់សេវាសាធារណៈ គឺនៅមានកត្តាប្រឈមចំពោះការអនុវត្ត។ ទិសដៅពេលអនាគត ប្រជាពលរដ្ឋខ្មែរនឹងអាចសម្របខ្លួនពីបច្ចេកវិទ្យាឌីជីថលដោយមិនដឹងខ្លួន ក៏ដូចជា មានការចាំបាច់ជំរុញពីរាជរដ្ឋាភិបាល។ ពាក្យគន្លឹះ៖ បរិវត្តកម្ម និងកម្មសិទ្ធិអចលនវត្ថុ។

ពាក្យថា បរិវត្តកម្ម (ប៉ៈ-រ៉ិ-វ័ត-តៈ-កាំ) បរិវត្ត+កម្ម មានន័យថា ជាការកែទម្រង់ទ្រង់ទ្រាយធំៗ នៅលើវិស័យអ្វីមួយដែលកើតឱ្យទៅជាប្រយោជន៍ឯកជន និងសាធារណៈ។ ឧទាហរណ៍ ការធ្វើបរិវត្តកម្មឌីជីថល។ រីឯ កម្មសិទ្ធិអចលនវត្ថុ (កាំ-ម៉ៈ-សិត និង អៈចៈល៉ៈន៉ៈវ័ត-ថុ) < កម្មសិទ្ធិ+ អចលនវត្ថុ< អចលន+វត្ថុ មានន័យថា សិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ ហើយសិទ្ធិនេះរួមបញ្ចូលលើសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងទៅលើទ្រព្យរបស់ខ្លួន។ ជារួម គឺសំដៅដល់ "ការចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុ ដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬស្វ័យប្រវត្តិកម្មប្រព័ន្ធអនឡាញ"។

ស្មោះសង្ឃឹមថា កិច្ចការសារណាបទមួយនេះនឹងក្លាយទៅជាឯកសារខាងជំនួយស្មារតីដល់មិត្តអ្នកអាន ជាពិសេសនិស្សិតនីតិវិទ្យា ដើម្បីធ្វើការសិក្សាបំពេញបន្ថែមទៅលើចំណេះដឹង ព្រមទាំងប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តពាក់ព័ន្ធនឹងវិស័យនគរូបនីយកម្ម និងសំណង់ និងវិស័យបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា ជាកោសិកាឈាមទ្រទ្រង់ដល់សង្គមកិច្ច-សេដ្ឋកិច្ចជាតិ។ នៅជុំវិញទិដ្ឋភាពទូទៅក្នុងដំណើរការបែបបទទាំងឡាយណា ដោយផ្តើមចេញពីការកាន់កាប់លើអចលនវត្ថុស្របច្បាប់, ការចុះបញ្ជីដីធ្លី, រហូតដល់ទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ ឬហៅថា ប្លង់រឹង និងឈានដល់ការអនុវត្តកាតព្វកិច្ចបង់ពន្ធអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធ ស្របទៅតាមបញ្ញត្តដូចមានចែងជាធរមាន។ ការណ៍នេះ អាចប្រើប្រាស់តាមមុខការឱ្យបានត្រឹមត្រូវ ដើម្បីជាតម្លៃតប

ស្នងចូលរួមជួយលើកកម្ពស់ដល់សកម្មភាពនៃការប្រកួតប្រជែងគ្រប់វិស័យទាំងអស់ សំខាន់បំផុតនោះ គឺវិស័យ ឌីជីថល តាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក និងបម្លែងជាពលរដ្ឋឌីជីថលឱ្យមានតម្លាភាព។

កិច្ចការសារណាបទនេះ គឺបានលះបង់ពេលវេលា ខិតខំប្រឹងប្រែងការរៀបចំ តាក់តែងកិច្ចការយ៉ាងយកចិត្ត ទុកដាក់ខ្ពស់បំផុត។ ទោះបីជាយ៉ាងណា ស្មេរជឿជាក់ថាស្នាដៃមួយនេះ មិនអាចគេចផុតបានពីចំណុចខ្វះខាត ជាមួយនឹងកំហុសឆ្គងទាំងឡាយណាលើអក្ខរាវិរុទ្ធ សូរស័ព្ទ បច្ចេកទេសតាមបណ្តាវិស័យពាក់ព័ន្ធ ជាពិសេស អត្ថន័យ មូលន័យ ខ្លឹមសារ ការប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ ជាងនេះទៅទៀត គឺការសិក្សាទៅ លើប្រព័ន្ធច្បាប់ ឬបទដ្ឋានគតិយុត្តរបស់ជាតិ និងអន្តរជាតិតាមរយៈការសិក្សាប្រៀបធៀបនិងការបកប្រែជាដើម។ ស្មេរសូមលើកហត្ថាសំពះ ខន្តីអភ័យទោស ប្រសិនបើកិច្ចការសារណាបទនេះ នៅខ្វះខាតលក្ខណៈគ្រប់គ្រាន់ទៅ តាមតម្រូវការសិក្សាស្រាវជ្រាវ ស្មេរសូមទទួលយកការរិះគន់ទាំងឡាយណាដែលអស់លោក លោកស្រី អាចធ្វើ ជាមូលវិចារណ៍មកកាន់ស្មេរតាមរយៈមធ្យោបាយសមរម្យ។

# មាតិកា

ទំព័រ

**ការឧទ្ទិសស្នាដៃ**
**សេចក្តីថ្លែងអំណរគុណ**
**អារម្ភកថា**
**អក្សរកាត់** ........ iv
**បញ្ជីតារាង** ........ vii
**សេចក្តីផ្តើម** ........ 1
១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 1
៣. គោលបំណងនៃការស្រាវជ្រាវ ........ 2
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ 3
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 3
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 3
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 4
**ជំពូកទី១. ទិដ្ឋភាពទូទៅលើការចុះបញ្ជីដីធ្លីដំបូង** ........ 5
**១.១. ក្របខណ្ឌបទដ្ឋានគតិយុត្ត** ........ 5
១.១.១. នីតិវិជ្ជមានក្នុងការគ្រប់គ្រងដីធ្លី ........ 5
១.១.១.១. វិធានទំនៀមទម្លាប់ ........ 7
១.១.១.២. ការកំណត់ភូមិសាស្ត្រចុះបញ្ជីដីធ្លី ........ 11
១.១.២. សមត្ថកិច្ចអនុវត្តអនុវិស័យរដ្ឋបាលដីធ្លី ........ 17
១.១.២.១. ក្រសួង ស្ថាប័នពាក់ព័ន្ធការងារសុរិយោដីចុះបញ្ជីដីធ្លី ........ 17
១.១.២.២. ក្រសួង ស្ថាប័នពាក់ព័ន្ធអន្តរកម្មឌីជីថល ........ 18
**១.២. ក្របខណ្ឌគោលនយោបាយ** ........ 19
១.២.១. ទស្សនវិស័យចំពោះតម្រូវការឌីជីថលូបនីយកម្ម ........ 19
១.២.១.១. កត្តាមូលធនមនុស្ស-សង្គមឌីជីថល ........ 21
១.២.១.២. ការត្រៀមលក្ខណៈជារដ្ឋាភិបាលបើកចំហ ........ 23
១.២.២. បម្លាស់ប្តូរលើសង្គម-សេដ្ឋកិច្ចឌីជីថល ........ 24
១.២.២.១. បរិយាបន្នកម្មឌីជីថល ........ 25
១.២.២.២. ការជំរុញធុរកិច្ចលើវិស័យអចលនទ្រព្យ ........ 26
**ជំពូកទី២. ភាពលទ្ធភាពចំពោះថ្នាលបច្ចេកវិទ្យាឌីជីថលរបស់កម្ពុជា** ........ 28
**២.១. ប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (CamDX) ........ 28

២.១.១. លក្ខខណ្ឌគុណវុឌ្ឍិក្លាយជាសមាជិក ........ 30
២.១.១.១. សមាជិកដោយស្វ័យប្រវត្តិ ........ 30
២.១.១.២. សមាជិកដោយការស្នើសុំ ........ 34
២.១.២. សមត្ថកិច្ច និងភារកិច្ចរបស់សមាជិក ........ 35
២.១.២.១. ចំពោះប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ........ 36
២.១.២.២. ចំពោះសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ........ 37
**២.២. ប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឌីជីថល** ( CamDigiKey ) ........ 38
២.២.១. ការចុះឈ្មោះអត្តសញ្ញាណឌីជីថល ........ 39
២.២.១.១. សមត្ថភាពចុះបញ្ជីទិន្នន័យបុគ្គល ........ 41
២.២.១.២. សមត្ថភាពផ្ទៀងផ្ទាត់ទិន្នន័យរបស់ប្រព័ន្ធព័ត៌មានវិទ្យា ........ 44
២.២.២. ការប្រមូលទិន្នន័យបុគ្គលប្រកបដោយបរិយាបន្នសង្គម ........ 46
២.២.២.១. ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) ........ 46
២.២.២.២. លក្ខណៈស្តង់ដារទិន្នន័យ ........ 48
**ជំពូកទី៣. បរិវត្តកម្មរដ្ឋាភិបាលឌីជីថលលើសេវាសាធារណៈ** ........ 50
**៣.១. ដំណើរការរៀបចំប្រព័ន្ធចុះបញ្ជីអចលនវត្ថុលើថ្នាលបច្ចេកវិទ្យាឌីជីថល** ........ 50
៣.១.១. ការរចនានិម្មាបនកម្ម និងការអនុវត្តវេទិកាឌីជីថលលើការចុះបញ្ជីអចលនវត្ថុ ........ 53
៣.១.១.១. ឌីជីថលូបនីយកម្មលើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ និងមានលក្ខណៈជាប្រព័ន្ធ ........ 58
៣.១.១.២. ការកសាងប្រព័ន្ធទិន្នន័យសុរិយោដី ........ 66
៣.១.២. ករណីសិក្សានៅប្រទេសមួយចំនួន ........ 67
៣.១.២.១. ក្នុងតំបន់អាស៊ី ........ 68
៣.១.២.២. ក្នុងតំបន់អឺរ៉ុប ........ 70
**៣.២. វិធានការសុវត្ថិភាពអេឡិចត្រូនិក** ........ 73
៣.២.១. សុវត្ថិភាពឯកសារសាធារណៈ ........ 74
៣.២.១.១. ហត្ថលេខា និងចេញបណ្ណទម្រង់ឌីជីថល ........ 75
៣.២.១.២. ថ្នាលផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកសារសុវត្ថិភាពឌីជីថល (Verify.gov.kh) ........ 77
៣.២.២. មធ្យោបាយទូទាត់ប្រាក់ ........ 78
៣.២.២.១. ប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ........ 78
៣.២.២.២. កំណត់ត្រាពន្ធដារ ........ 79
**ជំពូកទី៤. វាយតម្លៃការអនុវត្តតាមប្រព័ន្ធអនឡាញ** ........ 80
**៤.១. សក្តានុពលចំពោះវេទិកាឌីជីថល** ........ 80
៤.១.១. សុចរិតភាពអ្នកប្រើប្រាស់ និងកាន់កាប់អចលនវត្ថុ ........ 81
៤.១.១.១. កិច្ចធានាការអះអាងកម្មសិទ្ធិអចលនវត្ថុ ........ 82
៤.១.១.២. កិច្ចធានាដោយរដ្ឋ និងក្រុមការងារបច្ចេកទេសឌីជីថល ........ 85

៤.១.២. ផលវិជ្ជមាន និងផលប៉ះពាល់លើប្រព័ន្ធឌីជីថល ........ 87
៤.១.២.១. កត្តាមនុស្ស និងសង្គម ........ 87
៤.១.២.២. បរិស្ថានសុរិយោដី-ឌីជីថល ........ 89
**៤.២. សន្តិសុខសាយប័រ** ........ 91
៤.២.១. វិធានការសង្គ្រោះសន្តិសុខព័ត៌មានកម្មសិទ្ធិអចលនវត្ថុ ........ 92
៤.២.១.១. ការការពារសុវត្ថិភាពដល់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ........ 94
៤.២.១.២. យន្តការអប់រំ និងផ្សព្វផ្សាយ ........ 95
៤.២.២. លទ្ធផលស្ទង់មតិសាធារណជន ........ 96
**សេចក្តីសន្និដ្ឋាន** ........ 97
**អនុសាសន៍** ........ 98
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

## ក្រសួង ស្ថាប័ន

| | | |
|---|---|---|
| DEBC | = | Digital Economy and Business Committee<br>គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ) |
| DGC | = | Digital Government Committee<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល (គ.រ.ឌ) |
| DSC | = | Digital Security Committee<br>គណៈកម្មាធិការសន្តិសុខឌីជីថល (គ.ស.ឌ) |
| GDI | = | General Department of Identification<br>អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| GDT | = | General Department of Taxation<br>អគ្គនាយកដ្ឋានពន្ធដារ |
| MEF | = | Ministry of Economy and Finance<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | = | Ministry of Land Management, Urban Planning and Construction<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) |
| MOI | = | Ministry of Interior<br>ក្រសួងមហាផ្ទៃ |
| MPTC | = | Ministry of Post and Telecommunications<br>ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ) |
| NCDES | = | National Council for Digital Economy and Society<br>ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល (ក.ស.ឌ) |
| TRC | = | Telecommunication Regulator of Cambodia<br>និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) |
| TSC | = | Techo Startup Center<br>មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត) |

## ពាក្យបច្ចេកទេស

| | | |
|---|---|---|
| ថ.ផ.ទ /CamDX | = | Cambodia Data eXchange/CamDX<br>ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| 5G /5th G | = | 5th (fifth) Generation Mobile Network |

| | | |
|---|---|---|
| | | បណ្តាញចល័តជំនាន់ទី៥ |
| AI | = | Artificial Intelligence<br>បញ្ញាសិប្បនិម្មិត |
| API | = | Application Programming Interface<br>សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ |
| CamDigiKey | = | Cambodia Digital Key<br>ថ្នាលផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គល |
| CamDL | = | Cambodia Distributed Ledger<br>ប្រព័ន្ធកំណត់ត្រាចែកចាយកម្ពុជា |
| CaptCha | = | Completely Automated Public Turing test to tell Computers and Humans Apart<br>ការតេស្តស្វ័យប្រវត្តិកម្មដែលអាចដឹងពីការប្រើប្រាស់រវាងកុំព្យូទ័រ និងមនុស្ស |
| CCAs | = | Cyber Crime Attack-service<br>ការវាយប្រហារឧក្រិដ្ឋកម្មសន្តិសុខសាយប័រ |
| Cloud Computing-SM | = | Cloud Computing Service Model<br>ម៉ូដែលសេវាកម្មកុំព្យូទ័រក្លោដ |
| CORS | = | Cross-Origin Resource Sharing<br>ការឆ្លង/ផ្ទេរធនធានក្នុងប្រភពដើម |
| CSR | = | Certificate Signing Request<br>ឯកសារដែលតម្រូវការស្នើសុំ |
| DAS | = | Data Acquisition System<br>ប្រព័ន្ធទទួលទិន្នន័យ |
| E-Filling | = | Electronic Filling<br>ប្រព័ន្ធប្រកាសពន្ធតាមអេឡិចត្រូនិក |
| e-KYC | = | electronic Know Your Customer or digital KYC<br>ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល |
| E-payment | = | Electronic Payment<br>ប្រព័ន្ធទូទាត់តាមអេឡិចត្រូនិក |
| E-Tax Service | = | Electronic Tax Service<br>ប្រព័ន្ធផ្តល់សេវាកម្មពន្ធដារតាមអេឡិចត្រូនិក |
| HTTPS | = | Hypertext Transfer Protocol Secure<br>របបបណ្តាញផ្ទេរទិន្នន័យសុវត្ថិភាព |

| | | |
|---|---|---|
| ICT | = | Information and Communication Technologic<br>ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| IPIS | = | Integrated People Information System<br>ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន |
| MOU | = | A Memorandum of Understanding<br>អនុស្សរណៈយោគយល់ |
| MRZ Code | = | Mechine Readable Zone Code<br>កូដជាខ្សែលេខ និងអក្សរក្រោមបន្ទាត់នៃព័ត៌មានបណ្ណសម្គាល់ខ្លួន |
| OCR | = | Optical Character Recognition<br>បច្ចេកវិទ្យាសម្គាល់លក្ខណៈរូបីយ ទៅជា អរូបីយ |
| ODO | = | Original Data Owner<br>ម្ចាស់ទិន្នន័យដើម |
| OTP | = | One Time Password<br>លេខកូដបញ្ជាក់តែមួយលើក |
| QR Code | = | Quick Respone Code<br>ឃ្យូ.អ.កូដ ស្តង់ដារ ជាសញ្ញា ឬបាកូដឆ្លើយតបរហ័ស |
| SIT | = | System Integrated Test<br>ការធ្វើតេស្តរួមបញ្ចូលទៅក្នុងប្រព័ន្ធគោល |
| SL | = | Sign-off Letter<br>ហត្ថលេខាលើលិខិតទទួលស្គាល់ |
| SSIG | = | Security Server Installation Guideline<br>ដំឡើងម៉ាស៊ីនមេសុវត្ថិភាព |
| TIN | = | Tax Identification Number<br>លេខអត្តសញ្ញាណពន្ធ |
| UAT | = | User Acceptance Test<br>ការធ្វើតេស្តទទួលយកអ្នកប្រើប្រាស់ |
| UIC | = | Unit Identification Code<br>លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល |
| Web3.0 | = | The World Wide Web of Generation 3.0<br>វិបផតថលនៃបណ្តាញផ្សាយជំនាន់ទី៣ |
| WIFI | = | Wireless Fidelity<br>បណ្តាញតភ្ជាប់ឥតខ្សែ |

# បញ្ជីតារាង

**ទំព័រ**


តារាងទី១ ៖ លំនៅឋានដែលបានកាន់កាប់បែងចែកតាមស្ថានភាពកម្មសិទ្ធិ និងតាមតំបន់ភូមិសាស្ត្រនៅក្នុងឆ្នាំ២០២១ (គិតជាភាគរយ)… ……11

តារាងទី២ ៖ ផ្ទៃក្រឡាកម្រាលបែងចែកតាមតំបន់ភូមិសាស្ត្រក្នុងឆ្នាំ២០២១ (គិតជាភាគរយ) ជាមធ្យមភាគម៉ែត្រការ៉េក្នុងមួយគ្រួសារ…… 12

តារាងទី៣ ៖ ផ្ទៃដីកសិកម្មបែងចែកតាមប្រភេទនៃគ្រួសារ និងតំបន់ក្នុងឆ្នាំ២០២១ (គិតជាពាន់ហិកតា និងភាគរយ) …… 13

តារាងទី៤ ៖ ផ្ទៃដីកសិកម្មបែងចែកតាមប្រភេទនៃគ្រួសារ តាមប្រភេទដី និងតំបន់ទូទាំងប្រទេសឆ្នាំ២០២១ (គិតជាពាន់ហិកតា) ……13

តារាងទី៥ ៖ ចំនួនគ្រួសារមានផ្ទៃដីកសិកម្មបែងចែកតាមផ្ទៃដី និងតាមតំបន់ក្នុងឆ្នាំ២០២១ (គិតជាពាន់ហិកតា) …… 15

តារាងទី៦ ៖ ផ្ទៃដីកសិកម្មបែងចែកតាមលក្ខណៈនៃកម្មសិទ្ធិ និងតាមតំបន់ក្នុងឆ្នាំ២០២១ (គិតជាពាន់ហិកតា និងភាគរយ) ……16

តារាងទី៧ ៖ សូចនាករគន្លឹះជំរុញការអនុវត្តឌីជីថល…… 40

តារាងទី៨ ៖ យន្តការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្រសួង ដ.ន.ស…… 56

តារាងទី៩ ៖ ការផ្តល់យោបល់ចំពោះការបង្កើតផតថលប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ ……57

តារាងទី១០ ៖ របាយការណ៍ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ……60

តារាងទី១១ ៖ ប្លុកព័ត៌មានអ្នកស្នើសុំក្នុងបណ្តាញផតថល……62

តារាងទី១២ ៖ របាយការណ៍ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ……65

តារាងទី១៣ ៖ គំរូអភិបាលកិច្ចនៃរដ្ឋបាលអេឡិចត្រូនិក …… 74

តារាងទី១៤ ៖ ភាពខ្លាំង និងភាពខ្សោយចំពោះមនុស្ស-សង្គមលើប្រព័ន្ធឌីជីថល ……88

តារាងទី១៥ ៖ ភាពខ្លាំង និងភាពខ្សោយចំពោះបរិស្ថានសុរិយោដីលើប្រព័ន្ធឌីជីថល ……90

តារាងទី១៦ ៖ ភាពខ្លាំង និងភាពខ្សោយចំពោះសន្តិសុខសាយប័រលើប្រព័ន្ធឌីជីថល ……93

តារាងទី១៧ ៖ ការអង្កេត និងវាយតម្លៃមតិសាធារណជន……96

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បដិវត្តន៍ឌីជីថលបានផ្លាស់ប្តូរសង្គមជុំវិញពិភពលោកដោយឥតព្រាងទុក និងបានជះឥទ្ធិពលលើអ្វីៗគ្រប់យ៉ាង រាប់ចាប់តាំងពីការទំនាក់ទំនង និងពាណិជ្ជកម្ម រហូតដល់ការអប់រំ និងអភិបាលកិច្ចលើសេវាសាធារណៈសង្គម។ ហេតុផលមួយចំនួនដែលបច្ចេកវិទ្យាឌីជីថលកំពុងផ្លាស់ប្តូរសង្គមទំនៀមទម្លាប់ គឺ៖ ទី១. កិច្ចសហប្រតិបត្តិការនិងការតភ្ជាប់ដែលប្រើតាមរយៈខ្សែបណ្តាញអ៊ីនធឺណិត, ទី២.ការទទួលបានព័ត៌មាន និងការអប់រំដែលអាចដោយផ្ទាល់ផង និងផ្លាស់ប្តូរទទួលយកដោយបណ្តាញសង្គមផង, ទី៣. សេដ្ឋកិច្ច និងពាណិជ្ជកម្មដែលពឹងផ្អែកទៅលើប្រព័ន្ធអេឡិចត្រូនិកមួយភាគធំ និងទី៤. តក្កកម្មលើសេវាកម្ម នៃរដ្ឋាភិបាលអេឡិចត្រូនិកដែលងាយស្រួល និងលឿនរហ័ស។[1] ការផ្លាស់ប្តូរឌីជីថល គឺបានបង្ហាញទាំងឱកាស និងបញ្ហាប្រឈមសម្រាប់សង្គមដែរ។ មើលឃើញពីការចាំបាច់ ក្នុងការទាញយកឥទ្ធិពល ឬទាញយកប្រយោជន៍ពីបច្ចេកវិទ្យា ដល់ការផ្លាស់ប្តូរជាផលវិជ្ជមាន ខណៈពេលការកាត់បន្ថយហានិភ័យអាចកើតមាន ធានាបានពីការចូលប្រើប្រាស់ប្រកបដោយសមធម៌ និងការទទួលខុសត្រូវដល់អ្នកប្រើប្រាស់ ឬភាគីពាក់ព័ន្ធ តាមរយៈការជំរុញអក្ខរកម្មឌីជីថល ការលើកកម្ពស់ ការច្នៃប្រតិដ្ឋ ការដោះស្រាយកង្វល់សង្គម និងបញ្ហាសីលធម៌សង្គម។

បរិវត្តកម្មឌីជីថល ឬបដិវត្តន៍ឌីជីថល ជាយុគសម័យទំនើប ដែលមនុស្សជាតិកំពុងរស់នៅ និងសម្របខ្លួនដោយមិនដឹងខ្លួន។ ការរីកចម្រើន និងការស្វែងរកវិធីសាស្ត្រដំណោះស្រាយ ឆ្លើយតបនឹងរបៀបការរស់នៅប្រចាំថ្ងៃ ភាគច្រើនកើតចេញពីប្រទេសជឿនលឿន ដោយអាចចាត់ទុកថាវិធីសាស្ត្រនៃប្រទេសទាំងនោះ ជាគំរូម៉ូដែលមានសារៈសំខាន់សម្រាប់ការអនុវត្ត ដល់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជា ប្រទេសកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្អែកទៅលើបទដ្ឋានគតិយុត្តចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីភូមិបាល ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ច្បាប់ស្តីពីទូរគមនាគមន៍ អនុក្រឹត្យ សារាចរ សេចក្តីណែនាំ គោលនយោបាយ ទិនានុប្បវត្តិ និងច្បាប់ជាច្រើនទៀតដែលពាក់ព័ន្ធនឹងបញ្ហានេះ ដោយក្នុងនោះ ក៏បានទាញពីករណីសិក្សា បទពិសោធន៍ក្នុងការអនុវត្តរបស់ប្រទេសមួយចំនួន ផងដែរ។ អ្វីដែលបញ្ហាចោទនោះ គឺការសម្លឹងមើលចក្ខុវិស័យចំពោះការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលអាចមកជំនួសវិធីសាស្ត្រប្រពៃណីលើសេវាសាធារណៈក្នុងប្រទេសកម្ពុជា។

ដើម្បីសម្រេចបាន និងចាប់យកចំគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺត្រូវលើកយកបណ្តាបញ្ហា និងសន្ទតិកម្មមួយផ្នែក ចំពោះបរិវត្តកម្មឌីជីថលលើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ។ តើបរិវត្តកម្មឌីជីថលលើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ នឹងនាំមកនូវការប្រែប្រួលយ៉ាងដូចម្តេចខ្លះទៅដល់វិស័យដីធ្លីនៅកម្ពុជា?

[1] World Bank Group, "Digital Progress and Trends Roport 2023 [វឌ្ឍនភាពឌីជីថល និងរបាយការណ៍និន្នាការឆ្នាំ២០២៣]," (Washington DC, USA, 2024), https://openknowledge.worldbank.org/server/api/core/bitstreams /95fe55e9-f110-4ba8-933f-e65572e05395/content (ទស្សនាចុងក្រោយថ្ងៃទី១២ មីនា ២០២៤)។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ជាសារវន្តចំពោះការសិក្សាស្រាវជ្រាវនេះ គោលបំណងគឺសំដៅរួមចំណែក និងដោះស្រាយលើបញ្ហានៃការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុនៅកម្ពុជា ដែលមានការកកស្ទះផ្តល់ជូនបណ្ណកម្មសិទ្ធិ និងយឺតយ៉ាវក្នុងការអនុវត្តចុះបញ្ជី។ ស្មារតីក្នុងការផ្តល់ជាយោបល់នេះ គឺចង់លើកកម្ពស់ និងលើកទឹកចិត្តចំពោះការអនុវត្តតាមស្វ័យប្រវត្តិកម្មលើសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ដែលអនុវត្តស្របទៅតាមគោលនយោបាយបញ្ចកោណ-ដំណាក់កាលទី១ ក្នុងបញ្ចកោណទី៥, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥, និងគោលនយោបាយពាក់ព័ន្ធដទៃទៀត ផ្សាភ្ជាប់នឹងបទដ្ឋានគតិយុត្តចូលជាធរមាន ដែលជាគំរូគោលមួយរបស់រាជរដ្ឋាភិបាលដល់ការផ្តល់អនុសាសន៍ទៅកាន់ក្រសួង ស្ថាប័ន យកមកបំបែកជាក្លូនតូចៗ និងស្រូបយកធាតុចូលនីមួយៗ ដើម្បីផ្តល់សេវាសាធារណៈជាទីគាប់ចិត្តជូនប្រជាពលរដ្ឋ។

តាមការសិក្សាស្រាវជ្រាវប្រភពចម្បងលើវិវាទដីធ្លី គឺកើតចេញពីការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ។ ការកត់ត្រាព័ត៌មានសណ្ឋានដី ប្រភេទដី អត្តសញ្ញាណកម្មព្រំដី និងការកំណត់ផែនទីកសាងប្លង់សុរិយោដី នៅខ្វះភាពត្រឹមត្រូវ និងភ័ន្តច្រឡំដោយអចេតនា ដោយសារការធ្វេសប្រហែស ឬមាមី អំឡុងពេលសម្រុកការចុះបញ្ជី ដែលធ្វើឱ្យមន្ត្រីកាន់កាប់បញ្ជី និងមន្ត្រីពាក់ព័ន្ធមានផលវិបាកខ្លាំង។ បច្ចុប្បន្ន ឆន្ទៈកម្ពុជានឹងបញ្ចប់ការប៉ុនប៉ងបដិវត្តន៍ដីធ្លីដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ដ.ន.ស ក្នុងអាណត្តិទី៧នេះ ធ្វើយ៉ាងណាដើម្បីបញ្ចប់ការចុះបញ្ជីទូទាំងប្រទេសជូនប្រជាពលរដ្ឋឱ្យបានមុនឆ្នាំ២០២៩។[2] ដូចនេះ ការចុះបញ្ជីបន្ថែមជាបន្តបន្ទាប់ ពិតប្រាកដណាស់នឹងត្រូវស្វែងរកដំណោះស្រាយគ្រប់មជ្ឈដ្ឋាន ដើម្បីពន្លឿនដល់ការចុះបញ្ជី។

ម្យ៉ាងវិញ បញ្ញាបការអនុវត្តនេះ ក៏ចូលរួមការពារបរិស្ថាន ឆន្ទៈការពារការបម្រែបម្រួលអាកាសធាតុនៅលើពិភពលោក និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានកម្ពុជាឆ្នាំ២០២៣-២០២៨ ក៏ស្របតាមសន្ធិសញ្ញាទីក្រុងប៉ារីស និងអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីអំពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change-UNFCCC) ចាប់តាំងពីឆ្នាំ១៩៩៦, កម្ពុជាក៏បានចូលរួមប្តេជ្ញាកាត់បន្ថយសារធាតុកាបូនទូទាំងប្រទេសត្រឹមឆ្នាំ២០៥០ និងបង្កើនការដាំកូនឈើឡើងវិញ ការការពារដែនគម្របព្រៃឈើប្រមាណ៦០ភាគរយ នៅឆ្នាំ២០៣០ ដែលបញ្ហាកើតចេញពីការប្រើប្រាស់លើសតម្រូវការ។[3] ប៉ុន្តែ ការប្រើប្រាស់ក្រដាស ឬសៀវភៅគ្រប់ប្រភេទ និងគ្រប់ទំហំដ៏ច្រើនលើសលុប ក្នុងការបំពេញលិខិតរដ្ឋបាលនានា ទាំងនៅតាមបណ្តាក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជន នៅតែជាបញ្ហានៅឡើយ។

---

[2] An Bunthan, "រាជរដ្ឋាភិបាលនឹងបញ្ចប់ការប៉ុនប៉ងធ្វើបដិវត្តន៍ដីធ្លីនៅកម្ពុជាតាមរយៈការប្រើប្រាស់កម្លាំងសរុបទូទាំងប្រទេស ដើម្បីវាស់វែង និងចេញបណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ," https://mlmupc.gov.kh/2024/02/08/5852/ (ទស្សនាចុងក្រោយថ្ងៃទី១១ មីនា ២០២៤)។ *[ខួបលើកទី៤០នៃការចេញបណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ (១៩៨៩-២០២៩)]*

[3] កន ចំណាន, "UNDP ថាយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឆ្នាំ២០២៣-២០២៨ មានភាពច្បាស់លាស់ និងសាមញ្ញភាពដើម្បីផ្លាស់ប្តូរផ្នត់គំនិតជាវិជ្ជមានឆ្លើយតបនឹងនៃការប្រែប្រួលអាកាសធាតុក្នុងតំបន់," https://www.information.gov.kh/articles/125825 (ទស្សនាចុងក្រោយថ្ងៃទី១២ មីនា ២០២៤)។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សារណានេះមានការគ្របដណ្តប់លើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ ចម្បងលើការចុះបញ្ជីដំបូង ដោយស្វែងរកការប្រើប្រាស់ប្រព័ន្ធថ្នាលឌីជីថល បច្ចេកវិទ្យាព័ត៌មាន និងបណ្តាញប្លុកឆេននានា ឱ្យជាគំរូរចនានិម្មាបនកម្មដែលអាចសមស្របបំផុតយកមកអនុវត្តនៅកម្ពុជា។ ចំណែកនៃកម្មសិទ្ធិបន្ទាប់បន្សំ, សមាសភាគនៃវត្ថុ និងសិទ្ធិប្រត្យក្សផ្សេងទៀត មិនធ្វើការពិចារណាសិក្សាឡើយ។ ម្យ៉ាងវិញ បច្ចុប្បន្នកម្ពុជា ក៏នឹងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឯករាជ្យរបស់ខ្លួន ជាម៉ូដែលបច្ចេកវិទ្យាប្លុកឆេន (Blockchain) អាចបំពេញតម្រូវការ និងដោះស្រាយលើបណ្តាសេវាសាធារណៈជាបឋមមួយចំនួន ហៅថា CamDX (Cambodia Digital Exchange) ឬថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ផងដែរ។ ល្អីកនេះហើយ ការសិក្សាស្រាវជ្រាវនេះ នឹងជួយជាយោបល់ដល់ការបង្ហាញលទ្ធភាពពីកាលានុវត្តន៍អាចទៅរួចផ្អែកលើភស្តុតាង, ការស្រូបធាតុចូលពីបច្ចេកវិទ្យាបរទេស, និងជួយជំរុញជាវិធីសាស្ត្រដល់ការអភិវឌ្ឍ ឬបច្ចុប្បន្នកម្មលើបច្ចេកវិទ្យារបស់កម្ពុជា ដើម្បីជាជំនួយដល់ការពិចារណាបង្កើតផតចលការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុតាមរយៈប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធអនឡាញ។

តើកម្ពុជាគួរតែស្រូបយកធាតុចូលបន្ថែម លើការអនុវត្តបច្ចេកវិទ្យាឌីជីថល CamDX នៃបណ្តាសេវាសាធារណៈ ក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែរឬទេ? ជាពិសេស ការចុះបញ្ជីដីធ្លីដំបូង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ពន្លឿនដល់ការប្រែប្រួលយុគសម័យនៃសង្គមខ្មែរ ក្នុងការប្រើប្រាស់សេវាសាធារណៈឌីជីថលប្រកបដោយស្មារតីទទួលខុសត្រូវ សុទិដ្ឋិនិយម សុចរិតភាពនៃអត្តសញ្ញាណបុគ្គល និងអភិក្រមបែបចូលរួម។ ក្រៅពីនេះ នៅពេលដែលប្រជាពលរដ្ឋអាចប្រើប្រាស់ និងទាញប្រយោជន៍ឱ្យអស់ពីលទ្ធភាពនៃបច្ចេកវិទ្យាឌីជីថល នោះសង្គមសេដ្ឋកិច្ចជាតិនឹងប្រែប្រួលទៅតាមគុណតម្លៃ។ គុណតម្លៃនៅទីនេះ មានន័យថាប្រជាពលរដ្ឋទទួលសេវាសាធារណៈដោយការពេញចិត្ត កាត់បន្ថយពេលវេលា-មិនចំណាយថវិកាច្រើន និងលុបបំបាត់អំពើពុករលួយ។

ផលតបក្នុងតម្លៃដែលអាចមកជំនួសបានក្នុងការកាត់បន្ថយ ដែលពឹងផ្អែកលើការប្រើប្រាស់ក្រដាសហួសពីបរិមាណ ជំនួសការបំពេញបែបបទរដ្ឋបាលក្នុងសភាពដដែលៗច្រើនសារ ស្មុគស្មាញ និងជួយការពារការក្លែងបន្លំឯកសារ ងាយស្រួលផ្តល់ឯកសារយថាភូតទម្រង់ឌីជីថល ជាអាទិ៍ លើដំណោះស្រាយ ឆ្លើយតបនឹងវិវាទជាច្រើន ដែលកើតឡើងជាហូរហែដោយសារតែកម្មសិទ្ធិអចលនវត្ថុមិនស្របច្បាប់។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទការសិក្សាស្រាវជ្រាវនេះ គឺទាញយកចេញពីប្រភពសំខាន់ក្នុងការកំណត់បញ្ហាស្រាវជ្រាវ ពីការអនុវត្តជាក់ស្តែង។ លក្ខណៈវិទ្យាសាស្ត្រសង្គម នៃការស្រាវជ្រាវដែលបានកំណត់ទុកក្នុងច្បាប់ជាធរមាន គឺបានជ្រើសយកវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ។ លំអានពីការស្រាវជ្រាវបែបគុណភាពវិស័យ និងរបៀបប្រមូលយកឯកសារទាំងមូលមកដាក់ស្រាវជ្រាវជាដុំៗ ដែលភាគច្រើនអ្នកច្បាប់តែងតែប្រើវិធីសាស្ត្រនេះ និងភ្ជាប់របៀបមួយប្រភេទទៀតគឺ ការស្រាវជ្រាវតាមបែបបរិមាណវិស័យ។ ការស្រាវជ្រាវនេះ ត្រូវបានរៀបចំជាលក្ខណៈប្រព័ន្ធដើម្បីស្វែងរកចម្លើយមួយផ្អែកដាច់ដោយឡែក ដោយបង្កើតទៅជាបញ្ជីសំណួរ ការធ្វើបច្ច័យដោយប្រយោល និងការ

ចុះដោយទីវាលផ្ទាល់ ជាឧបករណ៍សម្រាប់ប្រមូលព័ត៌មានពីមតិសាធារណជន។ ការប្រើវិធីដោយប្រយោលត្រូវបានកំណត់គោលដៅប្រជាករចំនួន១០គ្រួសារ ពីសំណាកចំនួន២ គឺរាជធានីភ្នំពេញ និងខេត្តកណ្ដាល, រីឯវិធីទម្រង់ការសម្ភាសន៍ និងអង្កេតដោយផ្ទាល់ កំណត់គោលដៅប្រជាករចំនួន៣០គ្រួសារ ពីសំណាកចំនួន៣ គឺខេត្តព្រះសីហនុ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម។

ការស្រាវជ្រាវបែបគុណភាពវិស័យក្នុងប្រធានបទនេះ យកច្បាប់ជាធរមាន និងបាតុភូតអនុវត្ត មកផ្ទៀងផ្ទាត់ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។ តើអ្វីជាគោលដៅក្នុងការអនុវត្ត ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុនៅលើថ្នាលអេឡិចត្រូនិក? រីឯ តាមបែបបរិមាណវិស័យ គឺបានរម្លឹកទ្រឹស្តីដែលមានអចេរស្រាវជ្រាវ ដោយបញ្ចូលលើតម្លៃលេខ និងស្ថិតិក្នុងការវិភាគទិន្នន័យដែលបានមកពីរបាយការណ៍ ព្រឹត្តិបត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធយកមកបង្ហាញភស្តុតាង ជាលទ្ធភាពដើម្បីជំរុញដល់ការចុះបញ្ជីអេឡិចត្រូនិក។ តើអ្វីជាភាពខុសគ្នារវាងការចុះបញ្ជីតាមបែបទំនៀមទម្លាប់ និងការចុះបញ្ជីតាមបែបឌីជីថល ឬអេឡិចត្រូនិក?

លក្ខណៈការសរសេរ ភាគច្រើនបានព្យាយាមស្រាវជ្រាវរកប្រភពឯកសារដើម គឺផ្សាភ្ជាប់ជាមួយការវិភាគទុកមុន និងការពិចារណារកដើមហេតុ ដោយផ្អែកលើរបាយការណ៍ជាក់ស្តែង ដើម្បីអាចឈានដល់រកដំណោះ-ស្រាយមូលដ្ឋានណាមួយ និងការព្យាករទុកលើការអនុវត្តជាក់ស្តែង។ ករណី ព្រឹត្តិហេតុមួយចំនួនក៏បានទាញយកប្រភពឯកសារសង្ខេបខ្លះៗ ដើម្បីរម្លឹកទ្រឹស្តីផ្សាភ្ជាប់នឹងការអនុវត្ត ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះបែងចែកជា៤ជំពូក។ ជំពូកទី១ បង្ហាញពីទិដ្ឋភាពទូទៅលើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុផ្អែកលើបទដ្ឋានគតិយុត្តជាធរមាន ដោយផ្សាភ្ជាប់គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល និងលើកយកពីដែនសមត្ថកិច្ចអនុវត្តក្នុងបរិស្ថានឌីជីថល។រីឯជំពូកទី២ ចង់បង្ហាញពីឌីជីថលូបនីយកម្មដែលកម្ពុជាកំពុងអនុវត្តមានស្រាប់ និងការអនុញ្ញាតឱ្យចូលទៅប្រើប្រាស់ក្នុងប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន និងលក្ខខណ្ឌដែលបានកំណត់ក្នុងបទប្បញ្ញត្ត។ ចំណែកឯជំពូកទី៣ ពិភាក្សាអំពីនវានុវត្តន៍ចំពោះដំណើរការរៀបចំប្រព័ន្ធចុះបញ្ជីអចលនវត្ថុលើថ្នាលបច្ចេកវិទ្យាឌីជីថល ឬអេឡិចត្រូនិកដែលអាចប្រើប្រាស់បាន និងឆ្លើយតបទៅនឹងតម្រូវ-ការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្សាភ្ជាប់ទៅនឹងបទពិសោធន៍របស់ប្រទេសមួយចំនួនផងដែរ។ ជាចុងក្រោយ ជំពូកទី៤ បង្ហាញអំពីលទ្ធភាពលើវេទិកាឌីជីថល និងកិច្ចគាំពារសន្តិសុខសាយប័រដើម្បីផ្តល់ភាពងាយស្រួលលើបញ្ហាការអនុវត្តតាមបែបឌីជីថល។

# ជំពូកទី១

# ទិដ្ឋភាពទូទៅ
# លើការចុះបញ្ជីដីធ្លីដំបូង

# ជំពូកទី១
# និន្នាការទូទៅលើការចុះបញ្ជីដីធ្លីដំបូង

ជាទូទៅ ដីធ្លី លំនៅឋាន គឺជាអាយុជីវិតរបស់ប្រជាពលរដ្ឋ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ប្រជាពលរដ្ឋខ្មែរធ្លាប់ចូលទៅកាន់កាប់ដីធ្លីពុំមានកម្មសិទ្ធិច្បាស់លាស់យ៉ាងអាណាធិបតេយ្យ និងក្រោយបញ្ចប់សករាជកម្មសិទ្ធិជាសមូហភាព បានដាស់ស្មារតីឱ្យរដ្ឋាភិបាលទទួលខុសត្រូវខ្ពស់ ផ្លាស់ប្តូរយុទ្ធសាស្ត្រអនុវត្ត និងផ្តល់សិទ្ធិកម្ម-សិទ្ធិឯកជនភាវូបនីយកម្មលើអចលនវត្ថុ។ រដ្ឋាភិបាលបានព្យាយាមផ្សព្វផ្សាយតាមឧគ្ឃោសនាស័ព្ទជាដំណឹងទៅដល់ប្រជាពលរដ្ឋ ដើម្បីពន្លឿនចូលមកចុះបញ្ជីដីធ្លីដំបូងយ៉ាងណាក៏ដោយ ដោយសារប្រជាពលរដ្ឋនៅកង្វះការយល់ដឹង ពិបាកទទួលដំណឹងនិងទំនាស់ដីធ្លីស្របពេលកម្ពុជាបើកទីផ្សារសេរី ហេតុនាំឱ្យពុំមានប្រសិទ្ធភាពទើបរដ្ឋាភិបាលបានបង្កើតសេនាធិការឱ្យមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឆ្នាំ១៩៩៩ ជាអ្នកទទួលបន្ទុក។[4] ក្រោយពីមានដំណោះស្រាយ និងអត្ថិភាពនៃបទដ្ឋានគតិយុត្តតាមរយៈការអនុវត្តយ៉ាងឆាប់រហ័ស គឺបានបញ្ជ្រាប និងជំរុញឱ្យប្រជាពលរដ្ឋចុះបញ្ជីកម្មសិទ្ធិយ៉ាងច្រើនគួរឱ្យកត់សម្គាល់។ ប៉ុន្តែ នីតិវិធីសេវាសាធារណៈនៃការចុះបញ្ជីដីធ្លីតាមទម្លាប់ពីមុនៗ នៅបន្តមានភាពស្មុគស្មាញ និងជាបញ្ហាចម្បងដែលត្រូវដោះ-ស្រាយបន្ថែម។

សាវតាមុនឈានដល់ការពិនិត្យលទ្ធភាព គឺបានលើកជាភស្តុតាងគាំពារ ប្រកបដោយប្រសិទ្ធភាពតាមរយៈក្របខណ្ឌបទដ្ឋានគតិយុត្ត (១.១) និងក្របខណ្ឌគោលនយោបាយ (១.២)។

## ១.១. ក្របខណ្ឌបទដ្ឋានគតិយុត្ត

ជាទ្រឹស្តីក្នុងទស្សនទានមួយ និងផ្សាភ្ជាប់ការផ្តល់សេវាដែលប្រកបដោយភាពត្រឹមត្រូវ ដែលការអនុវត្តនោះត្រូវពិនិត្យលើនីតិវិជ្ជមានក្នុងការគ្រប់គ្រងដីធ្លី (១.១.១) និងសមត្ថកិច្ចអនុវត្តអនុវិស័យរដ្ឋបាលដីធ្លី (១.១.២)។

### ១.១.១. នីតិវិជ្ជមានក្នុងការគ្រប់គ្រងដីធ្លី

ក្នុងប្រវត្តិសាស្ត្រកម្ពុជា "សិទ្ធិលើកម្មសិទ្ធិដីធ្លីមានលក្ខណៈផ្សេងៗគ្នាទៅតាមការផ្លាស់ប្តូរនៃរបបនីមួយៗ។ តាមឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជា រាល់ដីធ្លីទាំងអស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងជាកម្មសិទ្ធិផ្តាច់មុខរបស់ព្រះមហាក្សត្រ។"[5] រាល់ការសម្រេចផ្តល់ជូនជាអំណោយ ឬគោលការណ៍ណាមួយស្របព្រះទ័យព្រះមហា-ក្សត្រនោះ ប្រជានុរាស្ត្រអាចធ្វើការទូលថ្វាយបង្គំស្នើសុំដីនៅកន្លែងណាមួយ ដើម្បីតាំងទីលំនៅ និងធ្វើកសិកម្ម។ នៅមុនបារាំងចូលមកកាន់កាប់ប្រទេសកម្ពុជា គឺរាល់កម្មសិទ្ធិជាសិទ្ធិ "ចល័ត"។[6] "ម្ចាស់ដីដែលកំពុងធ្វើកសិកម្ម

---

[4] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦៦អនក្រ.បក, ២០ កក្កដា ១៩៩៩ (ពីពេលនេះតទៅហៅថា អនុក្រឹត្យបង្កើតក្រសួងដែនដី)។

[5] Bhargavi Ramamurthy និងផ្សេងទៀត, "ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ" (ឯកសារពិភាក្សាលេខ២១, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា៖ ភ្នំពេញ, ២០០២), ២៥។

[6] Jeffrey S. Brand, "Cambodia Property Law" [នីតិទ្រព្យសម្បត្តិកម្ពុជា], *Faculty of the Public Management in Cooperation with The University of San Francisco Project to Strengthen the Faculty of Business* (Phnom Penh), (1998): 8។

អាចចាកចោលពីតំបន់មួយទៅចាប់តំបន់មួយទៀត និងអាចធ្វើជាម្ចាស់ដីនោះតាមឆន្ទៈ និងមិនចាំបាច់មានជាទម្រង់ការណាមួយឡើយ។" [7] ក្រោយពីឆ្នាំ១៨៨៤ ជាលើកដំបូងបំផុតដែលបារាំងបានប្រកាសឱ្យប្រើច្បាប់ដីធ្លីនៅកម្ពុជា។[8] របបនៃការផ្លាស់ប្តូររបស់បារាំងធ្វើឱ្យមានការតវ៉ាជាខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរ ដោយការគាបសង្កត់ ទើបបារាំងចាប់ផ្តើមបង្កើតឱ្យមានគោលការណ៍ច្បាស់លាស់ពីកម្មសិទ្ធិដីធ្លី តាមរយៈការបង្កើតក្រមរដ្ឋប្បវេណីដំបូងរបស់កម្ពុជាក្នុងឆ្នាំ១៩២០ និងបានចាប់ផ្តើមចុះបញ្ជីដីធ្លីលើកដំបូងក្នុងឆ្នាំ១៩២៥។[9]

ប្រជាពលរដ្ឋធ្លាប់តែចូលទៅវាស់ចង្អាមដី ឬខណ្ឌចែកជាដុំៗ ដើម្បីចូលទៅតាំងទីលំនៅ បង្កបង្កើនផលស្រែចំការនៅពាសពេញតំបន់ផ្លាស់ពីមួយជំនាន់ ទៅមួយជំនាន់។ ក្រោយមក កម្ពុជាបានអភិវឌ្ឍកម្មវិធីនយោបាយដោយប្រកាសឱ្យទទួលបានការកាន់កាប់សិទ្ធិជាឯកជនភាវូបនីយកម្ម ក្នុងឆ្នាំ១៩៨៩ ដែលកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ត្រូវបានគាំពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ "ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបអាចមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។"[10] ការចាត់ទុកថាជាអចលនវត្ថុក្នុងច្បាប់ភូមិបាល ដែលនៅទីនេះ សំដៅទៅដល់ "អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយ ដែលបានកំណត់ក្នុងច្បាប់ជាអចលនវត្ថុ។"[11] "អចលនវត្ថុ សំដៅទៅលើដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អគារ សំណង់ ដំណាំ រុក្ខជាតិ [លំនៅឋាន ដីធ្លី] ជាអាទិ៍។"[12]

កម្មសិទ្ធិលើអចលនវត្ថុនៅប្រទេសកម្ពុជា បានបែងចែកទៅជា៦ប្រភេទរួមមាន កម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ កម្មសិទ្ធិជាសមូហភាព កម្មសិទ្ធិអវិភាគ សហកម្មសិទ្ធិ កម្មសិទ្ធិសាធារណៈរបស់រដ្ឋ និងកម្មសិទ្ធិឯកជនរបស់រដ្ឋ។ ក្នុងនោះ កម្មសិទ្ធិជាសមូហភាព ត្រូវបានចែកជាអចលនវត្ថុរបស់វត្ត និងអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច។ នៅត្រង់ផ្នែកកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ គឺជាផ្នែកមួយលើកមកពិចារណា និងការសិក្សានៅទីនេះ ដែលជាចំណុចស្នូលនៃសកម្មភាព តែងកើតមានក្នុងទិដ្ឋភាពសង្គមកិច្ច និងសេដ្ឋកិច្ច។ កម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុ គឺឋិតនៅក្រោមការគាំពារនៃច្បាប់។[13] មានន័យថា ការកាន់កាប់អចលនវត្ថុ ដែលត្រឹមត្រូវ គឺគ្មានជនណាម្នាក់ ឬតតិយជនណាមួយមករំលោភបំពានបានឡើយ។ "ស្ទើរតែគ្រប់ប្រទេសទាំងអស់ផល-

---

[7] ទ្រី ហ៊ាង, "វិវាទដីធ្លីនៅកម្ពុជា២០០១-២០០៩" (និក្ខេបបទបណ្ឌិតៈ រាជបណ្ឌិត្យសភាកម្ពុជា, ២០១២), ១១។

[8] ដូច៥, ទំ.២៦។ *គោលការណ៍ច្បាប់ស្តីពីកម្មសិទ្ធិអចលនទ្រព្យឯកជន (ក្នុងសម័យអាណានិគម)។*

[9] Thoin, Serge, *Watching Cambodia: Ten Paths to Enter the Cambodia Tangle* [ទស្សនីយភាពកម្ពុជាៈ មាគ៌ាទាំង១០ ដើម្បីជ្រៀតជ្រែកកម្ពុជា] (ISBN:9748495916/1879155192, 1942), (1st edition, Bangkok Thailand, 1993): 29។

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, និងវិសោធនកម្មលើកទី១០ ឆ្នាំ២០២១, មាត្រា៤៤(១), (ពីពេលនេះតទៅហៅថា រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣)។ និងច្បាប់ស្តីពីភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣១ សីហា ២០០១, មាត្រា ៨(១), (ពីពេលនេះតទៅហៅថា ច្បាប់ភូមិបាល២០០១)។

[11] ច្បាប់ភូមិបាល២០០១, មាត្រា២ និង២(៤)។

[12] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ៨ ធ្នូ ២០០៧, មាត្រា១២០(២)។ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧)។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១,មាត្រា១៣។

[13] រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣, មាត្រា៤៤(២) និងច្បាប់ភូមិបាល២០០១, មាត្រា៣(១)។ *កម្មសិទ្ធិឯកជន គឺជាសិទ្ធិផ្តាច់មុខលើទ្រព្យដែលកម្មសិទ្ធិករមានសិទ្ធិក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែង ក្នុងទំហំដែលច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត បានកម្រិត។*

ប្រយោជន៍ពីដីធ្លី មានរហូតដល់ទៅ៣/៤ (បីភាគបួន) នៃទ្រព្យសម្បត្តិជាតិទាំងមូល។"[14]

"អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់, សមូហភាពដែនដីសាធារណៈ, គ្រឹះស្ថានសាធារណៈ, សហគមន៍ ឬសមាគមកម្ពុជា, សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មនៅកម្ពុជា និងគ្រប់អង្គការកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។"[15] ជនណាដែលបានគោរពទៅតាមលក្ខខណ្ឌកំណត់របស់ច្បាប់ ទើបអាចក្លាយជាជនដែលមានសញ្ជាតិខ្មែរ។ ក្នុងគោលដៅនៃការកំណត់អំពីសញ្ជាតិតាមវិធីរួមមាន ការទទួលបានសញ្ជាតិខ្មែរពីកំណើត ការទទួលបានតាមរយៈការសុំកូនពេញ-លេញ ការទទួលបានដោយរៀបអាពាហ៍ពិពាហ៍ និងសញ្ជាតូបនីយកម្ម។[16]

តាមរយៈសញ្ជាតូបនីយកម្ម គឺជនបរទេស អាចប្រព្រឹត្តឡើងតាមរូបភាពការចំណាយទុនគម្រោងវិនិយោគ ឬអំណោយដល់ថវិកាជាតិ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចក្នុងទំហំណាមួយដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ និងភស្តុតាងជាគុណសម្បត្តិពិសេស ឬថ្វីដៃអ្វីមួយជាផលប្រយោជន៍ជូនប្រទេសកម្ពុជា។[17] ចំពោះជនបរទេស ដែលលក់ទិញអចលនវត្ថុ ឃើញថាមានរូបភាពជាច្រើនដែលអាចទៅរួច និងកំណត់តាមច្បាប់កម្ពុជា។ ជាក់ស្ដែងដូចលក្ខណៈនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ គឺអាចឈរឈ្មោះតំណាងឱ្យជនបរទេស និងកាន់កាប់ភាគហ៊ុនដោយជនជាតិខ្មែរយ៉ាងតិច៥១%។ ពេលខ្លះតម្រូវ ឱ្យជនជាតិខ្មែរតំណាងឈ្មោះក្នុងការលក់ទិញអចលនវត្ថុដោយទទួលបានកម្រៃភាគលាភ។ យ៉ាងណាមិញ កាលក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ មានការចម្រូសចម្រាស់ជាខ្លាំងមួយ ពាក់ព័ន្ធនឹងព័ត៌មានចចាអារ៉ាមពីការលក់ទិញអចលនវត្ថុ និងតាំងទីលំនៅដោយសេរីរបស់ជនបរទេស។ ក្រោយមក រាជរដ្ឋាភិបាលបានបញ្ជាក់យ៉ាងច្បាស់ថា ជនបរទេសអាចធ្វើឡើងតាមរយៈ សិទ្ធិជួលអចិន្ត្រៃយ៍, សម្បទានសេដ្ឋកិច្ច, សហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ ជាអាទិ៍ មិនមែនជនបរទេស ជាម្ចាស់សិទ្ធិអចលនវត្ថុផ្ដាច់មុខដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញកម្ពុជានោះឡើយ។[18]

#### ១.១.១.១. វិធានទំនៀមទម្លាប់

ការគ្រប់គ្រងដីធ្លីនៅកម្ពុជា គឺនៅតែជួបនឹងផលវិបត្តិធ្ងន់ធ្ងរ ដោយសារតែឯកសារដែលពាក់ព័ន្ធនឹងដីធ្លី ត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍។[19]រាល់ទម្រង់ឯកសារ និងម៉ូដែលនៃចុះបញ្ជីដីធ្លីត្រូវបានកសាងឡើងវិញដើម្បីសម្រួលទៅដល់ការកាប់កាប់ដីធ្លីកសិកម្ម លំនៅឋាន ជួយដល់សេដ្ឋកិច្ចជាតិ ទាន់

[14] Kate Dalrymple, “Expanding Rural Land Tenures to Alleviate Poverty [ការពង្រីកកាន់កាប់ដីធ្លីជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ],” *(PhD Thesis,* University of Melbourne, Australia, 2005), 45។

[15] ច្បាប់ភូមិបាល២០០១, មាត្រា៨(២) និងក្រមរដ្ឋប្បវេណីកម្ពុជា, មាត្រា១៣៨ថ្មី។

[16] ច្បាប់ស្ដីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា២, ៦ និង៩។

[17] ដដែល, មាត្រា២១, ២២, និង២៣។

[18] អ៊ា សុវណ្ណារ៉ា, "ស្វែងយល់ពីលក្ខខណ្ឌដែលជនបរទេសអាចទិញអចលនទ្រព្យជាកម្មសិទ្ធិក្នុងប្រទេសកម្ពុជា," *AMS*, ២០២៣, https://economy.ams.com.kh/real-estate/news/understand-the-conditions-under-which-foreigners-can-buy-property/ (ទស្សនាចុងក្រោយថ្ងៃទី ១២ កុម្ភៈ ២០២៤)។

[19] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយដីធ្លី៖ សៀវភៅសដីធ្លី*, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០១៥), ២០។

សភាពការណ៍សេដ្ឋកិច្ចទីផ្សារសេរី។[20] ការបែងចែកម៉ូដែលចុះបញ្ជីអចលនវត្ថុជា២ប្រភេទគឺការចុះបញ្ជីដំបូងនិងការចុះបញ្ជីបន្ត។ ការចុះបញ្ជីដំបូងកម្មសិទ្ធិអចលនវត្ថុចែកចេញជា២ គឺមានការចុះបញ្ជីដំបូងមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដំបូងមានលក្ខណៈជាប្រព័ន្ធ។ ប្រព័ន្ធចុះបញ្ជីទាំង២នេះ គឺមានភាពពេញនិយមបំផុតក្នុងព្រះរាជាណាចក្រកម្ពុជា។ ការចុះបញ្ជីដំបូង ជាការចុះបញ្ជីក្បាលដីទាំងឡាយណា ដែលមិនទាន់បានកត់ត្រាព័ត៌មាន (ទិន្នន័យថ្មី) ទុកចូលក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ចំណែកឯការចុះបញ្ជីបន្ត ជាការចុះបញ្ជីទាក់ទងនឹងការបង្កើត, ផ្ទេរ, និងការកែប្រែសិទ្ធិប្រត្យក្ស ឬការចុះបញ្ជីពាក់ព័ន្ធក្នុងការកែប្រែរូបសណ្ឋាននៃក្បាលដីដែលបានចុះបញ្ជីដំបូងរួចហើយ។[21] ការចុះបញ្ជីដោយបំពេញបន្ថែម ក៏ប្រព័ន្ធចុះបញ្ជីនៅកម្ពុជាចាត់ទុក ថាជាផ្នែកមួយនៃការចុះបញ្ជីដំបូងផងដែរ។ ការចុះបញ្ជីដំបូងដែលមានលក្ខណៈដាច់ដោយដុំ ត្រូវអនុវត្តតាមការកំណត់៥ដំណាក់កាល ដោយស្នើសុំពីបុគ្គលម្ចាស់សិទ្ធិមានដូចជា៖[22] ទី១.ការបំពេញពាក្យស្នើសុំ, ទី២. ការងារបច្ចេកទេសរបស់ក្រុមវាល, ទី៣.ការបិទផ្សាយជាសាធារណៈ, ទី៤.ការសម្រេចលើឯកសារ, និងទី៥.ការចេញបណ្ណ។[23] ការដាក់ពាក្យស្នើសុំត្រូវធ្វើឡើងដោយអ្នកកាន់កាប់ដីធ្លីនោះ មកកាន់រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ តាមរយៈមេឃុំចៅសង្កាត់ដែលក្បាលដីនោះស្ថិតនៅ ត្រូវភ្ជាប់ព័ត៌មានអ្នកស្នើសុំ អត្តសញ្ញាណក្បាលដី និងភស្តុតាងនានាពាក់-ព័ន្ធនឹងសិទ្ធិលើក្បាលដីនោះ។[24] ចំពោះឯកសារណាប ត្រូវតែមានជូនភ្ជាប់។ ជាធម្មតា ប្រវត្តិការកាន់កាប់ដីធ្លីនីមួយៗ មេឃុំចៅសង្កាត់ ជាអ្នកចេញលិខិតទទួលស្គាល់ ដឹងឮជាសាធារណៈ និងចេញបញ្ជាក់លិខិត។[25] មេឃុំចៅសង្កាត់ ត្រូវត្រួតពិនិត្យលើពាក្យស្នើសុំឱ្យបានលម្អិតបំផុត។[26] ត្រូវតែចំណារលើពាក្យស្នើសុំ និងបញ្ជូនបន្ត។[27] រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌរួចមក ត្រូវកំណត់ត្រាទុក និងដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬក្រុង ស្រុក

---

[20] រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣, មាត្រា៥៦(១)។

[21] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៣០។ សិទ្ធិប្រត្យក្ស គឺសំដៅទៅដល់សិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។

[22] អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្រ.បក, ៣១ ឧសភា ២០០២។ និងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១អនក្រ.បក, ៩ មិថុនា ២០១៦ (ពីពេលនេះតទៅហៅថា អនុក្រឹត្យចុះបញ្ជីដាច់ដោយដុំ)។

[23] Korean Land & Housing Corporation, https://www.lh.or.kr/menu.es?mid=a20406000000 (ទស្សនាចុងក្រោយថ្ងៃទី២២ កុម្ភៈ ២០២៤)។ *[ការអនុវត្តក្នុងប្រទេសកូរ៉េខាងត្បូង ក៏បែងចែកដំណាក់កាលនៃការចុះបញ្ជីដីធ្លីប្រហាក់ប្រហែលនឹងកម្ពុជា ផងដែរ (ដូច២៧)]*

[24] អនុក្រឹត្យចុះបញ្ជីដាច់ដោយដុំ, មាត្រា៧។

[25] ប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី, លេខ២១៥ប្រក/ដនស.មផ, ៩ កញ្ញា ២០០៥, ប្រការ៩ថ្មី។ និងប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ស្តីពីការកែសម្រួលប្រការ ៩,លេខ១៥៩ប្រក/ដនស.មផ, ១៥ មិថុនា ២០១៦ (ពីពេលនេះតទៅហៅថា ប្រកាសរដ្ឋ-បាលឃុំ សង្កាត់ចុះបញ្ជីដីធ្លី)។

[26] ប្រទេសកូរ៉េខាងត្បូង, https://taxsummaries.pwc.com/republic-of-korea/corporate/other-taxes និងប្រទេសថៃ https://www.tilleke.com/ insights/new-land-and-building-tax-act-thailand/ (ទស្សនាចុងក្រោយថ្ងៃទី២២ កុម្ភៈ ២០២៤)។ ប្រសិនបើនៅប្រទេសទាំងពីរ ឃើញមានការទាមទារបង្កាន់ដៃពន្ធលើអចលនវត្ថុ និងមានការវិវត្តប្រើប្រាស់ទៅជាប្រភេទ e-ID របស់ពលរដ្ឋម្នាក់ៗ។ ការទាមទារបន្ថែមនេះ បម្រើគោលបំណងមិនក្រៅពីប្រមូលពន្ធទេ គឺរដ្ឋាភិបាលធានាដល់ការវាយតម្លៃអចលនទ្រព្យត្រឹមត្រូវក្នុងតម្លៃទីផ្សារ។

[27] សារាចរណែនាំស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១៤ដនស/សរណន, ៣០ កញ្ញា ២០០៩, ដំណាក់កាល១(២) និង(៣), (ពីពេលនេះតទៅហៅថា សារាចរអនុវត្តចុះបញ្ជីដាច់ដោយដុំ)។

ខណ្ឌ ដើម្បីចេញសេចក្តីជូនដំណឹង ក្នុងកាលបរិច្ឆេទ៧ (ប្រាំពីរ)ថ្ងៃយ៉ាងតិច។[28] ដំណាក់កាលបច្ចេកទេសរបស់ក្រុមវាល គឺការវាស់វែង ឬផលិតផែនទីគោល ដែលជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ក៏អាចសហការជាមួយក្រុមហ៊ុនវាស់វែងនានា។[29] ក្នុងករណី រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ណាមួយមានកង្វះខាតមន្ត្រី ឬកិច្ចការបច្ចេកទេសអ្វីមួយ អាចធ្វើការស្នើសុំទៅរដ្ឋបាលសុរិយាដីរាជធានី ខេត្ត។[30] ការងារនេះមន្ត្រីវាលត្រូវបញ្ចូលទៅប្រព័ន្ធកុំព្យូទ័រ ក្នុងការកសាងផែនទីក្បាលដី កសាងចងក្រងសៀវភៅចុះបញ្ជីដែលបានវាស់វែងដោយឧបករណ៍ DGPS(Differential Global Positioning System)។ ក្រុមវាលតែងជួបការលំបាកជារឿយៗ អំឡុងពេលចុះទៅវាស់វែងដូចជា៖

> ម្ចាស់ដី នៅតាមតំបន់វិនិច្ឆ័យ តែងជួបបញ្ហា ដូចជា ៖ ប្រជាពលរដ្ឋជាម្ចាស់លើអចលនវត្ថុខ្លះ ខ្វះខាតលិខិត និង/ឬ ឯកសារណាមួយផ្សេងៗដែលអាចមកបញ្ជាក់ជាម្ចាស់ស្របច្បាប់។ កិច្ចសហការចូលរួមពីអ្នកកាន់កាប់ដី ឬស្ថាប័នតំណាង នៅមានកម្រិត និងការដោះស្រាយវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យមានភាពយឺតយ៉ាវ និងច្រើនតែកកស្ទះ។ ....ជួបទៅនឹងកង្វះសំណុំលិខិតពេញលេញជាមូលដ្ឋានពីម្ចាស់ចំណែកឯកជន។ល។[31]

ដំណាក់កាលការបិទផ្សាយជាសាធារណៈចំពោះឯកសារវិនិច្ឆ័យ ត្រូវជូនដំណឹងយ៉ាងតិច៣(បី)ថ្ងៃ មុនបិទផ្សាយដល់សាធារណជន ដើម្បីចូលរួមពិនិត្យព័ត៌មាន និងមានរយៈពេល១៥ (ដប់ប្រាំថ្ងៃ) គិតទាំងថ្ងៃឈប់សម្រាក។[32] បច្ចុប្បន្ន ការបិទផ្សាយមិនទាន់ទូលំទូលាយទេ។ ក្រោយពីផុតរយៈពេលបិទផ្សាយ មន្ត្រីជំនាញទទួលបន្ទុកត្រូវធ្វើរបាយការណ៍វិនិច្ឆ័យ និងវាយតម្លៃដាក់ជូនរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ពិនិត្យ និង បញ្ជូនបន្តទៅរដ្ឋ-បាលសុរិយោដីរាជធានី ខេត្ត ដើម្បីសម្រេចលើឯកសារ។[33] ការចេញបណ្ណ ក្នុងករណីជំទាស់ណាមួយ អភិបាលរាជធានី ខេត្ត ត្រូវចារពីមូលហេតុឱ្យបានច្បាស់លាស់។[34] ក្រោយពីពិនិត្យរួច ត្រូវចុះហត្ថលេខាលើបណ្ណកម្មសិទ្ធិនោះ ដែលទទួលបានពីប្រតិភូកម្មហត្ថលេខា។[35] បណ្ណកម្មសិទ្ធិត្រូវបានទទួលស្គាល់ពេញសិទ្ធិ និងតម្រូវឱ្យកម្ម-សិទ្ធិករជាប់កាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យ គិតតាមសន្ទស្សន៍មូលដ្ឋាន និងអត្រាពន្ធរដ្ឋបានកំណត់។[36]

---

[28] អនុក្រឹត្យចុះបញ្ជីដាច់ដោយដុំ, មាត្រា៩។ *(ការកែប្រែកាលបរិច្ឆេទអនុវត្តក្នុងការចុះបញ្ជីអចលនវត្ថុតាមដំណាក់កាលនីមួយៗ ដោយគិតចាប់ពីក្រោយខែមិថុនា ឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន)*។

[29] អនុក្រឹត្យស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី, លេខ១៧អនក្រ.បក, ១ កុម្ភៈ ២០១៦, មាត្រា៥(២) និងមាត្រា១៤។

[30] សារាចរអនុវត្តចុះបញ្ជីដាច់ដោយដុំ, ដំណាក់កាល២(១) និង(២)។

[31] ដូច១៩, ទំ.២៥។ និងច្បាប់ភូមិបាល២០០១, មាត្រា២៣៤-២៣៦។ *[ក្នុងករណីចាំបាច់ អាចមានអាជ្ញាធរសាធារណៈនៅទីតាំងផ្ទាល់]*

[32] អនុក្រឹត្យចុះបញ្ជីដាច់ដោយដុំ, មាត្រា១៣។

[33] សារាចរអនុវត្តចុះបញ្ជីដាច់ដោយដុំ, ដំណាក់កាលទី៤ ចំណុច១ និង២។

[34] លិខិតក្រសួងមហាផ្ទៃជម្រាបជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សម្របសម្រួលឱ្យឆាប់រហ័សដល់ការចុះបញ្ជីដីធ្លី, លេខ៧៩៩សជណ, ៥ មីនា ២០២៤។

[35] សារាចរអនុវត្តចុះបញ្ជីដាច់ដោយដុំ, ដំណាក់កាលទី៥។

[36] អគ្គនាយកដ្ឋានពន្ធដារ, *កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ* (ភ្នំពេញ៖ អគ្គនាយកដ្ឋានពន្ធដារ, ២០១០); និងច្បាប់ភូមិបាល២០០១, មាត្រា២៤១ និង២៤២។

ចំពោះនីតិវិធីចុះបញ្ជីដំបូងដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវអនុវត្តគ្រប់ក្បាលដី (រដ្ឋ និងឯកជន) ដែលស្ថិតក្នុងតំបន់វិនិច្ឆ័យនិងឯកភាពពីក្រសួង ដ.ន.ស។[37] ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធនេះ ជាបន្ទុករបស់រាជរដ្ឋាភិបាលមួយផ្នែក នោះអ្នកស្នើសុំចុះបញ្ជីអចលនវត្ថុដែលមានទីតាំងក្បាលដីស្ថិតនៅក្នុងតំបន់វិនិច្ឆ័យមិនសូវអស់កម្រៃសេវាសាធារណៈឡើយ។ ដំណាក់កាលការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ គឺមាន៥ដំណាក់កាលដូចគ្នាៈ ទី១. ការរៀបចំឯកសារ, ទី២. ការងារបច្ចេកទេសក្រុមវាល, ទី៣. ការបិទផ្សាយសាធារណៈលើឯកសារវិនិច្ឆ័យ, ទី៤. សម្រេចឯកសារ និងទី៥. ចេញបណ្ណ។ ដំណាក់កាលរៀបចំឯកសារ គឺលុះត្រាតែមានការជ្រើសរើសប្រកាសទីតាំងពីអភិបាលរាជធានី ខេត្ត និងឯកភាពពីខាងក្រសួង ដ.ន.ស ក្នុងការកំណត់តំបន់ និងព្រំប្រទល់វិនិច្ឆ័យតាមផែនទីក្នុងតំបន់ដែលមិនទាន់ចុះបញ្ជី។[38] អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ គឺមានភារកិច្ចចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ។[39] អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតផ្លូវការ និងអនុញ្ញាតនីតិវិធី ដល់អាជ្ញាធរមូលដ្ឋានក្នុងតំបន់យ៉ាងតិចមុនកិច្ចប្រជុំផ្សព្វផ្សាយ៧ (ប្រាំពីរ)ថ្ងៃ និងជូនដំណឹងសាធារណៈអំពីកាលបរិច្ឆេទនិងទីកន្លែងប្រជុំឱ្យសាធារណជន ដឹងជាមុនយ៉ាង តិច៣(បី)ថ្ងៃ។[40] ក្រុមវាល ត្រូវជូនដំណឹងដល់ថ្នាក់មូលដ្ឋានបានដឹងជាមុនយ៉ាងតិច៣ (បី)ថ្ងៃ។[41] អភិបាលរាជធានី ខេត្ត ត្រូវជូនដំណឹងបិទផ្សាយសាធារណៈរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃគិតទាំងឈប់សម្រាក។[42] ករណីមានបណ្ដឹង ឬជំទាស់អ្វីមួយ ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដី។[43] បញ្ហានេះ មើលឃើញការអញ្ជើញចុះបញ្ជីរបស់ប្រជាពលរដ្ឋ និងមន្ត្រីសុរិយោដីនៅមានភាពច្របូកច្របល់និងគ្មានសណ្ដាប់ធ្នាប់ ការដណ្ដើមជួរគ្នា ការពិនិត្យព័ត៌មានមិនបានច្បាស់លាស់ បំពេញឯកសារច្រើនពេក និងមានផលវិបាកសម្រាប់មន្ត្រី។ ប្រធានគណៈកម្មការរដ្ឋបាល, ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងអភិបាលរាជធានី ខេត្ត ត្រូវចុះហត្ថលេខាលើលទ្ធផលនៃការវិនិច្ឆ័យ។ រដ្ឋមន្ត្រីក្រសួង ដ.ន.ស ត្រូវចុះហត្ថលេខា សម្រេចយល់ព្រម។[44] ដោយកត់សម្គាល់ឃើញថា មន្ត្រីតាមមូលដ្ឋានមួយចំនួនតាមតំបន់ជនបទ និងដាច់ស្រយាល នៅមិនទាន់យល់ជ្រាបអំពីនីតិវិធីនៅឡើយ។

[37] អនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ/បក, ៣១ ឧសភា ២០០២, មាត្រា២, (ពីពេលនេះតទៅហៅថា អនុក្រឹត្យកសាងប្លង់សុរិយោដី)។ និងអនុក្រឹត្យស្ដីពីការកែសម្រួលមាត្រា៦, ៧ និង១១, លេខ១២២អនក្រ/បក, ៩ មិថុនា ២០០៩ (ពីពេលនេះតទៅហៅថា អនុក្រឹត្យ១២២)។

[38] សារាចរណែនាំស្ដីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ០០១ដនស/សជ, ១៩ សីហា ២០០២, ដំណាក់កាលទី១ ចំណុចទី១ (ពីពេលនេះតទៅហៅថា សារាចរ០០១)។ *[ពិព្រោះកម្រៃសេវាចន្លោះពី១ ទៅ៥០០រៀល ប៉ុណ្ណោះ]*

[39] អនុក្រឹត្យកសាងប្លង់សុរិយោដី, មាត្រា៣។ *គណៈកម្មការរដ្ឋបាល គឺត្រូវបិទផ្សាយសាធារណៈពីប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី ស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង ដោយធ្វើសេចក្ដីសន្និដ្ឋានលើឯកសារវិនិច្ឆ័យ។*

[40] សារាចរ០០១, ដំណាក់កាលទី១ ចំណុចទី៦។

[41] អនុក្រឹត្យកសាងប្លង់សុរិយោដី, មាត្រា៨។

[42] អនុក្រឹត្យ១២២, មាត្រា១១។

[43] សារាចរ០០១, ដំណាក់កាលទី៣។

[44] សារាចរ០០១, ដំណាក់កាលទី៤។

### ១.១.១.២. ការកំណត់ភូមិសាស្ត្រចុះបញ្ជីដីធ្លី

កេរដំណែលបន្សល់ទុកពីបុព្វបុរស រហូតដល់បច្ចុប្បន្នមានផ្ទៃក្រឡាសរុប ១៨១.០៣៥Km$^2$ ដោយមានព្រំប្រទល់ជាប់នឹងប្រទេសថៃនៅភាគខាងលិច និងពាយ័ព្យ, ប្រទេសឡាវនៅភាគឦសាន្ត, ប្រទេសវៀតណាមនៅភាគខាងកើត, ឈូងសមុទ្រថៃនៅភាគនិរតី និងទន្លេមេគង្គដែលមានបណ្ដោយប្រវែង ៤.២០០Km។ កម្ពុជាមានរាជធានី/ខេត្តចំនួន២៥ គិតត្រឹមឆ្នាំ២០២៤ ដោយរាជធានីភ្នំពេញ គឺមានឈ្មោះដើមហៅថា "ក្រុងចតុមុខមង្គលសកលកម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរីរដ្ឋ រាជសីមា មហានគរ" ប្រែថា "ទីនៃទន្លេមុខបួន ដែលផ្ដល់សេចក្ដីសុខចម្រើនស្រីសួស្ដីនៃនគរកម្ពុជាជាម្ចាស់លើសគេ ជាទីឋានព្រះឥន្ទ្រដ៏ថ្លៃថ្លាលើសលែងនៃនគរដ៏មហាធំធេង" និងជាទីក្រុងដែលមានប្រជាជនរស់នៅច្រើនជាងប្រមាណ២.២៨លាននាក់។[45]

ការស្វែងយល់ពីរដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់មានសារៈសំខាន់ ក្នុងការសម្រេចឱ្យបានការធ្វើបរិវត្តកម្មឱ្យជីថលលើការចុះបញ្ជីដីធ្លី។ ចាប់ពីឆ្នាំ២០០៨មក កម្ពុជាចែកចេញជា "រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។"[46] ចាប់ពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤ គឺចំនួនក្រុង ស្រុក ខណ្ឌទូទាំងប្រទេសចំនួន២០៩ មានអាសនៈសមាជិកក្រុមប្រឹក្សាចំនួន រាជធានី ខេត្តប្រមាណ៥៥៩ និងអាសនៈសមាជិកក្រុមប្រឹក្សាចំនួនក្រុង ស្រុក ខណ្ឌប្រមាណ៣.៦៤១។ ចំណែករដ្ឋបាលថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេសចំនួន១.៦៥២ ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានបោះឆ្នោតគឺ ១១.៦២២។[47] របាយការណ៍វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០២១ កម្ពុជាមានចំនួនគ្រួសារ៩២% នៃគ្រួសារសរុបដែលមានលំនៅឋានជាកម្មសិទ្ធិផ្ទាល់ខ្លួន។[48]

| ស្ថានភាពកម្មសិទ្ធិ | កម្ពុជា | រាជធានី | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| លំនៅឋានកម្មសិទ្ធិផ្ទាល់ខ្លួន | **៩១,៧** | ៧២,៣ | ៩១,៧ | ៩៦,២ |
| លំនៅឋានគ្មានកម្មសិទ្ធិ តែរស់នៅមិនគិតថ្លៃ | ៣,៩ | ៦,១ | ៤,២ | ៣,៣ |
| លំនៅឋានជួលគេ | ៤,៣ | ២១,៤ | ៤,១ | ០,៤ |
| ផ្សេងទៀត | ០,១ | ០,២ | ០,០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | **៣.៨៦៩,៩** | ៥៥៣,៣ | ៩១៩,០ | ២.៣៩៧,៦ |

តារាងទី១៖ លំនៅឋានដែលបានកាន់កាប់បែងចែកតាមស្ថានភាពកម្មសិទ្ធិ និងតាមតំបន់ភូមិសាស្ត្រនៅក្នុងឆ្នាំ២០២១ (គិតជាភាគរយ)

---

45 ហួរ ជី, "អត្រាប្រជាជនរស់នៅភ្នំពេញបានកើនឡើងពី១០ម៉ឺនក្នុងឆ្នាំ១៩៧៩ដល់ជាង២.២៨លាននាក់ក្នុងឆ្នាំ២០២៣," *Cambodia Morning Post*, ២០២៣, https://morningpostkh.com/news (ទស្សនាចុងក្រោយថ្ងៃទី៣ មេសា ២០២៤)។

46 រដ្ឋធម្មនុញ្ញ១៩៩៣, មាត្រា១៤៥ថ្មី(មួយ)។

47 វង សុភ័ក្រ្ត, "គ.ជ.ប៖ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ កើនឡើងចំនួន៥អាសនៈ និង១ក្រុង," *CNC*, ២០២៤, https://www.cnc.com.kh/detail/news/49539 និង/ឬដោយ គ.ជ.ប https://www.nec.gov.kh/khmer/content/ 258 (ទស្សនាចុងក្រោយថ្ងៃទី៣ មេសា ២០២៤) ។

48 វិទ្យាស្ថានជាតិស្ថិតិ, *របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២១*, (ភ្នំពេញ៖ ក្រសួងផែនការ, ២០២២), ៤១ (ពីពេលនេះតទៅហៅថា របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០២១)។

តាមការបែងចែកគ្រួសារដែលមានលំនៅឋាន គិតជាផ្ទៃក្រឡាកម្រាលលំនៅឋានជាមធ្យមឆ្នាំ២០២១មានប្រមាណជា៥៥m² ដោយគ្រួសាររស់នៅតាមជនបទមាន៥២m²/គ្រួសារ និង៥៥m²/គ្រួសារ នៅតំបន់ទីប្រជុំជនផ្សេងៗ និងចំពោះគ្រួសារដែលលើសពី១០០m² ប្រមាណ១៦% នៅរាជធានីភ្នំពេញ៧%, តំបន់ទីប្រជុំជនផ្សេងៗ និងជនបទមាន៥%។[49]ក្នុងនោះបង្ហាញថា គ្រួសារ៣១% នៅតាមជនបទបានកាន់កាប់លំនៅឋានមានផ្ទៃក្រឡាកម្រាល៤០m² បើធៀបនឹងគ្រួសាររស់នៅតំបន់ទីប្រជុំជនផ្សេងៗ និងគ្រួសាររស់នៅរាជធានីភ្នំពេញគឺមាន២៩% ដែលមានលំនៅឋានផ្ទៃក្រឡាកម្រាលតែយ៉ាងតិច៤០m² ប៉ុណ្ណោះ។[50]

| ផ្ទៃក្រឡាកម្រាល | កម្ពុជា | រាជធានី | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ០០-១៩ | ៣,៥ | ១០,១ | ២,៣ | ២,៤ |
| ២០-៣៩ | ២៦,៦ | ១៩,២ | ២៦,៧ | ២៨,៣ |
| ៤០-៥៩ | ៣៥,៦ | ២៣,៧ | ៣៥,៨ | ៣៨,២ |
| ៦០-៧៩ | ១៩,៣ | ២១,០ | ១៩,០ | ១៩,១ |
| ៨០-៩៩ | ៨,២ | ១០,៤ | ៩,១ | ៧,៣ |
| ១០០+ | ៦,៨ | ១៥,៦ | ៧,០ | ៤,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| មធ្យមភាគម៉ែត្រការ៉េក្នុងមួយគ្រួសារ | ៥៥,១ | ៦៦,៤ | ៥៥,៣ | ៥២,៤ |

តារាងទី២៖ ផ្ទៃក្រឡាកម្រាលបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០២១ (គិតជាភាគរយ) ជាមធ្យមភាគម៉ែត្រការ៉េក្នុងមួយគ្រួសារ

នៅក្នុងការកំណត់ភូមិសាស្ត្រ ត្រូវយល់ច្បាស់ពីផ្នែកកសិកម្មដែលជាចំណុចស្នូល និងការប្រកបជីវភាពរបស់ ប្រជាពលរដ្ឋខ្មែរដែលបានតាំងទីលំនៅ។ ទិន្នន័យដែលត្រូវយកមកវិភាគ គឺរបាយការណ៍អង្កេតខាងលើបែងចែកផ្នែកកសិកម្មទៅជា៦ចំណុចរួមមាន កម្មសិទ្ធិដីធ្លី, ការដាំដុះដំណាំ, ការចំណាយសម្រាប់ដាំដុះដំណាំ, ការចិញ្ចឹមសត្វពាហនៈ និងបសុបក្សី, ការចិញ្ចឹមត្រី និងការនេសាទ, ព្រៃឈើ និងការបរបាញ់សត្វ។ ទៀតសោតត្រូវបានបែងចែកជា៥តំបន់ធំៗរួមមាន៖ រាជធានីភ្នំពេញ, តំបន់វាលទំនាប, តំបន់ទន្លេសាប, តំបន់ឆ្នេរសមុទ្រ, តំបន់ភ្នំនិងខ្ពង់រាប។[51] ក្នុងការសិក្សានេះលើកយកតែក្នុងចំនុចទី១ កម្មសិទ្ធិដីធ្លី "ដោយគ្រួសារដែលមានមុខរបរកសិកម្មជាចម្បង បានទទួលដីអាស្រ័យលើទំហំគ្រួសារ និងលក្ខណៈផ្សេងៗរបស់គ្រួសារ ហើយចាប់តាំងពីពេលនោះមកកម្ពុជាមានការផ្លាស់ប្តូរសេដ្ឋកិច្ច និងសង្គមកិច្ចគួរឱ្យកត់សម្គាល់ (ដូចជាមានការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន, ការធ្វើនគរូបនីយកម្ម, កំណើនសេដ្ឋកិច្ច និងកំណើនប្រជាជន) ដែលបង្កើតឱ្យមានតម្រូវការផ្សេងៗចំពោះដីធ្លី"។[52]

[49] ដដែល, ទំ.៤១-៤២។

[50] ដដែល, ទំ.៤២-៤៣។

[51] ដដែល, ទំ.៥៣។

[52] ដដែល, ទំ.៥៤(៣ វាក្យ.៣)។

តាមភូមិភាគនៃតំបន់វាលទំនាប គឺមានចំណែកភាគធំលើផ្ទៃដីកសិកម្ម បន្ទាប់ពីតំបន់ទន្លេសាប។ នៅក្នុងរាជធានីភ្នំពេញ ដោយសារតែមានការអភិវឌ្ឍ និងកើនឡើងនៃអគារពាណិជ្ជកម្ម អគារសហវិជ្ជតរាជ្យ (ខុនដូ) និងអគារការិយាល័យភាគច្រើន គឺធ្វើឱ្យផ្ទៃដីកសិកម្មរួមតូច ដែលសេសសល់នៅតាមតំបន់ជាយក្រុងតិចតួច។ នៅកម្ពុជាសមភាពយេនឌ័រនៃមេគ្រួសារជាស្ត្រី កាន់កាប់កម្មសិទ្ធិផ្ទៃដីកសិកម្មប្រមាណតែ១០% (ស្មើ៤២៣ពាន់ហិកតា) នៃផ្ទៃដីកសិកម្មសរុប ៤.០៦៩ពាន់ហិកតា ប៉ុណ្ណោះគិតត្រឹមឆ្នាំ២០២១។[53]

| តំបន់ | ស្ត្រី | | បុរស | | ទាំងពីរភេទ |
|---|---|---|---|---|---|
| | ហិកតា | % | ហិកតា | % | ហិកតា |
| កម្ពុជា | ៤២៣ | **១០,៤** | ៣.៦៤៧ | ៨៩,៦ | ៤.០៦៩ |
| រាជធានីភ្នំពេញ | ៧ | ១៩,៧ | ២៧ | ៨០,៣ | ៣៤ |
| តំបន់វាលទំនាប | ១៦៤ | ១៤,៣ | ៩៨៣ | ៨៥,៧ | ១.១៤៧ |
| តំបន់ទន្លេសាប | ១៦២ | ១០,០ | ១.៤៥២ | ៩០,០ | ១.៦១៤ |
| តំបន់ឆ្នេរសមុទ្រ | ១៥ | ៨,៦ | ១៦១ | ៩១,៤ | ១៧៧ |
| តំបន់ភ្នំ និងខ្ពង់រាប | ៧៥ | ៦,៨ | ១.០២៣ | ៩៣,២ | ១.០៩៨ |

តារាងទី៣៖ ផ្ទៃដីកសិកម្មបែងចែកតាមភេទនៃគ្រួសារ និងតំបន់ឆ្នាំ២០២១ (គិតជាពាន់ហិកតា)

ដើម្បីអាចបញ្ជាក់ឱ្យដឹងថា ផ្ទៃក្រឡាដីកសិកម្មដែលលាតសន្ធឹងទូទាំងប្រទេស ប្រជាពលរដ្ឋបាននឹងកំពុងប្រើប្រាស់ និងអាស្រ័យផលប្រកបដោយប្រសិទ្ធភាពឬយ៉ាងណា? គួរត្រូវដឹងថា ប្រជាពលរដ្ឋខ្មែរមានទម្លាប់ប្រើ-ប្រាស់ដីដោយវិធីណា និងស្រូបប្រយោជន៍ពីសិទ្ធិកម្មសិទ្ធិនៅចន្លោះណា។ ផ្ទៃដីកសិកម្មទូទាំងប្រទេសប្រមាណ ២លានហិកតា ប៉ុន្តែ ប្រើក្នុងរដូវវស្សាតែចំនួន១.៧៩២ពាន់ហិកតា និង២៥១ពាន់ហិកតា ដែលប្រើប្រាស់ដោយមេគ្រួសារជាស្ត្រី។

| តំបន់ | កម្ពុជា | | រាជធានី | | តំបន់វាលទំនាប | | តំបន់ទន្លេសាប | | តំបន់ឆ្នេរសមុទ្រ | | តំបន់ភ្នំ និងខ្ពង់រាប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | គិតជាពាន់ហិកតា | | | | | | | | | | | |
| ដីរដូវវស្សា | **២៥១** | **១.៧៩២** | ៣ | ១១ | ៩១ | ៤២៣ | ១០៦ | ៨៣២ | ១១ | ៩០ | ៤០ | ៤៣៧ |
| ដីរដូវប្រាំង | ៤៥ | ៣២៥ | ០ | ២ | ២៤ | ១៥៨ | ២០ | ១៤៥ | ០ | ៣ | ១ | ១៨ |
| ដីទាំងពីររដូវ | ៤០ | ៣៥០ | ១ | ៦ | ២០ | ១៣១ | ១៥ | ១៤៨ | ០ | ២២ | ៣ | ៤៣ |
| ដីសួនបន្លែ/ដីចម្ការ | ២២ | ៤៣៧ | ១ | ០ | ៨ | ៦៣ | ៦ | ១៨៣ | ០ | ៤ | ៧ | ១៨៧ |
| ដីដំណាំអចិន្ត្រៃយ៍ | ៤១ | ៦០៨ | ១ | ២ | ១៨ | ១៧១ | ៨ | ១២៨ | ៣ | ២៣ | ១២ | ២៨៣ |
| ដីចិញ្ចឹមសត្វ | ០ | ៣ | ០ | ១ | ០ | ១ | ០ | ០ | ០ | ១ | ០ | ០ |
| ដីព្រៃឯកជន | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ |
| ដីទំនេរ | ២២ | ១៣០ | ១ | ៥ | ២ | ៣៨ | ៧ | ១៦ | ១ | ១៧ | ១១ | ៥៤ |
| ដីដទៃទៀត | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ |
| សរុប | ៤២២ | ៣.៦៤៧ | ៧ | ២៧ | ១៦៤ | ៩៨៣ | ១៦២ | ១.៤៥២ | ១៥ | ១៦១ | ៧៥ | ១.០២៣ |

53 ដដែល, ទំ.៥៥-៥៦។

តារាងទី៤៖ ផ្ទៃដីកសិកម្មបែងចែកតាមភេទនៃគ្រួសារ តាមប្រភេទដី និងតំបន់ទូទាំងប្រទេសក្នុងឆ្នាំ២០២១ (គិតជាពាន់ហិកតា)

បើប្រៀបធៀបតំបន់ទាំង៥តំបន់នៃ២រដូវនេះ គឺក្នុងតំបន់ទន្លេសាបមានផ្ទៃដីកសិកម្មធំជាងគេប្រមាណ១.៦១៤ពាន់ហិកតា ក៏ជាដើមហេតុនៃរឿងអាស្រូវក្នុងអំឡុងឆ្នាំ២០២២ ផងដែរ ករណីកាប់ទន្រ្ទាន និងចូលទៅកាន់កាប់ខុសច្បាប់នៃតំបន់ទាំង៣ផ្នែក ក្នុងបណ្តាខេត្តទាំង៦នៃជុំវិញតំបន់ទន្លេសាប។ ខេត្តទាំង៦ មានដូចជា ខេត្តពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពង់ធំ, និងខេត្តកំពង់ឆ្នាំង។ មេឃុំចៅសង្កាត់ គឺត្រូវតែទប់ស្កាត់ឱ្យបានចំពោះរាល់សកម្មភាពរានដីតាមទំនើងចិត្ត និងការចូលកាន់កាប់ដោយគ្មានការអនុញ្ញាត។[54] ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបានគាំពារដោយរដ្ឋធម្មនុញ្ញ។[55] គិតត្រឹមចុងឆ្នាំ២០២២ ក្រោយពីការអនុវត្តទៅលើវិធានការបង្ក្រាបការទន្រ្ទានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៃបឹងទន្លេសាប រាជរដ្ឋាភិបាលបានសម្រេចការកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣ នៃបឹងទន្លេសាប បានចំនួនសរុបទំហំជាង២៤.៩៤០ហិកតា ជូនទៅដល់ពលរដ្ឋចំនួនជាង១៥.០០០គ្រួសារ។[56]

ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ នាយករដ្ឋមន្ត្រីថ្មីបានថ្លែងជំរុញដល់ស្ថាប័នពាក់ព័ន្ធឱ្យចុះបញ្ជីដីធ្លីនៅជុំវិញបឹងទន្លេសាបឱ្យបានរួចរាល់ ហើយត្រូវគូសផែនទី និងបោះបង្គោលព្រំដីឱ្យមានសុក្រឹតភាពដើម្បីធានាដល់ការគ្រប់គ្រងបឹងទន្លេសាបបានល្អប្រសើរ។[57] ស្របតាមអនុសាសន៍នេះ ក្រសួងរៀប-ចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស), គណៈកម្មការសុរិយោដីថ្នាក់ជាតិ, អាជ្ញាធរទន្លេសាប (Tonle Sap Authority-TSA), អាជ្ញាធរមូលដ្ឋាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានឯកភាពរួមគ្នាកំណត់យកតំបន់បឹងទន្លេសាបទាំងមូលដើម្បីធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជា ក៏បានចេញជាសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប ដើម្បីដឹកនាំចុះបញ្ជីក្នុងតំបន់ទាំង៣ បោះបង្គោលព្រំដែនដីលិចទឹក (តំបន់ទី៣) និងចាត់វិធានការរាល់បទល្មើសកាន់កាប់នានា។ ការណ៍នេះ គឺអនុវត្តតាមប្រកាសរបស់ក្រសួង ដ.ន.ស ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជី និងការផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋក្នុងតំបន់២ ក្នុងភូមិសាស្ត្រខេត្តទាំង៦ នៅជុំវិញបឹងទន្លេ, ដើម្បីអនុវត្តយ៉ាងមានប្រសិទ្ធភាពលើការកាន់កាប់កម្មសិទ្ធិស្របច្បាប់។

ប្រសិនបើក្រឡេកមើលប្រជាសាស្ត្ររបស់ប្រជាពលរដ្ឋខ្មែរ តើប្រជាកសិករចំនួនប៉ុន្មានគ្រួសារ បានបញ្ជាក់

[54] ប្រកាសរដ្ឋបាលឃុំ សង្កាត់ចុះបញ្ជីដីធ្លី, ប្រការ៥។

[55] រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣, មាត្រា៥៨។

[56] ញ៉ែម សុផល, "ឧបនាយករដ្ឋមន្ត្រីជំរុញខេត្តទាំង៦ជុំវិញបឹងទន្លេសាបពន្លឿនការងារចុះបញ្ជីដីធ្លី," *AMS*, ២០២៤, https://economy.ams.com.kh/real-estate/news/deputy-pm-say-sam-al-urges-6-provinces-around-tonle-sap-lake-to-accelerate-land-registration-in-tonle-sap-lake/ (ទស្សនាចុងក្រោយថ្ងៃទី៥ កុម្ភៈ ២០២៤)។

[57] ប្រតិកម្មរហ័ស, "នាយករដ្ឋមន្ត្រីជំរុញដល់ស្ថាប័នពាក់ព័ន្ធឱ្យចុះបញ្ជីដីធ្លីនៅជុំវិញបឹងទន្លេសាបឱ្យបានរួចរាល់," ២០២៤, https://pressocm.gov.kh/archives/90247 និងប្រភពមួយទៀត https://www.cpp.org.kh/details/366512 (ទស្សនាចុងក្រោយថ្ងៃទី៥ កុម្ភៈ ២០២៤)។

នីត្យានុកូលនៃកម្មសិទ្ធិដីកសិកម្មរបស់ខ្លួន? ចុះប្រជាកសិករដែលពុំទាន់មានកម្មសិទ្ធិ និងមិនបានរាយការណ៍តើអាចប៉ះពាល់ដល់ការឃើតយ៉ាវក្នុងការចុះបញ្ជីដែរឬទេ?

ការចង្អុលបង្ហាញក្នុងគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ គឺត្រូវតែលើកកម្ពស់ជាប្រចាំលើគុណភាពនៃជីវិតរបស់ប្រជាជនខ្មែរ និងការកាត់បន្ថយភាពក្រីក្រ ដោយគិតគូរធានាឱ្យដល់កំណើនសេដ្ឋកិច្ចក្នុងម្នាក់ៗ ជាពិសេស គឺមានជម្រកលំនៅឋាន ផ្ទះសម្បែង ដីស្រែចំការ ប្រកបដោយបរិយាបន្ន។ ការប៉ាន់ប្រមាណប្រជាជនខ្មែរ ពាក់កណ្តាលឆ្នាំ២០២៣ គឺមានចំនួន១៦.៩៤៤.៨២៦នាក់ ក្នុងដង់ស៊ីតេប្រជាជន៩១នាក់/Km$^2$។ បើគិតត្រឹមនាថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ មានចំនួនប្រជាជនប្រមាណជាង១៧.០៣៦.០១៥នាក់ និងអាចឈានដល់១៨.០៨៤.២៤៨នាក់ក្នុងឆ្នាំ២០៣០ នេះបើយោងតាមទិន្នន័យព្យាកររបស់អង្គការ Worldometer នៃអង្គ-ការសហប្រជាជាតិ។[58] បរិកាណ៍នេះប្រទេសកម្ពុជា ត្រូវតែរៀបចំផែនទីបង្ហាញផ្លូវសេដ្ឋកិច្ច សម្រាប់ការពង្រីកលើវិស័យនានា ត្រូវក្លាយជាឯកសារគោលសម្រាប់ការរៀបចំផែនការអភិវឌ្ឍតាមវិស័យ ជាពិសេស វិស័យកសិកម្មដែលត្រូវពន្លឿនសិទ្ធិកម្មសិទ្ធិជូនប្រជាកសិករ។ កម្ពុជា ក៏ត្រូវតែរៀបចំនិងបញ្ចូលការព្យាករកំណើននៅតាមតំបន់ជាពិសេស តំបន់ទីប្រជុំជនក្នុងរយៈពេល៣០-៤០ឆ្នាំខាងមុខ ក្នុងការធ្វើផែនការអភិវឌ្ឍន៍ ដោយគិតគូរពីកំណើនប្រជាជន និងយុវជននាពេលអនាគត អ្វីដែលសំខាន់ត្រូវមានភាពស៊ីសង្វាក់គ្នាទៅនឹងតម្រូវការ ដែលកើតចេញពីផ្ទៃដីកសិកម្ម។

ចំនួនគ្រួសារដែលបានរាយការណ៍អំពីភាពជាម្ចាស់កម្មសិទ្ធិនៃដីកសិកម្ម មានគ្រួសារតែប្រមាណ៤៧%នៃគ្រួសារសរុបទាំងអស់នៅកម្ពុជា ប៉ុណ្ណោះ ដែលមានដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនតិចជាង១០.០០០m$^2$ ឬស្មើនឹង១ហិកតា និងក្នុងរាជធានីភ្នំពេញមានផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនតិចជាងគេ គិតត្រឹមឆ្នាំ២០២១។[59]

| ផ្ទៃដី | កម្ពុជា | រាជធានី | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំ និងខ្ពង់រាប |
|---|---|---|---|---|---|---|
| | ចំនួនគិតជាពាន់គ្រួសារ | | | | | |
| តិចជាង១០.០០០m$^2$ | ១.០៨០ | ៨៤ | ៥០៦ | ២២៣ | ១១៤ | ១៥៣ |
| ១០.០០០m$^2$ - ១៩.៩៩៩m$^2$ | ៥៥៧ | ១០ | ២៣២ | ១៩០ | ៣៧ | ៨៨ |
| ២០.០០០m$^2$ - ២៩.៩៩៩m$^2$ | ២៥៦ | ០ | ៧៧ | ១១០ | ៩ | ៥៩ |
| ៣០.០០០m$^2$ - ៣៩.៩៩៩m$^2$ | ១៣៧ | ០ | ៣៤ | ៦៨ | ៣ | ៣២ |
| ៤០.០០០m$^2$ - ៤៩.៩៩៩m$^2$ | ៧៦ | ០ | ១៦ | ៣៣ | ២ | ២៦ |
| ៥០.០០០m$^2$ - ៩៩.៩៩៩m$^2$ | ១៣៧ | ០ | ២៦ | ៥៨ | ២ | ៥០ |
| ១០០.០០០m$^2$ ឡើងទៅ | ៤៩ | ០ | ១០ | ២០ | ២ | ១៧ |
| សរុប | ២.២៩៣ | ៩៤ | ៩០១ | ៧០៣ | ១៦៩ | ៤២៦ |

តារាងទី៥៖ ចំនួនគ្រួសារមានផ្ទៃដីកសិកម្មបែងចែកតាមផ្ទៃដី និងតាមតំបន់ឆ្នាំ២០២១ (គិតជាពាន់ហិកតា)

[58] Worldometer, "Cambodia Population," 2024, https://www.worldometers.info/world-population/cambodia-population/#google_vign ette (ទស្សនាចុងក្រោយថ្ងៃទី៥ មករា ២០២៤), និងគោលនយោបាយជាតិប្រជាជន២០១៦/៣០។

[59] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០២១, ៥៦។

អាស្រ័យទៅតាមលក្ខណៈកម្មសិទ្ធិ និងតាមតំបន់ដែលកំពុងប្រើប្រាស់ដីកសិកម្ម គឺនៅមានកង្វះភាគច្រើននៃភាពជាម្ចាស់កម្មសិទ្ធិដីកសិកម្ម បើធៀបនឹងផ្ទៃដីគ្រោងវាស់សរុបនៅទូទាំងប្រទេស។ ដូចនេះ មានន័យថាការស្រូបយកប្រយោជន៍ពីដីកសិកម្មនៅកម្ពុជា មានគម្លាតខ្លាំង និងរឹតតែត្រូវជំរុញដល់ការចុះបញ្ជីកម្មសិទ្ធិជូនប្រជា-កសិករតាមរូបភាពផ្សេងៗនៃគោលនយោបាយរាជរដ្ឋាភិបាល ដើម្បីផ្គត់ផ្គង់តាមតម្រូវការនៅចំពោះមុខ។ ការងារកែទម្រង់ដីធ្លី គឺមានសារៈសំខាន់ក្នុងការពង្រីក និងការបែងចែកដីកសិកម្ម ក្នុងក្របខណ្ឌដីសម្បទានសង្គមកិច្ច សំដៅលើកកម្ពស់បង្កើនផលិតភាព និងពិពិធភាវូបនីយកម្ម និងកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ។ ការចុះបញ្ជីដីធ្លី ត្រូវបានវាយតម្លៃថា គួរមានវឌ្ឍនភាពជួយដល់កសិករទទួលបានកម្មសិទ្ធិដែលត្រឹមត្រូវស្របច្បាប់។

ដីកសិកម្មកម្មសិទ្ធិផ្ទាល់ខ្លួនប្រមាណ៨២% ក្នុងផ្ទៃដីកសិកម្មសរុបបច្ចុប្បន្ន និង ៨%នៃដីកសិកម្មកម្មសិទ្ធិដែលបានដាក់ជួលឱ្យអ្នកដទៃប្រើប្រាស់ក្នុងគោលដៅណាមួយ និង/ឬកិច្ចសន្យា។ បើប្រៀបធៀបផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួននៃតំបន់ទាំង៥ ភាគចំណែកខ្ពស់បំផុតនៃផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនក្នុងតំបន់ឆ្នេរសមុទ្រប្រមាណ៩០%។ រីឯផ្ទៃដីកសិកម្មដាក់ជួលឱ្យអ្នកដទៃ មានកម្រិតខ្ពស់ប្រមាណ១១% ក្នុងតំបន់ទន្លេសាប។[60]

| ការកាន់កាប់ដី | កម្ពុជា | | រាជធានី | | តំបន់វាលទំនាប | | តំបន់ទន្លេសាប | | តំបន់ឆ្នេរសមុទ្រ | | តំបន់ភ្នំ និងខ្ពង់រាប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % | ហិកតា | % |
| | គិតជាពាន់ហិកតា | | | | | | | | | | | |
| ដីកម្មសិទ្ធិផ្ទាល់ខ្លួន | ៣.៣៣៣ | ៨១,៩ | ១៣ | ៣៨,៩ | ៩២៣ | ៨០,៥ | ១.២៦០ | ៧៨,១ | ១៦០ | ៩០,៤ | ៩៧៧ | ៨៩,០ |
| ដីកម្មសិទ្ធិតែជួយឱ្យអ្នកដទៃ | ៣២៣ | ៧,៩ | ១៧ | ៥១,១ | ១០៦ | ៩,៣ | ១៤៧ | ៩,១ | ៧ | ៤,២ | ៤៤ | ៤,១ |
| ដីជួលពីអ្នកដទៃ | ៣១៦ | **៧,៨** | ២ | ៦,២ | ៨៧ | ៧,៦ | ១៧១ | ១០,៦ | ៧ | ៤,២ | ៤៨ | ៤,៤ |
| ដីប្រើប្រាស់មិនគិតថ្លៃ | ៩៦ | ២,៤ | ១ | ៣,៨ | ៣១ | ២,៧ | ៣៤ | ២,១ | ២ | ១,២ | ២៨ | ២,៥ |
| ដីកាន់កាប់ផ្សេងៗ | ១ | 0,0 | 0 | 0,0 | 0 | 0,0 | ១ | 0,១ | 0 | 0,0 | 0 | 0,0 |
| សរុប | ៤.0៦៩ | ១00 | ៣៤ | ១00 | ១.១៤៧ | ១00 | ១.៦១៤ | ១00 | ១៧៧ | ១00 | ១.0៩៨ | ១00 |

តារាងទី៦៖ ផ្ទៃដីកសិកម្មបែងចែកតាមលក្ខណៈនៃកម្មសិទ្ធិ និងតាមតំបន់ឆ្នាំ២០២១ (គិតជាពាន់ហិកតា)

ដីសាធារណៈរបស់រដ្ឋជាច្រើន នៅពុំទាន់បានធ្វើអត្តសញ្ញាណកម្ម បោះបង្គោលកំណត់ព្រំប្រទល់ដីរដ្ឋ គួប-ផ្សំនឹងវិធានការគ្រប់គ្រង និងការប្រើប្រាស់មិនបានដិតដល់ នាំឱ្យមានឱកាសនៃការរំលោភយកដីរដ្ឋគ្រប់រូបភាពផ្សេងៗ។ ម្យ៉ាងវិញ កិច្ចសហការរវាងសមត្ថកិច្ចជំនាញ និងអាជ្ញាធរដែនដី ក្នុងការគ្រប់គ្រង និងការប្រើប្រាស់ដីរដ្ឋនៅមិនទាន់ប្រទាក់ក្រឡាក្នុងការអនុវត្តឡើយ។ កត្តានេះ កម្ពុជាបានបង្កើតច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, និងអនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ។ ទៀតសោត គឺបានចង្អុលបង្ហាញតាមរយៈប្លង់គោលប្រើប្រាស់ទៅតាមខេត្ត ក្រុង ស្រុក ខណ្ឌនានា ដែលជាចក្ខុវិស័យរហូតដល់ឆ្នាំ២០៣៥ របស់ក្រសួង ដ.ន.ស ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ភ្ជាប់ជាមួយបញ្ជីរាយនាមភូមិសាស្ត្រនៃព្រះ-

[60] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ច២០២១, ៥៨-៥៩។

រាជាណាចក្រកម្ពុជា ដែលទើបដាក់ឱ្យប្រើប្រាស់ផ្លូវការកាលពីខែតុលា ឆ្នាំ២០២៣។ នៅពេលដែលទីផ្សារដីធ្លីចាប់ផ្តើមមានសន្ទុះ បាតុភាពនៃការរំលោភលើដីរដ្ឋ ការដណ្តើមគ្នាកាន់កាប់ដី និងទំនាស់កើតមានឡើងជាបន្តបន្ទាប់ ដែលជាកត្តាឱ្យមានការទាមទារខិតខំពន្លឿនការចុះបញ្ជីដីធ្លី។[61]

### ១.១.២. សមត្ថកិច្ចអនុវត្តអនុវិស័យរដ្ឋបាលដីធ្លី

ការអនុវត្តផ្ទាល់ចាំបាច់បំផុត ត្រូវសហការជាអន្តរកម្មដើម្បីពន្លឿនឱ្យស្របតាមនីតិវិធី។ ប្រសិនបើអភិវឌ្ឍន៍ដល់ការប្រើប្រាស់ឌីជីថល គឺក្រសួង ស្ថាប័នសាមីត្រូវមានអភិក្រមអនុវត្តជាមួយស្ថាប័នពាក់ព័ន្ធឌីជីថល។

#### ១.១.២.១. ក្រសួង ស្ថាប័នពាក់ព័ន្ធការងារសុរិយោដីចុះបញ្ជីដីធ្លី

ការគ្រប់គ្រងរដ្ឋបាលសុរិយោដីចំពោះអចលនវត្ថុ ត្រូវបានបែងចែកជាថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល មានអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ទទួលបន្ទុករៀបចំសម្របសម្រួល និងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែងសុរិយោដី ដែលធ្វើឡើងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជីឈ្មោះកម្មសិទ្ធិករ កសាងសៀវភៅគោលបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដោយត្រូវកំណត់វិធី និងស្តង់ដារឯកសារ។[62] ចំណែកឯរដ្ឋបាលសុរិយោដីថ្នាក់មូលដ្ឋាន ដែលមានរដ្ឋបាលសុរិយោដីខេត្ត ក្រុង ឬស្រុក ខណ្ឌ ត្រូវបានផ្លាស់ប្តូរវិញមកជា រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ។ ក្នុងនោះ បានធ្វើប្រតិភូកម្មអំណាចខិតទៅដល់ ឃុំ សង្កាត់ ដើម្បីពន្លឿនក្នុងការចុះបញ្ជីអចលនវត្ថុ។[63]

ការគ្រប់គ្រងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ដែលត្រូវផ្តោតត្រឹមតែក្នុងទំហំការសិក្សាស្រាវជ្រាវនេះ គឺកំណត់សមត្ថកិច្ច ដែលពាក់ព័ន្ធទៅនឹងការចុះបញ្ជីលើអចលនវត្ថុ គឺអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលមាននាយកដ្ឋានរួមមាន នាយកដ្ឋានគ្រប់គ្រងដីធ្លី នាយកដ្ឋានបច្ចេកទេស នាយកដ្ឋានអភិរក្សសុរិយោដី នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី និងនាយកដ្ឋានកិច្ចការវិវាទដីធ្លី ក្នុងនោះមាន លេខាធិការដ្ឋានក្រុមការងារបរិវត្តកម្មឌីជីថលនៃក្រសួង ដ.ន.ស តែងបំពេញមុខងារអន្តរកម្មជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" លើការផ្លាស់ប្តូរបច្ចេកវិទ្យា។ អភិបាលកិច្ចប្រព័ន្ធរដ្ឋបាល បានធ្វើវិមជ្ឈការប្រតិភូកម្មទៅដល់អភិបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ដោយរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ។

ចំនែក វិសហមជ្ឈការទៅដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដោយរដ្ឋបាលសុរិយោដីរបស់មន្ទីរ ដ.ន.ស.ស។ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលដោយថ្នាក់ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ការធ្វើប្រតិភូកម្មហត្ថលេខាបាន ទៅដល់ថ្នាក់រដ្ឋបាលសុរិយោដីរាជធានី ខេត្ត

---

[61] ពេជ្រ សុជាវី និងខាន់ លក្ខិណា, "លោកនាយករដ្ឋមន្ត្រី ណែនាំឱ្យក្រសួង និងអាជ្ញាធរចុះបញ្ជីក្បាលដីជូនពលរដ្ឋឱ្យបានរួចរាល់នៅឆ្នាំ២០២៣," *VOD*, ភ្នំពេញ៖ ២០២២, https://www.vodkhmer.news/2022/12/28/hun-sen-instructs-authorities-to-complete-land-registration-for-citizens-by-2023/ (ទស្សនាចុងក្រោយថ្ងៃទី៥ មករា ២០២៤)។

[62] ច្បាប់ភូមិបាល២០០១, មាត្រា២៣១។

[63] ប្រកាសរដ្ឋបាលឃុំ សង្កាត់ចុះបញ្ជីដីធ្លី, ប្រការ១។ និងច្បាប់ភូមិបាល២០០១, មាត្រា២៣២។

ក្រោយពីបានទទួលការពិនិត្យ ឯកភាពរបស់អភិបាលរាជធានី ខេត្ត។ កិច្ចការចុះបញ្ជីលើអចលនវត្ថុ ក៏បានផ្តល់សេវានៅតាមបណ្តាច្រកចេញ-ចូលតែមួយរបស់ក្រសួងមហាផ្ទៃ ដែលជាសេវារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ភាពងាយស្រួលនៅតាមបណ្តាថ្នាក់មូលដ្ឋាន។[64] ឧទាហរណ៍. លោក ក រស់នៅ និងមានដីធ្លីស្ថិតក្នុងខណ្ឌដង្កោ នោះលោក ក អាចទៅចុះបញ្ជីអចលនវត្ថុនៅខាងសេវាការិយាល័យច្រកចេញ-ចូលតែមួយក៏បាន ឬអាចទៅចុះនៅខាងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក៏បាន ស្ថិតនៅក្នុងខណ្ឌដង្កោ (ទីតាំងដីស្ថិតនៅ)។ នៅប្រទេសកូរ៉េខាងត្បូង មុនពេលធ្វើសមាហរណកម្មឌីជីថលនៃការចុះបញ្ជី បានចង្អុលបង្ហាញថា ការចុះបញ្ជីអចលនវត្ថុ ជាភារកិច្ចខាងមន្ត្រីអត្រានុកូលដ្ឋានកូរ៉េ ដែលបានកំណត់ដោយប្រធានតុលាការក្នុងស្រុក ឬតំបន់ណាមួយក្នុងការជំរុញគ្រប់គ្រង និងការចុះបញ្ជី។[65]

### ១.១.២.២. ក្រសួង ស្ថាប័នពាក់ព័ន្ធអន្តរកម្មឌីជីថល

ក្រៅពីសមត្ថកិច្ចបំពេញមុខងារគោល ចាំបាច់គួរមានបណ្តាសមត្ថកិច្ចបច្ចេកទេសឌីជីថលទូទៅមកចូលរួមដោះស្រាយផងដែរ។ នៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មឈានដល់៤.០ គឺមានសារៈសំខាន់ជំនួយដល់សេវាសាធារណៈរបស់រដ្ឋគ្រប់វិស័យ។ ពីរទសវត្សរ៍ចុងក្រោយនេះ បច្ចេកវិទ្យាឌីជីថលបានក្លាយជាផ្នែកសំខាន់នៃសកម្មភាពសេដ្ឋកិច្ច និងសង្គម ព្រមទាំងផ្តល់កាលានុវត្តភាពថ្មីជាច្រើន ក្នុងការនាំមកជាគំរូធុរកិច្ចថ្មីៗ ការបង្កើនប្រសិទ្ធភាព និងផលិតភាពដែលធ្វើឱ្យបរិយាកាសប្រកួតប្រជែងមានភាពកាន់តែប្រសើរ។ ការណ៍នេះ លុះត្រាតែពង្រឹងលើយន្តការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ត្រូវផ្អែកលើគុណាធិបតេយ្យ ការធ្វើវិចារណកម្មមុខងារ និងរចនាសម្ព័ន្ធនៅតាមក្រសួង ស្ថាប័ន ដែលអាចកំណត់បែបបទច្បាស់លាស់ចំពោះមុខងារ, ការទទួលខុសត្រូវ, យន្តការសម្របសម្រួល, គណនេយ្យភាព និងសមាហរណកម្មសេវាដែលត្រូវផ្តល់ឱ្យតាមការកំណត់ច្បាប់។

ក្រោយពីទប់ស្កាត់ការរីករាលដាលជំងឺសកលកូវីត១៩ យ៉ាងមានប្រសិទ្ធភាព រាជរដ្ឋាភិបាលបានចាប់ផ្តើមបង្កើតក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល (ក.ស.ឌ) នៅឆ្នាំ២០២១ ដើម្បីធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល ជំរុញការកសាងអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឌីជីថលតាមរយៈការរៀបចំមូលដ្ឋានគ្រឹះ និងទទួលយកបរិវត្តកម្មឌីជីថលពីបណ្តាគ្រប់តួអង្គសង្គមទាំងរដ្ឋ, ទាំងពលរដ្ឋ, និងទាំងធុរជន។[66] ក្នុងនោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ និងក្រសួងទូរគមនាគមន៍ និងប្រៃសណីយ៍ ជាស្ថាប័នគោលក្នុងការកំណត់យន្តការ និងផែនការអនុវត្ត។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតសេនាធិការរបស់ខ្លួននៅឆ្នាំ២០១៩ ជាមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត) ឱ្យក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល, អគ្គនាយក-

[64] រចនាសម្ព័ន្ធបច្ចុប្បន្នកម្មរបស់ក្រសួង ដ.ន.ស, និងប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទី ភារកិច្ច (ឆ្នាំ១៩៩៨), និងច្បាប់ភូមិបាល២០០១, មាត្រា២៣។

[65] Law View, "Registration of Real Estate Act: Articles &11, January 1st, 1960 to September 2009 and continued amended Act," Nº.14901, on October 13th, (2017). https://elaw.klri.re.kr/eng_mobile/viewer.do?hseq=45681&type= part&key=8 (ទស្សនាចុងក្រោយថ្ងៃទី២២ មករា ២០២៤)។ *ច្បាប់ស្តីពីការចុះបញ្ជីអចលនទ្រព្យដែលបានកែសម្រួល២៣លើក ដោយនៅលើកទី១១ មុនថ្ងៃទី៣០ វិច្ឆិកា ១៩៩៦ (កូរ៉េបន្តវិសោធនកម្មជាច្រើនលើក ត្រឹមខែតុលា ឆ្នាំ២០១៧)*។

[66] ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល, លេខ នស/រកត/០៨២១/៥៦៤, ៧ សីហា ២០២១, (ពីពេលនេះតទៅហៅថា ព្រះរាជក្រឹត្យក.ស.ឌ)។

ដ្ឋានសេដ្ឋកិច្ចឌីជីថល បំពេញបន្ថែមក្នុងឆ្នាំ២០២៣និងចំណុះនាយកដ្ឋានផ្សេងទៀត ដែលកំពុងនឹងបង្កើតថ្នាលបច្ចេកវិទ្យាឌីជីថលជាបន្តបន្ទាប់ ដើម្បីបម្រើដល់សេវាសាធារណៈអេឡិចត្រូនិកនានា។ រីឯក្រសួងមហាផ្ទៃ ទើបបង្កើតអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ ក៏ដូចជា អគ្គនាយកដ្ឋានចំណុះផ្សេងៗទៀត ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសបច្ចេកវិទ្យាក្នុងប្រព័ន្ធអ៊ីនធឺណិត។ ម្យ៉ាងវិញ ក្រសួងទូរគមនាគមន៍ និងប្រៃ-សណីយ៍ រួមចំនែកសំខាន់ៗជាតួអង្គឯកលើបច្ចេកទេស ដោយបានបង្កើតអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងអង្គភាពចំណុះនានា ក៏ដូចជាអង្គភាពស្វយ័តនៃនិយ័តករទូរគមនាគមន៍កម្ពុជា និងការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCert) ជាជំនួយ និងដោះស្រាយរាល់បញ្ហាអេឡិចត្រូនិក។ រីឯខាងក្រសួងស្ថាប័នផ្សេងៗ ត្រូវចូលរួមជាសេនាធិការបន្ទាប់បន្សំ ដែលពាក់ព័ន្ធទៅនឹងមុខងារអន្តរាគមន៍ឌីជីថល។

ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល បានបង្កើតគណៈកម្មាធិការចំនួន៣ជាសេនាធិការខ្លួន រួមមាន គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ) ឆ្នាំ២០២១ ដោយអនុក្រឹត្យលេខ២២០, គណៈកម្មា-ធិការរដ្ឋាភិបាលឌីជីថល (គ.រ.ឌ) ឆ្នាំ២០២២ ដោយអនុក្រឹត្យលេខ៨១, និងគណៈកម្មាធិការសន្តិសុខឌីជីថល (គ.ស.ឌ)ឆ្នាំ២០២៤ ដោយអនុក្រឹត្យលេខ៤៤។ អង្គភាពទាំងនេះជាកាលានុវត្តន៍ថ្មីមួយ ចូលបំពេញបន្ថែមទៅលើម៉ូដែលចាស់នៃកំណើន និងគំរូនិយ័តកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា ក្នុងការអនុវត្តស្របតាមយុទ្ធសាស្ត្របញ្ច-កោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ ដើម្បីជំរុញដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចទំនើបនៃបរិវត្តកម្មឌីជីថល។[67] ដើម្បីធានាដល់ប្រសិទ្ធភាព សុក្រឹតភាព និងពន្លឿនដល់ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវមាននិន្នាការអន្តរកម្មជាមួយក្រសួង ស្ថាប័នទាំងនេះ និងផែនការយុទ្ធសាស្ត្ររួម ដែលអាចអនុវត្តប្រកបដោយបរិយាបន្នសង្គម និងឌីជីថល។

## ១.២. គ្របខណ្ឌគោលនយោបាយ

ជាតម្រូវការចាំបាច់ និងភាពបំពេញបន្ថែមចំពោះយុទ្ធសាស្ត្រដ៏ឆ្លាតវៃ ដែលស្របទៅនឹងការវិវត្តរបស់សង្គមខ្មែរ ការប្រកបមុខរបរ និងរបៀបរបបការរស់នៅបរិបទមួយបែបថ្មី រាជរដ្ឋាភិបាល ព្យាយាមកត់សម្គាល់ដោយយកចិត្តទុកដាក់ចំពោះបម្រែបម្រួលពិភពលោក ដោយផ្សាភ្ជាប់កម្ពុជាទៅនឹងសង្គមមួយ ហៅថា "**សង្គមខ្មែរឌីជីថល**" ឬ"**ពលរដ្ឋខ្មែរប្រើបច្ចេកវិទ្យា**"។ ល្អិតនេះ បង្កើតឱ្យមានទស្សនវិស័យចំពោះតម្រូវការឌីជីថលូបនីយកម្ម (១.២.១), និងបម្លាស់ប្តូរលើសង្គម-សេដ្ឋកិច្ចឌីជីថល (១.២.២)។

### ១.២.១. ទស្សនវិស័យចំពោះតម្រូវការឌីជីថលូបនីយកម្ម

ចាប់តាំងពីនីតិកាលទី៦ នៃរដ្ឋសភាដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ "យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤" ដែលបានតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពន្លឿនពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងការពង្រឹងភាពប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះ បានចង្អុលបង្ហាញពីភាពប្រាកដ

[67] ខេន ចន្ថា និងសូ សុភា, *ទស្សនាទាននៃនិយ័តកម្មសេដ្ឋកិច្ចឌីជីថលកម្ពុជា* (សមាគមសាលាត្រាជូះ ព្រឹត្តិបត្រលេខ៥, ២០២៣), ១០១-១២០, អាចរកបាននៅ៖ https://drive.google.com/file/d/14geyT-RiyP0mZzEAVou0DVKVpmM3LPEx/view (ទស្សនាចុងក្រោយថ្ងៃទី២៣ មករា ២០២៤) ។

ប្រជាក្នុងការត្រៀមខ្លួនចាប់យកសេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.០ ដើម្បីទាញយកប្រយោជន៍ពីភាពរីកចម្រើនបច្ចេកវិទ្យារបស់ពិភពលោក។ ក្នុងនីតិកាលទី៧ នៃរដ្ឋសភាឆ្នាំ២០២៣ គឺបានអនុម័តកម្មវិធីនយោបាយសម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ២០២៣-២០២៨ ដោយបង្កើតជា "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១"ដែលបន្តពីយុទ្ធសាស្ត្រខាងលើដើម្បីផ្តួចផ្តើមកំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព សំដៅដល់ការពារថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាព, ជំរុញសម្ទុះមានកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះសម្រេចបាន "ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"។[68] ស្មារតីបុរេសកម្ម និងច្បាស់លាស់នេះ គឺជំរុញឱ្យប្រជាជនកម្ពុជា ឱ្យមានបែបផែន៥ចំណុច៖ ដូចជាទី១. សង្គមជាតិមួយដ៏រស់រវើក, ទី២. ប្រទេសមានចំណូលខ្ពស់ និងមានសេដ្ឋកិច្ចធន់រឹងមាំ, ទី៣. មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត, ទី៤. ប្រជាជនរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស, និងទី៥. បរិស្ថានរូបវន្តនិងធម្មជាតិ ប្រកបដោយសុខដុមភាព ភាពធន់ បរិយាបន្ន និងតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិ។[69]

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាពគន្លឹះចំនួន៤ និងត្រូវបានផ្លាស់ប្តូរទៅតាមដំណាក់កាលនីមួយៗ ក្នុងនោះរួមមាន មនុស្ស, ផ្លូវ, ទឹក, និងភ្លើង។ ចំណែកឯ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បានកំណត់យកអាទិភាពគន្លឹះនេះចំនួន៥ ដោយបន្ថែម "**បច្ចេកវិទ្យា**" និងបន្តកំណត់យក "មនុស្ស" ជាអាទិភាពទី១ សំដៅដល់ **មូលធនមនុស្ស ឬមនុស្សក្នុងសម័យបច្ចេកវិទ្យា** (Gen.Z)។ អាទិភាព "បច្ចេកវិទ្យា" នេះ ត្រូវផ្តោតសំខាន់ក្នុងបញ្ចកោណទី៥ ជាពិសេសគឺ ការកសាង និងការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៃឌីជីថលូបនីយកម្ម ដែលមាននៅក្នុងមុំទី៣ និងបានប្រទាក់ក្រឡាជាមួយមុំផ្សេងៗ។ ក្នុងបរិបទនេះ ឌីជីថលូបនីយកម្មបានក្លាយជានិន្នាការដ៏មានឥទ្ធិពល និងជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងជាសកលនៃសតវត្សរ៍ទី២១។[70]

ភាពចាំបាច់នេះ ត្រូវអនុលោមតាមគោលការណ៍ចំនួន៣ រួមមាន ការកសាងមូលដ្ឋានគ្រឹះឌីជីថល (២០២១-២០២៥), ការចាប់យកឌីជីថល (២០២៦-២០៣០), និងធ្វើបរិវត្តកម្មឌីជីថល (២០៣១-២០៣៥)។[71] រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ ដែលផ្តោត

[68] រាជរដ្ឋាភិបាលកម្ពុជា, *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា* (ខែសីហា ឆ្នាំ២០២៣)។

[69] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្របញ្ចកោណៈដំណាក់កាលទី១* (ខែសីហា ឆ្នាំ២០២៣), ២៤ (ពីពេលនេះតទៅហៅថា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១)។

[70] ពាក្យថា ឌីជីថល ឬឌីជីថលនីយកម្ម ឬឌីជីថលូបនីយកម្ម(Digital or Digitalization) សំដៅលើដំណើរការនៃការកែសម្រួលអភិបាលកិច្ច ធុរកិច្ច ឬដំណើរការការងារឱ្យមានប្រសិទ្ធិភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទិន្នន័យក្នុងទម្រង់ឌីជីថល, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។ រីឯពាក្យថា បច្ចេកវិទ្យាឌីជីថល (Digital Technology) សំដៅដល់បច្ចេកវិទ្យាដែលប្រើប្រាស់លើឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន និងធនធានគណនាសម្រាប់ការបង្កើត ផ្ទុក បំប្លែង និងវិភាគទិន្នន័យ, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងឌីជីថលកម្ពុជា២០២១-២០៣៥។

[71] ពាក្យថា ការចាប់យកឌីជីថល (Digital Adoption) ជាស្ថានភាពដែលមនុស្សមានជំនាញក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលតាមបំណង និងឱ្យអស់លទ្ធភាព។ រីឯពាក្យថា បរិវត្តកម្មឌីជីថល (Digital Transformation) ជាសមាហរណកម្មនៃបច្ចេកវិទ្យាឌីជីថល ក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គមដើម្បីជំរុញឱ្យប្រសិទ្ធភាពសេដ្ឋកិច្ច ទំនាក់ទំនងសង្គម និងផលិតភាពនៃប្រតិបត្តិការការងារ, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។

លើសមាសធាតុចំនួន៥ ចែកចេញគ្រឹះជា២៖ រួមមានទី១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល, ទី២. ការកសាងទំនុកចិត្ត និងភាពជឿជាក់នៅលើប្រព័ន្ធឌីជីថល។ ភ្ជាប់សសរស្តម្ភចំនួន៣ ខាងលើនេះរួមមាន ទី១. ការកសាងពលរដ្ឋឌីជីថល, ទី២. ការកសាងរដ្ឋាភិបាលឌីជីថល, និងទី៣.ការជំរុញធុរកិច្ចឌីជីថល។[72] ញ៉ាំងឱ្យឈរលើគោលគំនិត "ទាញយកប្រយោជន៍ពីសេដ្ឋកិច្ច និងសង្គមឌីជីថលឱ្យបានជាអតិបរមា ព្រមទាំងស្រូបយក និងកាត់បន្ថយផលប៉ះពាល់ ឬបច្ច័យអវិជ្ជមានឱ្យស្ថិតក្នុងកម្រិតអប្បបរមា។"[73] ជាសារវន្ត រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុម័តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥ ដោយសម្លឹងទៅលើចក្ខុវិស័យ "ការកសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ" ដែលមានយន្តការថ្នាក់ជាតិដឹកនាំ ការសម្របសម្រួល និងអនុវត្តដោយមានការរៀបចំគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល អង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថលនៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ជាតិ ការរៀបចំកញ្ចប់ថវិកាជាតិ និងការជ្រើសរើសមន្ត្រីជំនាញជាដើម។[74] បរិការណ៍នេះតម្រូវឱ្យក្រសួង ស្ថាប័នផ្សេងៗ យកគោលនយោបាយជាឆ្អាន់ក្នុងការបង្កើតផែនការ វិធាន អនុវត្តនានាជាកូនក្លូនតូចៗ ដើម្បីបម្រើដល់សេវាសាធារណៈ ជាពិសេស នៅទីនេះគឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**១.២.១.១. កត្តាមូលធនមនុស្ស-សង្គមឌីជីថល**

នៅក្នុងបញ្ហាកោណទី១ នៃការអភិវឌ្ឍធនធានមនុស្ស ត្រូវឈរលើគោលគំនិតចំនួន៥រួមមានទី១. ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ទី២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស, ទី៣. ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន, ទី៤. ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង, និងទី៥. ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។[75]

ផលវិបាកនៃកំណើនរហ័សយុវជន ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសង្គមកិច្ច ហើយការអភិវឌ្ឍមូលធនមនុស្ស គឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការរីកចម្រើនរបស់ប្រទេសជាតិ។ កម្ពុជា ក៏នៅតែមានកង្វះមូលធនមនុស្ស ហើយកញ្ចប់ថវិកាជំនាញនានា មានការគ្រោងទុករបស់រាជរដ្ឋាភិបាល អាចទ្រទ្រង់បានត្រឹមកម្រិតទីផ្សារការងារដែលផ្តល់ប្រាក់កម្រៃទាប។ ការអភិវឌ្ឍលើមូលធនមនុស្សអាចពង្រីកសេដ្ឋកិច្ច ជួយឱ្យប្រទេសជាតិបង្កើនភាពប្រកួតប្រជែងលើពិភពលោកបាន។ តាមរយៈនេះ រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងអាណត្តិទី៧ បានបង្កើតគម្រោងអាហារូបករណ៍ផ្នែកឌីជីថលដល់សិស្សនិស្សិតឆ្នាំសិក្សា២០២៣-២០២៤ តាមរយៈក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងប្រភេទអាហារូបណ៍ទេពកោសល្យឌីជីថល និងខាងសាលារាជបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ឬហៅថា CADT (Cambodia Academy of Digital Technology) ជាច្រើនកន្លែង ក៏ដូចជាការបង្កើតសាកលវិទ្យាល័យឌីជីថលកម្ពុជា ឬ Digital University of

[72] រាជរដ្ឋាភិបាលកម្ពុជា, *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥* (ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ២០២១), (ពីពេលនេះតទៅហៅថា ក្របខណ្ឌ សសឌ.២០២១/៣៥)។

[73] ដដែល, ទំ.iii។

[74] រាជរដ្ឋាភិបាលកម្ពុជា, *គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥* (ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ខែមករា ឆ្នាំ២០២២), (ពីពេលនេះតទៅហៅថា គោលនយោបាយ រឌក.២០២២/៣៥)។

[75] យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ៣២។

Cambodia និងកម្មវិធី TVET។[76] បរិការណ៍នេះ ជាជំហានដំបូងរបស់កម្ពុជា ក្នុងការផលិតមូលធនមនុស្សក្នុងវិស័យឌីជីថលដើម្បីត្រៀមខ្លួន និងការផ្លាស់ប្តូរអភិបាលកិច្ចឌីជីថលទៅវិញទៅមក។[77] ម្យ៉ាងវិញ រាជរដ្ឋាភិបាលកម្ពុជា មានបំណងប្រាថ្នាឆ្ពោះទៅក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០ ដែលជាកត្តាសំខាន់ផ្តោតលើវិស័យអប់រំ ឱ្យមានតួនាទីសត្យានុម័តជាមូល-ដ្ឋានក្នុងការធានាឱ្យបានថា កម្ពុជាអាចធ្វើសមិទ្ធកម្មលើបំណងនេះបាន។

ដើម្បីឱ្យមានការងើបឡើងក្នុងសេដ្ឋកិច្ចឌីជីថល លុះត្រាមានការអប់រំបែបឌីជីថល ឬហៅថា ស្ទឹម (STEM) និងអេកូស៊ីស្តែម (Eco-System)។[78] ការអភិវឌ្ឍសេដ្ឋកិច្ច ឬសង្គមឌីជីថល តាមរយៈការទាញយកធាតុចូលការប្រើប្រាស់ និងយកផលប្រយោជន៍ឱ្យបានជាអតិបរមា គឺរាជរដ្ឋាភិបាលតម្រូវឱ្យជំរុញពីសង្គតិភាព ទៅលើការរីកចម្រើនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ដោយរដ្ឋាភិបាលបើកចំហ។[79] ក្នុងន័យនេះ ប្រសិនបើការអភិវឌ្ឍប្រព័ន្ធ ឬការប្រើប្រាស់សេវាសាធារណៈ លឿនជាងការអប់រំអក្ខរកម្មឌីជីថលរបស់ប្រជាជនក្នុងការចាប់យកមកប្រើប្រាស់ ក៏ប្រៀបដូចជាការបង្កើតដុំថ្ម ដូច្នោះដែរ។ ដូចនេះ ចាំបាច់ត្រូវដើរទន្ទឹមគ្នា គឺត្រូវតែរមួលដៃអាវជើងខោក្នុងការដោះស្រាយ។ ក្នុងរបាយការណ៍ទិន្នន័យពី Seasia Stats គឺបានបង្ហាញថា ប្រទេសកម្ពុជា បានក្លាយជាប្រទេសនាំមុខនៅអាស៊ីអាគ្នេយ៍ដែលចាត់ថ្នាក់ស្ថិតក្នុងក្រុមមនុស្ស Gen.Z ឬGeneration Zoom ដល់ **៦០%** ក្នុងឆ្នាំ២០២៤។ "មនុស្សក្នុងជំនាន់ Z ដែលគ្របដណ្តប់លើមនុស្សដែលកើតពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ដល់ដើមទសវត្សរ៍ឆ្នាំ២០១០ ត្រូវបានកំណត់លក្ខណៈដោយការចិញ្ចឹមបីបាច់នៅចំពេលដែលមានការរីកសាយភាយនៃបច្ចេកវិទ្យាឌីជីថល និងអាចមានលទ្ធភាពប្រើប្រាស់ព័ត៌មានវិទ្យាបាន។ ត្រូវបានសកលលោកហៅថា ដើមកំណើតឌីជីថល ជំនាន់នេះ គឺបង្ហាញពីគុណលក្ខណៈផ្សេងគ្នា ដូចជាការដាក់បញ្ចូលភាពច្នៃប្រតិដ្ឋ និងទស្សនវិស័យរីកចម្រើនឆ្ពោះទៅរកភាពចម្រុះ។"[80] បើយោងទៅតាមរបាយការណ៍របស់ World Population Review ក៏បង្ហាញពីលទ្ធភាព IQ (Intelligence Quotient) នៃបញ្ញាឆ្លាតវៃរបស់មនុស្សជាតិសកលលោកទាំង១៧៩ប្រទេស ក្នុងនោះប្រទេសកម្ពុជាចំណាត់ថ្នាក់ទី១៥ ពិន្ទុ៩៩.៧៥ ក្នុងឆ្នាំ២០២៤។ ល្ពឹកនេះ គឺសបញ្ជាក់ថា

---

[76] អនុក្រឹត្យស្តីពីការទទួលស្គាល់សាកលវិទ្យាល័យឌីជីថលកម្ពុជា, លេខ៦០អនក្រ.បក, ២២ មីនា ២០២៤, ក៏ដូចជា *វិទ្យាស្ថានស្រាវ-ជ្រាវ និងនវានុវត្តន៍ឌីជីថល (Institute of Digital Research and Innovation - IDRI)*។

[77] ប្រកាសអាហារូបករណ៍ផ្តល់ទៅសិស្សានុសិស្សលើជំនាញឌីជីថលដើម្បីបណ្តុះមូលធនមនុស្ស ដោយក្រសួង ក.ប.ទ។

[78] សាន វឌ្ឍនា, *ការអប់រំ៖ បរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ* (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១), ៤៣(១) និង(២)។ ពាក្យថា សេវាឌីជីថល (Digital Public Service) គឺជាឌីជីថលផតថល Portal ដែលអាចប្រើប្រាស់ដោយប្រជាពលរដ្ឋ, ធុរជន និងបុគ្គលិក/មន្ត្រីរាជរដ្ឋាភិបាលទៅតាមមុខងារ និងគោលបំណងរបស់ផតថលឌីជីថលនីមួយៗ ដែលពឹងផ្អែកលើថ្នាល និងទិន្នន័យ។

[79] ពាក្យថា រដ្ឋាភិបាលបើកចំហ (Open Government) ជាគំរូអភិបាលកិច្ច ដែលឈរលើគោលការណ៍តម្លាភាពបើកចំហទិន្នន័យ ផ្តល់ទំនុកចិត្តជូនប្រជាពលរដ្ឋ និងមានការចូលរួមពីប្រជាពលរដ្ឋក្នុងការសម្រេចចិត្តនានាដូចជា ការអនុម័តគោលនយោបាយ ឬការអនុវត្តគម្រោងស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។

[80] Anthony Ellis, "ប្រទេសកម្ពុជានាំមុខគេនៅអាស៊ីអាគ្នេយ៍ដែលមានចំនួនប្រជាជន Gen Z ខ្ពស់បំផុត," *Eacnews*, ភ្នំពេញ៖ ២០២៤, https://eacnews.asia/home/details/29063 ឬ https://dap-news.com/national/2024/03/20/402146/ ឬ https://www.pewresearch.org/short-reads/2019/01/17/where-millennials-end-and-generation-z-begins/ (ទស្សនាចុងក្រោយថ្ងៃទី១៥ មីនា ២០២៤)។

មូលធនមនុស្សនៅកម្ពុជា អាចប្រើប្រាស់ និងងាយជ្រាបបច្ចេកវិទ្យាឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។[81]

"នៅក្នុងបញ្ចកោណទី៥ នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល គឺបង្ហាញគំនូសចំនួន៥ រួមមានទី១. ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល, ទី២. ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តឌីជីថល, ទី៣. ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល, ទី៤.ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និងទី៥.ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ។"[82] ការកំណត់អាទិភាពយុទ្ធសាស្ត្រនៃ "សសរស្តម្ភ" សម្រាប់កសាងសេដ្ឋកិច្ច-សង្គមឌីជីថល នឹងឈានវិវត្តន៍ជាឌីជីថលភ្លោះ។

> បន្ថែមពីគ្រឹះ និងសសរស្តម្ភ ដែលជាមូលដ្ឋានគ្រឹះនៃការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ការរៀបចំថ្នាលឌីជីថល និងបណ្ដុំទិន្នន័យ ត្រូវបានចាត់ទុកជាស្នូលនៃក្របខណ្ឌអាទិភាព ដែលផ្សា-ភ្ជាប់ទៅគ្រប់ផ្នែកនៃដំណើរការបរិវត្តកម្មឌីជីថលនេះ... ដើម្បីឱ្យអន្តរកម្មរវាងតួអង្គទាំងអស់ កាន់តែមានភាពប្រសើរឡើង និងអាចទាញយកអត្ថប្រយោជន៍ពីបណ្ដុំទិន្នន័យ ដែលកើតចេញពីអន្តរសកម្មលើថ្នាលឌីជីថលនេះ...។ រាជរដ្ឋាភិបាល បានបង្កើតថ្នាលឌីជីថលជាមូលដ្ឋាន សម្រាប់កសាងហេ-ដ្ឋារចនាសម្ព័ន្ធឌីជីថលមូលដ្ឋាន [G2G]... សំណាក់ធុរជន [G2B] និងប្រជាពលរដ្ឋ [G4C]...។[83]

### ១.២.១.២. ការត្រៀមលក្ខណៈជារដ្ឋាភិបាលបើកចំហ

ការទទួលយក និងការប្រើប្រាស់ជាប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថលតម្រូវឱ្យរាជរដ្ឋាភិបាលលើកទឹកចិត្ត និងបង្គាប់ដល់ក្រសួង ស្ថាប័ន រហូតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ បង្កើតឱ្យមានសំណើគម្រោងស្រាវជ្រាវ និងវិធានការដំណោះស្រាយអ្វីមួយលើសេវាសាធារណៈ ដែលស្របនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ នៅក្នុងរបាយការណ៍គ្រប់គ្រងធនធានមនុស្សថ្នាក់ក្រោមជាតិនៃសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ នាថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ គឺបង្ហាញថាមន្ត្រីរាជការស៊ីវិលសរុប២២៧.៨៥១នាក់ ដោយថ្នាក់ជាតិមាន៥១.១១៥នាក់ និងថ្នាក់ក្រោមជាតិ១៧៦.៧៣៦នាក់, ក្នុងនោះមន្ត្រីថ្នាក់ក្រោមជាតិនៃមន្ត្រីអង្គភាពវិមជ្ឈការមាន១០២.៨៥១នាក់ និងមន្ត្រីអង្គភាពវិសហមជ្ឈការមាន៧៣.៨៨៥នាក់។[84] ក្នុងន័យនេះ រវាងមន្ត្រីសាធារណៈ និងការចូលរួមពីប្រជាពលរដ្ឋ ត្រូវមានកិច្ចសហការជាប់លាប់ដែលឈរលើគោលការណ៍នៃ "សង្គមមួយរស់រវើក" ដើម្បីជាប្រយោជន៍ដល់សង្គម-សេដ្ឋកិច្ចឌីជីថល។ យ៉ាងណាមិញ ក្នុងអភិបាលកិច្ចគ្រប់គ្រង ពិតណាស់ចាំបាច់ត្រូវផ្ដល់ទំនុកចិត្តដល់ប្រជាពលរដ្ឋ និងសេរីភាពក្នុងការបង្ហាញព័ត៌មានជាក់លាក់។

---

[81] World Population Review, "Countries by IQ - Average IQ by Country 2024," ២០២៤, https://worldpopulationreview.com/country-rankings/average-iq-by-country និងប្រភពមួយទៀត WorldData.info, "IQ Co," https://www.worlddata.info/iq-by-country.php (ទស្សនាចុងក្រោយថ្ងៃទី១៥ មីនា ២០២៤)។

[82] យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ៣៣។

[83] ក្របខណ្ឌ សសឌ.២០២១/៣៥, ix-x។ ពាក្យថា ឌីជីថលភ្លោះ (Digital Twins) ជាគំរូនិម្មិតនៃវត្ថុ, ប្រព័ន្ធ ឬរំហូរការងារក្នុងពិភពពិតគឺប្រមូលទិន្នន័យពីក្នុងពិភពពិត ទុកសម្រាប់វិភាគ ទស្សទាយ តាមដាន និងជួយកែលម្អរបស់ដែលនៅក្នុងពិភពពិតឱ្យតែល្អប្រសើរ។

[84] ថោ សេដ្ឋាណា, "ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" (សន្និបាតបូកសរុបជាលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤, ក្រសួងមុខងារសាធារណៈ, ខែមេសា ឆ្នាំ២០២៤)។

បណ្ដាក្រសួង ស្ថាប័នជាច្រើន ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទូរគមនាគមន៍ និងប្រៃ-សណីយ៍ ដែលមានបណ្ដាសេនាធិការរបស់ខ្លួនបានប្រឹងប្រែងស្រាវជ្រាវ និងកិច្ចសហប្រតិបត្តិអន្តរជាតិដើម្បីនឹងទាញធាតុចូលពីវិធីសាស្ត្រ បច្ចេកទេសប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលអាចសមស្របនឹងកម្ពុជា ក៏ដូចជាមានការបង្កើតឱ្យមានប្រកួតប្រជែងនវានុវត្តន៍របស់បណ្ដានិស្សិត យុវជន បញ្ញវន្តកម្ពុជា លើដំណោះស្រាយឌីជីថល។ ជាក់ស្ដែងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) បានលើកទឹកចិត្ត និងជំនួបជាមួយខាងសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកលវិទ្យាល័យផ្សេងៗ លើការបទបង្ហាញរបស់និស្សិតអ្នកស្រាវជ្រាវដែលបានជួយដល់ការអភិវឌ្ឍនគរូបនីយកម្មរាជធានី ខេត្ត ក្រុង។ ការណ៍នេះ ជាមាគ៌ាមួយដល់រាជរដ្ឋាភិបាល ដើម្បីចង់បង្ហាញដល់អន្តរជាតិថា "កម្ពុជាបានត្រៀមខ្លួនលក្ខណៈជាស្រេច" ចំពោះរាល់ការវិនិយោគនានាគ្រប់ទម្រង់ និងប្រភេទ ជាពិសេស វិស័យបច្ចេកវិទ្យា ដើម្បីជាផ្នែកជួយដល់ការសិក្សាបន្ថែម និងអភិវឌ្ឍន៍អប់រំជាតិ។[85]

### ១.២.២. បម្លាស់ប្ដូរលើសង្គម-សេដ្ឋកិច្ចឌីជីថល

ប្រទេសកម្ពុជា ធ្លាប់តែប្រាស្រ័យទាក់ទង និងបំពេញសកម្មភាពតាមការជួបដោយផ្ទាល់ ធ្វើដោយផ្ទាល់ ឬហៅថា តាមបែបប្រពៃណីឬទំនៀមទម្លាប់ការងារ ជាពិសេស ការបំពេញតម្រូវការលើសេវាសាធារណៈ ដែលបានផ្ដល់វិបាកខ្លាំងដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងសេដ្ឋកិច្ចសកលឌីជីថល។ ឧទាហរណ៍ថា ការធ្វើទំនាក់ទំនងពាណិជ្ជកម្ម ការលក់ដូរ (គិតទាំងសេដ្ឋកិច្ចក្រៅប្រព័ន្ធ) ពីមុនកម្ពុជា ត្រូវធ្វើ និងផ្លាស់ទីដោយផ្ទាល់រវាងអ្នកលក់ និងអ្នកទិញ ប៉ុន្តែបច្ចុប្បន្ន កម្ពុជាធ្វើពាណិជ្ជកម្ម ទោះបីនៅទីកន្លែងណា ពេលវេលាណា ក៏អាចធ្វើតាមរយៈប្រព័ន្ធឌីជីថល ឬអេឡិចត្រូនិកដោយងាយស្រួល។ មួយជ្រុងនៃគំនិត គឺការទៅចុះបញ្ជីអចលនវត្ថុទៅដល់ទីតាំងផ្ទាល់ប្រជាពលរដ្ឋមានការរង់ចាំទទួលសេវាកម្មយូរពេក, លំបាកបំពេញឯកសារ, ខាតបង់ទាំងពេលវេលា និងថវិកា។ ល្បឿននេះ បណ្ដាលឱ្យសេដ្ឋកិច្ចលើវិស័យអចលនទ្រព្យមានការថយចុះ និងប្រទាំងប្រទើសយឺតយ៉ាវក្នុងការបង្កើត កែប្រែ និងការលុបចោលចំពោះកម្មសិទ្ធិអចលនវត្ថុនានា។ "បន្ទាប់ពីជួបបញ្ហាជំងឺកូវីត១៩ ក៏បានតម្រូវឱ្យកម្ពុជាគិតគូរ និងរៀបចំម៉ូដែលកំណើនថ្មីដែលបានឆ្លើយតបរហ័ស និងមានភាពធន់ខ្ពស់នឹងការផ្លាស់ប្ដូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត...។ ផ្អែកលើសក្ដានុពល នៃវិស័យឌីជីថលអាចមានតួនាទីចម្បងពីរ ជាចន្ទល់កំណើនថ្មី និងចលករគាំទ្រវិស័យទ្រទ្រង់ និងលើកស្ទួយវិស័យសេដ្ឋកិច្ចផ្សេងទៀត...។ តាម-រយៈការធ្វើបរិវត្តកម្មឌីជីថល... គឺអាចត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយក្នុងប្រព័ន្ធសង្គមដែលធ្វើឱ្យការប្រា-ស្រ័យទាក់ទងរវាងបុគ្គល, ក្រុមគ្រួសារ និងសហគមន៍ឱ្យកាន់តែងាយស្រួល, ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសង្គមកាន់តែសកម្ម និងការទទួលបានសេវាសាធារណៈកាន់តែឆាប់រហ័ស។"[86]

---

[85] វណ្ណ សុជាតា, "លោកនាយករដ្ឋមន្ត្រី៖ កម្ពុជាបានត្រៀមខ្លួនរួចជាស្រេចដើម្បីស្វាគមន៍វិនិយោគិនពីគ្រប់តំបន់លើសកលលោក ក្នុងការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា," *ភ្នំពេញប៉ុស្តិ៍*, ភ្នំពេញ៖ ២០២៣, https://www.postkhmer.com/business/2023-12-23-1023-256982 (ទស្សនាចុងក្រោយថ្ងៃទី១៥ មករា ២០២៤)។

[86] ក្របខណ្ឌ សសឌ.២០២១/៣៥, ១-២។ ពាក្យថា និម្មាបនកម្ម ឬស្ថាបត្យកម្ម (Architecture) ជាអំពើ ឬការបង្កើតអ្វីៗដោយឫទ្ធិ។ ជាសិល្បៈផ្នែកខាងការកសាង ឬតាក់តែងនូវវត្ថុផ្សេងៗឱ្យបានល្អឆើតឆាយដូចជានិម្មិត។ អាចជាពាក្យថា និម្មាបនកម្មឌីជីថល (Digital of Architecture) ជាការរចនា ឬបង្កើតឡើងឱ្យមានគំរូ ឬទម្រង់អ្វីមួយតាមការនិម្មិត ឱ្យទៅជាលក្ខណៈឌីជីថល តាមគោលបំណងរបស់តក្កករ ឬស្ថាបត្យករ។

ក្រៅពីកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានជាមធ្យមក្នុងអត្រា៧% ក្នុងរយៈពេលពីរទសវត្សរ៍ តាមការវាយតម្លៃជាអន្តរជាតិ ការត្រៀមខ្លួនរបស់កម្ពុជាជារួមនៅក្នុងការចាប់យកវិស័យឌីជីថល គឺស្ថិតក្នុងកម្រិតទាប ដែលកម្ពុជាឈរលេខរៀងទី១០២ ក្នុងចំណោមប្រទេស១៤១ ឬលេខរៀងទី៧ នៅក្នុងចំណោមអាស៊ានទាំង៩ (លើកលែងប្រទេសព្រុយណេ), រីឯសន្ទស្សន៍ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលរបស់កម្ពុជាមានភាពប្រសើរឡើងជាងមុន ចំណាត់ថ្នាក់ទី១២៧ក្នុងចំណោមនៃ ១៩៤ប្រទេស ក្នុងរយៈពេល៧ឆ្នាំចុងក្រោយចន្លោះឆ្នាំ២០១៦-២០២២។[87] ការព្យាកររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងឆ្នាំ២០២៤ កម្ពុជាអាចស្ថិតក្នុងរង្វង់រវាង៥,៨% - ៦% ក្នុងឆ្នាំ ២០២៥ ដែលជាសញ្ញាបង្ហាញថា កម្ពុជាគួរយកចិត្តទុកដាក់ខ្លាំងលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធ និងត្រូវតែពឹងផ្អែកជាជំនួយលើសេដ្ឋកិច្ចឌីជីថល និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។[88]

### ១.២.២.១. បរិយាបន្នកម្មឌីជីថល

គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២-២០៣៥ រាជរដ្ឋាភិបាលគឺបានកំណត់ជាចក្ខុវិស័យនៃការកសាងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈ ដោយការប្រើប្រាស់ស្វ័យប្រវត្តិកម្មអនឡាញ។ ន័យនេះ បើសង្គមកម្ពុជាអាចបោះពួយទៅមុខបាន ដរាបណាមានការចូលរួមការអភិវឌ្ឍស្មើមុខស្មើមាត់ក្នុងកិច្ចការសេដ្ឋកិច្ច-សង្គមដោយការប្រើប្រាស់បច្ចេកវិទ្យា និងការសម្របឌីជីថល ពីសំណាក់ប្រជាពលរដ្ឋ។[89] ការចូលរួម មិនត្រឹមតែមួយផ្នែកពីមជ្ឈដ្ឋានក្នុងតំបន់ទីប្រជុំជននោះទេ គឺត្រូវសាយភាយតាមរយៈការផ្សព្វផ្សាយឱ្យទូលំទូលាយនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ យ៉ាងណាមិញ រាជរដ្ឋាភិបាល ក៏បានជួយជំរុញធុរកិច្ចថ្មីឌីជីថល សំដៅលើការចូលរួមពីធុរជន។ ប្រាកដណាស់តាមបណ្តាសហគ្រាសធំ និងសហគ្រាសធុនតូច និងមធ្យម (SME) អាចមានលទ្ធភាពអនុវត្តដោយពេញលេញ និងកំពុងតែដាក់ឱ្យប្រើប្រាស់តាមស្វ័យប្រវត្តិកម្ម https://enterprisedigital.gov.kh ដោយក្រសួងពាណិជ្ជកម្ម, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"។ គិតត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ មានក្រុមហ៊ុន/សហគ្រាសចុះបញ្ជី ២០.៩១៥ ប៉ុន្តែ ស្មារតីនៃធុរកិច្ចថ្មី ដែលរាជរដ្ឋាភិបាលបានដាក់ចេញអាទិភាពលើប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថល ក៏មានការរាប់បញ្ចូលនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ផងដែរ។ ឧទាហរណ៍ថា អ្នកលក់មីឆានៅតាមផ្លូវ, នោះអ្នកទិញអាចបញ្ជរទិញ និងដឹកជញ្ជូនតាមរយៈកម្មវិធីទូរសព្ទចល័តណាមួយ (dApp - A Decentralized Application) ដែលអ្នកលក់បង្កើតឡើងផ្ទាល់ និង/ឬ ចូលរួមនៅក្នុងប្លុកបណ្តាញអ្នកលក់ បន្ទាប់មក អ្នកទិញអាចទូទាត់ប្រាក់តាមរយៈ

---

[87] Sreekanth Ravindran, "Digital infra remains govt's top priority," *Khmer Times*, ២០២៣, https://www.khmertimeskh.com/501320178/digital-infra-remains-govts-top-priority/ (ទស្សនាចុងក្រោយថ្ងៃទី១៦ មករា ២០២៤)។

[88] ធន់ សេងហុង, "ADB បង្ហាញសុទិដ្ឋិនិយមលើកំណើនសេដ្ឋកិច្ចអាស៊ី តែព្រមានហានិភ័យមួយចំនួន," *ថ្មីៗ*, ២០២៤, https://thmeythmey.com/?page=detail&id=135682 (ទស្សនាចុងក្រោយថ្ងៃទី២៧ មេសា ២០២៤)។

[89] ពាក្យថា ការសម្របឌីជីថល (Digital Adaptation) គឺជាសមត្ថភាពរបស់មនុស្សក្នុងការយល់ដឹង និងការសម្របខ្លួនទៅតាមការវិវត្តឥតឈប់ឈររបស់បច្ចេកវិទ្យាឌីជីថលដែលបានចាក់ជ្រៅទៅក្នុងធុរកិច្ច សេដ្ឋកិច្ច និងសង្គម, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។ រីឯពាក្យថា បរិយាបន្នកម្មឌីជីថល (Digital Inclusion) ជាដំណាក់កាលមួយដែលមនុស្សគ្រប់រូបមានកាលានុវត្តភាពស្មើគ្នាដើម្បីចូលរួមកិច្ចការសេដ្ឋកិច្ច និងសង្គមដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥។

ស្វ័យប្រវត្តិកម្មធនាគារ។ នេះសបង្ហាញថា នៅក្នុងបណ្ដាសេវាសាធារណៈដែលមាននីតិវិធីតាមប្រព័ន្ធអនឡាញ គឺប្រព័ន្ធធុរកិច្ចកម្ពុជា បានចាប់យកឌីជីថលយ៉ាងលឿនឆាប់រហ័ស។ វិស័យដីធ្លី គួរតែរៀនសូត្រពីគន្លឹះនេះ។

ក្នុងសសរស្ដម្ភទាំង៣ នៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ បានបង្ហាញពីការកសាងពលរដ្ឋឌីជីថល ដោយប្រព្រឹត្តតាមរយៈការលើកកម្ពស់បរិយាបន្នសង្គមជួយឱ្យមនុស្សគ្រប់រូបមានឱកាស និងធនធានអាចប្រើប្រាស់ឌីជីថលដោយទូលំទូលាយ។ ជាទូទៅ ក្រុមជនងាយរងគ្រោះ គឺមានជនពិការ, ស្ត្រី, កុមារ, ចាស់ជរា និងជនជាតិភាគតិច ជាអាទិ៍ ច្រើនជួបប្រទះលើកង្វះខាតលទ្ធភាព, ការឆ្លើយតប និងប្រព័ន្ធជំនួយសង្គមក្នុងអំឡុងពីរទសវត្សរ៍នេះ នឹងត្រូវមានដំណោះស្រាយតាមរយៈឌីជីថល។ ក្រុមប្រឹក្សាជាតិកិច្ចគាំពារសង្គម បានប្រើប្រាស់វិធីចុះបញ្ជីក្នុងប្រព័ន្ធ និងផ្ដល់លេខកូដសម្គាល់អត្តសញ្ញាណថ្មីតែមួយគត់ ដើម្បីឆ្លើយតបជំនួយដល់ក្រុមងាយរងគ្រោះ។ រីឯស្ត្រី និងក្មេងៗស្រី គឺអាចរៀនសូត្រ និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល មិនចាញ់បុរសនោះទេ តាមរយៈការរុករកលើប្រព័ន្ធកម្មវិធី, ឯកសារបោះផ្សាយ និងការបំពេញកិច្ចការជាប្រចាំ-ការងារតាមប្រព័ន្ធឌីជីថល។[90] ការប្រើប្រាស់ក៏អាចជាអាវុធមុខពីរផងដែរសម្រាប់ស្ត្រី និងក្មេងស្រី ប្រសិនបើការប្រើប្រាស់នោះមិនបានត្រឹមត្រូវ ឬខុសគោលបំណង។ កត្តានេះ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ និងផ្ដល់អាទិភាពខ្ពស់ដល់អ្នកស្រាវជ្រាវឌីជីថល អ្នកបច្ចេកទេសឌីជីថល ក្នុងការពិចារណាជ្រើសរើសយកបច្ចេក-វិទ្យាប្រភេទ ឬទម្រង់ណាមួយដែលស្របវប្បធម៌សង្គមកម្ពុជា មិនប៉ះពាល់ដល់តម្លៃស្ត្រីខ្មែរ និងក្រុមជនងាយរងគ្រោះដទៃទៀត។[91]

### ១.២.២.២. ការជំរុញធុរកិច្ចលើវិស័យអចលនទ្រព្យ

ធុរកិច្ចនៅក្នុងវិស័យសេវាកម្ម ការចាប់យកឌីជីថល គឺមានសន្ទុះគួរឱ្យកត់សម្គាល់ តាមរយៈប្រតិបត្តិការពា-ណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ការធ្វើធុរកិច្ចលើវិស័យអចលនទ្រព្យដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក៏គួរពិចារណា និងចាំបាច់បំផុត។ បណ្ណកម្មសិទ្ធិដែលចុះបញ្ជីស្របច្បាប់ គឺជាមុខសញ្ញាជំរុញដល់ការវិនិយោគក្នុងវិស័យនេះ។ ការធានាសុវត្ថិភាពដល់អ្នកកាន់កាប់ដីធ្លី ពីសំណាក់រាជរដ្ឋាភិបាល ក៏ជាផ្នែកមួយជួយទៅដល់អ្នកតាំងទីលំនៅបណ្ដោះអាសន្ន អ្នកដែលងាយរងគ្រោះ និងលើកទឹកចិត្តដល់ប្រជាជនក្នុងការវិនិយោគលើវិស័យអចលនទ្រព្យ និងការអភិវឌ្ឍលំនៅឋាន តាមរយៈការជួល បញ្ចាំ ជាអាទិ៍។[92] ហាងឆេងដីធ្លីកើនថ្លៃ អាស្រ័យលើការវិនិយោគ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់នោះ។ ភាពមិនច្បាស់លាស់លើការវាយតម្លៃថ្លៃអច-

[90] ព្រុំ ទេវី, "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល៖ បទពិសោធន៍ និងបញ្ហាប្រឈមក្នុងការសិក្សាស្រាវជ្រាវ និងបង្ហាត់បង្រៀន" (រាជប-ណ្ឌិត្យសភាកម្ពុជា), ២។ និងប្រភពមួយទៀត. ក្រុមប្រឹក្សាជាតិកិច្ចគាំពារសង្គម, "បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមផែនការយុទ្ធ-សាស្ត្រ២០២៤-២០២៨" (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២០២៤), ១៦។

[91] UN Women, "*The digital revolution: Implications for gender equality and women's rights 25 years after Beijing,*" ២០២០, https://www.unwomen.org/en/digital-library/publications/2020/08/discussion-paper-the-digital-revolution-implications-for-gender-equality-and-womens-rights និងប្រភពមួយទៀត៖ Sascha Kraus, Paul Jones, and others, "*Digital Transformation: An Overview of the Current State of the Art of Research*" [បរិវត្តកម្មឌីជីថល៖ទិដ្ឋភាពទូទៅនៃស្ថានភាពបច្ចុប្បន្ននៃសិល្បៈការស្រាវជ្រាវ] *Sage Journal,* (2021). https://doi.org/10.1177/21582440211047576 (ទស្សនាចុងក្រោយថ្ងៃទី១៦ មីនា ២០២៤)។

[92] រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយជាតិស្ដីពីលំនៅឋាន, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ៩ ឧសភា ២០១៤)។

លនទ្រព្យ និងការប្រែប្រួលថ្លៃដី គួបផ្សំនឹងជំនាញបច្ចេកទេសនៅមិនទាន់ស៊ីជម្រៅ និងកង្វះខាតឯកសារលម្អិតជាមូលដ្ឋាន ធ្វើឱ្យប្រតិបត្តិការនៅមិនទាន់សុក្រឹតភាព។ កត្តានេះ គឺអាចជះឥទ្ធិពលអវិជ្ជមានដល់ការចុះបញ្ជីដីធ្លីលើកដំបូង, ការចុះបញ្ជីបន្ត, ការប្រមូលពន្ធលើអចលនទ្រព្យ, ការអនុវត្តលើសេចក្ដីសម្រេចរបស់តុលាការ, ការវិនិយោគ និងការផ្ដល់ឥណទានលើអចលនទ្រព្យ ដែលអាចខ្ពស់ជាង ឬទាបជាងតម្លៃទីផ្សារ។ ប្រព័ន្ធវាយតម្លៃអចលនទ្រព្យត្រូវរៀបចំឱ្យមាននីតិវិធីច្បាស់លាស់ នៅក្នុងការកសាងផែនទីវាយតម្លៃថ្លៃដី និងការរៀបចំបញ្ជីវាយតម្លៃថ្លៃអចលនទ្រព្យ បែបជារួមនៅទូទាំងប្រទេស។ ការងារនេះទាមទារខ្ពស់ ចំពោះពេលវេលាសិក្សាតំបន់ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។ ត្រីមាសទី១ ឆ្នាំ២០២៤ អចលនទ្រព្យលើសតម្រូវការ បន្តដាំក្បាលចុះ។[93]

រាជរដ្ឋាភិបាល បានបង្កើតសេនាធិការនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ស្ថិតក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានបង្កើតប្រព័ន្ធអេឡិចត្រូនិក ដែលស្នើសុំអាជ្ញាបណ្ណអាជីវកម្មបញ្ចាំ។ បរិការណ៍នេះ ជួយជាកិច្ចសហការជាមួយសមាគមធុរកិច្ចអចលនទ្រព្យនៅកម្ពុជា និងម្ចាស់អាជីវកម្មអចលនទ្រព្យ ក្នុងការទប់ស្កាត់តម្លៃទីផ្សារនិងជួយជំរុញដល់ការអភិវឌ្ឍអចលនទ្រព្យ ជាពិសេស ការប្រើប្រាស់ប្រព័ន្ធឌីជីថល។[94] ការប្រមើរមើលទុកមុន ចំពោះវិធីសាស្ត្រការលក់ទិញ និងផ្ទេរសិទ្ធិអចលនទ្រព្យតាមប្រព័ន្ធអនឡាញ ដែលត្រូវតែមានអន្តរការីកណ្ដាល (អាជ្ញាធរសុរិយោដី) ជាអ្នកតាមដាន ឃ្លាំមើល និងសម្រួលនីតិវិធី គឺជាដំណោះស្រាយមួយដែលកម្ពុជាគួរតែយកមកសិក្សាពិចារណា។

[93] រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយជាតិស្ដីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ, (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ៣០ ឧសភា ២០១៤។ *គម្រោងអភិវឌ្ឍន៍អចលនទ្រព្យលើសតម្រូវការខ្ពស់ក្នុងតម្លៃ៧៨៦លានដុល្លារអាមេរិក ធ្លាក់ចុះ៣៨,៨% បើធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២៣*។

[94] សេវាអេឡិចត្រូនិកស្នើសុំអាជ្ញាបណ្ណ, https://registrationservices.gov.kh (ទស្សនាចុងក្រោយថ្ងៃទី១៦ មីនា ២០២៤)។

# ជំពូកទី២

# ការឆ្លើយតបរបស់ថ្នាក់ដឹកនាំ
# ចំពោះថ្នាលបច្ចេកវិទ្យា
# ឌីជីថលរបស់កម្ពុជា

# ជំពូកទី២
# ការអនុវត្តភាពចំពោះថ្នាលបច្ចេកវិទ្យាឌីជីថលរបស់កម្ពុជា

បច្ចេកវិទ្យាសហសម័យកំពុងវិវត្តន៍ឥតឈប់ឈរ និងមានការប្រកួតប្រជែងក្នុងសង្គម។ ភាពឆ្លាតវៃនៃបញ្ញាសិប្បនិម្មិត (AI), បច្ចេកវិទ្យាប្លុកឆេន (Blockchain), កិច្ចសន្យាឆ្លាតវៃ (Smart Contracts), លេខសម្គាល់អេឡិចត្រូនិកនានា និងការរីកចម្រើនជាច្រើនទៀត ត្រូវបានធ្វើសមាហរណកម្មយ៉ាងសកម្មនៅក្នុងទំនាក់ទំនងជាប្រចាំថ្ងៃរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ ស្របតាមការវិវត្តនៃបច្ចេកវិទ្យាព័ត៌មាន និងក្នុងទំនាក់ទំនងនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវប្រឈមនឹងការផ្តល់សេវាសាធារណៈយ៉ាងតឹងរ៉ឹងក្នុងការអនុវត្ត និងប្រកបដោយប្រសិទ្ធភាពទៅដល់ប្រជាពលរដ្ឋ។ ប៉ុន្តែ អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែធានាដោយការទទួលខុសត្រូវចំពោះសុវត្ថិភាពបុគ្គលលើទិន្នន័យ តម្លាភាព សវនកម្ម និងឯកជនភាពលើអត្តសញ្ញាណកម្ម ដើម្បីបង្កទំនុកចិត្តខ្ពស់ យុត្តិធម៌ និងអព្យាក្រឹត្យភាព។

ទិដ្ឋភាពដែលអាចអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន គឺត្រូវគោរពលើលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់របស់បច្ចេកវិទ្យាព័ត៌មាន។ ក្នុងនោះ បច្ចេកវិទ្យាព័ត៌មានកម្ពុជា កំពុងដាក់ឱ្យដំណើរការ និងកំពុងនវានុវត្តន៍បច្ចេកវិទ្យាបន្តបន្ទាប់ ដែលមានស្រាប់នោះ គឺអាចមានលក្ខណៈសមស្របប និងតម្រូវការចំពោះសេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថល គឺមានប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា CamDX (២.១) និងប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឌីជីថល CamDigiKey (២.២)។

## ២.១. ប្រព័ន្ធថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)

ប្រទេសកម្ពុជា បានទទួលរងឥទ្ធិពលបច្ចេកវិទ្យាឆ្លាតវៃសកលមួយដែលពេញនិយមក្នុងការប្រើប្រាស់ និងជាជំនួយដល់ការរស់នៅជាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហៅថា "បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT)"។ បច្ចេកវិទ្យានេះ គឺបានរួមចំណែកដល់ការធ្វើបរិវត្តកម្មឌីជីថល និងជំរុញដល់ការអភិវឌ្ឍទៅមុខជានិច្ចក្នុងសកលលោក។ បច្ចេកវិទ្យា ICT គឺផ្តោតសំខាន់លើការតភ្ជាប់ទំនាក់ទំនងដោយប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ, ប្រព័ន្ធទូរគមនាគមន៍ និងឧបករណ៍ជាជំនួយដូចជា អ៊ីនធឺណិត, បណ្តាញឥតខ្សែ, ទូរសព្ទដៃ កុំព្យូទ័រ, វីដេអូខលសន្និសីទ, បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ដើម្បីជួយសម្រួលដល់ដំណើរការព័ត៌មានដែលត្រូវបានបង្កើត, ចែកចាយ, ទាញយក, រៀបចំ និងរក្សាទុកព័ត៌មាននៅក្នុងទម្រង់ឌីជីថល។[95] ប្រភពនៃបច្ចេកវិទ្យានេះ អាចគិតចាប់ពីការរកឃើញបន្ទះឈីប និងការផលិតសីមីកុងទ័រ ក្នុងចន្លោះឆ្នាំ១៩៤០ រហូតដល់មានវត្តមានអ៊ីនធឺណិតនៅឆ្នាំ១៩៦៩។ ការមកដល់នៃបច្ចេកវិទ្យានេះ បានផ្លាស់ប្តូរទម្លាប់នៃការបំពេញការងារ, ធ្វើឱ្យប្រសិទ្ធភាពការងារ, និងធ្វើឱ្យទីផ្សារការងារកាន់តែមានភាពច្នៃប្រតិដ្ឋដល់មនុស្សជាតិ។ យោងរបាយការណ៍ Datareportal ស្តីអំពីឌីជីថលក្នុងកម្រិតសកលគិតត្រឹមដើមខែមេសា ឆ្នាំ២០២៤ គឺមានប្រជាជនចំនួន៥.៤៤ប៊ីលាននាក់ នៅជុំវិញពិភពលោកកំពុងប្រើប្រាស់អ៊ីនធឺណិត ស្មើនឹង៦៧,១%ប្រជាជនសកលសរុប ខណៈដែលប្រជាជនពុំបានប្រើ-

[95] Australian Curriculum, "Information and Communication Technology (ICT)," *Sydney*: Acara, https://www.australiancurriculum.edu.au/f-10-curriculum/general-capabilities/information-and-communication-technology-ict-capability/ (ទស្សនាចុងក្រោយថ្ងៃទី៤ មេសា ២០២៤)។

ប្រាស់ថយចុះត្រឹម២.៦៦ប៊ីលាននាក់ ភាគច្រើននៅតាមអាស៊ីខាងត្បូង ខាងកើត និងតំបន់អាហ្វ្រិក។[96] នៅក្នុងចំណោមប្រជាជន៥.០៧ប៊ីលាននាក់ ស្មើនឹង៦២,៦% កំពុងប្រើប្រាស់បណ្ដាញសង្គម។ តាមការព្យាករនៅឆ្នាំ២០២៧ នឹងមានទំហំទីផ្សារនៃបច្ចេកវិទ្យា ICT ដល់៥៩១.៩១ប៊ីលានដុល្លារសហរដ្ឋអាមេរិក។[97] តម្រូវការកាន់តែកើន ផលិតភាពបច្ចេកវិទ្យាទាមទារការវិវត្តថ្មី គឺបង្កើតបច្ចេកវិទ្យាអ៊ីនធឺណិតនៃវត្ថុ (Internet of Thing), ទិន្នន័យធំ (Big Data), ប្រព័ន្ធកុំព្យូទ័រក្លោដ (Cloud of System), ការគ្រប់គ្រងមាតិកា និងសន្តិសុខ (Contents management and securities) ដែលនឹងត្រូវលើកបង្ហាញបន្តដោយផ្សាភ្ជាប់នៅក្នុងជំពូកទី៣ និងទី៤។

ផ្នែកសំខាន់ៗនៃមុខងារបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) ត្រូវបានផ្អែកលើការចាត់ថ្នាក់ចំនួន៤ គឺទី១.ផ្អែកលើមុខងារ ដែលសំដៅទៅដល់ឧបករណ៍ឌីជីថល កម្មវិធី និងបណ្ដាទូរគមនាគន៍, ទី២.ផ្អែកលើការប្រើប្រាស់ អាស្រ័យតាមគោលបំណងរបស់អ្នកប្រើប្រាស់ដូចជា ការអប់រំ, សេវាសាធារណៈ, ធុរកិច្ច, និងព័ត៌មានផ្ទាល់ខ្លួន, ទី៣.ផ្អែកលើសេវាកម្ម សំដៅដល់ការទំនាក់ទំនង, សេវាព័ត៌មាន និងសេវាបែបកម្សាន្ត, និងទី៤.ផ្អែកបណ្ដាញឥតខ្សែ ជាអាទិ៍។[98] បច្ចេកវិទ្យា ICT នេះប្រទេសកម្ពុជាបានចាប់ផ្ដើមយកប្រើប្រាស់ និងតភ្ជាប់ជាមួយបច្ចេកវិទ្យាប្លុកឆេន (Blockchain) នឹងអាចឈានដល់ការបន្ថែមមុខងារបញ្ញាសប្បនិម្មិត AI ពេលអនាគត ដើម្បីជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឌីជីថលកម្ពុជា និងកំពុងតែដាក់ឱ្យដំណើរការ ហៅថា "ប្រព័ន្ធថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (ថ.ផ.ទ ឬ CamDX)"។

ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (ថ.ផ.ទ) ជាទម្រង់ម៉ូដែលសកលមួយ ក្នុងបច្ចេកវិទ្យាប្លុកឆេន (Blockchain) ដែលបានយកមកអនុវត្តនៅកម្ពុជា ចាប់ពីឆ្នាំ២០២០មក ដោយមានក្រសួង ស្ថាប័ន និងអង្គភាពមិនចំណុះរដ្ឋាភិបាលជាច្រើន បានអនុវត្តជាបន្តបន្ទាប់។ ថ្នាលនេះ គឺសំដៅដល់បច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការផ្លាស់ប្ដូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ននានាដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្ដាញតភ្ជាប់ឌីជីថលផ្សេងៗ នៅក្នុងគោលដៅឱ្យតភ្ជាប់ជាប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល។ នេះជាបរិវត្តកម្មឌីជីថលដំបូងនៅកម្ពុជា ក្នុងអំឡុងពេលជួបប្រទះវិបត្តិជាសកលនៃជំងឺកូវីត១៩ ដែលផ្លាស់ប្ដូរបរិបទក្នុងការរស់នៅរបស់មនុស្សជាតិលើពិភពលោក ហើយកម្ពុជា ក៏បានជះឥទ្ធិពលលើបញ្ហានេះ ផងដែរ និងព្យាយាមរុករកវិធីសាស្ត្របម្លាស់ខ្លួន ដើម្បីសម្រួលប្រជាពលរដ្ឋអាចប្រើប្រាស់សេវាសាធារណៈពីចម្ងាយ ដោយផ្អែកលើការប្រើប្រាស់បបមនៃធនូបនីយកម្ម។[99]

---

[96] Simon Kemp, "Digital 2024: Global Overview Report" [ឌីជីថលឆ្នាំ២០២៤៖ របាយការណ៍ទិដ្ឋភាពសកល], *Datareportal*: (2024), https://datareportal.com/reports/digital-2024-global-overview-report (ទស្សនាចុងក្រោយថ្ងៃទី៩ មេសា ២០២៤)។

[97] Global Data, "ICT Market Report" [របាយការណ៍ទីផ្សារបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន], (2024), https://www.globaldata.com/store/report/client-computing-market-analysis/ (ទស្សនាចុងក្រោយថ្ងៃទី៩ មេសា ២០២៤)។

[98] Unesco, "2017 ЦИНДАОСКОЕ ЗАЯВЛЕНИЕ: Стратегии использования ИКТ для достижений целей повестки Образование-2030" [សេចក្ដីថ្លែងការណ៍ Qingdoa ឆ្នាំ២០១៧៖ យុទ្ធសាស្ត្រប្រើប្រាស់ ICT សម្រេចគោលដៅនៃការអប់រំឆ្នាំ២០៣០], https://unesdoc.unesco.org/ark:/48223/pf0000253061 (ទស្សនាចុងក្រោយថ្ងៃទី៩ មេសា ២០២៤)។

[99] ពាក្យថា ធនូបនីយកម្ម (Digitization) គឺជាដំណើរការបំប្លែងទិន្នន័យ និងព័ត៌មានពីទម្រង់អាណាឡូក ទៅជាក្នុងទម្រង់ឌីជីថល, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥។

ជាក់ស្តែងរាល់តម្រូវការសេវាសាធារណៈនៃក្រសួង ស្ថាប័ន និងអន្តរការពាក់ព័ន្ធត្រូវគោរព អនុវត្តដើម្បីអាចប្រព្រឹត្តបច្ចេកវិទ្យាឌីជីថលនេះបាន គឺលក្ខខណ្ឌគុណវុឌ្ឍិក្លាយជាសមាជិក (២.១.១) សមត្ថកិច្ច និងភារកិច្ចរបស់សមាជិក (២.១.២)។

### ២.១.១. លក្ខខណ្ឌគុណវុឌ្ឍិក្លាយជាសមាជិក

ការទាញចូលទៅប្រើប្រាស់សេវាសាធារណៈដោយបច្ចេកវិទ្យាឌីជីថល គឺតម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពបំពេញលក្ខន្តិកៈ និងពេញសិទ្ធិលក្ខណៈណាមួយដែលច្បាប់បានកំណត់, ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ត្រូវបានបែងចែក២ប្រភេទរួមមាន ៖ សមាជិកដោយស្វ័យប្រវត្តិ (២.១.១.១) និងសមាជិកដោយការស្នើសុំ (២.១.១.២)។ សមាជិកទាំង២ប្រភេទ គឺអាចជាអ្នកទទួលទិន្នន័យ និង/ឬ ជាអ្នកផ្តល់ទិន្នន័យ។[100] មានន័យថា រាល់សមាជិកទាំង២នេះ គឺមានសិទ្ធិក្នុងការទទួលទិន្នន័យ ព័ត៌មាន អត្តសញ្ញាណរបស់បុគ្គលណាមួយ និងសិទ្ធិផ្តល់ត្រឡប់ទៅវិញលើទិន្នន័យ ព័ត៌មាន អត្តសញ្ញាណរបស់បុគ្គលណាមួយ ដោយចាំបាច់មានការអនុញ្ញាតដែលច្បាប់បានកំណត់។ ឧទាហរណ៍ អង្គភាព/បុគ្គល ក ចង់ទទួល និង/ឬ ផ្តល់ទិន្នន័យ ព័ត៌មាន អត្តសញ្ញាណរបស់អង្គភាព/បុគ្គល ខ គឺតម្រូវឱ្យអង្គភាព/បុគ្គល ក នោះធ្វើការស្នើសុំនៅលើ ថ.ផ.ទ ដោយការអនុញ្ញាតពីម្ចាស់ទិន្នន័យដើម និងម្ចាស់អត្តសញ្ញាណ។ ការណ៍នេះ ជាចំណុចរក្សាសិទ្ធិបុគ្គលភាពគតិយុត្ត។

#### ២.១.១.១. សមាជិកដោយស្វ័យប្រវត្តិ

សមាជិកដោយស្វ័យប្រវត្តិ សំដៅវិស័យសាធារណៈដែលមានជាអាទិ៍ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។[101] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ដ.ន.ស) ក៏ត្រូវបានចាត់ទុកជាសមាជិកដោយស្វ័យប្រវត្តិ ក្នុងករណី ក្រសួងចង់ចាប់ផ្តើមប្រើប្រាស់ថ្នាលនេះ គឺដោយអនុស្សរណៈយោគយល់ (MOU)។ ក្រសួង ដ.ន.ស គឺបានពិភាក្សា និងពិនិត្យមើលស្ថានភាពក្នុងការប្រើប្រាស់ ជាមួយខាងតំណាងប្រតិបត្តិករអំពីលទ្ធភាពបច្ចេកទេស បញ្ហាប្រឈម និងតម្រូវការនានានៅក្នុងការរៀបចំទិន្នន័យ និងសេវាសាធារណៈរបស់ក្រសួង (នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដី) ដោយបានក្លាយជាសមាជិកដោយស្វ័យប្រវត្តិ និងធ្វើការផ្សព្វផ្សាយពីសមាជិកភាពជាផ្លូវការដោយប្រតិបត្តិករ ថ.ផ.ទ នៅចុងឆ្នាំ២០២៣។

លក្ខខណ្ឌជាក់លាក់សម្រាប់សមាជិកនៃ ថ.ផ.ទ ចំពោះសមាជិកដោយស្វ័យប្រវត្តិ ក៏ត្រូវតែគោរពតាមលក្ខខណ្ឌមួយចំនួនដូចជា៖

> ១.រាល់ការផ្លាស់ប្តូរទិន្នន័យក្នុងក្របខណ្ឌទិន្នន័យគោល ដើម្បីផ្តល់សេវាសាធារណៈ និងនៅក្នុងក្របខណ្ឌអន្តរប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវធ្វើឡើងនៅលើ ថ.ផ.ទ តែមួយគត់, ២.គឺត្រូវសហការ និងសម្របសម្រួលជាមួយប្រតិបត្តិករ ថ.ផ.ទ ក្នុងការរៀបចំបែបបទ និងនីតិវិធី ឬអនុស្សរណៈនៃការយោគយល់គ្នា សម្រាប់ការផ្លាស់ប្តូរទិន្នន័យលើ ថ.ផ.ទ និងអាចមានការកែសម្រួលបែប

[100] អនុក្រឹត្យស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, លេខ១៦៤អនក្រ.បក, ២៤ សីហា ២០២១, មាត្រា៩, (ពីពេលនេះតទៅហៅថា អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា)។

[101] អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា១០(១)។

បទ និងនីតិវិធី ឬអនុស្សរណៈនៃការយោគយល់គ្នាតាមការចាំបាច់ និង, ៣.មិនតម្រូវឱ្យដាក់ពាក្យស្នើសុំចូលជាសមាជិកនោះទេ និងមិនអាចត្រូវបោះបង់សមាជិកភាពបាននោះទេ វៀរលែងតែនៅក្នុងករណីសមាជិកដោយស្វ័យប្រវត្តិនោះ ត្រូវបានរំលាយចោល ឬធ្វើសមាហរណកម្មជាមួយស្ថាប័នដទៃស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានចូលជាធរមាន។[102]

សមាជិកទាំងពីរប្រភេទដែលអាចជាអ្នកផ្តល់ទិន្នន័យ និង/ឬ ជាអ្នកទទួលទិន្នន័យ ត្រូវធានាថារាល់នីតិវិធីនៃការផ្លាស់ប្តូរទិន្នន័យ ត្រូវបានអនុវត្តប្រកបដោយតម្លាភាព គណនេយ្យភាព និងអនុលោមតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នា ឬកិច្ចសន្យា ឬលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានដោយគ្មានសមាជិកណាមួយ មានសិទ្ធិអនុម័ត ឬរក្សាវិធានណាមួយដែលប្រាសចាកនឹងលក្ខខណ្ឌដែលបានកំណត់នោះឡើយ។ មានន័យថា រាល់ដំណើរការប្រព្រឹត្តទៅបាន គឺត្រូវត្រួតពិនិត្យពីប្រតិបត្តិករ ថ.ផ.ទ។ រាល់ការធ្វើបច្ចុប្បន្នភាព ឬការកែប្រែលក្ខខណ្ឌណាមួយនៃនីតិវិធីក្នុងការផ្លាស់ប្តូរទិន្នន័យ គឺសមាជិកនីមួយៗ ត្រូវជូនដំណឹងមកប្រតិបត្តិករ ថ.ផ.ទ ដើម្បីជួយសម្របសម្រួល។ ប្រសិនបើសមាជិកណាមួយដែលជាអ្នកផ្តល់ទិន្នន័យបដិសេធការផ្លាស់ប្តូរទិន្នន័យ សមាជិកនោះត្រូវផ្តល់ឱ្យសមាជិកដែលជាអ្នកស្នើសុំទិន្នន័យ (អ្នកទទួលទិន្នន័យ) នូវការពន្យល់ពីមូលហេតុនៃការបដិសេធក្នុងរយៈពេលសមស្រប បន្ទាប់ពីមានការសម្របសម្រួលពីប្រតិបត្តិករ ថ.ផ.ទ។ ឧទាហរណ៍. ស្ថាប័ន/អង្គភាព ក ដែលចង់ធ្វើបច្ចុប្បន្នភាព ឬកែប្រែអំពីលក្ខខណ្ឌ ឬព័ត៌មានណាមួយដែលយល់ថាចាំបាច់ ឬភាពខុសប្រក្រតី ឬគាំងវិធីណាមួយ នៅមុនពេល ឬក្នុងអំឡុងពេលផ្លាស់ប្តូរទិន្នន័យ គឺស្ថាប័ន/អង្គភាព ក ត្រូវតែជូនដំណឹងមកកាន់ប្រតិបត្តិករ ថ.ផ.ទ ដើម្បីឲ្យសម្រួលក្នុងដំណើរការនោះ ក្នុងករណីបើចង់បដិសេធ មិនទទួលយកការផ្លាស់ប្តូរទិន្នន័យណាមួយនោះ ស្ថាប័ន/អង្គភាព ក ត្រូវផ្តល់អំណះអំណាងហេតុផលណាមួយ ដែលខ្លួនបានបដិសេធ មិនទទួលយកនោះ ក្នុងរយៈកាលសមរវេលាណាមួយ ក្រោយមានអន្តរាគមន៍ពីប្រតិបត្តិករ ថ.ផ.ទ។

តម្រូវការបច្ចេកទេស និងកាតព្វកិច្ចធ្វើតេស្ត សមាជិកទាំងពីរប្រភេទត្រូវធានាបានថាមានលទ្ធភាពក្នុងការតំឡើងម៉ាស៊ីនមេសុវត្ថិភាពនៅក្នុងក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួនបាន។ ការណ៍នេះ រាជរដ្ឋាភិបាលបានកំពុងពន្លឿនបណ្តុះបណ្តាលមូលធនមនុស្សឌីជីថលតាមរយៈប្រព័ន្ធអប់រំ និងមន្ត្រីជំនាញការ ដែលដើរតួនាទីនាពេលអនាគតក្នុងពិភពរូបវន្តចំពោះការអនុវត្តនិងដំណោះស្រាយឌីជីថល ដោយអាចឆ្លើយតប និងបំពេញតម្រូវការក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលឱ្យកាន់តែទំនើបទៅមុខ។ លក្ខខណ្ឌលើបច្ចេកទេស តម្រូវឱ្យសមាជិកត្រូវគោរព និងអនុវត្តតាមឯកសារជាធរមានដូចជា៖ ឯកសារណែនាំក្នុងការតំឡើងម៉ាស៊ីនមេសុវត្ថិភាព (Security Sever Installation Guideline), ឯកសារណែនាំសម្រាប់ការប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ API & API Catalog, ឯកសារធានាគុណភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Information Security Guideline) និងឯកសារណែនាំសម្រាប់ការប្រើប្រាស់ក្នុងប្រព័ន្ធវិក្កយបត្រនៃ ថ.ផ.ទ (CamDX Billing System

[102] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៣។ អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា១២, ១៣, និង១៤។ ពាក្យថា ពិភពពិត ឬពិភពរូបវន្ត (Physical World) ជាពិភពជីវិតពិតដែលមនុស្សជាតិគ្រប់គ្នាប្រាស្រ័យទាក់ទងគ្នា និងទទួលបទពិសោធន៍តាមរយៈឥន្ទ្រិយារម្មណ៍, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥។

Guideline)។[103]

ការងារបច្ចេកទេសនេះ ដែលមានការរៀបចំ និងការប្រព្រឹត្តទៅចូលរួមសម្របសម្រួលដោយប្រតិបត្តិករ ថ.ផ.ទ។ គិតមកត្រឹមថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ក្នុងប្រព័ន្ធ ថ.ផ.ទ គឺមានម៉ាស៊ីនមេសុវត្ថិភាពសរុបជាង៧៤ម៉ាស៊ីន។ មានសមាជិករួមជាមួយប្រព័ន្ធ ថ.ផ.ទ គិតត្រឹមថ្ងៃខែឆ្នាំដដែលនេះ មានចំនួនសរុបជាង៥៤ក្រសួង ស្ថាប័ន អង្គភាព ដោយស្ថាប័នរដ្ឋមានចំនួនប្រមាណជាង២៥ក្រសួង ស្ថាប័ន និងស្ថាប័នមិនចំណុះរដ្ឋាភិបាលមានចំនួន២៩ស្ថាប័ន។ ស្ថិតិប្រតិបត្តិការសរុបរបស់ ថ.ផ.ទ មានការប្រើប្រាស់ឈានរហូតដល់ ៣២លានដង គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤។ ការអង្កេតលើប្រតិបត្តិការសរុបប្រចាំថ្ងៃ យ៉ាងហោចណាស់ជាង៨ម៉ឺនដងនៃកំណត់ត្រាអេឡិចត្រូនិក ដែលជាកត្តាទទួលបានជ័យលាភីសម្របខ្លួនឌីជីថលរបស់កម្ពុជា។[104] ក្រសួង ដ.ន.ស កំពុងប្រើប្រាស់ម៉ាស៊ីនមេចំនួន១ ក្នុងប្រតិបត្តិការទូទៅ។

នៅក្នុងប្រព័ន្ធ ថ.ផ.ទ គឺជាប្រព័ន្ធនៃចង្កោមអេកូឡូស៊ី ក្នុងការប្រតិបត្តិកូដនីយកម្មព័ត៌មាន និងបន្សល់ជាកំណត់ត្រាអេឡិចត្រូនិក អាស្រ័យលើចំនួនប្រតិបត្តិការ។ ក្នុងការពន្យល់អំពីអន្តរប្រតិបត្តិការនៅក្នុងវិធាននីតិវិធីមានដូចតទៅ ៖ គឺលេខ១. ជាសមាសភាគស្នូលធំមួយ ឬជាក្បាលម៉ាស៊ីនស្តុកទុកមានសមត្ថភាពក្នុងការគ្រប់-គ្រង បែងចែក និងបានបញ្ជាទៅកាន់បណ្តាញម៉ាស៊ីនផ្សេងៗដែលជាតំណតភ្ជាប់ដោយអ៊ីនធឺណិត និងច្រកទ្វារអ៊ីនធឺណិតក្នុងការផ្តល់ និងបញ្ជូនទៅវិញទៅមកនៅក្នុងប្រព័ន្ធ។ លេខ២. ជាម៉ាស៊ីនមេសុវត្ថិភាពដែលបានរៀប-ចំតំឡើងនៅតាមក្រសួង ស្ថាប័ន អង្គភាព ទៅតាមចំនួនអាស្រ័យលើទំហំការងាររបស់សមាជិកទាំងពីរប្រភេទ។ ម៉ាស៊ីនមេសុវត្ថិភាពនេះ មានសមត្ថភាពការកំណត់ច្រកចេញ-ចូលទិន្នន័យ វាយតម្លៃដោយសទ្ធានកម្មនៃកម្មវិធីកុំព្យូទ័រ ប្រតិបត្តិការយ៉ាងណាឱ្យជោគជ័យលើកូដនីយកម្ម ទើបអនុញ្ញាតឱ្យចុះហត្ថលេខាឌីជីថល ដោយទំនុកចិត្ត សុវត្ថិភាពខ្ពស់ និងរហ័ស ដែលបានកំណត់ត្រាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។ លេខ៣. ជាដែនខណ្ឌព័ត៌មានក្នុងការផ្តល់ និងទទួលទិន្នន័យ ដែលត្រូវឆ្លងកាត់តភ្ជាប់រវាងម៉ាស៊ីនមេសុវត្ថិភាព ដើម្បីធានាអំពីសុចរិតភាពក្នុងការផ្លាស់ប្តូរទិន្នន័យរវាងអន្តរប្រតិបត្តិការក្នុងមួយលើកៗ នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ លេខ៤. គឺជាសមា-សភាគទំនុកចិត្ត ឬជាម៉ាស៊ីនដែលបំពេញការងារលើការគ្រប់គ្រងវិញ្ញាបនបត្រឌីជីថលណាមួយ ដែលចេញដោយប្រតិបត្តិករ ថ.ផ.ទ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល សម្រាប់យកទៅប្រើប្រាស់ក្នុងការកំណត់អត្តស-ញ្ញាណសមាជិក ធ្វើកូដនីយកម្ម/វិកូដនីយកម្មពេលធ្វើការផ្លាស់ប្តូរទិន្នន័យ និងកំណត់ត្រាអេឡិចត្រូនិក។

---

[103] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៥, និងអាចស្វែងរកឯកសារតម្រូវការបច្ចេកទេសនៅក្នុងឧបសម្ព័ន្ធនៃវិធាន និងនីតិវិធី ថ.ផ.ទ. នេះ ប្រើប្រាស់ជាភាសាបច្ចេកទេស និងភាសាអង់គ្លេស។

[104] https://monitoring.camdx.gov.kh ។ ពាក្យ ប្រតិបត្តិការ ឬចំនួនប្រតិបត្តិការ (Number of Transaction) សំដៅដល់ចំនួននៃការស្នើសុំទិន្នន័យមកកាន់ អ្នកផ្តល់ទិន្នន័យ ដែលក្នុងមួយប្រតិបត្តិការត្រូវបានកំណត់យក ពេលដែលអ្នកផ្តល់ទិន្នន័យឆ្លើយតបទៅវិញដោយជោគជ័យ តាមតម្រូវការនៃការស្នើសុំទិន្នន័យនោះ។ រីឯពាក្យថា កំណត់ត្រាអេឡិចត្រូនិក (Timestamp) ជាកំណត់ត្រាដែលត្រូវបានបង្កើតឡើង ការទាក់ទង ទទួល រក្សាទុក ឬដំណើរការនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយ ទៅកាន់ប្រព័ន្ធអេឡិចត្រូនិកមួយទៀត, ក្នុងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា។ ***កំណត់ត្រា ឬចំនួនប្រតិបត្តិការត្រូវបានរក្សាជាតួលេខ ប៉ុន្តែ រាល់ទិន្នន័យគ្មានការរក្សាទុកទេ។*** ពាក្យថា សទ្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) សំដៅដល់ច្រកចេញចូលស្តង់ដារដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាមួយផ្សេងទៀត, ក្នុងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា។

ប្រតិបត្តិករ ថ.ផ.ទ អាចកំណត់អំពីវិធី និងកាលបរិច្ឆេទនៃការធ្វើតេស្ត ផ្អែកលើផែនការសកម្មភាពសម្រាប់ការធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ API ដែលសមាជិកបានដាក់ជូន ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការរវាងប្រព័ន្ធ និងប្រព័ន្ធ។ ប្រតិបត្តិករ ថ.ផ.ទ នឹងផ្តល់ជូនសមាជិកជាឯកសារធ្វើតេស្តរួមមាន ការធ្វើតេស្តរួមបញ្ចូលទៅក្នុងប្រព័ន្ធគោល (SIT) និងការធ្វើតេស្តទទួលយកអ្នកប្រើប្រាស់ (UAT) ជូនដល់សមាជិក។ បន្ទាប់មក សមាជិកត្រូវរៀបចំផែនការធ្វើតេស្តទាំង SIT និង UAT រួចជូនដំណឹងជាមុនមកកាន់ប្រតិបត្តិករ ដើម្បីខាងប្រតិបត្តិករ ថ.ផ.ទ អាចពិនិត្យ និង/ឬ កែប្រែផែនការធ្វើតេស្តរបស់សមាជិក ដោយចូលរួមពិនិត្យការធ្វើតេស្ត និងទាមទារឱ្យមានការធ្វើតេស្តសាជាថ្មីតាមការចាំបាច់។ ក្នុងករណី ការធ្វើតេស្តទទួលបានជោគជ័យ សមាជិកត្រូវចុះហត្ថលេខាលើលិខិតទទួលស្គាល់ (SOL)។[105] ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើហត្ថលេខាឌីជីថល និងផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលទៅដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។[106] នីតិវិធីនៃការស្នើសុំចូលនេះ គឺសមាជិកទាំង២ប្រភេទ គឺត្រូវតែធ្វើតេស្តសាកល្បងជាមុន។

តាមពិតទៅប្រទេសកម្ពុជាធ្លាប់បានប្រើប្រាស់ កត់ត្រារបាយការណ៍ និងព័ត៌មានឯកសារជាទម្រង់ឌីជីថល (Digital) ផងដែរ។[107] ប៉ុន្តែ ការប្រើប្រាស់ សម្រាប់តែការកត់ត្រាព័ត៌មានក្បាលដី ផែនទី អត្តសញ្ញាណខ្លីៗរបស់កម្មសិទ្ធិករអចលនវត្ថុនីមួយៗ និងប្រើប្រាស់នៅក្នុងទម្រង់តែផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប៉ុណ្ណោះ។ ការចងក្រងឯកសារទិន្នន័យកន្លងមកនេះ គឺជាតួនាទី និងភារកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង រួមទាំងខាងបណ្ណាការិយាល័យស្ថិតក្រោមឱវាទ ជាសេនាធិការឱ្យអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ។[108] ការអនុវត្តនេះ ក៏មានការចង្អុលបង្ហាញនៃសេចក្តីណែនាំពីវិធានការសុវត្ថិភាពលើឯកសារ រាល់ការចុះបញ្ជី ការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីដែរ គ្រាន់តែការអនុវត្ត គឺមន្ត្រីនៅតាមថ្នាក់មូលដ្ឋានមិនទាន់ស៊ីចង្វាក់គ្នា និងកម្មវិធីចាស់គំរិលហួសសម័យកាលប្រើប្រាស់។ ការបំពេញមុខងារកត់ត្រាដើម្បីត្រួតពិនិត្យព័ត៌មានរបស់មន្ត្រីសុរិយោដី ចាប់តាំងពីឆ្នាំ២០០៦ មក ដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ Window XP នៃជំនាន់ឆ្នាំ២០០០, ចងក្រងសុសវែរ (Software) របស់កម្មវិធី Microsoft Access

[105] អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦អនក្រ.បក, ២៩ ធ្នូ ២០១៧, (ពីពេលនេះតទៅហៅថា អនុក្រឹត្យហត្ថលេខាឌីជីថល)។ ពាក្យថា ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី (Startup Ecosystem) សំដៅដល់ស្ថាប័ន ឬតួអង្គពាក់ព័ន្ធ ដែលធ្វើការជាប្រព័ន្ធ និងបំពេញមុខងារឱ្យគ្នាទៅវិញទៅមកក្នុងការបណ្តុះ និងពន្លឿនធុរកិច្ចថ្មី។ រីឯពាក្យថា កូដនីយកម្ម (Encryption) សំដៅដល់ការបម្លែង ព័ត៌មាន ឬទិន្នន័យទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ ឬប្រើប្រាស់បាន។ ពាក្យបន្ថែម វិកូដនីយកម្ម ជាការសម្រួល បកប្រែ ឬពន្យល់ដោយអ្នកបច្ចេកទេស ដើម្បីងាយយល់លើកូដពិសេស ប្រើប្រាស់ក្នុងគោលបំណងណាមួយ, ក្នុងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា។

[106] អនុក្រឹត្យហត្ថលេខាឌីជីថល, មាត្រា៥(១), និងច្បាប់ស្តីពីទូរគមនាគមន៍, លេខ នស/រកម/១២១៥/០១៧, ១៧ ធ្នូ ២០១៥, មាត្រា៥ និង៦, (ពីពេលនេះតទៅហៅថា ច្បាប់ទូរគមនាគមន៍), ពាក្យថា ហត្ថលេខាឌីជីថល (Digital Signature) សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិចត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថល និងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា, ក្នុងអនុក្រឹត្យនេះ។

[107] សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីវិធានការធានាសុវត្ថិភាពនៃឯកសារ សុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital, លេខ៩៥អ/សដក, ២៣ ឧសភា ២០០៦, ចំណុចទី១។

[108] ដូច៦៤, ប្រការ១។

ជំនាន់ឆ្នាំ២០០៣ និងវិរត្តឆ្នាំ២០០៧។[109]

មន្ត្រីសុរិយោដី អាចអនុលោមតាម៤ដំណាក់កាលដូចជា៖ ទី១.ការថតចម្លងទិន្នន័យទុក (Backup) ដោយមានទិន្នន័យមូលដ្ឋាន និងទិន្នន័យប្លង់សុរិយោដី ត្រូវតែចម្លងទុករៀងរាល់ថ្ងៃ។ របៀបរៀបចំត្រូវមាន Network Server to Folder បង្កើត Sub Folder ចំនួន៥ ដោយរាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ប្រព្រឹត្តទៅរាល់ចុងម៉ោងធ្វើការរបស់មន្ត្រីសុរិយោដីនៃថ្ងៃនីមួយៗ។[110] ទី២.រក្សាទិន្នន័យទុកជាឯកសារ (Archiving) មន្ត្រីសុរិយោដីត្រូវតែរក្សាទុកនៅមុន និងក្រោយការបិទផ្សាយជាសាធារណៈនៃឯកសារវិនិច្ឆ័យ និងមិនត្រូវឱ្យមានកែតម្រូវផ្តេសផ្តាសលើព័ត៌មានក្បាលដីនៃ File នេះឡើយ។[111] ទី៣.ការថតទិន្នន័យផ្ញើទុកនៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវតែទិន្នន័យសម្រេចចុងក្រោយ ផ្ញើនៅរាល់២សប្តាហ៍ម្តង ដើម្បីប្រើបន្តទាក់ទងនឹងការប្រែប្រួលលក្ខណៈរូបដីចំពោះការចុះបញ្ជីបន្ត។ នៅមុនពេលបិទផ្សាយជាសាធារណៈ ត្រូវចម្លងជូនអគ្គនាយកដ្ឋានមួយច្បាប់។ ចំពោះការប្រព្រឹត្តទៅចប់ដោយស្ថាពរលើការចុះបញ្ជីដីធ្លី ឬឯកសារដែលសម្រេចចុងក្រោយ ត្រូវផ្ញើរបាយការណ៍ និងរាល់ឯកសាររណបការចុះបញ្ជី ផ្ញើមកកាន់អគ្គនាយកដ្ឋានយ៉ាងយូរក្រោយ៧ (ប្រាំពីរ) ថ្ងៃកំណត់ចេញបណ្ណ និងនៅលើខ្នងស៊ីឌី(CD) ត្រូវចំណារកាលបរិច្ឆេទ និងរាយនាមខេត្ត ក្រុងនោះ។ ក្រោយមក មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក៏ត្រូវតែផ្ញើទៅគណៈកម្មការរដ្ឋបាលយ៉ាងយូរក្រោយ៧ (ប្រាំពីរ) ថ្ងៃកំណត់ចេញបណ្ណ ផងដែរ។ ទី៤.លេខសំងាត់ និងឈ្មោះអ្នកប្រើប្រាស់ ត្រូវផ្តល់ជូនមន្ត្រីការិយាល័យដោយចែកជា៣ប្រភេទជាលេខរបស់មន្ត្រីបញ្ចូលទិន្នន័យ, លេខមន្ត្រីគ្រប់គ្រងទិន្នន័យ, និងលេខមន្ត្រីទទួលបន្ទុកចុះបញ្ជីបន្ត។[112]

### ២.១.១.២. សមាជិកដោយការស្នើសុំ

សមាជិកដោយការស្នើសុំ គឺជាវិស័យឯកជនដែលមានជាអាទិ៍ ក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[113] ស្របទៅតាមមាត្រា៩ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ លក្ខខណ្ឌជាក់លាក់សម្រាប់សមាជិកដោយការស្នើសុំមានដូចជា៖

> ១.ត្រូវធានាថារាល់ការទទួលយក និងការផ្លាស់ប្តូរទិន្នន័យ មិនផ្តល់ការគំរាមកំហែងដល់សន្តិសុខជាតិឡើយ មិនប៉ះពាល់ដល់ភាពស្របច្បាប់នៃផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់ និងផលប្រយោជន៍សង្គម សិទ្ធិឯកជនរបស់ម្ចាស់ទិន្នន័យ ឬប៉ះពាល់ដល់នយោបាយសាធារណៈ របស់រាជរដ្ឋាភិបាល, ២.ត្រូវធានាឱ្យបានថា ទិន្នន័យដែលបានផ្លាស់ប្តូរតាមរយៈ ថ.ផ.ទ ត្រូវបានប្រើប្រាស់

---

[109] Samuel Gibbs, "From Window 1 to Window 10:29 years of Window Solution," *The Guardian*, 2014, https://www.theguardian.com/technology/2014/oct/02/from-windows-1-to-windows-10-29-years-of-windows-evolution និងបណ្តាកូដVPN ប្រើប្រាស់នៅកម្ពុជា https://vbdotnetforums.com/threads/khmer-culture-country-problem-on-windows-xp.18624/ (ទស្សនាចុងក្រោយថ្ងៃទី២៨ មីនា ២០២៤)។

[110] ដូច១០៧, ចំណុចទី២។

[111] ដដែល, ចំណុចទី៣, ៤ និង៥។

[112] ដដែល, ចំណុចទី៦ និង៧។

[113] អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា១០(២)។

ក្នុងគោលបំណងនៃការធ្វើធុរកិច្ច និងសង្គមកិច្ច ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន, ៣.ត្រូវធានាបាននូវគុណភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ៤.ត្រូវមានហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងសម្ភារបរិក្ខារបច្ចេកវិទ្យាព័ត៌មានស្នូលដើម្បីការបម្រុង សម្រាប់ប្រតិបត្តិការ ដោយធានាសន្តិសុខ សុវត្ថិភាព សុក្រឹតភាព និងគុណភាពប្រព័ន្ធ, ៥.ត្រូវមានលទ្ធភាពតំឡើងម៉ាស៊ីនមេសុវត្ថិភាព ក្នុងបណ្តាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន, ៦.ត្រូវមានសមត្ថភាពចូលរួមសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធក្នុងការចាត់វិធានការឆ្លើយតបណាមួយលើការវាយប្រហារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិង, ៧.ត្រូវទទួលបន្ទុកចំណាយពាក់ព័ន្ធនឹងថ្លៃសមាជិកភាព។[114]

នីតិវិធីដើម្បីអាចក្លាយជាសមាជិកដោយការស្នើសុំ ត្រូវអនុវត្តទៅតាមតម្រូវការ និងបំពេញគ្រប់លក្ខខណ្ឌដូចមានការពន្យល់នៅក្នុងនីតិវិធីការស្នើសុំសមាជិកដោយស្វ័យប្រវត្តិ ផងដែរ។ ស្ថាប័ន អង្គភាព ដែលបានដាក់ពាក្យស្នើសុំ ត្រូវទទួលបានលិខិតឯកភាព ជាគោលការណ៍ពីប្រតិបត្តិករ ថ.ផ.ទ ដែលតម្រូវឱ្យអនុវត្តតាមលិខិតឯកភាពជាគោលការណ៍ ក្នុងរយៈពេលដែលបានកំណត់។ ក្នុងករណីចាំបាច់ណាមួយ ស្ថាប័ន អង្គភាព អាចសុំពន្យារពេលជាផ្លូវការជាលាយលក្ខណ៍អក្សរទៅកាន់ប្រតិបត្តិករ ថ.ផ.ទ ដើម្បីពន្យារពេលអនុវត្តកាតព្វកិច្ចការធ្វើតេស្ត ដោយផ្អែកទៅលើមូលហេតុច្បាស់លាស់ និងមិនបង្កផលប៉ះពាល់នានាដល់សមាជិក ថ.ផ.ទ ដទៃទៀត។ ប្រតិបត្តិករ ថ.ផ.ទ គឺមានឆន្ទានុសិទ្ធិក្នុងការយល់ព្រម ឬបដិសេធលើសំណើសុំពន្យារពេល។ ក្នុងករណី ស្ថាប័ន អង្គភាព ដាក់ពាក្យស្នើសុំទទួលបានលិខិតឯកភាពជាគោលការណ៍ពីប្រតិបត្តិករ ថ.ផ.ទ ហើយ មិនព្រមអនុវត្តទៅតាមកាតព្វកិច្ចក្នុងរយៈពេលដែលបានកំណត់ ដោយមិនមានការស្នើសុំពន្យារពេល ឬជូនដំណឹងណាមួយប្រតិបត្តិករ ថ.ផ.ទ មានឆន្ទានុសិទ្ធិក្នុងការលុបចោលពាក្យស្នើសុំរបស់ស្ថាប័ន អង្គភាពនោះ។

ការបញ្ចប់សមាជិកភាព ធ្វើឡើងសម្រាប់តែសមាជិកភាពដោយការស្នើសុំ និងធ្វើឡើងនៅក្នុងរូបភាពចំនួន ២ គឺដោយសមាជិកផ្ទាល់ និងដោយសេចក្តីសម្រេចប្រតិបត្តិករ ថ.ផ.ទ។[115] ក្រោយពីការស្នើសុំបោះបង់ ឬបញ្ចប់សមាជិកភាពរួចរាល់ ស្ថាប័ន អង្គភាពជាសមាជិកស្នើសុំនោះ គឺគ្មានសិទ្ធិចូលប្រើប្រាស់ផតថលនៃប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មារាជរដ្ឋាភិបាល គ្រប់គ្រងដោយប្រតិបត្តិករ ថ.ផ.ទ បន្តទៀយ។ ករណី ការអះអាង ឬបន្តអនុវត្តសកម្ម-ភាពទុច្ចរិតណាមួយ ស្ថាប័ន អង្គភាពនោះត្រូវតែទទួលខុសត្រូវចំពោះបទដ្ឋានគតិយុត្តជាធរមាន។

### ២.១.២. សមត្ថកិច្ច និងភារកិច្ចរបស់សមាជិក

ការរុញច្រានទំនាក់ទំនងសមត្ថកិច្ចរវាងគ្នាទៅវិញទៅមក ជាបញ្ហាចម្បងនៅកម្ពុជា។ ការអនុវត្តចំពោះគំនិតច្រើនពេក ការដាក់ចេញផែនការឱ្យ គឺចេះតែអាចអនុវត្តទៅរួចហើយ ប៉ុន្តែ នៅពេលមានបញ្ហាកើតឡើង ធ្វើដោយគ្មានការជាក់លាក់ គ្មានទំនួលខុសត្រូវ គ្មានដំណោះស្រាយបង្ការទុក នៅតែជាដំបៅរបស់សង្គម។ ចំនែកឯនៅ

[114] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៤។ ពាក្យថា សន្តិសុខបច្ចេកវិទ្យាព័ត៌មាន (Cyber Security) គឺជាបច្ចេកវិទ្យាប្រឆាំងនឹងការប្រើប្រាស់ទិន្នន័យព័ត៌មានដោយគ្មានការអនុញ្ញាត, ពាក្យនេះពេលខ្លះ គឺអាចហៅថា សន្តិសុខ-សាយប័រ។ រីឯពាក្យថា ឧក្រិដ្ឋកម្មឌីជីថល (Digital Crime) សំដៅទៅដល់ការប្រព្រឹត្តអំពើល្មើសទាំងឡាយណាដែលច្បាប់ហាមឃាត់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ក្នុងអនុក្រឹត្យថ្នាលទិន្នន័កម្ពុជា។

[115] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៧។

លើថ្នាលបច្ចេកវិទ្យា ប្រសិនបើគ្មានការកំណត់ទុក និងរកដំណោះស្រាយជាមុនទេ វិបត្តិលើប្រព័ន្ធឌីជីថល នឹងធ្វើឱ្យបង្កមានភាពចលាចលនៅក្នុងសេដ្ឋកិច្ច-សង្គមឌីជីថល។ ល្អិកនេះ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា គឺបង្ការចេងហត្ថាជាសំណាញ់ស្រេច ចំពោះការប្រាសចាកគោលការណ៍ឌីជីថលណាមួយ ឬមានន័យថា ល្មើសបច្ចេកវិទ្យាព័ត៌មាន។ ការចេងជើងឱ្យជាប់សំណាញ់លើតួនាទី និងទំនួលខុសត្រូវ គឺសង្កត់ធ្ងន់ចំពោះប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (២.១.២.១) និងចំពោះសមាជិកភាពថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (២.១.២.២)។

### ២.១.២.១. ចំពោះប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា

ប្រតិបត្តិករ ថ.ផ.ទ មានតួនាទីគ្រប់គ្រងប្រតិបត្តិការរបស់ ថ.ផ.ទ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ។ បន្ថែមលើតួនាទី ជាអ្នកគ្រប់គ្រងប្រតិបត្តិការរបស់ ថ.ផ.ទ គឺមានតួនាទីត្រួតពិនិត្យការផ្លាស់ប្តូរទិន្នន័យលើ ថ.ផ.ទ របស់សមាជិក ថ.ផ.ទ ដើម្បីធានាបានរាល់ការផ្លាស់ប្តូរទិន្ន-ន័យតាមរយៈ ថ.ផ.ទ **គឺទិន្នន័យមិនត្រូវបានរក្សាទុកទេ** ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ ថ.ផ.ទ និង/ឬ ចែកចាយជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ **ដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យដើម**ទេ។[116] បំពេញមុខការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំ និងគ្រប់គ្រងនៅលើ ថ.ផ.ទ សំដៅជំរុញដល់ការទទួលយក និងធ្វើបរិវត្តកម្មឌីជីថល ដែលសម្រេចក្នុងប្រការ១នៃសេចក្តីសម្រេចស្តីពីការអនុញ្ញាតឱ្យមជ្ឈមណ្ឌលបណ្តុះធុរកិច្ច "តេជោ" (ម.ធ.ត) ជាប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២២, ក្នុងការបំពេញមុខងារអំឡុងពេលអន្តរកាល រហូតដល់ពេលដែលប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យត្រូវបានបង្កើត និងដាក់ឱ្យដំណើរការជាផ្លូវការ។[117]

ក្នុងការដោះស្រាយវិវាទ គឺប្រតិបត្តិករ ថ.ផ.ទ ត្រូវបង្កើតឱ្យមានយន្តការអព្យាក្រឹតមួយសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយវិវាទរបស់សមាជិក ថ.ផ.ទ ពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរទិន្នន័យនៅលើ ថ.ផ.ទ។ ក្នុងវិធាន និងនីតិវិធី កំណត់ការដាក់ពាក្យបណ្តឹង សំដៅដល់ការតវ៉ា ឬការទាមទារ ឬការមិនពេញចិត្តដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យនៅលើ ថ.ផ.ទ។ ការសម្រុះសម្រួលដោះស្រាយបណ្តឹង ឬវិវាទ សំដៅដល់ដំណើរការនៃការស្វែងរកដំណោះស្រាយមួយសមស្រប ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងការស៊ើបអង្កេត ជាដំណើរការស្រាវជ្រាវស្វែងរកភស្តុតាង ដើម្បីបញ្ជាក់ការពិត ឬមិនពិតចំពោះអង្គហេតុ។

ប្រតិបត្តិករ ថ.ផ.ទ គឺមានសិទ្ធិក្នុងការស៊ើបអង្កេតបណ្តឹង ពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យនៅលើ ថ.ផ.ទ ឬអាចផ្តល់របាយការណ៍ ព័ត៌មាន ឬក៏ទិន្នន័យពាក់ព័ន្ធនឹងប្រតិបត្តិករដែលជាកម្មវត្ថុនៃបណ្តឹង ឬវិវាទក្នុងអំឡុងពេលដោះស្រាយបណ្តឹង ឬវិវាទទៅតាមការស្នើសុំរបស់សមាជិក ថ.ផ.ទ ប៉ុន្តែ ពុំមានសិទ្ធិចេញសេចក្តីសម្រេចដើម្បីចាត់វិធានការដោះស្រាយ ឬដាក់ទណ្ឌកម្មឡើយ។ ប្រតិបត្តិករ ថ.ផ.ទ អាចធ្វើការស្នើសុំកិច្ចសហការ ឬការចូលរួមពីសមាជិកពាក់ព័ន្ធ ឬអង្គភាពពាក់ព័ន្ធនានាក្នុងការដោះស្រាយវិវាទទៅតាមការចាំបាច់។ ក្នុងករណីបណ្តឹង ឬវិវាទមិនអាចសម្រុះ សម្រួលដោះស្រាយបានទេ គឺប្រតិបត្តិករ ថ.ផ.ទ ត្រូវរាយការណ៍ ជូនដល់ក្រសួង

[116] អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា៦។

[117] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៨។ និងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា១៨, ២០, ២២, និង ២៤។

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬបញ្ជូនបន្តទៅកាន់ស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ផ្អែកទៅលើនីតិវិធីច្បាប់ជាធរមាន។[118] ប្រតិបត្តិករ ថ.ផ.ទ ត្រូវតែចាត់វិធានការការពារសន្តិសុខតាមបច្ចេកវិទ្យាព័ត៌មាន ឬសន្តិសុខសាយប័រ និងសុវត្ថិភាពនានានៃទិន្នន័យ CamDigiKey និងប្រតិបត្តិការលើ CamDX ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាព និងគណៈកម្មាធិការដែលមានសមត្ថកិច្ចលើបច្ចេកវិទ្យាព័ត៌មាន ដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[119]

**២.១.២.២. ចំពោះសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា**

សមាជិក ថ.ផ.ទ ត្រូវធានាបានថា ប្រព័ន្ធរបស់ខ្លួននឹងប្រព្រឹត្តទៅដោយសុវត្ថិភាពខ្ពស់ ហើយមិនអាចធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធដទៃផ្សេងលើបណ្តាញឌីជីថលនៃថ្នាល ថ.ផ.ទ ឡើយ។ ក្នុងករណី បើប្រព័ន្ធរបស់សមាជិក ថ.ផ.ទ ណាមួយមានបញ្ហា (ភាគីបង្ក) ដោយមិនបានគោរពតាមវិធាន និងនីតិវិធី ឬតាមការណែនាំរបស់ប្រតិបត្តិករ ថ.ផ.ទ ឬក៏មានបញ្ហាណាមួយ ដែលបង្កផលប៉ះពាល់ដល់ប្រព័ន្ធរបស់សមាជិកដទៃ (ភាគីរងការប៉ះពាល់) នោះ ភាគីបង្កត្រូវទទួលខុសត្រូវចំពោះការខាតបង់ និង/ឬ បន្ទុកដោះស្រាយបញ្ហា។[120] សមាជិក ថ.ផ.ទ ទាំង២ប្រភេទត្រូវមានតួនាទី និងភារកិច្ចដូចមានចែងក្នុងវិធាន។[121]

ការអនុវត្តមួយចំនួនដែលមានលក្ខណៈថ្មីស្រឡាងពេក តែងតែជួបផលវិបត្តិទៅលើសុវត្ថិភាពបច្ចេកវិទ្យាដែលកំពុងដាក់ដំណើរការណ៍នៅលើខ្សែបន្ទាត់មួយ ឬថ្នាលមួយ។ ដើម្បីអាចធានាកិច្ចគាំពារយន្តការសុវត្ថិភាព និងប្រសិទ្ធភាពលើប្រតិបត្តិការ ថ.ផ.ទ គឺរាល់សមាជិកត្រូវមានឆន្ទៈ និងសុចរិតភាពក្នុងការអនុវត្តប្រកបដោយស្មារតីបុរេសកម្មដូចខាងក្រោម៖

១.ត្រូវមានវិធានការសន្តិសុខ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរៀងៗខ្លួនក្នុងការការពារ និងទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដែលប៉ះពាល់ដល់ប្រក្រតីភាពនៃដំណើរការផ្លាស់ប្តូរទិន្នន័យលើ ថ.ផ.ទ និងទិន្នន័យផ្ទាល់ខ្លួនរបស់ឯកជន ដែលបានការពារស្របច្បាប់, ២.ត្រូវរៀបចំយន្តការត្រួតពិនិត្យផ្ទៃក្នុង ដែលមានប្រសិទ្ធភាព និងការត្រូវរៀបចំឱ្យមានការត្រួតពិនិត្យ និងវាយតម្លៃលើសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមការចាំបាច់របស់ស្ថាប័នជំនាញ, ៣.រៀបចំប្រព័ន្ធប្រតិបត្តិការនៅកន្លែងមានសុវត្ថិភាព ការពារឱ្យបានរឹងមាំ ដើម្បីរក្សានូវជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់ ជាពិសេស រាល់ប្រតិបត្តិការនៅលើ ថ.ផ.ទ, ៤.ត្រូវមានមូលធនមនុស្ស

[118] អនុក្រឹត្យស្តីពីការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា, លេខ២០៧អនក្រ.បក, ២៦ កក្កដា ២០២៣, មាត្រា៣៤, (ពីពេលនេះតទៅហៅថា អនុក្រឹត្យ CamDigiKey)។ និងអនុក្រឹត្យស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, លេខ២៥២អនក្រ.បក, ២២ ធ្នូ ២០២១, មាត្រា១៧, (ពីពេលនេះតទៅហៅថា អនុក្រឹត្យសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល)។

[119] អនុក្រឹត្យ CamDigiKey, មាត្រា២៥, ២៦ និង២៧។ និងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា២២ និង២៤។ ពាក្យថា សន្តិសុខសាយប័រ (Cybersecurity) ជាការអនុវត្តការពារកុំព្យូទ័រ ម៉ាស៊ីនមេ ឧបករណ៍ចល័ត ប្រព័ន្ធអេឡិចត្រូនិក បណ្តាញឥតខ្សែ និងទិន្នន័យសំខាន់ៗនានាពីការវាយប្រហារតាមបច្ចេកវិទ្យា, ឬអាចហៅថា សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ឬសន្តិសុខព័ត៌មានអេឡិចត្រូនិក។

[120] អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា២៣។ ពាក្យថា អត្តសញ្ញាណឌីជីថល (Digital Idenity) ជាព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណបុគ្គលក្នុងពិភពឌីជីថល ដែលព័ត៌មាននេះបានភ្ជាប់ទៅនឹងអត្តសញ្ញាណបុគ្គលនៅក្នុងពិភពពិត ស្របតាមច្បាប់ជាធរមាន។

[121] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៨។ និងអនុក្រឹត្យ CamDigiKey, មាត្រា៣១។

និងឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ សម្រាប់ដំណើរការប្រព័ន្ធឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព, ៥. រៀបចំផែនការសង្គ្រោះបន្ទាន់ រួមទាំងមធ្យោបាយសម្រាប់ការរក្សាទុក និងសង្គ្រោះទិន្នន័យ កុំឱ្យបាត់បង់ដោយថាហេតុ, ៦.ប្រតិបត្តិការអាចផ្អាកបណ្ដោះអាសន្នក្នុងករណីប្រធានសក្តិ ដាច់ចរន្តបណ្តាញ ឬអគ្គិសនី, និង៧.រៀបចំយន្តការតាមដាន និងទប់ស្កាត់ប្រតិបត្តិការក្លែងបន្លំ ព្រមទាំងយុទ្ធសាស្ត្រក្នុងការកំណត់ និងបង្ការហានិភ័យ និង/ឬយន្តការសុវត្ថិភាពផ្សេងទៀត។[122]

សមាជិកទាំងពីរប្រភេទនៃ ថ.ផ.ទ ដែលជាម្ចាស់ទិន្នន័យដើម អាចកំណត់កម្រៃសេវាតាមការចាំបាច់ ក្នុងប្រតិបត្តិការនៃការទាញយកទិន្នន័យពីសមាជិក ថ.ផ.ទ ផ្សេងដែលជាអ្នកទទួលទិន្នន័យតាមប្រភេទនោះ, និងអាចយកកម្រៃសេវាសាធារណៈពីអ្នកប្រើប្រាស់ (ប្រជាពលរដ្ឋ) ក្នុងតម្លៃណាមួយដែលបានកំណត់ ជាពិសេសសមាជិកដោយស្វ័យប្រវត្តិ។ ឧទាហរណ៍. ក្រសួង ដ.ន.ស យកតម្លៃស្នើសុំពិនិត្យព័ត៌មានអេឡិចត្រូនិកលើបណ្ណ, តម្លៃវាស់វែងក្បាលដី, តម្លៃសេវាចុះបញ្ជីដំបូង, តម្លៃផ្ទេរកម្មសិទ្ធិប្លង់រឹង និងខាងពន្ធដារ ជាអាទិ៍។ កម្រៃសេវាដែលបានមកពីប្រតិបត្តិការលើ ថ.ផ.ទ ឬចំណូលផ្សេងៗទៀតរបស់ ថ.ផ.ទ គឺជាចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។[123]

## ២.២. ប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនឌីជីថល (CamDigiKey)

ភាពងាយស្រួលបន្ថែមដល់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល រាជរដ្ឋាភិបាលកម្ពុជា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំប្រតិបត្តិករ ថ.ផ.ទ នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មី "តេជោ" បង្កើតឱ្យមានថ្នាល CamDigiKey នៅក្នុងឆ្នាំ២០១៩ ដំបូងជាប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណសម្រាប់ការចូលទៅប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន សហការជាមួយក្រសួងពាណិជ្ជកម្ម។ ក្រោយមកថ្នាលនេះ ត្រូវបានប្រើប្រាស់នៅក្នុងថ្នាលធុរកិច្ចថ្មីកម្ពុជានៃប្រព័ន្ធ "ទេពកោសល្យសម្រាប់សេដ្ឋកិច្ចឌីជីថល" និងប្រព័ន្ធដាក់ពាក្យស្នើសុំចូលបម្រើការងារនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ បច្ចុប្បន្ន ថ្នាល CamDigiKey ត្រូវបានដាក់ឱ្យប្រើប្រាស់ផ្លូវការដល់សាធារណជនទូទៅ ទាំងរូបវន្តបុគ្គល, នីតិបុគ្គល, ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ដែលកំពុងតែពង្រីកមុខងារបន្ថែមថ្មី តាមរយៈការស្កេនឃ្យូ អរ កូដស្តង់ដារ នៅតាមបណ្តាសេវាសាធារណៈ ដែលមានគេហទំព័រ https://camdigikey.gov.kh/kh ។

ថ្នាល CamDigiKey បានធ្វើការតភ្ជាប់ពីប្រព័ន្ធថ្នាល CamDX ដើម្បីសម្រួលដល់ការរត់នៅតាមបណ្តាញសេវាសាធារណៈ ជំនួយដល់ការផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គល ដែលអ្នកប្រើប្រាស់បានបង្កើតគណនីថ្មី។ អ្នកប្រើប្រាស់ សំដៅដល់ប្រជាពលរដ្ឋទូទៅដែលបានដាក់ស្នើសុំគណនីអនឡាញ ដោយផ្ទៀងផ្ទាត់លើអត្តសញ្ញាណបណ្ណទទួលស្គាល់ដោយរាជរដ្ឋាភិបាល។ ការចុះឈ្មោះ ការចុចចូល និង/ឬ ការប្រតិបត្តិលើប្រព័ន្ធបណ្តាញបច្ចេកវិទ្យាណាមួយ ប្រជាជនគ្រប់រូបៗត្រូវតែគោរពចំពោះទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន។[124]ទ្រព្យសាធារណៈនៅទីនេះ សំដៅលើទ្រព្យសាធារណៈអេឡិចត្រូនិកដែលជា ទិន្នន័យព័ត៌មានផ្ទាល់

[122] វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ២០២២, ៩។ និងអនុក្រឹត្យសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, មាត្រា៩, និង១៣។

[123] អនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា, មាត្រា២១។

[124] រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣, មាត្រា៥០។

ខ្លួន និងម្ចាស់ទិន្នន័យដើម ដែលត្រូវបានឆ្លបចូលវាយប្រហារ ឬគ្រប់មធ្យោបាយនានា នៅលើបណ្ដាញអ៊ីនធឺណិត ឬក៏សកម្មភាពអាណាធិបតេយ្យលើប្រព័ន្ធរណប (Statellite Hack) ដើម្បីទាញផលប្រយោជន៍ពីសាធារណៈ មកជាផលប្រយោជន៍បុគ្គល ឬក្រុមដោយទុច្ចរិត។ ក្នុងបរិការណ៍នេះ ក៏អាចសំដៅដល់កម្មសិទ្ធិលើអចលនវត្ថុ ដែលប្រតិបត្តិការនៅលើអនឡាញផងដែរ។ ព័ត៌មានអត្តសញ្ញាណកម្មបុគ្គល សិទ្ធិបុគ្គលឯកជនភាព (Privacy) និងសិទ្ធិប្រើប្រាស់បណ្ដាញព័ត៌មានវិទ្យារបស់ប្រជាពលរដ្ឋខ្មែរ គឺត្រូវបានគាំពារដោយច្បាប់យ៉ាងតឹងរ៉ឹង។[125]

អត្តសញ្ញាណបុគ្គល ឬអត្តសញ្ញាណបុគ្គលជាទម្រង់ឌីជីថល ក៏មានអត្ថន័យ និងលក្ខណៈបុគ្គលភាពគតិយុត្តស្មើនឹងអត្តសញ្ញាណអតិថិជនឌីជីថល ផងដែរ ដោយការប្រើប្រាស់អត្តសញ្ញាណបណ្ណតែមួយ។ ការប្រមូលយកព័ត៌មាន ដើម្បីអាចកំណត់អត្តសញ្ញាណលើបុគ្គលណាម្នាក់ ដោយតម្រូវឱ្យប្រជាពលរដ្ឋអនុវត្តទៅតាមនីតិវិធីចុះឈ្មោះអត្តសញ្ញាណឌីជីថល (២.២.១) និងបណ្ដាក្រសួង ស្ថាប័ន អង្គភាព ដែលបានមកពីមូលដ្ឋានទិន្នន័យក្នុងការប្រមូលប្រកបដោយបរិយាបន្នសង្គម (២.២.២)។

### ២.២.១. ការចុះឈ្មោះអត្តសញ្ញាណឌីជីថល

សមត្ថកិច្ចសំខាន់នៃការគ្រប់គ្រងអត្តសញ្ញាណកម្មលើប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺជាភារកិច្ចក្រសួងមហាផ្ទៃ។ អត្តសញ្ញាណបុគ្គលឌីជីថល អាចមានអត្ថិភាពទៅបានក្នុង៣ករណី ៖ ទី១. ថ្នាលរបស់ CamDigiKey មិនមែនជាអត្តសញ្ញាណឌីជីថលពិតមែន ប៉ុន្តែ បើសម្លឹងមើលមួយជ្រុង រាល់ទិន្នន័យប្រជាពលរដ្ឋបានចុះអត្តសញ្ញាណលក្ខណៈឌីជីថល Log-in ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈថ្នាលនេះ គឺជាបច្ច័យមួយ ជាប្រយោជន៍ដល់ក្រសួងមហាផ្ទៃ ដែលក្រសួងអាចប្រើប្រាស់ និងកែតម្រូវទិន្នន័យអត្តសញ្ញាណបុគ្គលដែលបានមកពីប្រភពនានា។[126] ដោយងាយយល់មានន័យថា ក្រសួងមហាផ្ទៃ ជាសមាជិកដោយស្វ័យប្រវត្តិរបស់ថ្នាល ថ.ផ.ទ. អាចប្រើប្រាស់កូនថ្នាល CamDigiKey ជាអ្នកប្រមូលអត្តសញ្ញាណបុគ្គលមួយផ្នែក តាមរយៈប្រតិបត្តិការ និងធ្វើការផ្ទៀងផ្ទាត់ យកមកជាប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន បែបថ្នាលឌីជីថល។ វិធីនេះ ដែលអាចអនុញ្ញាតឱ្យក្រសួងស្ថាប័នវិស័យសាធារណៈប្រើប្រាស់ផលប្រយោជន៍សេវាសាធារណៈ។[127] និងទី២. ក្រសួងមហាផ្ទៃប្រមូល ចងក្រងលេខអត្តសញ្ញាណបុគ្គលម្នាក់ៗ(UIC) ក្នុងទិន្នន័យរបស់ខ្លួន បញ្ចូលក្នុងផតថលដោយស្វ័យប្រវត្តិក្នុងអន្តរប្រតិបត្តិការ ថ.ផ.ទ អនុញ្ញាតឱ្យសមាជិកទាំង២ប្រភេទ គឺអាចប្រើប្រាស់ស្របច្បាប់ចំពោះទិន្នន័យបុគ្គល។[128] ក្រសួងមហាផ្ទៃ ក៏មានភារកិច្ចចូលរួមផ្ដល់ទិន្នន័យមួយចំនួន ចំពោះទិន្នន័យអត្តសញ្ញាណបុគ្គល ទៅកាន់ថ្នាល CamDigiKey វិញផងដែរ។ ទី៣. ការចុះលេខកូដអត្តសញ្ញាណបុគ្គល (UIC) ទៅកាន់បុគ្គលគ្រប់រូបដែលបានកើតនៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា ជាអចិន្ត្រៃយ៍ និងសម្រាប់ប្រើប្រាស់រហូតដល់បុគ្គលនោះទទួលមរ-

---

125 អនុក្រឹត្យសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, មាត្រា១១ និង១៤។

126 ដដែល, មាត្រា៥។ ពាក្យថា ម្ចាស់ទិន្នន័យដើម (Original Data Owner) សំដៅដល់ក្រសួង ស្ថាប័នដែលមានសិទ្ធិអំណាចពេញលេញកាន់កាប់ទិន្នន័យរបស់ខ្លួន និងដែលមានសមត្ថកិច្ចក្នុងការធ្វើបច្ចុប្បន្នភាពទិន្នន័យ, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថល។

127 ដដែល, មាត្រា៨(១) និង(២)។

128 ពាក្យថា អន្តរប្រតិបត្តិការ (Interoperability) សំដៅដល់សមត្ថភាពនៃប្រព័ន្ធឌីជីថល ដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និងការប្រើប្រាស់ទិន្នន័យ ជាទូទៅកើតឡើងដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌកំណត់, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថល។

ណភាព។[129] បរិការណ៍នេះ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ ដើម្បីឱ្យបុគ្គលគ្រប់រូបអាចទទួលបានក្នុងទម្រង់អត្តសញ្ញាណឌីជីថល។[130]

ប្រព័ន្ធអនុវត្តទាំង៣ករណីនេះ នឹងប្រែក្លាយអត្តសញ្ញាណបុគ្គលម្នាក់ៗ ឬអត្តសញ្ញាណប្រជាជនទៅជាអត្តសញ្ញាណប្រជាជនឌីជីថល ឬប្រព័ន្ធទិន្នន័យបុគ្គល ទៅក្នុងទិន្នន័យមូលដ្ឋាន។ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ផ្តល់ជាគន្លឹះជំរុញឱ្យការអនុវត្តឌីជីថលលើសូចនាករចំនួន៩ និងផ្តល់ឱកាសទៅដល់ក្រសួង ស្ថាប័ន អង្គភាពដែលទទួលបន្ទុកអាចយកទៅបំបែកជាបន្តបន្ទាប់ ដូចមានបញ្ជាក់ក្នុងតារាងទី៧ខាងក្រោម។

| **អង្គភាពទទួលបន្ទុក** | **សូចនាករ** | **គោលបំណង** | **ប្រភពទិន្នន័យ** | **រាយការណ៍** |
|---|---|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ចំនួនសមាជិកសរុបរបស់ CamDX | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺដើម្បីគាំទ្រ និងជំរុញដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេវិទ្យាព័ត៌មាន | ទិន្នន័យបញ្ជីឈ្មោះសមាជិក | ប្រចាំត្រីមាស |
| | ចំនួនសមាជិកសរុបរបស់ CamDigiKey | ដូចគ្នាខាងលើ | ក្របខណ្ឌ CamDigiKey | ប្រចាំត្រីមាស |
| | ចំនួនប្រជាជនសរុប ដែលមានអត្តសញ្ញាណឌីជីថល | ដូចគ្នាខាងលើ | ទិន្នន័យអត្តសញ្ញាណឌីជីថល | ប្រចាំត្រីមាស |
| | មុខងារបើកប្រាក់បៀវត្សតាមប្រព័ន្ធអេឡិចត្រូនិក | ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | របាយការណ៍ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ក្រសួងមហាផ្ទៃ | ចំនួនស្ថាប័នដែលមានការបម្រើសេវាសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺដើម្បីគាំទ្រ និងជំរុញដល់ការប្រើប្រាស់ប្រព័ន្ធបច្ចេវិទ្យាព័ត៌មាន | របាយការណ៍បម្រើសេវាសាធារណៈ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ប្រចាំត្រីមាស |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំនួនប្រជាជនដែលមានអត្តសញ្ញាណឌីជីថលដើម្បីចូលប្រើប្រាស់សេវាសាធារណៈតាមអនឡាញ | ដូចគ្នាខាងលើ | ទិន្នន័យអត្តសញ្ញាណឌីជីថល | ប្រចាំត្រីមាស |

[129] អនុក្រឹត្យ CamDigiKey, មាត្រា៦។ ពាក្យថា ទិន្នន័យមូលដ្ឋាន (Database) សំដៅដល់បណ្តុំនៃទំនាក់ទំនងទិន្នន័យ ឬព័ត៌មានដែលរក្សាទុកក្នុងកុំព្យូទ័រតាមវិធីណាមួយ ដោយក្នុងនោះបានផ្តល់ភាពងាយស្រួលក្នុងការពិនិត្យមើលបំពេញបន្ថែម ស្វែងរក ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ, ក្នុងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា។

[130] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា១៤២, (ពីពេលនេះតទៅហៅថា ច្បាប់អត្រានុកូល២០២៣)។

| | | | | |
|---|---|---|---|---|
| | ចំនួនផតថលរដ្ឋាភិបាលសម្រាប់បម្រើទៅដល់សេវាសាធារណៈ | ដូចគ្នាខាងលើ | របាយការណ៍ផតថលរបស់រដ្ឋាភិបាល | ប្រចាំត្រីមាស |
| ក្រសួងពាណិជ្ជកម្ម | ចំនួនសហគ្រាសដែលបានប្រើប្រាស់សេវាស្វែងរកដំណោះស្រាយឌីជីថល | ការគាំទ្រសហគ្រិនភាពរបស់សហគ្រាសនៅក្នុងគ្រប់វិស័យ និងគ្រប់ទំហំ | របាយការណ៍វឌ្ឍនភាពរបស់សេវាកម្ម | ប្រចាំត្រីមាស |
| | កម្រិតពេញចិត្តការទទួលយកសេវាឌីជីថល | ដូចគ្នាខាងលើ | មតិយោបល់លើគុណភាពសេវា | ប្រចាំត្រីមាស |

តារាងទី៧. សូចនាករគន្លឹះជំរុញការអនុវត្តឌីជីថល

### ២.២.១.១. សមត្ថភាពចុះបញ្ជីទិន្នន័យបុគ្គល

នាបច្ចុប្បន្ន ថ្នាល CamDigiKey, eKYC ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល ត្រូវបានប្រើប្រាស់ជំនួសឱ្យការសម្គាល់ទៅលើអត្តសញ្ញាណអតិថិជន ឬក៏បុគ្គលណាម្នាក់ តាមបែបប្រពៃណី ដែលជាដំណើរការកំណត់អត្តសញ្ញាណបុគ្គល ដោយប្រើប្រាស់ឯកសារជាក្រដាស ដូចជានៅក្នុងវិស័យពាណិជ្ជកម្ម ធនាគារ ជាដើម មកជាទម្រង់ឌីជីថល។ ប្រព័ន្ធ eKYC ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អតិថិជន ដោយប្រើប្រាស់ឯកសារទម្រង់ឌីជីថល, ព័ត៌មានជីវមាត្រ និងដំណើរការផ្ទៀងផ្ទាត់ផ្សេងទៀត។ ប្រព័ន្ធ eKYC អាចត្រូវបានបង្កើត និងផ្តល់ជាដំណោះស្រាយឌីជីថលដោយអ្នកផ្តល់សេវាកម្មនានាក្នុងវិស័យសាធារណៈ និងវិស័យឯកជន ទៅតាមតម្រូវការ ចំណេញទាំងពេលវេលា និងថវិកា។[131] ប្រទេសកម្ពុជា នៅមិនទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ក្នុងការការពារទិន្នន័យ និងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នៅលើប្រព័ន្ធឌីជីថលឡើយ។ ដោយសារការផ្តល់និយមន័យពាក្យថា ទិន្នន័យបុគ្គល គឺនៅមិនទាន់ជជែក ត្រូវគ្នានៅឡើយ។ ហេតុផល ដោយសារប្រើប្រាស់ពាក្យបច្ចេកទេសក្នុងន័យរួម មានលក្ខណៈទូលាយពេកក្នុងការអនុវត្ត និងប្រើបានច្រើនបែបពេកក្នុងភាសាខ្មែរ ហើយនិយមន័យក៏បានផ្តល់ឱ្យផ្សេងៗគ្នា និងទៅតាមលក្ខខណ្ឌច្បាប់របស់ប្រទេសផ្សេងៗ ផងដែរ។

ព័ត៌មានរបស់អតិថិជន ឬទិន្នន័យបុគ្គល នៅទីនេះសំដៅដល់បុគ្គលណាម្នាក់ ក្នុងការសម្គាល់ពីគោត្តនាម និងនាម, លេខអត្តសញ្ញាណបណ្ណ, ថ្ងៃខែឆ្នាំកំណើត, ទីកន្លែងកំណើត, អាសយដ្ឋាននា បច្ចុប្បន្ន, លេខទូរសព្ទ និងអំពីព័ត៌មានផ្សេងៗទៀត ដែលមិនត្រូវបានអនុញ្ញាតឱ្យផ្សព្វផ្សាយជាសាធារណៈឡើយ ក្រៅពីសាមីខ្លួនផ្ទាល់

[131] ពាក្យថា ព័ត៌មានជីវមាត្រ (Biometric Information) ជាការវាស់ស្ទង់លក្ខណៈជីវសាស្ត្រ និងលក្ខណៈផ្សេងទៀត ដូចជា ស្នាមខ្សែដៃ ប្រស្រីភ្នែក មុខ ហត្ថលេខា ឬសម្លេង ជាអាទិ៍ ដែលអាចប្រមូលបានដោយឌីជីថល និងត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ, ក្នុងសេចក្តីព្រាងច្បាប់អគ្រានុកូល២០២៣។ រីឯពាក្យថា ទម្រង់អេឡិចត្រូនិក (Electronic Platform) សំដៅដល់ព័ត៌មាន ឬទិន្នន័យដែលអាចយកមកដំណើរការដោយកុំព្យូទ័រ ធ្វើការកែប្រែ និងការចែករំលែករវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ចំណែកឯពាក្យថា ឯកសារទម្រង់ឌីជីថល (Digital Document) ជាឯកសារដែលមានទម្រង់ទៅជា Portable Document Format (PDF) ឬរូបភាពសម្រាប់ប្រើប្រាស់ជាឯកសារយោង ឬភ្ជាប់ដែលបានស្កេន ឬថតចេញពីឯកសាររូបី ឬឯកសារដែលមានទម្រង់ទៅជា PDF ឬរូបភាពដែលប្រើប្រាស់សម្រាប់បោះពុម្ពប្រើប្រាស់ជាផ្លូវការបាន។

និងអាជ្ញាធរមានសមត្ថកិច្ច។[132]

អត្តសញ្ញាណឌីជីថល ផ្តោតទៅលើតំណាងនៃអត្តសញ្ញាណបុគ្គលម្នាក់ណាមួយ ក្នុងលំហឌីជីថល។ អត្តសញ្ញាណឌីជីថលអាចក្តោបដំណើរការលើមុខងារទំនើបបំផុត រួមមានការសម្គាល់លើព័ត៌មានទាក់ទងទៅនឹងទិន្នន័យផ្ទាល់ខ្លួន, លក្ខណៈសម្បត្តិបុគ្គល និងព័ត៌មានបញ្ជាក់អត្តសញ្ញាណទាំងឡាយដែលអាចសម្គាល់ភាពដាច់ដោយឡែករបស់បុគ្គលណាមួយ ក្នុងការធ្វើប្រតិបត្តិការ និងការប្រើប្រាស់សេវាកម្មតាមប្រព័ន្ធអនឡាញ។ អត្តសញ្ញាណឌីជីថល មានវិសាលភាពទូលំទូលាយជាងដំណើរការសម្គាល់ និងការកំណត់អត្តសញ្ញាណតាមប្រព័ន្ធអនឡាញរបស់ប្រព័ន្ធ eKYC និងរួមបញ្ចូលទាំងក្នុងការគ្រប់គ្រង និងការប្រើប្រាស់ជារួមនៃអត្តសញ្ញាណរបស់បុគ្គលជាទម្រង់ឌីជីថលនៅលើថ្នាលផ្សេងៗ។ និយាយក្នុងន័យចង្អៀត ប្រព័ន្ធ eKYC មិនមែនជាអត្តសញ្ញាណឌីជីថលឡើយ ដោយគ្រាន់តែជាបច្ចេកវិទ្យាជំនួយដល់ការផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គលជាក់លាក់ និងត្រឹមត្រូវស្របតាមច្បាប់កំណត់។[133]

អត្តសញ្ញាណឌីជីថល គឺត្រូវបានផ្តល់ និងគ្រប់គ្រងដោយរាជរដ្ឋាភិបាល ចាត់ថាជាទិន្នន័យគោល។ ប្រព័ន្ធ eKYC និងអត្តសញ្ញាណឌីជីថល មានភាពខុសគ្នា។ ពោលគឺ ប្រព័ន្ធ eKYC គឺជាផ្នែក ឬមុខងារមួយដែលស្ថិតក្រោមវិសាលភាពនៃអត្តសញ្ញាណឌីជីថល។[134] ប្រព័ន្ធ eKYC អាចត្រូវបានបង្កើតឡើង និងផ្តល់ឱ្យដោយអ្នកផ្តល់សេវាផ្សេងៗជាច្រើន ដើម្បីបម្រើសេវាកម្មទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ ដោយឡែក បុគ្គលម្នាក់អាចមានអត្តសញ្ញាណឌីជីថលតែមួយគត់ ដែលត្រូវបានផ្តល់ឱ្យដោយរាជរដ្ឋាភិបាលនៃក្រសួងមហាផ្ទៃ និងអាចយកទៅប្រើប្រាស់តាមគោលបំណងផ្ទាល់ខ្លួន ក្នុងការតំណាងឱ្យអត្តសញ្ញាណរបស់ខ្លួនដោយស្របច្បាប់ជាទម្រង់ឌីជីថល។ ឧទាហរណ៍. លោក ក ទទួលបានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) តែមួយគត់ ដោយគ្មានជនណាម្នាក់អាចថ្លោះសិទ្ធិ ឬប៉ះពាល់បានឡើយ។ ដូចនេះ លោក ក ចង់ចូលប្រើប្រាស់សេវាសាធារណៈអេឡិចត្រូនិកណាមួយ នោះ eKYC នឹងអាចស្គេនដឹងច្បាស់ថាពិតជាអត្តសញ្ញាណលោក ក។

ការប្រើប្រាស់លើថ្នាល CamDigiKey គឺអនុញ្ញាតមនុស្សម្នាក់ មានអត្តសញ្ញាណមួយ មានគណនីមួយ។

---

132 The Phnom Penh Post, "Who Wants Some Protection for Personal Data?," [ជនណាខ្លះចង់ការការពារទិន្នន័យបុគ្គល?], (2023) https://www.phnompenhpost.com/opinion/who-wants-some-protection-for-personal-data-
និងប្រភពមួយទៀត៖ *EU*, https://commission.europa.eu/aid-development-cooperation-fundamental-rights/your-rights-eu/know-your-rights/freedoms/protection-personal-data_en (ទស្សនាចុងក្រោយថ្ងៃទី១ ឧសភា ២០២៤)។

133 Bajaj Finserv, "What is eKYC" [អ្វីជា eKYC], (2023), https://www.bajajfinserv.in/insights/what-is-ekyc (ទស្សនាចុងក្រោយថ្ងៃទី២៩ មីនា ២០២៤)។ និងអនុក្រឹត្យសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, មាត្រា៣។

134 ពាក្យថា ទិន្នន័យគោល (Base Registry) សំដៅដល់ទិន្នន័យមូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចជាម្ចាស់ទិន្នន័យដើម ហើយមានតែម្ចាស់ទិន្នន័យដើមទេ ដែលមានសិទ្ធិធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនោះស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលមានជាអាទិ៍ ទិន្នន័យអត្រានុកូលដ្ឋាន ទិន្នន័យបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែន បណ្ណបើកបរ បណ្ណរបបសន្តិសុខសង្គម បសស) ទិន្នន័យយានយន្ត ទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទិន្នន័យធុរកិច្ច ទិន្នន័យអចលនវត្ថុ ទិន្នន័យភូមិសាស្ត្រ ទិន្នន័យចំណូលសារពើពន្ធ និងមិនមែនជាសារពើពន្ធ ទិន្នន័យអប់រំ ទិន្នន័យកិច្ចការងារ ទិន្នន័យធានារ៉ាប់រង ទិន្នន័យរបបសន្តិសុខសង្គម ទិន្នន័យសុខាភិបាល និងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្នុងអនុក្រឹត្យថ្នាលទិន្នន័យកម្ពុជា។

មនុស្សម្នាក់មានសិទ្ធិទទួលបានគណនី CamDigiKey តែមួយប៉ុណ្ណោះ ដែលព័ត៌មានទាំងអស់នៅក្នុងគណនីឆ្លុះបញ្ចាំងពីអត្តសញ្ញាណពិតប្រាកដរបស់ម្ចាស់គណនី។ ការចុះឈ្មោះ Log-in ចូលតែម្តង អាចប្រើប្រាស់សេវាកម្មជាច្រើន មិនចាំបាច់ Log-in ច្រើនដង ដដែលៗនោះទេ ហើយអ្នកប្រើប្រាស់មិនតម្រូវឱ្យចងចាំឈ្មោះគណនី Username និង Password ច្រើន សម្រាប់គណនីអនឡាញនីមួយៗ ដែលអ្នកប្រើប្រាស់មាននោះដែរ។ មានសិទ្ធិក្នុងការចូលទៅប្រើប្រាស់សេវាកម្មឌីជីថលជាច្រើនរបស់ក្រសួង ស្ថាប័ន អង្គភាព ដោយប្រើប្រាស់តែថ្នាល CamDigiKey នោះអ្នកប្រើប្រាស់នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីសេវាកម្មឌីជីថលទាំងនោះ។ ករណីអ្នកប្រើប្រាស់មិនបានចុះឈ្មោះ Log-in នោះមិនអាចប្រើប្រាស់បានទេ ប្រសិនបើគ្មានគណនី CamDigiKey។ ពិព្រោះ នៅលើថ្នាលនេះ ជាខ្សែបណ្តាញតភ្ជាប់ទៅនឹងថ្នាលឌីជីថល ថ.ផ.ទ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលហៅថាជា ថ្នាលគ្រឹះឌីជីថល។[135] ម្ចាស់គណនី ក៏មានសិទ្ធិដឹងព័ត៌មានអំពីសកម្មភាពការប្រើប្រាស់ទិន្នន័យអត្តសញ្ញាណ និងទិន្នន័យផ្ទាល់ខ្លួន ផងដែរ។[136]

នាពេលបច្ចុប្បន្ន ថ្នាល CamDigiKey បានអនុញ្ញាតឱ្យអ្នកប្រើប្រាស់មានសិទ្ធិ អាចចូលទៅប្រើប្រាស់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល និងអាចបំពេញពាក្យអនឡាញប្រឡងក្របខណ្ឌរដ្ឋ ឬវិជ្ជាជីវៈនានា។ ជាក់ស្តែងនាចុងឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បើកដំណើរការបំពេញពាក្យប្រឡងតាមថ្នាល CamDigiKey ដំបូងបំផុត ក្រោយមក ការបង្កើតវិញ្ញាសារអនឡាញភ្លាមៗនៃការប្រឡងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាបច្ចេកទេសដោយសេនាធិការរបស់ខាងក្រសួងមុខងារសាធារណៈ។ ប្រព័ន្ធគោលសំខាន់ៗ មានដូចជា៖ ១. ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (សម្រាប់ការចុះបញ្ជីអាជីវកម្ម, ចុះបញ្ជី, ពន្ធដារ និងការត្រួតពិនិត្យ, ទទួលសេចក្តីប្រកាសជូនដំណឹងការបើកសហគ្រាស), ២. ប្រព័ន្ធស្នើសុំប្រកាសបង្កើតសហគ្រាសធុនតូច និងមធ្យម (ផតថលសម្រាប់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់សហគ្រាសធុនតូច និងមធ្យម), ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (ក. អាជ្ញាទេសចរណ៍សម្រាប់ការីទេសចរណ៍និងភ្នាក់ងារទេសចរណ៍, ខ. អាជ្ញាបណ្ណទេសចរណ៍សម្រាប់សណ្ឋាគារនិងសេវាស្នាក់នៅទេសចរណ៍, គ. អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋានអាហារ), ៣.ប្រព័ន្ធផ្តល់សេវាសាធារណៈឌីជីថលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ផតថលសម្រាប់ការស្នើសុំ ក. អាជ្ញាបណ្ណ/វិញ្ញាបនបត្រ/ លិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការលើបច្ចេកវិទ្យាទូរគមនាគមន៍, ខ. អាជ្ញាបណ្ណ/វិញ្ញាបនបត្រ/ លិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការលើសេវាប្រៃសណីយ៍), ៤. ប្រព័ន្ធផ្តល់សេវាសាធារណៈនៃនិយ័តករអាជីវកម្មអចលនទ្រព្យ និងបញ្ចាំ (អាជ្ញាបណ្ណអាជីវកម្មទទួលបញ្ចាំ និងអាជ្ញាបណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន), ៥. ថ្នាលធុរកិច្ចថ្មីកម្ពុជា (ជាកម្មវិធីថ្នាក់ជាតិ ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាបេសកកម្មគាំទ្រធុរកិច្ចថ្មីក្នុងស្រុក និងជំរុញការកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅកម្ពុជា), ៦. ប្រព័ន្ធទេពកោសល្យ

[135] ពាក្យថា ថ្នាលគ្រឹះឌីជីថល (Digital Enabler) ជាថ្នាលបច្ចេកវិទ្យាជាមូលដ្ឋានគ្រឹះ ឬជាឆ្អឹងខ្នងដែលជាឃ្នាស់ជួយសម្រួល និងបម្រើដល់ការបង្កើត និងរៀបចំគំនិតច្នៃប្រតិដ្ឋថ្មីៗដោយការប្រើប្រាស់បច្ចេកវិទ្យា និងនាវានុវត្តន៍, ក្នុងអនុក្រឹត្យធុរកិច្ចថ្មី "តេជោ"។ រីឯពាក្យថា យថាភូតភាព (Authenticity) ជាការ បញ្ជាក់អត្តសញ្ញាណអ្នកប្រើប្រាស់កុំព្យូទ័រក្នុងគោលបំណងសន្តិសុខដោយការផ្ទៀងផ្ទាត់ (ឈ្មោះ, លេខសម្ងាត់ កាត ក្រយៅដៃ សម្លេង ភ្នែក មុខ ជាអាទិ៍, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា...។

[136] អនុក្រឹត្យថ្នាល CamDigiKey, មាត្រា១៨(២)។

សម្រាប់ស្នើសុំចូលបម្រើការងារសេដ្ឋកិច្ចឌីជីថល, និង៧. ប្រព័ន្ធដាក់ពាក្យស្នើចូលបម្រើការងារអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងសេវាសាធារណៈឌីជីថលជាច្រើនទៀត។[137]

### ២.២.១.២. សមត្ថភាពផ្ទៀងផ្ទាត់ទិន្នន័យរបស់ប្រព័ន្ធព័ត៌មានវិទ្យា

ថ្នាល CamDigiKey អាចត្រូវបានយកទៅប្រើប្រាស់ជា២ប្រភេទ ៖ ទី១. អ្នកប្រើប្រាស់ជារូបវន្តបុគ្គល អាចប្រើប្រាស់ថ្នាល CamDigiKey នៅក្នុងទម្រង់ជាកម្មវិធីទូរសព្ទដៃ CamDigiKey ដើម្បីបង្កើតគណនី យកទៅផ្ទៀងផ្ទាត់ថាភូតកម្មអត្តសញ្ញាណអតិថជនឌីជីថល (eKYC Authentication) ឬជាភាសាសាមញ្ញ ចូលទៅប្រើប្រាស់ (Log-in) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ គណនី CamDigiKey តែមួយ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចផ្ទៀងផ្ទាត់ថាភូតកម្ម ជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងឡាយណា ដែលបានធ្វើសន្ធានកម្មជាមួយថ្នាល CamDigiKey។ ការផ្ទៀងផ្ទាត់ថាភូតកម្មនេះ ដើម្បីអាចកំណត់លើអត្តសញ្ញាណ (ជាបណ្ដោះអាសន្ន ឬដំណាក់កាលដំបូងក្នុងទម្រង់បច្ចេកវិទ្យាព័ត៌មាន) ពិតប្រាកដត្រឹមត្រូវ និងច្បាស់លាស់របស់អ្នកប្រើប្រាស់។ ទី២. អ្នកប្រើប្រាស់ជានីតិបុគ្គលក៏អាចស្នើប្រើប្រាស់ថ្នាល CamDigiKey ក្នុងទម្រង់សន្ធានកម្មពេញលេញ ឬសន្ធានកម្មតាមរយៈ Open APIs ផងដែរ ដើម្បីអាចប្រើប្រាស់សម្រាប់ការកំណត់អត្តសញ្ញាណអតិថិជនឌីជីថល ក្នុងន័យបម្រើដល់សេវាផ្សេងៗប្រយោជន៍ក្នុងស្ថាប័នរបស់ខ្លួន។[138] ការផ្ទៀងផ្ទាត់ថាភូតកម្មអត្តសញ្ញាណអតិថិជនឌីជីថលនៃថ្នាល CamDigiKey មិនមានអានុភាពប្រើប្រាស់ជំនួសអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែនបរទេសបាននោះទេ។ ការផ្ទៀងផ្ទាត់ថាភូតកម្ម និងការប្រើប្រាស់អត្តសញ្ញាណអតិថិជនឌីជីថលនៃ CamDigiKey ក៏មិនមែនជាភស្តុតាង ដែលបញ្ជាក់អំពីភាពជាពលរដ្ឋ ឬទីកន្លែងស្នាក់នៅនៃអតិថិជន ឬបុគ្គលនោះដែរ។[139]

ការស្នើសុំបង្កើតគណនី CamDigiKey តម្រូវឱ្យមានការផ្ដល់ទិន្នន័យពិតប្រាកដរបស់បុគ្គល សម្រាប់រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ដូចតទៅ ៖ ទិន្នន័យជីវមាត្រពាក់ព័ន្ធនឹងមុខ និងភាពរស់រវើកនៃមុខរបស់បុគ្គល, លេខអត្តសញ្ញាណបណ្ណ, ឈ្មោះជាភាសាខ្មែរ និងឈ្មោះជាអក្សរឡាតាំង, ភេទ, ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើត, លេខទូរសព្ទ និងអាសយដ្ឋានបច្ចុប្បន្នដែលមានសុពលភាព។ សម្រាប់រូបវន្តបុគ្គលមានសញ្ជាតិបរទេសវិញ ការស្នើសុំបង្កើតគណនី តម្រូវឱ្យមានការផ្ដល់ទិន្នន័យពិតប្រាកដរបស់បុគ្គល ដូចទៅនឹងរូបវន្តបុគ្គលសញ្ជាតិខ្មែរផងដែរ ដោយគ្រាន់តែបន្ថែម លិខិតឆ្លងដែន, និងអាសយដ្ឋានបច្ចុប្បន្ន ដែលរស់នៅក្នុងដែនព្រះរាជាណាចក្រកម្ពុជាមានសុពលភាព។[140] នីតិវិធីទាញយក និងស្នើសុំគណនី CamDigiKey បង្ហាញក្នុងសៀវភៅមគ្គុទ្ទេសក៍។[141]

ម្ចាស់គណនី CamDigiKey ដែលមានបំណងកែតម្រូវ ឬលុបទិន្នន័យអត្តសញ្ញាណរបស់ខ្លួននោះ ត្រូវស្នើ

[137] CamDigiKey, https://camdigikey.gov.kh/individual និង https://registrationservices.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១ ឧសភា ២០២៣), និងអាចស្វែងរកសេវាសាធារណៈឌីជីថលនានា។

[138] Open APIs, https://www.openapis.org ឬ https://swagger.io/resources/open-api/ ឬ https://github.com /OAI/OpenAPI-Specification (ទស្សនាចុងក្រោយថ្ងៃទី១ ឧសភា ២០២៣)។

[139] អនុក្រឹត្យថ្នាល CamDigiKey, មាត្រា២២។

[140] ដដែល, មាត្រា៧ និង៨។

[141] សៀវភៅមគ្គុទ្ទេសក៍ CamDigiKey, Version 2.0, ២០២២។

សុំកែតាមរយៈ CamDigiKey ទៅកាន់ប្រតិបត្តិករ ថ.ផ.ទ។ ប្រតិបត្តិករ ថ.ផ.ទ គឺមានឆន្ទានុសិទ្ធិទទួលយក ឬបដិសេធការស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យអត្តសញ្ញាណម្ចាស់គណនី CamDigiKey តាមប្រព័ន្ធ ដោយផ្អែកលើហេតុផលសមស្របតាមការស្នើសុំរបស់ម្ចាស់គណនី CamDigiKey ឬតំណាងស្របច្បាប់របស់ម្ចាស់គណនីនៃអត្តសញ្ញាណ CamDigiKey នោះ។[142] ឧទាហរណ៍. លោក ក បានប្រើប្រាស់គណនី CamDigiKey និងបានចូលទៅប្រើសេវាសាធារណៈ ក្នុងសេវាកម្មឯកជនជាច្រើន នៅលើថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល។ ក្រោយមកលោក ក ចង់ធ្វើការកែប្រែព័ត៌មានមួយចំនួន (លេខទូរសព្ទ, អ៊ីម៉ែល, អាសយដ្ឋាន ឬក៏អត្តសញ្ញាណបណ្ណផុតសុពលភាព) ឬលោកចង់លុបគណនីចោល ក្រោមហេតុផលណាមួយ, ត្រូវដាក់ស្នើទៅកាន់ប្រតិបត្តិករ ថ.ផ.ទ តាមកម្មវិធីទូរសព្ទដៃនៃ CamDigiKey នោះ។ ម្យ៉ាងវិញ តំណាងស្របច្បាប់នៅក្នុងការប្រើប្រាស់ជំនួសឱ្យម្ចាស់គណនី គឺក្នុងលក្ខខណ្ឌដែលច្បាប់សារធាតុ ឬបទដ្ឋានគតិយុត្តដោយឡែកបានកំណត់។

តំណាងស្របច្បាប់ ក្នុងការប្រើប្រាស់កម្មវិធីនេះ ក្នុងមូលហេតុម្ចាស់គណនី គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅទៅដល់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ និងជនស្ថិតក្រោមហិតូបត្ថម្ភ។[143] ចំពោះអនីតិជន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ និងបង្កើតគណនីផ្ទាល់ខ្លួនឡើយ ដោយមូលហេតុមិនទាន់មានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់នៅក្នុងការបំពេញសកម្មភាព ដែលមានកម្មវត្ថុជាសេវាសាធារណៈ ឬក្នុងតម្លៃខ្ពស់នៃកម្មវត្ថុនោះ។ ឧទាហរណ៍. ការសិក្សានេះ សំដៅលើម្ចាស់កម្មសិទ្ធិអចលនវត្ថុចូលប្រើសេវាចុះបញ្ជីកម្មសិទ្ធិដែលមានគណនី និងព័ត៌មានសម្គាល់លើអចលនវត្ថុស្របតាមច្បាប់។ នីតិភាព ត្រូវបានកំណត់អាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[144] បើទោះបីជា ច្បាប់បានអនុញ្ញាតឱ្យមានសិទ្ធិធ្វើអត្តសញ្ញាណបណ្ណគ្រប់អាយុ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ។ ប៉ុន្តែ អនីតិជនអាយុ ១៥ (ដប់ប្រាំ) ចង់ចុះឈ្មោះប្រើប្រាស់ គឺអាចបានក្នុងសេវាសាធារណៈកម្មវត្ថុផ្សេងដូចជា ការអប់រំឌីជីថល, សុខភាពសាធារណៈឌីជីថល, និងកិច្ចគាំពារឌីជីថល ជាអាទិ៍។ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ គឺជាឯកសារមួយផ្លូវការ សម្រាប់បញ្ជាក់អត្តសញ្ញាណបុគ្គលម្នាក់ៗដែលមានសញ្ជាតិខ្មែរ ដោយមិនត្រូវអនុញ្ញាតឱ្យធ្វើការផ្ទេរពីបុគ្គលមួយ ទៅបុគ្គលមួយទៀត ឬយកទៅបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សបានឡើយ និងរាល់បញ្ជីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានទម្រង់ជាអេឡិចត្រូនិក។[145]រាល់ការស្នើសុំធ្វើយថាភូតកម្មទិន្នន័យអត្តសញ្ញាណ CamDigiKey ដើម្បីប្រើប្រាស់ត្រូវរាប់ជាចំនួនប្រតិបត្តិការ។ ការធ្វើយថាភូតកម្មទិន្នន័យ និងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់ CamDigiKey នៅក្នុងវិស័យសាធារណៈ មិនត្រូវយកកម្រៃសេវានោះឡើយ។[146]

ដំណើរប្រព្រឹត្តទៅនេះ ស្ថិតិចំនួនការស្នើសុំប្រើប្រាស់ថ្នាល CamDigiKey ដោយគិតចាប់ពីថ្ងៃទី១៥ មិថុនា ២០២០ រហូតដល់ថ្ងៃទី១៦ ឧសភា ២០២៤ មានការតំឡើងសរុប៣៩.១៧០ដង ដោយមានគណនីបង្កើតសរុប

---

[142] អនុក្រឹត្យថ្នាល CamDigiKey, មាត្រា១០។

[143] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៦, ២៤ និង២៨។

[144] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។ និងច្បាប់វិសោធនកម្មក្រមព្រហ្មទណ្ឌ, លេខ នស/រកម/០២១៨/០០៣, ២៧ កុម្ភៈ ២០១៨, មាត្រា៣៨, (ពីពេលនេះតទៅហៅថា ក្រមព្រហ្មទណ្ឌកម្ពុជា២០០៩)។

[145] ច្បាប់អត្រានុកូល២០២៣, មាត្រា១២៨(១) និង១២៩។

[146] អនុក្រឹត្យថ្នាល CamDigiKey, មាត្រា៣២(១) និង(២)។

២៦.៨៥៩គណនី/នាក់, APIs ចំនួន៦ និងដៃគូសរុបចំនួន២១។[147] ការស្នើសុំបង្កើតគណនី លុះត្រាតែព័ត៌មានអ្នកប្រើប្រាស់បំពេញគ្រប់ទម្រង់ ឯកសារណបត្រឹមត្រូវ និងអនុម័តស្របច្បាប់រយៈពេល៨ម៉ោងនៃម៉ោងធ្វើការ។

### ២.២.២. ការប្រមូលទិន្នន័យបុគ្គលប្រកបដោយបរិយាបន្នសង្គម

ទិន្នន័យ គឺជាឿងចម្បងក្នុងដំណើរការតាមដាន និងវាយតម្លៃលើសូចនាករដែលបានមកពីក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។ ទិន្នន័យ ឬស្ថិតិ ត្រូវបានប្រមូល ចងក្រង កែប្រែកំណត់ដោយច្បាប់។[148] ពិព្រោះ បើគ្មានសេណារីយ៉ូការគ្រប់គ្រងឱ្យមានសណ្តាប់ធ្នាប់ ត្រឹមត្រូវ និងសុវត្ថិភាព ទិន្នន័យបុគ្គលនោះទេ គឺអាចនឹងមានអាណាធិបតេយ្យភាពនៅលើបណ្តាញឌីជីថល និងវិវាទក្នុងសង្គម ពិតជាកើតឡើង។ ការប្រើប្រាស់ និងប្រមូលទិន្នន័យបុគ្គល អាចមានការរួមចំណែកពីអន្តរកម្មក្រសួង ស្ថាប័នពាក់ព័ន្ធនឹងឌីជីថល។ ក្នុងនោះបាន តាមរយៈទិន្នន័យរដ្ឋបាលពីប្រភពរាជរដ្ឋាភិបាល និងមិនមែនរាជរដ្ឋាភិបាលដែលអាចធ្វើឡើងតាមការអង្កេត ឬតាមការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល និងអាចជំនួយពីបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន។[149]

#### ២.២.២.១. ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS)

អត្តសញ្ញាណឌីជីថល គឺស្ថិតក្នុងប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ដែលជាប្រព័ន្ធស្នូលទិន្នន័យអត្តសញ្ញា-ណបុគ្គល។[150] ការបង្កើត និងការអភិវឌ្ឍប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ត្រូវប្រើដោយបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) ដើម្បីអាចតភ្ជាប់ និងធ្វើអន្តរកម្មជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធគ្រប់គ្រងអត្ត-សញ្ញាណបណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ និងប្រព័ន្ធផ្សេងៗ។ ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ខាងមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជន (NCPIM) នៃក្រសួងមហាផ្ទៃ។[151] កិច្ចការក្នុងការប្រមូល ចងក្រង រក្សាទុក គ្រប់គ្រង និងការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល ដែលបានមកចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាសម-ត្ថកិច្ចដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តប្រគល់ឱ្យក្រសួងមហាផ្ទៃ។[152] ក្រសួងមហាផ្ទៃ គឺជាម្ចាស់ទិន្នន័យដើមនៃអត្រានុកូលអត្តសញ្ញាណកម្ម អាចអនុញ្ញាតឱ្យខាងក្រសួង ស្ថាប័ន អង្គភាពទាំងវិស័យសាធារណៈ និងវិស័យឯកជន ឬបុគ្គលប្រើប្រាស់ទិន្នន័យអត្តសញ្ញាណបុគ្គល បានដោយស្របទៅតាមបែបបទ និងនីតិវិធីដែលបានកំណត់។[153] តាមការគ្រោងទុករបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺត្រៀមដើម្បីកសាង

---

[147] https://camdigikey.gov.kh (ទស្សនាចុងក្រោយថ្ងៃទី១០ ធ្នូ ២០២៣)។

[148] ច្បាប់ស្តីពីស្ថិតិ, លេខ នស/រកម/១២១៥/០១៨, ២៤ ធ្នូ ២០១៥, មាត្រា៤, (ពីពេលនេះតទៅហៅថា ច្បាប់ស្ថិតិ)។ ពាក្យថា ស្ថិតិ សំដៅដល់ទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ បោះពុម្ព និងផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យរដ្ឋបាល។ ចំណែកឯពាក្យថា ទិន្នន័យផ្តុំ ជាទិន្នន័យពាក់ព័ន្ធទៅនឹងក្រុមបុគ្គល គ្រួសារ សហគ្រាស ឬស្ថាប័នផ្សេងៗ ត្រូវបានប្រមូលផ្តុំក្នុងកម្រិតមួយដែលមិនអនុញ្ញាតឱ្យស្គាល់ទិន្នន័យបុគ្គល។

[149] ច្បាប់ស្ថិតិ, មាត្រា៦(គ), ១១ និង១៣។

[150] ច្បាប់អត្រានុកូល២០២៣, មាត្រា១៣៩(១)។

[151] ដដែល, មាត្រា១៣៩(២) និង(៣)។

[152] អនុក្រឹត្យសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, មាត្រា៤។

[153] ដដែល, មាត្រា៤(២)។

ប្រព័ន្ធទិន្នន័យសុរិយោដីទម្រង់ឌីជីថល ផងដែរ ដោយការប្រើប្រាស់ជាជំនួយពីបណ្ដាញប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន។[154] ការប្រមូលទិន្នន័យបុគ្គលត្រូវបានបែងចែកជា២រួមមាន៖ ប្រភពទិន្នន័យក្នុងក្របខណ្ឌ និងប្រភពទិន្នន័យក្រៅក្របខណ្ឌ។ ទន្ទឹមនេះ មជ្ឈមណ្ឌលទិន្នន័យធំជាតិរបស់កម្ពុជា បច្ចុប្បន្នកំពុងអនុវត្ត និងស្ថិតនៅក្នុងទីស្ដីការគណៈរដ្ឋមន្ត្រី ដោយបានបញ្ជូនរាល់ទិន្នន័យទៅកាន់ក្រសួង ស្ថាប័នដើម្បីបម្រើឱ្យសេវាសាធារណៈ។

ប្រភពទិន្នន័យក្នុងក្របខណ្ឌ គឺសំដៅដល់ទិន្នន័យរាជរដ្ឋាភិបាល ដែលត្រូវបានចាត់ទុកជាធាតុចូលយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃទៅលើវឌ្ឍនភាពនៃបរិវត្តកម្មសេដ្ឋកិច្ច និងសង្គមកិច្ចឌីជីថលកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដែលការណ៍នេះទាមទារឱ្យមានកាតព្វកិច្ចការចូលរួមចាំបាច់ពីអង្គភាពទទួលបន្ទុក។ ទិន្នន័យដែលអង្គភាពទទួលបន្ទុក ដាក់ជូនមកគឺ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមកិច្ចឌីជីថល ត្រូវមានការទទួលស្គាល់ពីថ្នាក់ដឹកនាំ របស់អង្គភាពសាមី ព្រមទាំងស្របទៅតាមគោលការណ៍ធានាគុណភាពទិន្នន័យ។ គោលការណ៍ធានាគុណភាពទិន្នន័យ ជាអង្គភាពទទួលបន្ទុកត្រូវធានាឱ្យបានភាពត្រឹមត្រូវ និងពេញលេញរាល់ព័ត៌មាន និងទិន្នន័យដែលបានបញ្ចូលនៅក្នុងផតថលប្រព័ន្ធតាមដាន និងវាយតម្លៃសេដ្ឋកិច្ចរបស់អគ្គលេខាធិ-ការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។[155] គោលការណ៍ជាមូលដ្ឋានប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន ដែលប្រភពទិន្នន័យក្នុងក្របខណ្ឌ ត្រូវតែធានាបរិយាបន្ន។[156]

ការបង្កើតលេខកូដសម្គាល់អត្តសញ្ញាណ (UIC) គឺបង្កើតឡើងដោយប្រព័ន្ធរួមអត្តសញ្ញាណប្រជាជនតាម-រយៈការជ្រើសរើសដោយការចៃដន្យ និងស្វ័យប្រវត្តិកម្មសម្រាប់ផ្ដល់ជូនបុគ្គលគ្រប់រូបដែលមានសញ្ជាតិខ្មែរ និងបុគ្គលទាំងឡាយណាដែលកើត និង/ឬស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះទម្រង់ និងជាលំដាប់លេខរៀងលម្អិតនៃលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ដែលត្រូវរៀបចំដោយអាជ្ញាធរជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។[157] លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល គឺត្រូវបានផ្ដល់ជូនឱ្យបុគ្គលម្នាក់ៗជាអចិន្ត្រៃយ៍ សម្រាប់ប្រើប្រាស់រហូតដល់បុគ្គលនោះទទួលមរណភាព ឬពេលបាត់បង់អស់សមត្ថ-ភាពទទួលសិទ្ធិ។[158] បុគ្គលគ្រប់រូប នឹងត្រូវបានផ្ដល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលតាមរយៈការស្នើសុំចុះបញ្ជីកំណើតរស់។ សម្រាប់ជនអន្តោប្រវេសន៍ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬចូលសញ្ជាតិទៅជាប្រជា-ពលរដ្ឋខ្មែរ នោះលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល នឹងត្រូវផ្ដល់ជូនឱ្យតាមរយៈការចុះបញ្ជីអន្តោប្រវេសន៍ ឬការចុះបញ្ជីសញ្ជាតិ។[159] ការចុះបញ្ជីអត្រាកំណើតរស់ ឬការចុះបញ្ជីកំណើតរស់ ត្រូវបានធ្វើការសាកល្បងជោគ-ជ័យចុះបញ្ជី តាមរយៈប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន ពីប្រព័ន្ធជូនដំណឹងក្រសួងសុខាភិបាល ទៅ

[154] សេចក្ដីព្រាងច្បាប់ភូមិបាលថ្មី២០២៣, មាត្រា១០១។

[155] Rutan Battacharyya, "Data Quality Assurance" [ធានាគុណភាពទិន្នន័យ], *WallstreetMojo*, (2024), https://www.wallstreetmojo.com/data-quality-assurance/ (ទស្សនាចុងក្រោយថ្ងៃទី១០ ធ្នូ ២០២៣)។

[156] ច្បាប់អត្រានុកូល២០២៣, មាត្រា១៣៨។

[157] ដដែល, មាត្រា១៤១។

[158] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា៨។

[159] ច្បាប់អត្រានុកូល២០២៣, មាត្រា១៤២(១) និង(២)។

កាន់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មកម្ពុជា។[160]

ការកំណត់អត្តសញ្ញាណដែលបានមកពីប្រភពទិន្នន័យក្នុងក្របខណ្ឌនេះ ដោយយោងតាមទស្សនវិស័យរបស់រាជរដ្ឋាភិបាល គឺចង់ឱ្យកើតមានការប្រើប្រាស់ជាលំហ ឬទូលំទូលាយក្នុងខ្នាតអន្តរជាតិ តាមរយៈលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលនេះ។ ឧទាហរណ៍. លោក ក អាចប្រើប្រាស់លេខកូដ UIC របស់ខ្លួនក្នុងការចូលទៅប្រើប្រាស់សេវាកម្មបណ្តាញគមនាគមន៍ជាសកលលោក ឬក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា ក៏បានដែរ ដោយភ្ជាក់ងារបច្ចេកទេសរបស់ព្រះរាជាណាចក្រកម្ពុជា ជាអន្តរការីក្នុងការទទួលស្គាល់អត្តសញ្ញាណ។ ម្យ៉ាងវិញ ខាងរាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើការសិក្សាស្រាវជ្រាវទៅលើខ្សែសង្វាក់អត្តសញ្ញាណឌីជីថល (Blockchain eID) របស់បុគ្គលគ្រប់រូប ដោយប្រែមកឱ្យប្រើប្រាស់បណ្ណ ឬកាតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលអាចស្កេនផ្ទាល់ ឬសន្ទានកម្មជាមួយម៉ាស៊ីនដោយវិធីណាមួយ តាមបែបគំរូឌីជីថលថ្មី។ ការធ្វើទំនើបកម្មលើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនេះ គឺប្រើប្រាស់ដូចគ្នាទៅនឹងការប្រើប្រាស់កាត ឬបណ្ណប្លាស្ទិចធនាគារ (ATM Card) ដែលបច្ចុប្បន្នអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ មានត្រឹមតែស៊ីមភ្ជាប់នៅលើបណ្ណ ដោយក្រសួងមហាផ្ទៃទើបអាចប្រើប្រាស់បានប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវលើខ្សែសង្វាក់អត្តសញ្ញាណឌីជីថល (Blockchain eID) គឺកំពុងសហការជាមួយក្រុមហ៊ុន X-Infotech ដោះស្រាយបញ្ហាបច្ចេកទេសនានា ក៏ដូចជាលិខិតឆ្លងដែនព្រះរាជាណាចក្រកម្ពុជា។

ទិន្នន័យក្រៅក្របខណ្ឌទាញយកពីវិស័យឯកជន អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិនានា។ ក្នុងនោះប្រភេទទិន្នន័យ ដែលខាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមកិច្ចឌីជីថល ធ្វើការទាញយកនោះ ជាប្រភេទទិន្នន័យបែបបរិមាណវិស័យដែលពាក់ព័ន្ធ និងស្របតាមគោលការណ៍គន្លឹះ។[161] ប្រភពទិន្នន័យនៃវិស័យឯកជន អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ ក៏ជាផ្នែកមួយសំខាន់ដែលអាចយកមកប្រើប្រាស់ វិភាគ និងប៉ាន់ស្មានផងដែរ។ ប្រភេទទិន្នន័យមួយចំនួន ត្រូវតែយកមកពីក្រៅក្របខណ្ឌដូចជាការប្រៀបធៀបរបាយការណ៍អន្តរជាតិរវាងប្រទេស និងប្រទេស ឬទិន្នន័យក្រៅក្របខណ្ឌមួយចំនួនទៀតដែលបានមកពីអង្គការសង្គមនានា។ ឧទាហរណ៍. World Bank បង្ហាញអំពីរបាយការណ៍តម្លៃអចលនទ្រព្យនៅកម្ពុជា និងរិះគន់លើកម្មសិទ្ធិកើនឡើង ដោយសារកង្វះខាតក្នុងការគ្រប់គ្រងទិន្នន័យ។

### ២.២.២.២. លក្ខណៈស្តង់ដារទិន្នន័យ

ការចាប់យកឌីជីថលនៅកម្ពុជា លើការប្រើប្រាស់កុំព្យូទ័រ, បណ្តាញតភ្ជាប់តខ្សែ, អ៊ីនធឺណិត តាមរយៈការប្រមូលទិន្នន័យ និងជំនួយដល់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងជីវភាពប្រចាំថ្ងៃ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានប្រកាសឱ្យប្រើប្រាស់ស្តង់ដារកម្ពុជាផ្នែកឌីជីថលចំនួន៣ស្តង់ដារ ដែលត្រូវ

[160] អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, "ទារិកាទី១ ចុះបញ្ជីកំណើតដោយជោគជ័យ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ពីប្រព័ន្ធជូនដំណឹងសុខាភិបាល ទៅកាន់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម," ២០២៣, https://news.gdi.gov.kh/posts/22469 (ទស្សនាចុងក្រោយថ្ងៃទី៨ ឧសភា ២០២៤)។ ពាក្យថា រដ្ឋាភិបាលបរិវត្តកម្ម ពេញលេញ (Fully Transformed Government) ដែលក្រសួង ស្ថាប័នទាំងអស់ប្រើប្រាស់បច្ចេកវិទ្យា និងអន្តរប្រតិបត្តិការល្អសម្រាប់គ្រប់គ្រងអភិបាលកិច្ច ផ្តល់សេវាជូនប្រជាពលរដ្ឋជាធំ និងប្រើទិន្នន័យសម្រាប់សម្រេចចិត្ត។

[161] ច្បាប់ស្ថិតិ, មាត្រា៤(១០) និង(១១)។

គោរពតាមស្តង់ដារអន្តរជាតិ (ISO/IEC) និងកម្រិតប្រហាក់ប្រហែលក្នុងតំបន់អាស៊ាន។[162] ក្នុងន័យនេះ គឺបានផ្តល់ភាពងាយស្រួល ដែលជំរុញឱ្យកម្ពុជាអាចប្រើប្រាស់បណ្តាញតាមលទ្ធភាព និងលក្ខណៈសកល។ កម្ពុជាមាននិយ័តករទូរគមនាគមន៍ (ន.ទ.ក) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសេនាធិការគ្រប់គ្រងលើខ្សែបណ្តាញសេវាគ្រប់ប្រភេទនៅទូទាំងប្រទេស។[163] ប៉ុន្តែ សេវាទូរគមនាគមន៍ដែលកំពុងប្រើប្រាស់ នៅមានកម្រិតគម្លាតឌីជីថល ដោយមានតំបន់មួយចំនួន កំពុងតែបន្តអភិវឌ្ឍន៍បន្ថែម។[164] ដូចនេះ ការប្រមូលទិន្នន័យជារួម គឺអាចនៅមានផលលំបាក ញ៉ាំងឱ្យនិយ័តករទូរគមនាគមន៍ ត្រូវពង្រឹងបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន និងបន្ថែមបង្គោលអង់តែនតាមតំបន់ ដោយកិច្ចសហប្រតិបត្តការដៃគូរវាងរដ្ឋ និងឯកជន។

របាយការណ៍អ្នកប្រើប្រាស់ទូរសព្ទចល័ត ឬទូរសព្ទឆ្លាតវៃ (Smart Phone) នៅក្នុងប្រទេសកម្ពុជា គិតត្រឹមឆ្នាំ២០២២ គឺមានចំនួន១៩.៥លានគ្រឿង (ករណីខ្លះប្រើចន្លោះ ២-៣ គ្រឿង/នាក់) ខណៈពេលអត្រាកម្មហិរញ្ញវត្ថុមាន១៨%នៃប្រជាជនអាយុលើសពី១៨ឆ្នាំ។[165] រីឯប្រជាពលរដ្ឋដែលតភ្ជាប់ប្រើប្រាស់អ៊ីនធឺណិតចំនួន១៨លាននាក់គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ ខណៈពេលអត្រាកម្មឌីជីថលក្នុងចំណោមសិស្សវិទ្យាល័យ និស្សិត និងធ្វើការវ័យក្មេងមាន៤៨% និងប្រជាជនប្រើប្រាស់បណ្តាញសង្គមមាន**១២លាននាក់**ក្នុងឆ្នាំ២០២១។[166] ការកសាងលើសេដ្ឋកិច្ច-សង្គមឌីជីថលជំរុញដល់ការអភិវឌ្ឍ និងបន្ថែមវិស័យទូរគមនាគមន៍កម្ពុជាដើម្បីឆ្ពោះដល់ទសវត្សរ៍ឌីជីថលអាស៊ីអាគ្នេយ៍ឆ្នាំ២០២១-២០៣០ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងឈានចាប់យកបច្ចេកវិទ្យា 5G ក្នុងស្រុក និងសេចក្តីថ្លែងការណ៍ "សេដ្ឋកិច្ចឌីជីថលប្រទេសសមាជិកអាស៊ានកើន២ពាន់ទ្រីលានដុល្លារ ឆ្នាំ២០៣០"។[167]

[162] ប្រកាសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ស្តីពីស្តង់ដារកម្ពុជាផ្នែកឌីជីថលចំនួន៣ស្តង់ដារ, លេខ០៤៦ MISTI/២០២១, ៥ កុម្ភៈ ២០២១។ ប្រទេសក្នុងតំបន់អឺរ៉ុប https://www.iso.org/standard/27001 និងតំបន់អាស៊ាន https://asean.org/wp-content/uploads/2021/08/ASEAN-Data-Management-Framework.pdf, Asean, "ASEAN Digital Masterplan 2025" [ផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥], (*Conference* Jakarta Indonesia, 2021), ១៣, +*(ITU)*។

[163] ច្បាប់ទូរគមនាគមន៍, មាត្រា៨ និង១២។ *រាជរដ្ឋាភិបាលកម្ពុជា មានកិច្ចសហការណ៍ជាមួយក្រុមហ៊ុន HUAWEI ចាប់យក 5G។*

[164] ពាក្យថា គម្លាតឌីជីថល (Digital Zone) ក្នុងន័យទ្រព្យសម្បត្តិរដ្ឋ ឬជាន័យទូលាយ ជាគម្លាតនៃការទទួលបានសេវា និងការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) នៅតាមទីក្រុង ទីប្រជុំជន និងជនបទ, https://lexicon.legalcouncilmef.com/home ។

[165] និយ័តករទូរគមនាគមន៍, https://trc.gov.kh/mobile-phone-subscriptions/, និង NBC's FDR, 2021, https://digitaleconomy.gov.kh/public/images/fintech/pdf/FinTech_Development_Roadmap_06012021_Final_06Jan2021_English_translation.pdf (ទស្សនាចុងក្រោយថ្ងៃទី៥ ឧសភា ២០២៤)។

[166] ដដែល, https://trc.gov.kh/internet-subscriptions/, និង UNDP, 2021-2023, https://www.undp.org/sites/g/files/zskgke326/files/2023-11/8.%20ICPE%20Cambodia%202023.pdf (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤)។

[167] ស្ថានភាព 5G នៅក្នុងតំបន់អាស៊ាន, និងស្ថានភាព 6G ប្រទេសជប៉ុន, https://j2sourcing.com/blog/japans-6g-breakthrough-a-glimpse-into-the-future-of-connectivity/ (ទស្សនាចុងក្រោយថ្ងៃទី ១០ ឧសភា ២០២៤)។

# ជំពូកទី៣

# បរិវត្តកម្ម
# រដ្ឋាភិបាលឌីជីថល
# លើសេវាសាធារណៈ

# ជំពូកទី៣
# បរិវត្តកម្មរដ្ឋាភិបាលឌីជីថលលើសេវាសាធារណៈ

ការចុះបញ្ជីដីធ្លីតាមបែបប្រពៃណី ជារឿយៗពឹងផ្អែកការកត់ត្រាដែលមានមូលដ្ឋានលើក្រដាស និងប្រព្រឹត្តទៅដោយដៃ ដែលបណ្ដាលឱ្យគ្មានប្រសិទ្ធភាព ពន្យារពេល និងកំហុសដែលអាចកើតមាន។ បញ្ហាចម្បង ក្នុងការរក្សាទុកឯកសារច្បាប់ចម្លង (Hard paper) នៃឯកសារដីធ្លីនីមួយៗ គឺមានភាពលំបាកថែទាំឱ្យនៅសភាពដើម និងការរុះរើឯកសារដើម្បីយកមកធ្វើបច្ចុប្បន្នភាព ជាអាទិ៍។ បរិការណ៍ទាំងនេះ គឺងាយនឹងមានភាពមិនស៊ីសង្វាក់គ្នាលើទិន្នន័យ កង្វះតម្លាភាព និងភាពងាយរងគ្រោះចំពោះអំពើពុករលួយ ឬការក្លែងបន្លំ។ ទំនើបភាវូបនីយកម្ម មានគោលបំណងដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយការផ្លាស់ប្ដូរទៅជាប្រព័ន្ធឌីជីថល ងាយស្រួល និងសុវត្ថិភាព។ ប្រទេសកម្ពុជា ក៏កំពុងសម្លឹងមើលបណ្ដាបច្ចេកវិទ្យា ដើម្បីទាញជាតុចូលអភិវឌ្ឍន៍ដល់សេវាសាធារណៈឌីជីថលរបស់ខ្លួន។

ជាសារបាននៃដំណើរហេតុ និងផលជះត្រឡប់ទៅនឹងបញ្ហាទាំងឡាយ ដែលបច្ចេកវិទ្យាអាចជ្រាបចូលមកជំនួសបាន ដោយតម្រូវឱ្យបង្កើតវេទិកាឌីជីថល ក្នុងដំណើរការរៀបចំប្រព័ន្ធចុះបញ្ជីអចលនវត្ថុលើថ្នាលបច្ចេកវិទ្យាឌីជីថល (៣.១), និងវិធានការសុវត្ថិភាពវេខូបនីយកម្ម (៣.២) ដែលរួមចំណែកផ្ដល់ជាយោបល់សុទិដ្ឋិនិយមក្នុងការពិចារណា ឈានដល់ដំណោះស្រាយរួម។

## ៣.១. ដំណើរការរៀបចំប្រព័ន្ធចុះបញ្ជីអចលនវត្ថុលើថ្នាលបច្ចេកវិទ្យាឌីជីថល

អចលនវត្ថុ ជាធនធានសំខាន់, ការគ្រប់គ្រងដីធ្លីមានលក្ខណៈត្រឹមត្រូវ ជាធាតុផ្សំសំខាន់ដល់គោលនយោបាយសង្គម-សេដ្ឋកិច្ចនៃប្រទេសនោះ។ ការធ្វើទំនើបកម្មប្រព័ន្ធចុះបញ្ជីដីធ្លី គឺជាការខិតខំប្រឹងប្រែងយ៉ាងសំខាន់សម្រាប់ធានាការគ្រប់គ្រងសិទ្ធិអចលនទ្រព្យប្រកបដោយស្មារតីបុរេសកម្ម ធានារាល់ប្រតិបត្តិការលើដីធ្លី និងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ដំណើរការនេះ គឺពាក់ព័ន្ធការធ្វើឱ្យប្រសើរឡើងនៃដំណើរការហួសសម័យ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យរឹងមាំ។ ការបង្កើត "រដ្ឋាភិបាលឌីជីថល ជាតួអង្គសំខាន់ជំរុញកំណើនថ្មី តាមរយៈ*ការបង្កើនចំណូលរដ្ឋ* និង*ការកាត់បន្ថយពេលវេលា ការងារស្ទួន ចំណាយសាធារណៈ* និង*ជះផលប៉ះពាល់បរិស្ថាន* ព្រមទាំង*សម្រួលការផ្លាស់ប្ដូរទិន្នន័យ*រវាងក្រសួង ស្ថាប័ន និងរំហូរការងាររដ្ឋបាល។"[168] ក្នុងយុទ្ធសាស្ត្រទី៥ បង្ហាញពីការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល នៃគោលដៅយុទ្ធសាស្ត្រទី២ភ្ជាប់ទៅនឹងសេវាសាធារណៈឌីជីថលក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បានបង្ហាញពីស្មារតីក្នុងការរៀបចំ "សេចក្ដីព្រាងច្បាប់ស្ដីពីរដ្ឋាភិបាលឌីជីថល" ក្នុងឆ្នាំ២០២២ ដែលត្រូវធ្វើយ៉ាងណាឱ្យមានឯកភាពជាតិតែមួយចំពោះការអនុវត្តលើវេទិកាឌីជីថល និងជំរុញដល់គ្រប់ក្រសួង ស្ថាប័ន រួមគ្នាបង្កើនសមិទ្ធផលថ្មីៗ។[169]

---

168 Freshnews, "ប្រសាសន៍របស់អតីតនាយករដ្ឋមន្ត្រីកម្ពុជា៖ រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកឌីជីថលូបនីយកម្មក្នុងវិស័យសាធារណៈ និងឯកជនជាការងារអាទិភាព," *Freshnews*, ២០២៣, https://freshnewsasia.com/index.php/en/localnews/284014-2023-03-26-03-23-58.html (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤)។

169 ពាក្យថា វេទិកាឌីជីថល នៅទីនេះអាចសំដៅដល់លំហូរការងារឌីជីថល បណ្ដាញតភ្ជាប់ឌីជីថល ឬហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

នៅក្នុងឆ្នាំ២០២២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយរដ្ឋាភិបាលឌីជីថល តាមរយៈប្រព័ន្ធអនឡាញ ដែលធ្វើបទបង្ហាញពីមន្ត្រីជំនាញតាមក្រសួង ស្ថាប័ន និងអង្គការអន្តរជាតិជាច្រើន ក្នុងការចូលរួមអភិវឌ្ឍបរិវត្តកម្មឌីជីថលនៅកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតវេទិការដ្ឋាភិបាលឌីជីថល (Digital Government Forum-DGF) លើកទី០១ ជាប្រវត្តិសាស្ត្រក្នុងការពិព័រណ៍ថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីជាការបង្ហាញអំពីសមិទ្ធផលនៃការកសាងរដ្ឋាភិបាលឌីជីថល, ការអភិវឌ្ឍថ្នាលបច្ចេកវិទ្យា, គុណប្រយោជន៍ការប្រើប្រាស់ថ្នាលបច្ចេកវិទ្យា, ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នរដ្ឋដោយប្រើប្រាស់ថ្នាលឌីជីថលដែលអភិវឌ្ឍដោយក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល, សេវាកម្មទូរសព្ទនិងអ៊ីនធឺណិត, សេវាប្រៃសណីយ៍, សេវាហិរញ្ញវត្ថុ (Fintech) និងសេវាធុរកិច្ចថ្មីឌីជីថល (Digital Startups) ជាដើម ដោយផ្តល់ឱកាសដល់សាធារណជន ក្នុងការប្រើប្រាស់សាកល្បង និងផ្សព្វផ្សាយពីឧបករណ៍បច្ចេកវិទ្យាទំនើប និងចុងក្រោយដោយក្រុមហ៊ុនជាតិ និងអន្តរជាតិល្បីៗមកពីគ្រប់បណ្តាប្រទេស ក្នុងខែមីនា ឆ្នាំ២០២៤។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ក៏បានចូលរួមរៀបបង្ហាញពីសមិទ្ធផលសេវាកម្មឌីជីថលមួយចំនួនផងដែរ ដូចជា សេវាព័ត៌មានសុរិយោដី ការផ្ទៀងផ្ទាត់បណ្ណកម្មសិទ្ធិ និងសេវាសំណង់តាមប្រព័ន្ធអេឡិចត្រូនិក។[170] បច្ចុប្បន្ន រដ្ឋាភិបាលឌីជីថលកម្ពុជា មានគម្រោង និងកំពុងតែអនុវត្តដោយយន្តការបែងចែកជា៣ផ្នែក រួមមាន សេវាកម្មពី**រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ**(Government to Citizen-G4C), ពីរដ្ឋាភិបាលទៅធុរកិច្ច (Government to Business-G2B) និងរដ្ឋាភិបាលទៅរដ្ឋាភិបាល (Government to Government-G2G)។

សេវាកម្ម G4C ជាការផ្តល់សេវាសធារណៈជូនប្រជាពលរដ្ឋតាមថ្នាលឌីជីថលតាមរយៈការផ្តល់ព័ត៌មាន ឬសេវាកម្ម ដូចជាសេវាអត្រានុកូលដ្ឋាន ធ្វើនីត្យានុកូលកម្ម (នៅតាមការិយាល័យច្រកចេញចូលតែមួយ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ), ការធ្វើលិខិតឆ្លងដែន, ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ ជាអាទិ៍។ ការណ៍នេះ បានជួយឱ្យប្រជាពលរដ្ឋអាចស្នើសុំពីចម្ងាយ និងឆ្លើយតបទាន់ពេលវេលា។ សេវាកម្ម G2B គឺជាការផ្លាស់ប្តូរសេវាកម្មទៅវិញទៅមករវាងរដ្ឋាភិបាល និងធុរជន អាជីវករ ដើម្បីផ្តល់ ឬទទួលព័ត៌មានពីវិធីសាស្ត្រការអនុវត្ត និងការប្រើប្រាស់ថ្នាលឌីជីថលតាមរយៈការធ្វើអាជ្ញាបណ្ណ, ចុះបញ្ជីអាជីវកម្ម និងបង់ពន្ធ ជាអាទិ៍ ជាក់ស្តែង សេវាកម្មនេះ គឺទទួលបានជោគជ័យ ផុសផុល ងាយស្រួលការប្រើប្រាស់តាមរយៈម៉ូដែលធុរកិច្ចថ្មីៗពីសំណាក់អ្នកស្រាវជ្រាវកម្ពុជា។ សេវាកម្ម G2G ជាការសម្រួលដល់ការចែករំលែកទិន្នន័យ និងអន្តរកម្មរវាងក្រសួង ស្ថាប័នរដ្ឋនិងរដ្ឋតាមអនឡាញនៃដំណើរការរាជរដ្ឋាភិបាលកម្ពុជា ដូចជាការផ្ទេរទៅកាន់អង្គភាពពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការទាំងក្នុងកម្រិតតំបន់ និងសកល ដែលបានកំណត់ដោយបទប្បញ្ញត្ត ឧទាហរណ៍តាមរយៈ CamDX, CamDigiKey ជាអាទិ៍ គឺមានសមត្ថភាពលឿន ទំនុកចិត្ត និងប្រសិទ្ធភាព។ ម្យ៉ាងវិញ កម្ពុជាគឺមិនទាន់អនុវត្តពេញលេញចំពោះសេវាកម្មពីរដ្ឋាភិបាលទៅមន្ត្រី (Government to Employee-G2E) នៅឡើយ ដោយត្រូវការអភិវឌ្ឍប្រព័ន្ធបន្ថែម។[171]

[170] Semtararath, "សន្និសីទសារព័ត៌មានស្តីអំពីវេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៤ និងពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ," ២០២៤, https://mptc.gov.kh/2024/02/សន្និសីទសារព័ត៌មាន-ស្ត-2/ និង https://m.freshnewsasia.com/index.php/en/localnews/331956-2024-03-11-02-22-40.html (ទស្សនាចុងក្រោយថ្ងៃទី ១០ ឧសភា ២០២៤), *បណ្តាសមិទ្ធផលសេវាកម្មអនឡាញរបស់ក្រសួង ដ.ន.ស កន្លងមក*។

[171] Cambodia 4.0 Center, https://cambodia4point0.org/kh/eGovernment16092022 ។

ដំណើរការរៀបចំប្រព័ន្ធអេឡិចត្រូនិក គឺអាចនឹងមានលក្ខណៈស្មុគស្មាញ។ កម្ពុជា គឺបន្តត្រូវការមន្ត្រីជំនាញ មន្ត្រីបច្ចេកទេស មូលធនមនុស្សឌីជីថល និងការគាំទ្រពីសំណាក់អន្តរជាតិ។ តាមរយៈស្មារតីមុតមាំរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបគោលជំហរ និងយុទ្ធសាស្ត្រក្លូនជាតូចៗពីយុទ្ធសាស្ត្របញ្ចកោណ ធ្វើយ៉ាងណាឱ្យវិស័យដីធ្លីអាចបោះពួយទៅមុខ និងអំពាវនាវដល់យុវជន និងពីសំណាក់អ្នកស្រាវជ្រាវផ្តល់ជាយោបល់ជួយដល់ក្រសួង ជាដំណោះស្រាយឆ្លើយតបនឹងបញ្ហាជាប់គាំងនានា ជាពិសេស ការចុះបញ្ជីដីធ្លី។ ក្រសួង ដ.ន.ស បានដាក់ចេញជាគោលនយោបាយគន្លឹះ ៣ចំណុចៈ គឺត្រូវតែវាស់វែងដីបង្ហើយ ក៏ដូចជាការបំបែកក្បាលដី និងការចុះបញ្ជីបញ្ចប់, បរិយាកាសគ្មានវិវាទ, និងសេវាគាប់ចិត្ត (មានន័យថាសេវាកម្មគ្រប់យ៉ាងនៅលើដៃអ្នកប្រើប្រាស់ [ឧបករណ៍ ឬទូរសព្ទឆ្លាតវៃ])។[172]

ការរៀបចំវិស័យដីធ្លីនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង គឺត្រូវមានភារកិច្ចកិច្ចការទូតជាសំខាន់។ ដំណើរការ គឺប្រព្រឹត្តទៅ ចាំបាច់ត្រូវមានវិធានការហិរញ្ញវត្ថុ ដើម្បីគាំទ្រគ្រប់សកម្មភាព។ យ៉ាងណាមិញ ក្រសួង ដ.ន.ស បានប្រឹងប្រែងតាមរយៈកិច្ចការបរទេស និងទទួលការគាំទ្រពីរដ្ឋពហុភាគី និងចំណងភាពជាដៃគូរវាងរដ្ឋ និងរដ្ឋ, រដ្ឋ និងឯកជន, រដ្ឋ និងឯកជនបរទេស។ ក្នុងនោះរួមមាន ធនាគារពិភពលោក (World Bank) បានជួយជ្រោមជ្រែងគម្រោងជាច្រើនវិស័យ ជាពិសេស វិស័យដីធ្លីកម្ពុជា គឺបានរួមចំណែកខ្ពស់ និងគាំទ្រថវិកាលើការអនុវត្តគម្រោងទី៣ នៃការបែងចែកដីធ្លីសម្រាប់គម្រោងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (Third Land Allocation for Social and Economic Development Project-LASED III) ក្នុងគោលបំណងដើម្បីជួយបង្កើនសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ សេវាកសិកម្ម និងសង្គមសម្រាប់ប្រជាជនក្រីក្រគ្មានដីធ្លី និងសហគមន៍ជនជាតិដើមភាគតិចកម្ពុជា ដោយចាប់ផ្តើមពីថ្ងៃទី២៦ មិថុនា ២០២០ និងបញ្ចប់នៅថ្ងៃទី៣១ ធ្នូ ២០២៦ ក្នុងទំហំទឹកប្រាក់សរុប៩៣លានដុល្លារអាមេរិក។[173] ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយអ្នកតំណាងថាបានគាំទ្រផ្តោតលើគម្រោង ២ចំណុច ទី១. ជំនួយបច្ចេកទេសក្នុងការរៀបចំផែនការសម្រាប់ប៉ូលសេដ្ឋកិច្ចកម្ពុជា និងទី២. ផែនការអភិវឌ្ឍន៍តំបន់ឆ្នេរកម្ពុជា។[174] រីឯការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង (UNOPS) បានសន្យាថា អាចនឹងជួយការចុះបញ្ជីដីធ្លី និងបន្តផ្តល់បណ្ណកម្មសិទ្ធិឱ្យកាន់តែលឿនតាមគោលនយោបាយកម្ពុជា។ ក្នុងនោះក្រុមហ៊ុន Google នឹងដាក់បុគ្គលសម្ព័ន្ធរបស់ខ្លួន និងប្រកាសគាំទ្រលើវេទិកានៃផ្នែក

[172] Freshnews, "គោលនយោបាយគន្លឹះ៣ចំណុច របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់," *Youtube*, ២០២៤, https://www.youtube.com/watch?v=unQj5RQlA3w (ទស្សនាចុងក្រោយថ្ងៃទី១២ ឧសភា ២០២៤)។

[173] World Bank, "Cambodia - Third Land Allocation for Social and Economic Development Project (LASED III): Fact Sheet (English)," ២០២១, https://documents1.worldbank.org/curated/en/872911608199117198/pdf/Cambodia-Third-Land-Allocation-for-Social-and-Economic-Development-Project-LASED-III-Fact-Sheet.pdf និងប្រភពមួយទៀតៈ https://documents.worldbank.org/en/publication/documents-reports/documentlist?qterm=P171331 (ទស្សនាចុងក្រោយថ្ងៃទី៩ ឧសភា ២០២៤)។

[174] Ann Bunthan, "ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់សង្ឃឹមថាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងរួមចំណែកជួយសម្រួលដល់ការងារចុះបញ្ជីដីធ្លីឱ្យបានចប់សព្វគ្រប់នៅទូទាំងប្រទេសកម្ពុជា," ២០២៤, https://mlmupc.gov.kh/2024/01/29/5784/ (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤)។ *[គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ ADB ជួយកម្ពុជាសរុបប្រមាណ២០៧គម្រោង ស្មើ៤,៨ប៊ីលាន($)]។*

បច្ចេកវិទ្យាជូនទៅកម្ពុជា ដើម្បីអាចពង្រឹងឱ្យកម្ពុជាមានលទ្ធភាពផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថល។[175] ក្រុមហ៊ុន Huawei, LUMA បានជួយដល់ពន្លឿនសេវាអ៊ីនធឺណិត និងជួយធ្វើទំនើបកម្មប្រព័ន្ធមូលដ្ឋានទិន្នន័យស៊ុរិយោដី។ ក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ គឺប្រទេសជប៉ុន បានជួយស្ថានីយវាស់វែងអចិន្ត្រៃយ៍ (Continuously Operating Reference Stations-CORS + JICA) និងកិច្ចសហការនៃផ្កាយរណប JAXA ទឹកប្រាក់ប្រមាណ ៩,៧លានដុល្លាអាមេរិក, ប្រទេសចិន តាមរយៈក្រុមហ៊ុន China Siwei ជួយដល់កម្ពុជាក្នុងការប្រមូលទិន្នន័យ និងផលិតជាផែនទីដែលមានគុណភាពច្បាស់ និងជួយបោសសម្អាតគ្រាប់មីនលើផ្ទៃដីកម្ពុជា ដែលមិនទាន់វាស់វែង ទឹកប្រាក់ជាង២,៥លានដុល្លារអាមេរិក ដែលកម្ពុជាទទួលរងគ្រោះស្លាប់ដោយសារមីនជាង១៩.៨១៩ និងរងរបួស៦៥.០០៤នាក់ គិតចាប់ពីឆ្នាំ១៩៩៣មក និងអាចឱ្យប្រជាជនកម្ពុជាទៅតាំងទីលំនៅថ្មីបន្ថែម៩លានទូទាំងប្រទេស។[176] ទៀតសោត សហរដ្ឋអាមេរិក កូរ៉េខាងត្បូង និងស្វីស ទទួលយកមន្ត្រីកម្ពុជា ដើម្បីបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជួយបង្ហាញផ្លូវពីការវិវត្តនៃបច្ចេកវិទ្យាសកលលោក ធ្វើយ៉ាងណាឱ្យកម្ពុជាមានលទ្ធភាពល្អគ្រប់គ្រាន់ក្នុងការអនុវត្ត និងសាកល្បងប្រើប្រាស់សេវាសាធារណៈអនឡាញនាថ្ងៃអនាគត។

ហេតុនេះកម្ពុជាគួររៀបចំតម្រូវការអនុវត្តដោយស្វ័យប្រវត្តិកម្ម គឺត្រូវការរចនានិម្មាបនកម្ម និងការអនុវត្តវេទិកាឌីជីថលលើការចុះបញ្ជីអចលនវត្ថុ (៣.១.១) និងរៀនសូត្រពីករណីសិក្សានៅប្រទេសមួយចំនួន (៣.១.២)។

តើបរិវត្តកម្មឌីជីថលលើសេវាសាធារណៈ កម្ពុជាត្រូវត្រៀមខ្លួនដោយរបៀបណាខ្លះ? និងគួរសិក្សាបែបណាខ្លះ ដើម្បីអាចយកបទពិសោធន៍ពីប្រទេសផ្សេងៗ?

### ៣.១.១. ការរចនានិម្មាបនកម្ម និងការអនុវត្តវេទិកាឌីជីថលលើការចុះបញ្ជីអចលនវត្ថុ

កម្ពុជា កំពុងតែអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល នៅមានកម្រិតទាប។ ពិព្រោះ រាជរដ្ឋាភិបាលកម្ពុជា ពុំទាន់មានស្តង់ដារបច្ចេកទេសតម្រូវរួមមួយ សម្រាប់ជាលក្ខណៈក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) ដែលអាចធានាបានសង្គតិភាពនៃរូបរាងការរចនាផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ យន្តការអន្តរប្រតិបត្តិការ ព្រមទាំងស្តង់ដារសន្តិសុខព័ត៌មាន និងសុវត្ថិភាពទិន្នន័យ។ កន្លងមកក្រសួង ស្ថាប័ន ធ្លាប់ធ្វើកម្មវិធីតាមរយៈផតថលមួយចំនួន ផងដែរ គ្រាន់តែការប្រើប្រាស់នោះ គឺមានលក្ខណៈប្រើប្រាស់ព័ត៌មានតែផ្ទៃក្នុងនៃក្រសួង ស្ថាប័នសាមីប៉ុណ្ណោះ។ ដូចនេះ ឧទាហរណ៍បើមានក្រសួង ស្ថាប័នបង្កើតផតថលចំនួន២០ គឺត្រូវការត្រួតពិនិត្យ ធ្វើប្រតិបត្តិការ និងវាយតម្លៃទៅវិញទៅមកចំនួន២០លើកវិញ ដដែលៗ ញ៉ាំងឱ្យខាតពេលវេលា និងចំណាយថវិកាជាតិខុសទិសដៅ។ ដូចករណី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតជាមជ្ឈមណ្ឌលទិន្នន័យជាតិមួយ ដែលផ្ទុកអ៊ីម៉ែល ខ្លឹមសារ និងគេហទំព័ររបស់ក្រសួង ស្ថាប័នមួយចំនួន ប៉ុន្តែ បណ្តាស្ថាប័នខ្លះបែរជាមានមជ្ឈមណ្ឌលទិន្នន័យរៀងៗខ្លួនទៅវិញ ដោយមិនបានប្រើប្រាស់រួមគ្នា ឱ្យអស់ពីលទ្ធភាពទេ។ ល្អីកនេះ

[175] Koem Bunthoeun, "ក្រុមហ៊ុន Google ប្រកាសគាំទ្រវេទិកាបច្ចេកវិទ្យា Cambodia Tech Catalyst 2024 ដែលរៀបចំលើកដំបូងនៅកម្ពុជា," *Business Cambodia*, ២០២៤, https://business-cambodia.com/articles/cambodia-tech-catalyst-2024- (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤)។

[176] ឯកសារចាំបាច់, អាចរកបានបឋមនៅ https://kh.cc-times.com/posts/17163 និង https://www.information.gov.kh/articles/49767 (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤), (ឯកសារនៅជាមួយអ្នកនិពន្ធ)។

រាជរដ្ឋាភិបាលអាណត្តិទី៧ គឺបានជំរុញ និងលើកកម្ពស់អនុវត្តផែនការ ដោយបន្ស៊ីជាវេទិកាផតថលជាតិតែមួយ ធ្វើយ៉ាងណាឱ្យស្ថិតក្រោមគណៈកម្មាធិការមានសមត្ថកិច្ចដែលច្បាប់បានកំណត់ គឺតម្រូវឱ្យក្រសួង ស្ថាប័ននានាធ្វើបរិវត្តកម្មឌីជីថល ស្ថិតក្នុងអភិបាលកិច្ចឌីជីថលអន្តរកម្មតែមួយ និងប្រែជារដ្ឋាភិបាលបរិវត្តកម្មពេញលេញ។

បច្ចេកវិទ្យា គឺជាចលករកំណើនអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។[177] គំរូអភិបាលកិច្ចក្នុងសម័យឌីជីថល ត្រូវការបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) ជាចាំបាច់ ដើម្បីអាចមកជំនួសកិច្ចការមួយចំនួនដែលធ្វើឡើងជាប្រចាំ និងកិច្ចការដដែលៗ លើលិខិតស្នាមក្នុងសេវាសាធារណៈ។ បច្ចុប្បន្ន កម្ពុជាបានប្រើប្រាស់បច្ចេកវិទ្យានេះរហូតដល់ថ្នាក់មូលដ្ឋានភូមិ ឃុំ សង្កាត់រួចហើយ តាមរយៈការទំនាក់ទំនង ប្រតិបត្តិការ និងសេវាកម្ម ជាតម្រូវការរបស់ប្រជាពលរដ្ឋ។ ដូចនេះ សេវាសុរិយោដី គួរតែជាជម្រើសដល់ការអភិវឌ្ឍប្រើប្រាស់ប្រព័ន្ធឌីជីថល។ ប៉ុន្តែ ការពិចារណាឧបសគ្គលើថ្លៃចំណាយខ្ពស់ ក្នុងការរៀបចំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល គឺលទ្ធភាពកម្ពុជា អាចប្រព្រឹត្តទៅបានក្នុងកម្រិតមធ្យម និងតម្លៃសមរម្យប៉ុណ្ណោះ។[178] ហេតុនេះ កម្ពុជាអាចពិចារណា និងអភិវឌ្ឍន៍បន្តិចម្តងៗលើប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដែលសមស្របបំផុត និងងាយចាប់យកពីប្រជាពលរដ្ឋក្នុងដំណាក់កាលបឋម។

ថ្វីត្បិតយ៉ាងនេះក្តីប្រទេសកម្ពុជា បានព្យាយាមអភិវឌ្ឍន៍យ៉ាងខ្លាំងក្លា និងសហប្រតិបត្តិភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីឱ្យប្រព័ន្ធអេកូឡូស៊ីឌីជីថលឈានមុខ ជឿនលឿន និងទំនុកចិត្ត ដែលមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា។[179] ទន្ទឹមនេះ តាមរយៈការស្រាវជ្រាវ មើលឃើញថាមានបច្ចេកវិទ្យាធំចំនួន៦ និងថ្នាលនានាដែលអាចសមស្របសម្រាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ក្នុងការរៀបចំសេវាកម្មចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុតាមប្រព័ន្ធអនឡាញ គឺដូចជា៖ បច្ចេកវិទ្យា ICTs, បច្ចេកវិទ្យាប្លុកឆេន (Blockchian), បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AIs), បច្ចេកវិទ្យាប្រព័ន្ធក្លោដ (Cloud), ប្រព័ន្ធទិន្នន័យធំ (Big Data), ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ (DBMS), ប្រព័ន្ធព័ត៌មានសម្គាល់ភូមិសាស្ត្រ (GIS) និងមានថ្នាលតូចៗដូចជា CamDX, CamDigiKey, dApp, និងថ្នាលផ្ទៀងផ្ទាត់និងបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារ (Verify.gov.kh) ជាអាទិ៍។

យោងតាមទស្សនាវដ្តី Forbes បានចុះផ្សាយអំពីបច្ចេកវិទ្យាប្លុកឆេន បង្ហាញពីភាពឆ្លាតវៃ និងការបញ្ជូនទៅដល់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត AI ក្នុងការផ្លាស់ប្តូរបញ្ជីកំណត់ត្រាទៅវិញទៅមក និងមិនអាចផ្លាស់ប្តូរបាន។[180]

[177] PH104, "កម្ពុជា ចាត់ទុកបច្ចេកវិទ្យាឌីជីថល ជាចលករដ៏សំខាន់ ក្នុងដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច," *ដើមអម្ពិល*, ២០២៤, https://dap-news.com/national /2024/04/22/409307/ (ទស្សនាចុងក្រោយថ្ងៃទី១២ ឧសភា ២០២៤)។

[178] ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤, លេខ នស/រកម/១២២៣/០២២, ៧ ធ្នូ ២០២៣, តារាងខ១នៃចំណាយថវិកាថ្នាក់ជាតិ។ និងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥, លេខ០៦សរ, ១៣ ឧសភា ២០២៤, ទំព័រ៣(៨) និង៦។

[179] ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, លេខ នស/រកម/១១២១/០១៨, ១៨ វិច្ឆិកា ២០២១, មាត្រា២៣(១)។

[180] ពាក្យថា ប្លុកឆេន (Blockchain) ជាសំណុំកំណត់ត្រាប្រតិបត្តិការជាប្លុក តភ្ជាប់គ្នាពីមួយទៅមួយ ដោយសុវត្ថិភាពតាមរយៈការប្រើប្រាស់លេខសម្គាល់សម្ងាត់ និងកំណត់ត្រាពេលវេលា នៃប្រតិបត្តិការដែលមិនអាចកែបាន និងត្រូវបានចែករំលែកនៅក្នុងបណ្តាញពាក់ព័ន្ធ, https://www.forbes.com/companies/blockchain/?sh=6bb71fc2296d (ទស្សនាចុងក្រោយថ្ងៃទី១២ ឧសភា ២០២៤)។

មានន័យថាបច្ចេកវិទ្យានេះនឹងជួយកាត់បន្ថយភាពលំអៀង ឬកំហុសឆ្គងទិន្នន័យ, អនុវត្តតាមបទប្បញ្ញត្តិតឹងរ៉ឹងនៃប្រទេសដែលបានកំណត់ក្នុងប្រព័ន្ធ, ទទួលខុសត្រូវ និងជួយការសម្រេចចិត្តអ្នកប្រើប្រាស់ប្រកបដោយសីលធម៌សង្គមនៃប្រទេស, ផ្តល់ព័ត៌មានលម្អិត និងតាមដានលំហូរការងារភ្លាមៗ, និងធ្វើប្រតិបត្តិការដោយសុវត្ថិភាពតម្លាភាពនៃខ្សែសង្វាក់ដែលបានកំណត់ទុកនោះ។ រីឯបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត AI គឺអាចដំណើរការស្ទើរតែឆ្លាតវៃជាងខួរមនុស្ស។[181] ប៉ុន្តែ មិនមានន័យថា AI អាចជំនួសការងារមនុស្សទាំងស្រុងឡើយ។ AI មានអត្ថប្រយោជន៍ខ្លាំងដល់មនុស្សជាតិ ក៏អាចគ្រោះថ្នាក់ខ្លាំងផងដែរ និងនៅតែជជែកតស៊ូមតិជាខ្លាំង ដើម្បីបង្ការទុក។[182] ទស្សនៈមួយបានលើកឡើងថា "AI មិនអាចមកជំនួសមនុស្សបានទេ, ប៉ុន្តែ មនុស្សដែលប្រើប្រាស់ AI អាច" និង "៧១% នៃថ្នាក់ដឹកនាំស្ថាប័ន/ក្រុមហ៊ុន ឬរដ្ឋាភិបាលនិយាយថា នឹងជ្រើសយកបេក្ខជនដែលមានបទពិសោធន៍តិច តែមានជំនាញ និងយល់ដឹងពី AI ជាជាងជ្រើសយកបេក្ខជនមានបទពិសោធន៍ច្រើន តែមិនចេះ AI។" [183]

ការអនុវត្តនៅលើថ្នាលបច្ចេកវិទ្យា គឺនៅតែជាកង្វល់ពីបញ្ហាភាសា។ មន្ត្រីថ្នាក់មូលដ្ឋាន ឬមន្ត្រីសុរិយោដី ក៏ដូចជាប្រជាពលរដ្ឋ នៅមានកម្រិតភាសាបរទេស និងការយល់ដឹងពីបច្ចេកវិទ្យា។ ដូចនេះ តម្រូវឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំរុញអភិវឌ្ឍន៍ និងជ្រើសរើសមន្ត្រីជំនាញកម្មវិធី Software ផលិត និងសម្រួលឱ្យទៅជាខេមរភាសាជាតិ។ ជាធម្មតា ប្រព័ន្ធកុំព្យូទ័រទូទៅ មិនអាចអានភាសាខ្មែរបានទេ ប្រសិនបើមិនបានកំណត់។ ចំណែកឯប្រព័ន្ធក្លោដ ឬសេវាកម្មលើប្រព័ន្ធក្លោដ (Cloud-based services) អនុញ្ញាតឱ្យអ្នកប្រើប្រាស់ទូទៅ អាចរក្សាទុកឯកសារឌីជីថលលើអ៊ីនធឺណិតដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក។ បច្ចុប្បន្ន មិនថាក្នុងស្ថាប័នរដ្ឋបរទេសគឺតែងតែប្រើប្រាស់សេវាប្រព័ន្ធនេះ និងពេញនិយមតំណ Google Drive, OneDrive, និង Dropbox។ ប្រព័ន្ធនេះត្រូវបានបែងចែក និងកំណត់វិធីសាស្ត្រតាមតម្រូវបច្ចេកវិទ្យា ដែលរដ្ឋនោះបានកំណត់ទុកដោយបទប្បញ្ញត្ត គឺអាចប្រើប្រាស់ធនធានរួម (Database, Analytics, Networking ជាអាទិ៍) ដោយពុំចាំបាច់មានការអនុញ្ញាតពីម្ចាស់សេវាកម្ម ឬលំបាកក្នុងការរក្សាហេដ្ឋារចនាសម្ព័ន្ធរូបវន្តទេ។[184] ករណីប្រើក្រដាសស្នាមច្រើនពេក គឺពិបាក។

---

[181] ពាក្យថា បញ្ញាសិប្បនិម្មិត (Artificial Intelligence-AI) ជាជ្រុងមួយនៃវិទ្យាសាស្ត្រកុំព្យូទ័រផ្តោតលើការ បង្កើតសុសវែរ (Software) កម្មវិធី ឬឧបករណ៍ ដែលមានសមត្ថភាពអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន និងអាចធ្វើសកម្មភាពជំនួសមនុស្សបាន ក្នុងការគិតវិភាគ យល់ដឹងពីបញ្ហាជាក់លាក់ណាមួយតាមលំនាំខួរក្បាលមនុស្ស, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។

[182] United Nation, "Seizing the of Opportunities of Safe, secure and Trustworthy Artificial Intelligence Systems for Sustainable Development" [ការចាប់យកប្រព័ន្ធបញ្ញាសិប្បនិម្មិតដែលមានសុវត្ថិភាព និងទំនុកចិត្តសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព], *General Assembly* 24-04670(E) 180324, A/78/L (2024): 49។

[183] Imane El Atillah, "How do you get ahead in an AI-dominated jobs market? These skills are what you need to master", *Euronews*, ២០២៤, https://www.euronews.com/next/2024/05/18/ (ទស្សនាចុងក្រោយថ្ងៃទី១៣ ឧសភា ២០២៤)។

[184] IBM-Saas, https://www.ibm.com/topics/iaas-paas-saas (ទស្សនាចុងក្រោយថ្ងៃទី១៣ ឧសភា ២០២៤)។ *សេវាកម្មនេះមាន ៣ប្រភេទតាមតម្រូវការប្រើប្រាស់៖ ១. Software as a Service(SaaS) គំរូនេះ គឺត្រូវបានរក្សាទុក គ្រប់គ្រងដោយម៉ាស៊ីនមេពីអ្នកផ្តល់សេវាតាមរយៈ Website, App & APIs ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទទួលបានសេវាភ្លាមៗ, ២.Platform as a Service(PaaS) ជាគំរូថ្នាលបង្កើតដែលសម្របខ្លួន និងធ្វើមាត្រដ្ឋានសម្រាប់ការអភិវឌ្ឍ ដំណើរការ និងគ្រប់គ្រងកម្មវិធីតាមអ៊ីនធឺណិតពីអ្នកផ្តល់សេវា, ៣. Infrastructure as a Service(IaaS) អ្នកផ្តល់សេវាអាចប្រើសេវានេះតាមតម្រូវការហេដ្ឋារចនាសម្ព័ន្ធឌីជីថលលើអ៊ីនធឺណិត ដោយអាចរៀបចំ គ្រប់គ្រង ថែទាំបណ្តាញមជ្ឈមណ្ឌលទិន្នន័យរបស់ខ្លួន និងធនធានរួមមាន ម៉ាស៊ីនមេ, បណ្តាញតភ្ជាប់ពីស្ថាប័នមួយទៅមួយទៀត, និងប្រព័ន្ធប្រតិបត្តិការ ជាអាទិ៍។* ពាក្យថា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាមូលដ្ឋានបម្រើឱ្យតម្រូវការសង្គម-សេដ្ឋកិច្ច, ឧ. បណ្តាញវារីប្បកម្ម។

ព័ត៌មាន ទិន្នន័យ របាយការណ៍របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) អាចនឹងត្រូវចងក្រង បច្ចុប្បន្នកម្ម ប្រើប្រាស់ប្រចាំ ដែលមានបរិមាណដ៏ច្រើនពេកនោះ ប្រាកដជាពិបាកដំណើរការ។ ឧទាហរណ៍. ព័ត៌មានឯកសារស្នើសុំ, អត្តសញ្ញាណកម្មម្ចាស់កម្មសិទ្ធិ, ផែនទីមាត្រដ្ឋាន, មូលដ្ឋានទិន្នន័យសុរិយោដីជាអាទិ៍។ ដូចនេះ ចាំបាច់ត្រូវការដំណោះស្រាយពីបច្ចេកវិទ្យាប្រព័ន្ធទិន្នន័យធំ។[185] ជាប្រព័ន្ធមួយ ដែលប្រមូលពីទិន្នន័យអ្នកប្រើប្រាស់រាល់ទំហំប្រតិបត្តិការ និងមានសមត្ថភាពអាចសិក្សា វិភាគ ឆ្លើយតបពីទម្លាប់ ជម្រើស និងកំណត់អត្តសញ្ញាណណាមួយបានច្បាស់លាស់ពីតម្រូវការរបស់អ្នកប្រើប្រាស់។ ជាធម្មតា ស្ថាប័នរដ្ឋបរទេស គឺប្រើប្រាស់ដើម្បីព្យាករអនាគត តម្រូវការអភិវឌ្ឍជាតិ និងជាវិធីសាស្ត្របង្ការហានិភ័យពីការក្លែងបន្លំនានា។[186]

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ចាំបាច់គួរមានយន្តការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងអភិវឌ្ឍន៍បណ្ដាមាត្រដ្ឋានបន្ថែម ៖

| **ការកសាងប្រព័ន្ធ** | **ដំណើរការលើអេឡិចត្រូនិក** | |
|---|---|---|
| ប្រព័ន្ធចុះបញ្ជីដីធ្លី | សម្រួលការបំពេញបែបបទព័ត៌មានរបស់អ្នកស្នើសុំ/អ្នកកាន់កាប់/ម្ចាស់កម្មសិទ្ធិករ កាត់បន្ថយសំណើព័ត៌មានច្រើនពេក និងឱ្យងាយយល់ លឿនជាងមុន ទំនុកចិត្ត | ធ្វើយ៉ាងណាត្រូវតែប្រមូលផ្ដុំទិន្នន័យពាក់ព័ន្ធការចុះបញ្ជីមានលក្ខណៈរួមតែមួយ និងទម្រង់ឌីជីថល ភាពងាយស្រួលទាំងក្រសួងសាមី និងអន្តរកម្ម |
| សេវាកម្មពិនិត្យព័ត៌មានសុរិយោដី | បច្ចុប្បន្នកម្មជាប្រចាំជំនួយពីបច្ចេកវិទ្យា ធានាភាពត្រឹមត្រូវអត្តសញ្ញាណ និងអាចងាយស្រួលធុរកិច្ចអចលនទ្រព្យដោយសុវត្ថិភាពខ្ពស់ និងរហ័ស | ត្រូវកាត់បន្ថយសំណើព័ត៌មាន ឬបែបបទសលាកបត្រក្បាលដី និងវិបាកស្ថានភាពជាប់បន្ទុកផ្សេងៗ |
| ប្រព័ន្ធស្នើសុំសេវាសាធារណៈផ្សេងៗ | ផ្ទាំងផតថលមិនស្មុគស្មាញរញ៉េរញ៉ៃ និងមានសោភណ្ឌភាពទាក់ទាញ នាំឱ្យអ្នកប្រើប្រាស់ងាយស្រួលអាន និងជ្រើសរើសទៅតាមប្រភេទសេវាសាធារណៈក្រសួង និងផ្ដល់អត្តសញ្ញាណផ្ទាល់ខ្លួនតែមួយដងគត់ គឺអាចស្នើសុំសេវាផ្សេងៗបាន | សម្រួលចរន្តដោយមិនត្រូវបំពេញព័ត៌មានច្រើនសារ ដដែលៗពេក និងកំណត់គោលដៅអ្នកប្រើប្រាស់សេវា (ទោះបីអាយុ១៨ ដល់លើស៦០ឆ្នាំក៏ងាយស្រួលទទួលសេវា) និងសម្រួលការទូទាត់អនឡាញ e-Payment |
| ប្រព័ន្ធចរន្តការរដ្ឋបាលក្រសួងសាមី | ចងក្រង គ្រប់គ្រង និងអភិវឌ្ឍន៍ចរន្តការសុវត្ថិភាពឯកសារសាធារណៈចេញចូល | គ្រប់គ្រងទិន្នន័យអត្តសញ្ញាណកម្ម គ្រប់ទម្រង់ និងសម្រួលដល់ការចូល |

[185] Geeksforgeeks, https://www.geeksforgeeks.org/cloud-based-services/ (ទស្សនាចុងក្រោយថ្ងៃទី១៣ ឧសភា ២០២៤)។ ពាក្យថា ទិន្នន័យធំ (Big Data) គឺសំដៅដល់សំណុំទិន្នន័យដែលមានបរិមាណច្រើនសន្ធឹកសន្ធាប់ ច្រើនប្រភព ច្រើនប្រភេទ និងមានកំណើនកើនឡើងយ៉ាងឆាប់រហ័ស ដែលតម្រូវឱ្យមានវិធីសាស្ត្រ និងបច្ចេកវិទ្យាពិសេសសម្រាប់ការគ្រប់គ្រង និងវិភាគទៅលើទិន្នន័យទាំងនោះ សម្រាប់ជាជំនួយដល់ការសម្រេចចិត្តរហ័ស និងបម្រើផលប្រយោជន៍ផ្សេងៗទៀត, ក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។

[186] Xuan Liu, “The Study on National Security in Big Data Era” [ការសិក្សាពីសន្តិសុខជាតិនៅក្នុងទិន្នន័យធំ], *Research Gate* (China) DOI:10.54097-v5i3.2006-ISSN:2766-824X lVol.5.No3 (2022): 191។

| | | |
|---|---|---|
| | ដោយផ្ទុកឃ្លាំងឯកសារអេឡិចត្រូនិក និង ដោយប្រើប្រាស់ផ្លាស់ប្តូរទិន្នន័យ | ទៅពិនិត្យពីមន្ត្រីគ្រប់ជាន់ថ្នាក់របស់ក្រសួងសាមី |
| ឃ្លាំងបណ្ណាល័យ | ចងក្រងរាល់ឯកសារដែលមានតម្លៃស្មើ ឬបណ្ណកម្មសិទ្ធិជាទម្រង់ឌីជីថល ដោយផ្ទៀងផ្ទាត់ ស្វែងរក និងនីត្យានុកូលកម្ម តាមទម្រង់ HTML ជាពិសេសគឺឯកសារច្បាប់នានា | ដោយស្រួលការស្វែងរកពាក្យពេចន៍ គោត្តនាម និងនាមកម្មសិទ្ធិករ ប្រភេទ ទំហំ ខ្នាតក្បាលដី ផែនទី និងព័ត៌មានដែលពាក់ព័ន្ធចាំបាច់ |

តារាងទី៨. យន្តការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្រសួង ដ.ន.ស

រាជរដ្ឋាភិបាលកម្ពុជា បានកសាងហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលរួចមកហើយ។ ដូចនេះ តាមបណ្តាក្រសួង ស្ថាប័ន គឺអាចប្រែសម្រួលសេវាសាធារណៈទៅជាស្វ័យប្រវត្តិកម្មអនឡាញ តាមរយៈការចនានិម្មាបនកម្មដោយខាងមន្ត្រីជំនាញរបស់ខ្លួនក៏បាន ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជួយរៀបចំអភិវឌ្ឍន៍ផតថលក៏បាន។ ការប្រើប្រាស់ផតថលទម្រង់សេវាសាធារណៈរដ្ឋាភិបាលឌីជីថលនេះ ត្រូវមានលក្ខណៈស្តង់ដាររួមតែមួយ និងអន្តរប្រតិបត្តិការរវាងក្រសួង ស្ថាប័នដទៃ។ ជាយោបល់នៅក្នុងន័យស្រាវជ្រាវចំពោះការបង្កើតផតថលប្រព័ន្ធចុះបញ្ជីអចលនវត្ថុ គឺគួរតែពិនិត្យលើលទ្ធភាព និងដាក់ឱ្យប្រើប្រាស់ក្នុងរយៈកាលសមស្របណាមួយ។

| ដំណើរការ | ជំហាន | |
|---|---|---|
| ការបង្កើត ប្រមូល និងបញ្ចូលទិន្នន័យព័ត៌មានក្បាលដីបឋម ដោយភ្ជាប់លេខក្បាលដី និងទិន្នន័យព្រំដីដោយស្វ័យប្រវត្តិ | វិភាគ និងវាស់វែងផ្ទៃដីដែលត្រូវចុះបញ្ជី ឱ្យរួចរាល់ជាមុនបង្កើតផែនទីអេឡិចត្រូនិកដែលឯកភាព អាចពិនិត្យមើលដោយទូលំទូលាយ។ ការវាស់វែងដីអាចធ្វើឡើងតាមរយៈនៃបច្ចេកវិទ្យា AI, ដ្រូន Drone, បណ្តាញផ្កាយរណបទាញបញ្ជូនមកស្ថានីយ៍វាស់វែងអចិន្ត្រៃយ៍ | ផ្ទៃក្រឡាប្រទេសកម្ពុជាតូច ដូចនេះវាស់វែងទុកលឿនបំផុត ៣ ទៅ ៤សប្តាហ៍ |
| ការកំណត់អត្តសញ្ញាណកម្មតែមួយលើកគត់ ការផ្ទៀងផ្ទាត់ ការធ្វើសន្ទានកម្មឌីជីថល និងការគ្រប់គ្រងអ្នកប្រើប្រាស់/អ្នកកាន់កាប់/ម្ចាស់ដី | ជំនួយពីបច្ចេកវិទ្យាដើម្បីឱ្យផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៅក្នុងអត្តសញ្ញាណកម្មដីធ្លីដែលបានកំណត់រវាងរដ្ឋ, កម្មសិទ្ធិករដែលបានចុះបញ្ជីត្រឹមត្រូវ និងអចលនវត្ថុដែលមិនទាន់ចុះបញ្ជី ឬកំពុងតែមាន និងដោះស្រាយវិវាទ។ ផ្ទៀងផ្ទាត់ក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យសាមីក្រសួង ឬរបស់ខាងរាជរដ្ឋាភិបាលដែលកំពុងមានស្រាប់ នៃបណ្តាញដាច់ដោយឡែក | បើធៀបទៅនឹងរបាយការណ៍ចំនួនក្បាលដី បណ្ណ (តារាងទី១០-១២) និងប្រជាសាស្ត្រ ២ ទៅ ៤សប្តាហ៍ |
| ដំណើរការចុះបញ្ជី (ទម្រង់មានលក្ខណៈដាច់ដោយដុំ និង មានលក្ខណៈជាប្រព័ន្ធ) | លើកបង្ហាញលម្អិតក្នុងចំណុច ៣.១.១.១ សលាកបត្រព័ត៌មានបន្ថយបរិមាណ, ជាឯកសារឌីជីថល, និងផ្អែកបទដ្ឋានគតិយុត្តចំពោះហត្ថលេខាឌីជីថល គឺមានតម្លៃស្មើនឹងត្រា ហត្ថលេខាដៃ ឬពុម្ពត្រារឹង | ទាំងពីរទម្រង់យ៉ាងយូរបំផុត ១៥ថ្ងៃ(^ជាដុំ) ៣០ថ្ងៃ(^ជាប្រព័ន្ធ) |
| ការបង្កើត ការគណនា ការកំណត់ ការកែសម្រួល ការគ្រប់គ្រងតំបន់វិនិច្ឆ័យ និងការរៀបចំស្រទាប់ទិន្នន័យ | ប្រើប្រាស់ឧបករណ៍វិភាគលំហ, និងបច្ចេកវិទ្យាពាក់ព័ន្ធនឹងភូមិសាស្ត្រ ដើម្បីគណនាដោយស្វ័យប្រវត្តិនៃតំបន់ក្បាលដីនីមួយៗ ដែលបានគូសប្រមូលទិន្នន័យទុកពីខាងលើ | យ៉ាងយូរ៣ថ្ងៃ |

| | | |
|---|---|---|
| នៃលេខកូដសម្គាល់តំបន់ភូមិសាស្ត្រ | | |
| ការវិនិច្ឆ័យ អនុម័ត និងការផលិតបណ្ណកម្មសិទ្ធិ/ផែនទីចុះបញ្ជី | លក្ខណៈឌីជីថល និងងាយស្រួលប្រើប្រាស់ ធន់មាំ និងការកាត់បន្ថយទុកដាក់ឯកសារច្រើន។ ដូចជាករណីការចេញវិញ្ញាបនបត្រសម្គាល់ជាទម្រង់ឌីជីថល pdf ឬរូបភាព | យ៉ាងយូរ៣ថ្ងៃ |
| ទំនួលខុសត្រូវ និងដំណោះស្រាយវិវាទ | ធានាការចែករំលែកទិន្នន័យរវាងក្រសួង ស្ថាប័នដែលជាព័ត៌មានអ្នកប្រើប្រាស់ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងបរិយាបន្ន។ រីឯព័ត៌មានដោយឡែករបស់អ្នកប្រើប្រាស់ដែលអាចបង្ហាញបាន ត្រូវបញ្ជាក់លម្អិតឱ្យបានត្រឹមត្រូវ។ គួរបន្ថែមយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | ១ ទៅ ២សប្តាហ៍ |

តារាងទី៩. ការផ្តល់យោបល់ចំពោះការបង្កើតផតថលប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ

#### ៣.១.១.១. ឌីជីថលូបនីយកម្មលើការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ និងមានលក្ខណៈជាប្រព័ន្ធ

យុទ្ធសាស្ត្រកំណែទម្រង់ដីធ្លីកម្ពុជាឆ្នាំ១៩៨៩ ចាំបាច់ត្រូវតែបដិសេធការទាមទារសិទ្ធិអចលនទ្រព្យមុនឆ្នាំ១៩៧០, និងទទួលស្គាល់ភោគៈត្រឹមត្រូវស្របច្បាប់ ឬកម្មសិទ្ធិឯកជន (បារាំងបាននាំនាំកម្មសិទ្ធិដំបូងបំផុតមកកម្ពុជា)។[187] នេះជាគន្លឹះសំខាន់ ដើម្បីទប់ស្កាត់វិវាទកើតឡើងម្តងទៀត។ ប៉ុន្តែ វិវាទដែលកើតឡើងជាបន្តបន្ទាប់ក្នុងសង្គមខ្មែរ ភាគច្រើនអចលនវត្ថុដែលមិនទាន់ចុះបញ្ជី, តែធ្វើការផ្ទេរកម្មសិទ្ធិតាមរយៈអាជ្ញាធរឃុំ សង្កាត់ និងឈានរហូតដល់នីតិវិធីផ្អកផ្តាក់ឱ្យចុះបញ្ជីរបស់តុលាការ។[188] ករណីនេះ គួរតែបញ្ឈប់សកម្មភាពផ្ទេរកម្មសិទ្ធិមិនទាន់ចុះបញ្ជី ពិព្រោះដោយសារម្ចាស់កម្មសិទ្ធិគ្មានលទ្ធភាពទៅចុះបញ្ជី ទើបសុខចិត្តលក់ រួចផ្ទេរសិទ្ធិឱ្យអ្នកទិញថ្មី ជាអ្នកទៅចុះបញ្ជីដោយខ្លួនឯង។ នេះជាករណីសិក្សា ដែលខាងអាជ្ញាធរឃុំ សង្កាត់ឧស្សាហ៍ធ្វើឱ្យណាស់ទើបកើតជាទម្លាប់ ព្រោះអាងជាថ្នូរ។ ដល់ពេលមានវិវាទ គ្មានប្រភពព័ត៌មានកម្មសិទ្ធិត្រឹមត្រូវ ឆ្លើយថាអត់ដឹង និងរុញសមត្ថកិច្ចដាក់គ្នា។ ពាក្យស្លោកថា "បរិយាកាសគ្មានវិវាទ" គួរតែមានប្រសិទ្ធភាពក្នុងការដោះស្រាយ និងបង្កើនទំនុកចិត្តពីកម្មសិទ្ធិករស្របច្បាប់។ បរិការណ៍នេះ នឹងលើកយកមកបង្ហាញបន្តក្នុងជំពូកទី៤។

តាមរយៈការចូលរួមពិព័រណ៍ផទិការដ្ឋាភិបាលឌីជីថល ក៏បានសាកសួរជាច្រើនសំណួរពីមន្ត្រីសុរិយោដីម្នាក់ដោយក្នុងនោះឆ្លើយថា "ការចុះបញ្ជីអចលនវត្ថុតាមប្រព័ន្ធអនឡាញ ប្រាកដជាអាចទៅរួច! ប្រហែលជាក្រសួង ដ.ន.ស អាចនឹងដាក់ឱ្យអនុវត្តជាបណ្តោះអាសន្ននៅចុងឆ្នាំ២០២៤នេះ ដោយសារបច្ចុប្បន្នក្រសួងកំពុងតែនៅបន្តសិក្សាជាមួយអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាននៅឡើយ និងមន្ត្រីជឿជាក់ថាអាចទទួលបានជោគជ័យ (នេះបើតាមការអះអាងពីមន្ត្រីសុរិយោដីនៅស្តង់ពិព័រណ៍ផទិកាឌីជីថល, ២០២៤)។"[189]

---

[187] ច្បាប់ភូមិបាល២០០១, មាត្រា៤២។ សេចក្តីព្រាងច្បាប់ភូមិបាលថ្មី២០២៣, មាត្រា១០, ១១ និង១១៦។ *[មុនថ្ងៃ៣១ សីហា ២០០១]*

[188] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់ចុះបញ្ជី, លេខ២១៤ប្រក.ដនស, ២១ វិច្ឆិកា ២០១៤, ប្រការ១ និង២។

[189] បានអនុញ្ញាតឱ្យថតខ្សែអាត់សម្លេង (នៅជាមួយអ្នកនិពន្ធ)។ ពាក្យថា សារកិច្ច (Messaging) ជាដំណើរការនៃការផ្ញើសារ និងទទួលសារតាមរយៈបរិក្ខារអេឡិចត្រូនិក ដូចជា កុំព្យូទ័រ ទូរសព្ទ ថាប្លេត ជាអាទិ៍។

ប្រទេសកម្ពុជា គិតត្រឹមខែឧសភា ឆ្នាំ២០២៤ ការងាររដ្ឋបាលដីធ្លី បន្តចែកបណ្ណកម្មសិទ្ធិ និងវាស់វែងក្បាលដីជាបន្តបន្ទាប់នៅឡើយ។ យោងតាមរបាយការណ៍ កម្ពុជាមានក្បាលដីបណ្ដោះអាសន្ន ដែលបានវាស់វែងរួចរាល់ប្រមាណ៧លាន និងផ្ដល់ជូនបណ្ណកម្មសិទ្ធិជាង៦.៨លានក្បាលដី។ បើគិតតួលេខរាយ គិតចាប់ពីចាប់ផ្ដើមរហូតដល់ឆមាសទី១ ឆ្នាំ២០២៣ បានចេញបណ្ណកម្មសិទ្ធិចំនួន៦.៨៩៥.៨៤០បណ្ណ ស្មើនឹង៩៨,៥% នៃចំនួនក្បាលដីប៉ាន់ស្មានដំបូងជាង៧លានបណ្ណ។[190] នាពេលអនាគត ស្របតាមបរិវត្តកម្មឌីជីថល និងការត្រៀមអនុវត្តបច្ចេក-វិទ្យាផ្កាយរណប កម្ពុជាបាននឹងកំពុងសាកល្បងប្រើប្រាស់ដ្រូនភ្ជាប់ AI ក្នុងការផលិតផែនទី និងបន្តវាស់វែងលើផ្ទៃក្រឡាសរុបទូទាំងប្រទេស ដែលអ្នកជំនាញប៉ាន់ស្មានសរុបប្រមាណ ៥លានក្បាលដីបន្ថែមទៀត ស្មើនឹងសរុបទូទាំងប្រទេសជាង ១២លានក្បាលដី។ ដូចនេះ ការចុះបញ្ជីដំបូងជាបន្តបន្ទាប់ ពិតប្រាកដណាស់ នឹងត្រូវស្វែងរកដំណោះស្រាយដើម្បីពន្លឿនដល់ការចុះបញ្ជី។ រីឯទីតាំងត្រូវទៅចុះបញ្ជី និងពេញនិយមក្នុងប្រទេសកម្ពុជាទាំង២៖ ១. ការិយាល័យច្រកចេញចូលតែមួយ និងឃុំ សង្កាត់ បានទទួលសំណើ(ទូទៅ)សរុប១៤៩.០៩៩សំណើ ក្នុងនោះថ្នាក់កណ្ដាលចំនួន៨៧៤សំណើ និងថ្នាក់រាជធានី ខេត្តចំនួន១៤៨.២០៣សំណើ, ក្រៅពីនោះ ប្រជាពលរដ្ឋចុះទៅទទួលសេវាកម្មនៅ ២.មន្ទីរការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។[191]

ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្លាស់ប្ដូរដាក់ឱ្យប្រើប្រាស់ការចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុតាមប្រព័ន្ធអនឡាញ, តើអាចផ្ដល់ទំនុកចិត្ត ធានាអធិបតេយ្យភាពដីធ្លីដល់ប្រជាពលរដ្ឋដែរឬទេ?

**ក.ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុមានលក្ខណៈដាច់ដោយដុំ**

"ប្រព័ន្ធចុះបញ្ជីដីធ្លីដែលមិនពេញលេញ គឺបញ្ចេះជម្លោះ អំពើពុករលួយលើការកាន់កាប់ដីធ្លី (Benbunan-Fich and Castellanos, ២០១៨)។"[192] ការគ្រប់គ្រងដីធ្លី ចាំបាច់ត្រូវមានវិធានការបន្ទាន់ក្នុងការកែសម្រួលថ្មី។ ចំនួនប្រជាជនកម្ពុជា និងបណ្ណកម្មសិទ្ធិ គឺមានចំនួនតិច, ចុះប្រសិនបើថ្ងៃអនាគតមានកំណើន និងតម្រូវការខ្ពស់ តើវិវាទដីធ្លីនៅតែបន្តជាជំងឺ? ដូចនេះ ត្រូវតែមានថ្នាំសះ ទាំងបង្ការ និងព្យាបាល។ "ប្រហែលមួយភាគបីនៃបណ្ដាប្រទេសទូទាំងពិភពលោកត្រូវបានប៉ាន់ប្រមាណថា គឺមានប្រព័ន្ធកត់ត្រាដីធ្លីប្រភេទឌីជីថលមួយចំនួនធំ(Shang and Price, ២០១៩)។"[193] របាយការណ៍ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ គឺសម្រេចបាន៦២៨.៥០១បណ្ណ

---

[190] ឆាន់ សាផាន, *របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៣ និងលើកទិសដៅការងារបន្ត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់*, លេខ០២២ជនស/អរប/នរប/របា, (ភ្នំពេញ៖ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់, ៧ កក្កដា ២០២៣), ១០-១២។ *[របាយការណ៍ក្រៅផ្លូវការគិតត្រឹមខែមេសាឆ្នាំ២០២៤ ចេញបណ្ណកម្មសិទ្ធិទាំង២ជំហានចំនួន**៧.៦៥១.១២៨បណ្ណ**]*

[191] ដដែល, ១០។ ពាក្យថា បច្ចេកវិទ្យាផ្កាយរណប (Satellite Technology) គឺជាបច្ចេកវិទ្យាប្រើប្រាស់ផ្កាយរណបក្នុងការបញ្ជូនទិន្នន័យ រូបភាព សម្លេង វីដេអូ និងព័ត៌មានដើម្បីសម្រួលទៅដល់ប្រព័ន្ធទំនាក់ទំនង, ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥។

[192] Arturo Castellanos, and Raqule Benbunan-Fi., "Digitalization of Land Records: From Paper to Blockchain" [ឌីជីថលូបនីយ-កម្មនៃកំណត់ត្រាដីធ្លី៖ ផ្លាស់ប្ដូរពីប្រើក្រដាស ទៅប្លុកឆេន], *Research Gate* (San Francisco), (2018): 1-3។

[193] Qiuyun Shang, and Allison Price "A Blockchain-Based Land Titling Project in the Republic of Georgia: Rebuilding Public Trust and Lessons for Future Pilot Projects" [គម្រោងផ្ដល់បណ្ណកម្មសិទ្ធិដីធ្លីផ្អែកលើប្លុកឆេននៅសាធារណរដ្ឋហ្សកហ្ស៊ី៖ ទំនុកចិត្តសាធារណៈឡើងវិញ និងគម្រោងមេរៀនសម្រាប់សាកល្បងពេលអនាគត], *Research Gate* (Georgia) DOI:10.1162/inov-a-00276 (2019): 72-78។

(គិតទាំងសម្បទានដីសេដ្ឋកិច្ច) នេះបើគិតត្រឹមឆមាសទី១ ឆ្នាំ២០២៣។[194] រយៈពេលនៃការចុះបញ្ជី បានកំណត់ជាអតិបរមានៃការផ្ដល់សេវានៃដំណើរការសរុបគឺ៦០ថ្ងៃ និងមានសុពលភាពអចិន្ត្រៃយ៍។[195] ប៉ុន្តែដំណោះស្រាយលើការចុះបញ្ជីតាមប្រព័ន្ធអនឡាញ អាចនឹងកាត់បន្ថយរយៈពេលមកត្រឹមយ៉ាងយូរ១០ ទៅ១៥ថ្ងៃ។

| ប្រភេទ | គោលដៅ | ស្ថាប័នកាន់កាប់ | ចំនួនទីតាំង | ចំនួនបណ្ណ | ទំហំ (ហិកតា) |
|---|---|---|---|---|---|
| ដីរដ្ឋ | សម្បទានដីសេដ្ឋកិច្ច | | ១៨៦ | ២.១០៤ | ៧២៩.៤៦៦ |
| | តំបន់ការពារ/ព្រៃស្ការ | ក្រសួងបរិស្ថាន | ១១ | ៧០ | ១៩៨.៦២៥ |
| | | ក្រសួងកសិកម្ម | ៩ | ៣០ | ២២.៣៣៥ |
| **ដីឯកជនរបស់បុគ្គលឯកជន** | **៦២៥.២៧៧បណ្ណ** | | | | |
| ដីសហគមន៍ជនជាតិដើមភាគតិច | ៤០សហគមន៍ ស្មើនឹង១.០៣៣បណ្ណ, ទំហំ៤០.៧៣២,៤២ហិកតា និង៣.៨៩៣គ្រួសារ | | | | |
| ដីគរុភណ្ឌវត្ត | ១.៩៣៦វត្ត ស្មើនឹង២.៤០៤បណ្ណ | | | | |

តារាងទី១០. របាយការណ៍ចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

ក្រសួង ស្ថាប័នសាមី ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) អាចវិវត្តតភ្ជាប់បណ្ដាញអ៊ីនធឺណិតនៃគេហទំព័រ៣.០ (Web3.0) ដែលជាគេហទំព័រផ្ដោតសំខាន់ការអាន-ការសរសេរ-កម្មសិទ្ធិឌីជីថល។ ឱ្យងាយយល់ជាគេហទំព័របច្ចេកវិទ្យាចុងក្រោយរបស់សកលលោក ដែលទូទៅចំណាំថា "https://www." មានបណ្ដាញវិមជ្ឈការជាមួយបណ្ដាញបច្ចេកវិទ្យាដទៃដោយសុវត្ថិភាព ជាពិសេស ប្លុកឆេនដែលអ្នកប្រើប្រាស់អាចបង្កើតគេហទំព័រ និងអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ មិនចាំបាច់ឆ្លងអន្តរការីផ្ទេសផ្ទាសច្រើនពេក និងលក្ខណៈស្វ័យប្រវត្តិ។[196] បន្ទាប់មកត្រូវបង្កើតដែនកំណត់នៃលំហគេហទំព័រនោះ ជាសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា។[197] បណ្ដាញសាធារណៈផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ភាគច្រើនឃើញបង្កើតតាមរយៈដែនកម្រិតទី១តាមកូដប្រទេស (ccTLD) សម្រាប់ប្រទេសកម្ពុជាដែលទទួលស្គាល់ដោយសាជីវកម្មអ៊ីនធឺណិតសម្រាប់ការផ្ដល់ឈ្មោះ និងលេខ (ICANN) ដោយកំណត់ខាងចុងគេហទំព័រ ".gov.kh"។[198] ការចូលទៅកាន់តំណភ្ជាប់ផតថល ឬថ្នាលសេវាកម្មសាធារណៈ តម្រូវឱ្យក្រសួង ដ.ន.ស អាចបង្កើតជាឃ្យូ អរ កូដស្តង់ដារ ដើម្បីភាពងាយស្រួលដល់អ្នកប្រើប្រាស់តាមរយៈ https://qr.gov.kh របស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។

---

[194] ដូច១៩០, ១១។ ពាក្យថា បណ្ដាញដាច់ដោយឡែក (Private Network) ជាបណ្ដាញកុំព្យូទ័រដែលរៀបចំដាច់ដោយឡែកពីអ៊ីនធឺណិត សម្រាប់តភ្ជាប់តែផ្ទៃក្នុងរវាងក្រសួង ស្ថាប័នដើម្បីធានាសុវត្ថិភាព និងបង្កើនប្រសិទ្ធភាពប្រព័ន្ធរដ្ឋាភិបាលឌីជីថល, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥។ *ពាក្យ អ្នកកាន់កាប់ដី ឬម្ចាស់ដី ឬអ្នកប្រើប្រាស់សេវាឌីជីថល ឬអ្នកស្នើសុំ ជាន័យរួម*។

[195] ប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៣៥៦សហវ.ប្រក, ២៦ មីនា ២០១៩, ២២-៤៤, (ពីពេលនេះតទៅហៅថា ប្រកាសអន្តរក្រសួងលេខ៣៥៦សហវ.ប្រក)។

[196] UNDP, https://www.undp.org/publications/web3for2030-how-can-web3-help-achieve-sustainable-development-goals (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២៤)។

[197] *Country Code Top-Level Domain (ccTLD), Internet Corporation for Assigned name and number (ICANN)*។

[198] សេវាចុះឈ្មោះដែនជាតិ .kh របស់រាជរដ្ឋាភិបាល, https://www.domain.gov.kh (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២៤)។

គំនិតយោបល់នេះ មិនមែនជាការគិតម្តង ធ្វើម្តងនោះទេ ប៉ុន្តែ ជាការគូសវាសសំដៅដល់អនាគត និងស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ នីតិវិធីការចុះបញ្ជីដំបូងនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំតាមយៈ៖ ទី១.ការស្នើសុំចុះបញ្ជី អ្នកកាន់កាប់ដី ឬម្ចាស់ដី ឬអ្នកប្រើប្រាស់សេវាកម្មឌីជីថល ត្រូវប្រាកដថាក្បាលដីនោះពុំមានជាប់ជាមួយក្បាលដីរដ្ឋ ឬ/និងស្ថិតក្នុងតំបន់ដែលអាជ្ញាធរមានសមត្ថកិច្ចអាចកំណត់ព្រំប្រទល់ដីរដ្ឋបាន។ កាលៈទេសៈនេះ អាចវិនិច្ឆ័យដឹងច្បាស់ពីប្រព័ន្ធឌីជីថល តាមរយៈសម្រង់សុរិយោដី។ រដ្ឋបាលសុរិយោដីមានកាតព្វកិច្ចបញ្ចូលទិន្នន័យក្បាលដី ចំពោះការចុះបញ្ជីដីដាច់ដោយដុំរួចហើយនោះ ទៅក្នុងតំបន់វិនិច្ឆ័យ និងផែនទីដោយស្វ័យប្រវត្តិ ពេលកំពុងចុះអនុវត្តការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។ អ្នកប្រើប្រាស់សេវាកម្មឌីជីថល អាចស្កេនយ្យូ អរ កូដស្គង់ដារចំពោះផតថលសេវាកម្មចុះបញ្ជីរបស់ក្រសួង ដ.ន.ស តាមរយៈអត្តសញ្ញាណឌីជីថលរបស់ខ្លួន ដែលបានស្នើសុំតាមថ្នាល CamDigiKey រួចមក។ ម្យ៉ាងវិញ ថ្នាលនេះអាចនឹងអនុវត្តដោយប្រសិទ្ធភាពជាមួយលេខកូដអត្តសញ្ញាណប្រជាជន (UIC) អ្នកប្រើប្រាស់អាចស្នើសុំប្រើសេវាសាធារណៈចុះបញ្ជីអនឡាញបាន។ គិតត្រឹមខែមិថុនា ឆ្នាំ២០១២ ដល់ខែកក្កដា ឆ្នាំ២០២៣ គឺក្រសួងមហាផ្ទៃបានផ្តល់អត្តសញ្ញាណបណ្ណចំនួន១២.៣៣៦.២៣៥នាក់ ក្នុងនោះនីតិភាពឡើងទៅចំនួន១១.៦៧០.៨៦២នាក់។[199]

រាល់សំណើឯកសារដែលមានលទ្ធភាពគតិយុត្ត អាចត្រូវបាននីត្យានុកូលកម្មតាមរយៈបច្ចេកវិទ្យា AIs អានឯកសារជាភាសាខ្មែរ ផ្លាស់មកទម្រង់ឌីជីថលស្វ័យប្រវត្តិបាន។ ដូចនេះ មន្ត្រីទទួលបន្ទុកចុះបញ្ជីងាយស្រួលការពិនិត្យ និងផ្ទៀងផ្ទាត់ ដោយកាត់បន្ថយកំហុសនៃអត្តសញ្ញាណពលរដ្ឋ។[200] នៅលើផ្ទាំងផតថលសេវាកម្ម ត្រូវតែមានជំនួយការអានអក្ខរកម្មជាសម្លេង រាប់ចាប់តាំងពីការចុចចូល និងការដាក់ឯកសាររណប។ វិធីនេះ អាចជួយដល់ពលរដ្ឋជនពិការភ្នែក ងាយស្រួលស្តាប់ និងមានលទ្ធភាពទទួលយកសេវាកម្មតាមប្រព័ន្ធជំនួយ Telegram នៃ SariKaDGF https://t.me/sarika_dgf_bot នោះ AI នឹងជួយអានមិនឱ្យខ្វះមួយពាក្យ មួយសញ្ញាឡើយ។ ការស្នើសុំសេវាកម្មឌីជីថល ដំណាក់កាលបន្ទាប់គួរតែសាកល្បងទូទាត់កម្រៃសេវាយ៉ាងតិច ១.០០០ (មួយពាន់) រៀល តាម e-Payment បច្ចេកវិទ្យាប្រព័ន្ធធនាគារ (៣.២.២.១)។ ក្នុងន័យនេះ ដើម្បីជៀសវាងការចុចចូលច្រើនសារ ឬដាក់ឯកសារស្នើហើយ បោះបង់សេវា។ ករណីបើកម្មវត្ថុដីធ្លីចុះបញ្ជីនោះ ប្រព័ន្ធប្លុកឆេនអាចឆែកឃើញថា "ជាប់វិវាទ ឬកំពុងដោះស្រាយវិវាទ" មន្ត្រីត្រូវកំណត់ប្រព័ន្ធផែកនោះ ឱ្យរត់ចូលទៅផ្នែកម្ខាងនៃប្រព័ន្ធ ដោយទុកមួយឡែក រួចរុញទៅកាន់ប្រព័ន្ធគណៈកម្មការសុរិយោដីដើម្បីដោះស្រាយវិវាទជាមុន (ពេលវេលាអាចត្រូវពន្យារ និងត្រូវជូនដំណឹងត្រឡប់ទៅអ្នកកាន់កាប់ដី ឬម្ចាស់ដី ឬអ្នកប្រើប្រាស់សេវាកម្មឌីជីថល អំពីមូលហេតុពិត)។[201]

---

[199] Hun Sirivath, "*ក្រសួងមហាផ្ទៃដាក់យុទ្ធនាការផ្តល់អត្តសញ្ញាណបណ្ណចាប់ពីចុងខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែតុលាឆ្នាំ២០២៣*," *Eac. News*, ២០២២, https://eacnews.asia/home/details/16482 (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២៤)។ ពាក្យថា បណ្តាញ-វិមជ្ឈការ ជាបណ្តាញមួយប្រភេទដែលថ្នាំងត្រូវតភ្ជាប់សេវូបករណ៍ ឬកុំព្យូទ័រមេច្រើន ដោយធ្វើអន្តរកម្មឯករាជ្យ។

[200] ជំនួយ AIs ដែលកម្ពុជាកំពុងប្រើប្រាស់ និងអភិវឌ្ឍន៍, https://ai.techostartup.center (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២៤), (បទពិសោធន៍ផ្ទាល់ខ្លួន៖ *អាចបកប្រែអត្តសញ្ញាណបុគ្គល ទៅជាអត្តសញ្ញាណឌីជីថល*)។

[201] ច្បាប់ភូមិបាល២០០១, មាត្រា២៣៧។ *ករណីដោយផ្ទាល់. រដ្ឋបាលសុរិយោដីនិងគណៈកម្មការរដ្ឋបាលមានភារៈសម្របសម្រួល ប៉ុន្តែបើស្វ័យប្រវត្តិកម្មបែបនេះ ជាយោបល់គួរតែរុញទៅគណៈកម្មការគោលណាមួយទទួលភារៈ*។

ក្រោយពីបានសន្ទានកម្មឯកសារណបត្រឹមត្រូវរួច ព័ត៌មានលម្អិតទាក់ទិននឹងអ្នកស្នើសុំ គឺត្រូវបានបង្ហាញក្នុងប្លុក (Block) ទូទាំងបណ្តាញក្រសួង ដ.ន.ស, អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ និងរដ្ឋបាលសុរិយោ-ដី។ ព័ត៌មានទាំងនេះ ក្រសួង ដ.ន.ស មានភារៈទទួលខុសត្រូវ ចំពោះព័ត៌មានសម្ងាត់អត្តសញ្ញាណបុគ្គល។

| **ប្លុកដីតែមួយនៃអ្នកស្នើសុំមួយ** |
|---|
| ប្រព័ន្ធអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ |
| ប្រព័ន្ធរដ្ឋបាលសុរិយោដី |
| ប្រព័ន្ធគណៈកម្មការ និងអន្តរកម្មពាក់ព័ន្ធ |
| លេខប្លុកប្រព័ន្ធបណ្តាញវិមជ្ឈការ |
| លេខបណ្តាញវិមជ្ឈការនៃតំបន់ចុះបញ្ជី |
| ប្រព័ន្ធប្រវត្តិកាន់កាប់អចលនវត្ថុក្នុងតំបន់ ភូមិសាស្ត្រ |
| លេខកូដសម្គាល់ភូមិសាស្ត្រ |
| ប្រព័ន្ធតំបន់វិនិច្ឆ័យ និង/ឬវាយតម្លៃអចលនទ្រព្យ |
| ប្រព័ន្ធនីត្យានុកូលកម្មនៃអត្តសញ្ញាណអ្នកស្នើសុំ |

| **អ្នកស្នើសុំទី១** | **អ្នកស្នើសុំទី២** | **អ្នកស្នើសុំទី៣** |
|---|---|---|
| អត្តសញ្ញាណឌីជីថលនៃអ្នកប្រើប្រាស់ទី១ | អត្តសញ្ញាណឌីជីថលនៃអ្នកប្រើប្រាស់ទី២ | អត្តសញ្ញាណឌីជីថលនៃអ្នកប្រើប្រាស់ទី៣ |
| គោត្តនាម និងនាម | គោត្តនាម និងនាម | គោត្តនាម និងនាម |
| អត្តសញ្ញាបណ្ណ ឬសំបុត្រកំណើត | អត្តសញ្ញាបណ្ណ ឬសំបុត្រកំណើត | អត្តសញ្ញាបណ្ណ ឬសំបុត្រកំណើត |
| សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ | សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ |
| អ៊ីម៉ែល លេខទូរសព្ទ គណនីធនាគារ | អ៊ីម៉ែល លេខទូរសព្ទ គណនីធនាគារ | អ៊ីម៉ែល លេខទូរសព្ទ គណនីធនាគារ |
| ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត | ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត | ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត |
| លេខកូដសម្គាល់បុគ្គល និងជីវមាត្រ | លេខកូដសម្គាល់បុគ្គល និងជីវមាត្រ | លេខកូដសម្គាល់បុគ្គល និងជីវមាត្រ |
| បន្ទុក(បើមាន) និងប្រព័ន្ធកិច្ចគាំពារសង្គម | បន្ទុក(បើមាន) និងប្រព័ន្ធកិច្ចគាំពារសង្គម | បន្ទុក(បើមាន) និងប្រព័ន្ធកិច្ចគាំពារសង្គម |

តារាងទី១១. ប្លុកព័ត៌មានអ្នកស្នើសុំក្នុងបណ្តាញផតថល

អ្នកស្នើសុំ គឺត្រូវតែបំពេញព័ត៌មានទីតាំងត្រូវចុះបញ្ជីដីនោះឱ្យបានត្រឹមត្រូវ និងឱ្យលម្អិតតាមរយៈ Location Google earth map (ដែលតភ្ជាប់ស្រេចនៃឧបករណ៍ឆ្លាតវៃរបស់អ្នកប្រើប្រាស់)។[202] ទី២.ការងារបច្ចេកទេសក្រុមវាល បន្ទាប់ពីទទួលការអនុញ្ញាតពីប្រព័ន្ធសារជូនដំណឹងរបស់ប្រព័ន្ធរដ្ឋបាលសុរិយោដី នៅក្នុងតំបន់នៃដីចុះបញ្ជីនោះ ត្រូវជូនដំណឹងផ្ញើសារកិច្ច ឬបច្ចេកវិទ្យានាំសារ https://nomsa.gov.kh ទៅកាន់អ្នកស្នើសុំ ឬជនដែលពាក់ព័ន្ធផលប្រយោជន៍*៣(បី)ថ្ងៃយ៉ាងតិច* មុនចុះវាស់ព្រំដីសម្រង់សុរិយោដី។ ការជូនដំណឹងផែនការវាស់ដីចុះបញ្ជីនេះអាចមានដីកសិកម្មជនបទ, ដីលំនៅឋានជនបទ, ដីទីប្រជុំជនក្នុងស្រុក, ដីជាយទីប្រជុំជនខេត្ត, ដីជាយក្រុងភ្នំពេញ, ដីទីប្រជុំជនរាជធានីភ្នំពេញ។[203] ការវាស់វែង ចាំបាច់ត្រូវវិវត្តន៍ដោយការប្រើប្រាស់ AI និងឧបករណ៍ដ្រូន ជាជំនួយ។ នាបច្ចុប្បន្ន ក្រសួង ដ.ន.ស បានសហការជាមួយម្ចាស់ជំនួយបរទេស និងអាជ្ញាធរមូលដ្ឋានក្នុង

[202] អាចរកបានសាកល្បងនៅ៖ https://earth.google.com/web/ (ទស្សនាចុងក្រោយថ្ងៃទី១៦ ឧសភា ២០២៤)។

[203] ច្បាប់ភូមិបាល២០០១, មាត្រា២៣៤-២៣៧។

ការប្រើប្រាស់ឧបករណ៍ AI សាកល្បងក្នុងខេត្តកំពង់ឆ្នាំង ឃុំពានី ដែលមានភូមិចំនួន៩ និងបន្តនៅខេត្តកំពង់-ចាម, កណ្តាល និងស្វាយរៀង។ ជំហាននៃការវាស់នេះ ក្នុងមួយថ្ងៃអាចវាស់បានជាង៣.០០០ហិកតា និងយកទៅកសាងផែនទីសិប្បនិម្មិត (ប្រើពេលវេលាយូរជាង៧ថ្ងៃ៖ ដោយសារខ្វះបច្ចេកទេសអនុវត្ត) ដើម្បីបន្តផ្ទៀងផ្ទាត់ទីវាលជាមួយឧបករណ៍ DGPS ទំនើបបន្ថែម។ ជាលទ្ធផល ស្វែងរកពីភាពលម្អៀងពីគ្នាតែ0,០១ប៉ុណ្ណោះ។[204] ប្រសិនបើ ក្រសួង ដ.ន.ស ចុះវាស់វែងកំណត់ព្រំដីត្រូវចុះបញ្ជីជាមុន ប្រាកដជាផ្តល់ភាពងាយស្រួលដល់ការផ្តល់សេវាគាប់ចិត្តនៃការចុះបញ្ជីដីជូនពលរដ្ឋ។ ប៉ុន្តែ បើដំណើរការដើរទទឹមគ្នាវិញ ប្រាកដជាដើរមួយជំហាន ត្រូវដោះមួយជំហានមិនខាន។ ក្រសួង ដ.ន.ស ចាំបាច់ត្រូវតែពន្លឿនដល់ការកំណត់លេខកូដសម្គាល់ភូមិសាស្ត្របន្ថែមទូទាំងប្រទេស ដោយសារបច្ចុប្បន្នឃើញមានត្រឹមតែការកំណត់លេខកូដប៉ុស្តិ៍ក្នុងតំបន់សំខាន់ៗ និងបញ្ជីរាយនាមភូមិសាស្ត្រ ឬនិយាមការមិនទាន់រួចរាល់។[205] ឧទាហរណ៍. បើចង់ស្វែងរកនៅភូមិអូរធំ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ គឺត្រូវវាក៖ 1/102/10201/1020101/E103°01′57.372″N13°30′50.831″ ។

នគរបាលការពារព្រំដែន សព្វថ្ងៃក៏កំពុងប្រើប្រាស់ផែនទីប្រព័ន្ធព័ត៌មានវិទ្យាភូមិសាស្ត្រ (GIS) សម្រាប់ការបង្កើតផែនទី និងរបាយការណ៍ពីព័ត៌មានជាក់ស្តែងនៃភូមិសាស្ត្រឋានលេខា, និងប្រព័ន្ធវាស់វែងទីតាំងដោយប្រើ-ប្រាស់សញ្ញាផ្កាយរណប (GPS & GNSS) ដើម្បីវាស់រកនិយាមកា និងស្វែងរកទីតាំងភូមិសាស្ត្រ តាមរយៈការរៀបចំលេខកូដសម្គាល់ភូមិសាស្ត្ររាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិរបស់ក្រសួង ដ.ន.ស។ ការរៀបចំផែនការវាស់វែងផ្ទៀងផ្ទាត់ដើម្បីកំណត់ដាមទុម២០២៣ (Datum) ងាយស្រួលដល់ការអានផែនទី និងប្រើប្រាស់យ៉ាងត្រឹមត្រូវលើផែនទីក្រដាស និងផែនទីឌីជីថល ដែលអាចមានលទ្ធភាពបែងចែកច្បាស់លាស់រវាងដាតទុម WGS-84 និងដាតទុម Indian-60 [គម្រោងអភិវឌ្ឍន៍ដាតទុម CGD23 & Server 5CORS ដោយ JICA]។[206]

ការវាស់វែងដែលមានលក្ខណៈត្រឹមត្រូវ ជាគុណប្រយោជន៍ទៅដល់គ្រប់មជ្ឈដ្ឋាន ក្នុងការកំណត់កូអរដោនេជាក់លាក់ ដូចនេះ គួរតែវិវត្តការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាភូមិសាស្ត្រGIS ជំនួយពីបច្ចេកវិទ្យា AI, ផ្កាយរណប (ចាប់សញ្ញាពីប្រព័ន្ធរណបលើអាកាស បញ្ជូនទិន្នន័យទៅភូមិសាស្ត្រស្ថានីយ៍វាស់វែងអចិន្ត្រៃយ៍), និងប្រព័ន្ធលើសេវាកម្មផែនទីអ៊ីនធឺណិត (Web Mapping Service)។[207] បច្ចេកទេសនេះក៏មានប្រើប្រាស់ក្នុងប្រទេសហូឡង់ ប្រទេសហុ្សកហ្ស៊ី និងប្រទេសវៀតណាមផងដែរ។ កំណត់ត្រានៅលើផែនទីឌីជីថល ត្រូវកំណត់អត្តសញ្ញាណ-

---

204 កណ្តៀរ, "ការចុះបញ្ជីដីធ្លីក្នុងសហសម័យដោយប្រើសាកល្បង AI នៅកម្ពុជា," *Facebook*, ២០២៣, https://www.facebook.com/watch/?v=4333976340159848&_rdc=1&_rdr (ទស្សនាចុងក្រោយថ្ងៃទី១៧ ឧសភា ២០២៤)។ ពាក្យថា ដាតទុម (Datum) ជាបន្ទាត់រង្វាស់នៃចំណុចយោងកូអរដោនេនៃរយៈទទឹង និងរយៈបណ្តោយលើផ្ទៃដី ដែលមានលក្ខណៈមួយពិសេស ដល់ការបង្កើតទីតាំងជាក់លាក់ ឬបង្គោលព្រំដីក្នុងការគណនាលំហភូមិសាស្ត្រ។

205 Postal, https://www.cambodiapostalcode.com/phnom-penh-capital/ (ទស្សនាចុងក្រោយថ្ងៃទី១៧ ឧសភា ២០២៤)។ បញ្ជីរាយនាមភូមិសាស្ត្រកម្ពុជាឆ្នាំ២០២៣។

206 Datum, https://epsg.io/?q=WGS%2084&page=13 បច្ចេកវិទ្យាថ្មី https://www.esri.com/arcgis-blog/produ cts/arcgis-pro/data-management/prepare-your-data-for-the-nsrs-2022/ (ទស្សនាចុងក្រោយថ្ងៃទី១៧ ឧសភា ២០២៤)។ *នៅប្រទេសនូវ៉ែលសេឡង់ ប្រើប្រាស់ដាតទុមទំនើប Datum2016 (NZVD2016-3D)។ [គួរតែបន្ថែមអភិវឌ្ឍន៍លើជំនាន់ ArcGIS Pro]*

207 Khmer Geonet, https://khmergeonet.xyz [ជាប្រព័ន្ធបញ្ជូនទិន្នន័យទីតាំងច្បាស់លាស់ ជាមួយកម្រិត Cm ដោយប្រើ CORS] និង http://221.120.160.130:8080/TrimblePivotWeb/Map/SensorMap.as px (ទស្សនាចុងក្រោយថ្ងៃទី១៧ ឧសភា ២០២៤)។

កម្មម្ចាស់កម្មសិទ្ធិករ ដែលក្រសួង ដ.ន.ស អាចបង្ហាញព័ត៌មានបាន និងងាយស្រួលអន្តរកម្មជាមួយ CamDX។ ករណីក្នុងប្រទេសរុស្ស៊ី រាល់សម្រង់សុរិយោដី គឺត្រូវបង្ហាញព័ត៌មានចាំបាច់ពីកម្មសិទ្ធិករនៃអត្តសញ្ញាណឌីជីថលជាសាធារណៈ ដែលងាយស្រួលដល់អ្នកប្រើប្រាស់ និងការធ្វើធុរកិច្ចឌីជីថល។ កម្ពុជាក៏កំពុងបង្កើតឡើងផែនទីសាកល្បងមួយហៅថា "វេបសាយកម្ពុជាមាតុភូមិខ្ញុំ https://cmhl.gov.kh" ដែលអាចបម្រើប្រយោជន៍មជ្ឈដ្ឋានទូទៅនាថ្ងៃអនាគត។ មានតែម្ចាស់អត្តសញ្ញាណឌីជីថលបុគ្គលម្នាក់តែប៉ុណ្ណោះ ដែលអាចមានសិទ្ធិដឹងព័ត៌មានលម្អិតក្នុងផតថល និងចុចចូលក្នុងគណនីរបស់ខ្លួនតាមកូដនីយកម្មបច្ចេកវិទ្យា លុះត្រាតែបានកំណត់ពិសេសជាសេណារីយ៉ូ ពីម្ចាស់ទិន្នន័យដើម។ ការអនុវត្តក្រុមវាល អាចដំណើរឌីជីថល*៣(បី)ថ្ងៃយ៉ាងតិច* (ដំបូងៗ)។

<u>ទី៣.ការបិទផ្សាយជាសាធារណៈ</u> អាចត្រូវជូនដំណឹងតាមរយៈបច្ចេកវិទ្យាសារកិច្ចបណ្តាញវិមជ្ឈការរបស់ក្រសួងចន្លោះ*មុន១ ឬ៣(មួយ ឬបី)ថ្ងៃ* ពីការបិទផ្សាយតាមគ្រប់មធ្យោបាយឌីជីថល និងមានរយៈពេល *៧(ប្រាំពីរ)ថ្ងៃគិតទាំងថ្ងៃឈប់សម្រាកយ៉ាងតិច* (ពិព្រោះមធ្យោបាយឌីជីថល គឺរហ័ស និងងាយទៅដល់ភាគីពាក់ព័ន្ធ)។ <u>ទី៤.ការសម្រេចលើឯកសារ</u> មន្ត្រីទទួលបន្ទុកត្រូវធ្វើរបាយការណ៍ និងវាយតម្លៃ*សម្រេចភ្លាម* ក្រោយកាលបរិច្ឆេទនេះ មិនត្រូវតម្កល់ទុកយប់យន់សុបន្តិយូរឡើយ។ <u>ទី៥.ការចេញបណ្ណ</u> ក្រោយសន្ទានកម្មត្រឹមត្រូវពីបច្ចេកវិទ្យានិងឆ្លងការពិនិត្យអន្តរការីនៃបណ្តាញសាធារណៈ នោះរដ្ឋបាលសុរិយោដីអាចប្រើវិធីសាស្ត្រពីរហត្ថលេខាលើបណ្ណគឺ ១. អាចហត្ថលេខា វាយត្រា រួចស្កេនចេញ (យូរ) និង២.ហត្ថលេខាឌីជីថល និង/ឬស្កេនជីវមាត្រ (Biometry)ដូចនឹងកម្មសិទ្ធិករក៏បាន (៣.២.១.១)។ បណ្ណសម្គាល់សិទ្ធិមានលក្ខណៈគតិយុត្ត និងងាយស្រួល ត្រូវតែមានឃ្យូ អរកូដស្កេន Verify.gov.kh (៣.២.១.២) និងគួរចេញបណ្ណទម្រង់ឌីជីថលជូនកម្មសិទ្ធិករ រីឯការទូទាត់កម្រៃសេវា-កម្មចុះបញ្ជី និងបង់ពន្ធ គួរតែអនុវត្តលើឌីជីថល (៣.២.២.២)។ ការកសាងប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិលើអចលនវត្ថុ និងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី គឺមានតម្លៃពេញលេញតាមផ្លូវច្បាប់ និងគួរផ្លាស់មកជាទម្រង់ឌីជីថល។[208] សរុបដំណើរការស្វ័យប្រវត្តិកម្មអនឡាញនេះយ៉ាងយូរ*១៥(ដប់ប្រាំ)ថ្ងៃ*។

**ខ.ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុមានលក្ខណៈជាប្រព័ន្ធ**

របាយការណ៍ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ គឺសម្រេចបាន៥.៧៤៨.៦១៨បណ្ណ (គិតរួមទាំងសម្បទានដីសង្គមកិច្ច) នេះបើគិតត្រឹមឆមាសទី១ ឆ្នាំ២០២៣។[209] រយៈពេលនៃការចុះបញ្ជីបានកំណត់ ជាអតិបរមានៃការផ្តល់សេវានៃដំណើរការសរុបគឺ១០០ថ្ងៃ និងមានសុពលភាពអចិន្ត្រៃយ៍។[210] ប៉ុន្តែ ដំណោះស្រាយលើការចុះបញ្ជីតាមប្រព័ន្ធអនឡាញ អាចនឹងកាត់បន្ថយរយៈពេលមកត្រឹមយ៉ាងយូរ២៥ ទៅ៣០ថ្ងៃ។ ជាយន្តការទម្រង់នៃការចុះបញ្ជីដីមួយបែបទៀតនេះ ដែលអ្នកកាន់កាប់ដី ឬម្ចាស់ដី ឬអ្នកប្រើប្រាស់សេវាកម្មឌីជីថល អាចស្នើសុំចុះបញ្ជីក្រោមរូបភាពជាក្រុម ឬក្បាលដីមានចំនួនច្រើនជាប់ៗគ្នា ភ្ជាប់នឹងការកំណត់តំបន់វិនិច្ឆ័យរបស់រដ្ឋបាលសុរិយោ-ដីរាជធានី ខេត្ត។ ជូនកាលក្នុងទិដ្ឋភាពសម្បទានដី ឬសហគមន៍ជនជាតិដើមភាគតិច ជាអាទិ៍ តាមរយៈគោល-

[208] ច្បាប់ភូមិបាល២០០១, មាត្រា២៣៩។

[209] ដូច១៩០, ទំ.១២។

[210] ប្រកាសអន្តរក្រសួងលេខ៣៥៦សហវ.ប្រក, ២២-៤៤ (ចំណុចទី១៖ ការចុះបញ្ជីលើកដំបូង)។

នយោបាយ ឬលក្ខណៈវិនិច្ឆ័យនៃការប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ។[211] ម្យ៉ាងវិញក្រោយការចុះបញ្ជី អាចនៅមានដីធ្លីខ្លះសេសសល់ពុំទាន់ចុះបញ្ជី សម្គាល់ឃើញមានការចុះបញ្ជីដីបំពេញបន្ថែមដែលជាយន្តការបំពេញភាពខ្វះចន្លោះ និងការបំបែកក្បាលដី (ភាគច្រើនតំបន់បុរី និងអគារសហវិជ្ជតរាជ្យ)។[212]

| **ប្រភេទ** | **គោលដៅ** | **ចំនួនបណ្ណ ( ទំហំគិតជាហិកតា )** |
|---|---|---|
| **ដីមានលក្ខណៈជាប្រព័ន្ធ** | **សរុប៦.២៦៧.៣៣៩បណ្ណ, សម្បទានដីសង្គមកិច្ចចំនួន១៧.៩៩៣បណ្ណ** | |
| ការងារដីចុះបញ្ជីបន្ត | ផ្ទេរកម្មសិទ្ធិ | ៦៤៥.១០៥ករណី |
| | សិទ្ធិប្រាតិភោគ (ដាក់បញ្ចាំ/ហ៊ីប៉ូតែក) | ៣៤៦.៣៥៣ករណី |
| | សិទ្ធិជួលអចិន្ត្រៃយ៍ | ៦១២បណ្ណ ស្មើនឹង៨២.១១៧ហិកតា ១៨អា |
| | សម្បទានដីសេដ្ឋកិច្ច | ៤៤២បណ្ណ ស្មើនឹង២៧៥.៥៣១ហិកតា ១៧អា |
| | បំបែកក្បាលដីបុរី | ៣៣៤បុរី ស្មើនឹង៦៧.៣៧៣បណ្ណ |

តារាងទី១២. របាយការណ៍ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

នីតិវិធីការចុះបញ្ជីដំបូងនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មានដំណោះស្រាយចុះបញ្ជីតាមស្វ័យប្រវត្តិកម្មប្រព័ន្ធឌីជីថល លក្ខណៈប្រហាក់ប្រហែលទៅនឹងការចុះបញ្ជីដាច់ដោយដុំ ផងដែរ គ្រាន់តែកែសម្រួលប្រតិបត្តិការខ្សែសង្វាក់ប្រព័ន្ធបន្តិចបន្តួច។ គណៈអភិបាលរាជធានី ខេត្ត កំណត់តំបន់និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ និងត្រូវចាត់តាំងគណៈកម្មការរដ្ឋបាល ធ្វើយ៉ាងណាត្រូវតភ្ជាប់បណ្តាញទំនាក់ទំនងរួមថ្នុកមួយ ដើម្បីងាយត្រួតពិនិត្យ ពិភាក្សា និងវិនិច្ឆ័យតាមគម្រោងផែនការ។ បច្ចុប្បន្ន ឃើញថាការប្រើប្រាស់ Group Telegram bot ជម្រើសពេញនិយម ប៉ុន្តែ គាំពារត្រូវមានបណ្តាញអ៊ីនធឺណិតមួយបែបទៀតជាអន្តរកម្ម និងរហ័ស។[213] ការផ្ញើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតដល់អាជ្ញាធរមូលដ្ឋានមុនកិច្ចប្រជុំប្រកាសតំបន់វិនិច្ឆ័យយ៉ាងតិច*មុន៣(បី)ថ្ងៃ* ។ ការជូនដំណឹងសាធារណៈអំពីកាលបរិច្ឆេទ ទីកន្លែងកិច្ចប្រជុំយ៉ាងហោចណាស់*មុន១ ឬ៣(មួយ ឬបី)ថ្ងៃ* នៃ<u>ទី១.ការរៀបចំឯកសារ</u>របស់ប្រជាពលរដ្ឋ។ ក្នុងដំណាក់កាល<u>ទី២.ការងារបច្ចេកទេសក្រុមវាល</u> អាចអនុវត្តតាមបច្ចេកទេសខាងលើ (ក) គ្រាន់តែក្រុមវាលត្រូវជូនដំណឹងទៅកាន់ថ្នាក់មូលដ្ឋានពីការកំណត់ព្រំដី*មុន១ ឬ៣(មួយ ឬបី)ថ្ងៃ*។រីឯ

[211] ច្បាប់ភូមិបាល២០០១, មាត្រា៨៣ និង២២៩។ *(បង្កើតតាំងពីថ្ងៃទី១៩ ឧសភា ២០០២)*។ សារាចរបស់រាជរដ្ឋាភិបាលស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ, លេខ០៦សរ, ២៣ កក្កដា ២០១៩។ និងសារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, លេខ០៧សរ, ៣០ មិថុនា ២០១៤។

[212] សារាចរណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម, លេខ០៦ ស.ណ.ន, ៥ ឧសភា ២០០៦។ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងបុរី, លេខ៣៩អនក្រ.បក, ១០ មីនា ២០១១, មាត្រា១០, ១៥(១), ២១,និង២៥(១)។ *[ការគ្រោង ប្រមូលនិងកត់ត្រាចំណូលកម្រៃចុះបញ្ជីលក្ខណៈជាប្រព័ន្ធត្រូវប្រគល់ឱ្យក្រសួង ដ.ន.ស រហូតដល់៣១ ធ្នូ ២០២៧]*

[213] MRTS Consulting, "social media usage in cambodia in 2023," ២០២៣, https://mrtsconsulting.com/new s/social-media-usage-in-cambodia-in-2023 *គិតត្រឹមខែមេសា ឆ្នាំ២០២៣ មានអ្នកប្រើប្រាស់រហូតដល់៥លាននាក់*។ និង Julia E. dinger, "Staying Agile in the Changing World of Government Social Media," ២០២៤, https://www.govtech.c om/gov-experience/staying-agile-in-the-changing-world-of-government-social-media (ទស្សនាចុងក្រោយថ្ងៃទី១៧ ឧសភា ២០២៤)។ *[ក្រៅពីតំណភ្ជាប់ **Telegram bot** អាចពិបាកបន្តិច ពេលប្រជាជនបំពេញឯកសារណេបលើថ្នាល រួចរង់ចាំប្រកាសតំបន់វិនិច្ឆ័យជូនដំណឹងពេលក្រោយ។]*

ទី៣.ការបិទផ្សាយជាសាធារណៈលើឯកសារវិនិច្ឆ័យ ការជូនដំណឹងរបស់អភិបាលរាជធានី ខេត្ត តាមគ្រប់មធ្យោបាយឌីជីថល និងមានរយៈពេល*យ៉ាងតិច៧ ឬ១០(ប្រាំពីរ ឬដប់)ថ្ងៃ*។ ការប្រើប្រាស់មធ្យោបាយជំនួយពីបច្ចេកវិទ្យាឌីជីថល មានភាពងាយស្រួល ឬបើទោះបីអ្នកកាន់កាប់ ឬតតិយជនដែលពាក់ព័ន្ធនៅក្រៅប្រទេសក៏ដោយ ក៏អាចទទួលដំណឹងពីបណ្ដាញសាធារណៈ និងយល់ជ្រាបពីការដំណាក់កាល និងការពិនិត្យស្វែងរកព័ត៌មាន។

ករណីនៅសហព័ន្ធរុស្ស៊ី ការចុះបញ្ជីក្នុងទម្រង់មានលក្ខណៈជាប្រព័ន្ធបែបនេះ ប្រើប្រាស់វិធីសាស្ត្រប្លុកឆេនជាមធ្យោបាយ ចំណាយពេលវេលាត្រឹមរយៈពេល៨(ប្រាំបី)ថ្ងៃ ក្នុងចំនួនក្បាលដីពី៣០០.០០០ ទៅ៣៥០.០០០ ក្នុងមួយតំបន់វិនិច្ឆ័យ។[214]ទី៤.ការសម្រេចឯកសារនិងទី៥.ការចេញបណ្ណដោយសារតែមានចំនួនច្រើន ចាំបាច់គួរប្រើប្រាស់បច្ចេកទេសថ្មីដូចខាងលើ (ក) គឺជៀសវាងដោយកាត់បន្ថយអំពីកំហុសឆ្គង និងអាចក្តោបកាប់ការគ្រប់គ្រងព័ត៌មាន របាយការណ៍ទិន្នន័យត្រឹមត្រូវ។ វណ្ណកម្មនេះ ងាយស្រួលទាំងការស្រាវជ្រាវប្រវត្តិសុរិយោដី និងលោតបញ្ជាក់សញ្ញាអាសន្នណាមួយ ដែលដីធ្លីនោះហួសដល់ការប៉ះពាល់លើទ្រព្យសាធារណៈរបស់រដ្ឋ។ រាជរដ្ឋាភិបាល ជាពិសេស ក្រសួង ដ.ន.ស គួរតែ "សង្កត់ឱ្យតឹង ហើយបើកឱ្យរលុង" លើការការពារទុកមុន និងទាញប្រយោជន៍។ ទិន្នន័យនៃព័ត៌មានអចលនទ្រព្យមួយចំនួន ឬមួយផ្នែកជាព័ត៌មានសម្ងាត់គឺត្រូវគាំពារ រីឯព័ត៌មានចាំបាច់ផ្សេងៗទៀតនៃអចលនទ្រព្យគួរតែបើកចំហ ដើម្បីជាប្រយោជន៍ដល់ធុរកិច្ចថ្មីនិងវិនិយោគិន(ព្យាករទុក)។ សរុបដំណើរការស្វ័យប្រវត្តិកម្មអនឡាញនេះយ៉ាងយូរ*២៥ ទៅ៣០(ម្ភៃប្រាំទៅសាមសិប)ថ្ងៃ*។

### ៣.១.១.២. ការកសាងប្រព័ន្ធទិន្នន័យសុរិយោដី

ទម្លាប់ពីមុនធ្លាប់ហៅថា "ប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យចុះបញ្ជីដីធ្លី" បច្ចុប្បន្ន បើជារួម ឃើញប្រើពាក្យថា "ប្រព័ន្ធទិន្នន័យសុរិយោដី"។ ក្រោយសម័យខ្មែរក្រហម ស្ទើរតែបាត់បង់ទាំងស្រុងរាល់ព័ត៌មាន និងបណ្ណកាន់កាប់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងសម័យសង្គមរាស្ត្រនិយម។ រាជរដ្ឋាភិបាល បានប្រមែប្រមូលទិន្នន័យ របាយការណ៍ពីក្រសួងចាស់ៗទាំងអស់ និងកសាងថ្មីពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិដីធ្លី មកកាន់ក្រសួង ដ.ន.ស ថ្មីវិញ រាប់តាំងពីថ្នាក់មូលដ្ឋានមក ដែលក្រសួងមានឃ្លាំងផ្ទុកឯកសារក្រដាសទាំងនោះ។ ប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី ជាមូលដ្ឋានគោលនៃប្លង់សុរិយោដី សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជី ជាអាទិ៍។[215] ប្រព័ន្ធនេះ អាចត្រូវតភ្ជាប់ជាមួយប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (IPIS) ដើម្បីផ្តល់លក្ខណៈងាយស្រួលថែមមួយកម្រិតទៀត។ តាមរយៈការអនុញ្ញាតដាក់ឱ្យត្រួតពិនិត្យព័ត៌មានតាមប្រព័ន្ធអនឡាញ ដោយអាចពិនិត្យមើលបន្ទុកដីធ្លី និងបង់កម្រៃអស់២០.០០០រៀល https://mlmupc.gov.kh/electronic-cadastral-services/ និងសេវាកម្មតាមការិយាល័យច្រកចេញចូលតែមួយ (OWS) https://online.owso.gov.kh គឺនៅមានកម្រិត គួរតែបន្ថែមពីការអភិវឌ្ឍកម្មវិធី។ នៅសាធារណរដ្ឋអេស្តូនី ព័ត៌មានក្នុងបណ្ណកម្មសិទ្ធិ គឺបន្ថែមដាក់ឈ្មោះកម្មសិទ្ធិករព្រំដីអ្នកជិតខាងផងដែរ ដែល

---

214 Работа Правительства, “Регистрация Земли” [ការចុះបញ្ជីដីធ្លី], http://government.ru/news/46003/ (ទស្សនាចុងក្រោយថ្ងៃទី១៨ ឧសភា ២០២៤)។

215 សេចក្ដីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា៩៨។ *ប្រទេសនូវែលសេឡង់ បង់ថ្លៃពិនិត្យព័ត៌មានដីធ្លីគឺអស់តែ**៦ដុល្លារអាមេរិក/លើក**៖* https://lrs.linz.govt.nz/។]

អាចបញ្ជាក់ពីព្រំដីជាប់គ្នា និងអំណះអំណាងនាពេលក្រោយបើមានវិវាទ ឬជាសាក្សីនៃកម្មសិទ្ធិនោះ។[216] ក្នុងក្របខណ្ឌសមាហរណកម្មព័ត៌មានភូមិសាស្ត្រនៃអង្គការសហប្រជាជាតិ (UN-IGIF) ក៏បានផ្តល់ជាយុទ្ធសាស្ត្រដល់ប្រទេសដែលកំពុងអភិវឌ្ឍន៍ អំពីរបៀបរបបនៃការកសាង និងគ្រប់គ្រងភូមិសាស្ត្រទិន្នន័យជាតិ។[217]

ការកសាងប្រព័ន្ធទិន្នន័យឱ្យមានសណ្តាប់ធ្នាប់ គឺងាយស្រួលបច្ចុប្បន្នកម្មដំណាលគ្នានៃបណ្តាញសាធារណៈដែលតភ្ជាប់រវាងអន្តរប្រតិបត្តិការ។ គួរប្រើប្រាស់បច្ចេកវិទ្យា Cloud Computing និង Big Data ដូចករណីនឹងប្រទេសថៃ ជាប្រទេសដែលប្រើប្រាស់ដំណោះស្រាយនេះសម្រាប់ការប្រព័ន្ធគ្រប់គ្រងដីធ្លីហៅថា "e-Land ឬ eT-Land"។[218] ការអភិវឌ្ឍកម្មវិធីនេះ គឺមានប្រសិទ្ធភាពនៃការចំណាយរបស់កម្ពុជា ទិន្នន័យផ្ទុកមានតម្លៃថោកជាជាងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណ(ឃ្លាំង)។ លទ្ធភាពការធ្វើមាត្រដ្ឋានផ្ទុកទិន្នន័យ គឺអាចសម្របទៅនឹងតម្រូវការចុះបញ្ជីដីធ្លីដែលកំពុងកើនឡើងនៅកម្ពុជា។ ចំណែកឯប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ DBMS ជាជម្រើស Open Data ស្រដៀងទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ប្រទេសកម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីជម្រើស Open Data ដូចជា PostgreSQL ជំនាន់ថ្មី ជាដើម។ បើក្រឡេកទៅមើលផ្នែកហិរញ្ញវត្ថុ កន្លងមកកម្ពុជាបានអភិវឌ្ឍន៍ជឿនលឿនល្អប្រសើរ ដែលរាជរដ្ឋាភិបាលធ្លាប់ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាទម្រង់ម៉ូដែលរបស់ចក្រភពអង់គ្លេស នឹងកំពុងអភិវឌ្ឍន៍បន្ថែមលើការប្រើប្រាស់បែប FinTech។ នៅចក្រភពអង់គ្លេស មានវិស័យឯកជនជាច្រើន បានចូលរួមសហការជាមួយរាជរដ្ឋាភិបាលអង់គ្លេសក្នុងការកសាងមជ្ឈមណ្ឌលទិន្នន័យ និងបណ្តាញម៉ាស៊ីនមេយ៉ាងមានប្រសិទ្ធភាព និងបានចែកចាយបច្ចេកវិទ្យាជាង១០០+ប្រទេស ក្នុងនោះក៏មានកម្ពុជា ផងដែរ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។[219]

យន្តការថ្នាលការផ្លាស់ប្តូរទិន្នន័យកម្ពុជា CamDX ជាវិធីសាស្ត្រល្អបំផុតមួយក្នុងការផ្លាស់ប្តូរ ផ្ទេរទិន្នន័យពីប្រព័ន្ធទិន្នន័យសុរិយោដី ទៅកាន់ក្រសួង ស្ថាប័ន អង្គភាពដទៃ។ ដំណើរការអាចរក្សាប្រព័ន្ធប្រតិបត្តិការច្រើនតំណក្នុងប្រព័ន្ធក្រសួងសាមី និងអាចដឹងថាដំណើរការលើប្លង់ដីនោះ បើទោះបីជាលក់ពីម្ចាស់មួយ ទៅកាន់ម្ចាស់មួយទៀត ឬតាមវិធីសាស្ត្រដទៃទៀតក៏ដោយ ក៏អាចមើលឃើញប្រវត្តិសុរិយោដីយ៉ាងច្បាស់ មិនខុសអីពី Transaction ទូទាត់ធនាគារឡើយ (ព្យាករទុក)។ នេះគ្រាន់តែជាការបង្ហាញស្នូលនីមួយៗ ដែលក្រសួង ដ.ន.ស គួរតែចាប់យកប្រយោជន៍ និងការកសាងប្រព័ន្ធទិន្នន័យសុរិយោដី ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

### ៣.១.២. ករណីសិក្សានៅប្រទេសមួយចំនួន

ក្នុងចំណោមប្រទេសសេដ្ឋកិច្ចកំពូលទាំងដប់(G10-IMF) របស់ពិភពលោកមានប្រទេស៖ សហរដ្ឋអាមេរិក, ជប៉ុន, អ៊ីតាលី, បារាំង, ឥណ្ឌា និងប្រេស៊ីល គឺភាគច្រើនមានទម្រង់ការចុះបញ្ជីដីធ្លីដំបូងមានលក្ខណៈជាប្រព័ន្ធ។

[216] កម្រងវិធីសាស្ត្រចុះបញ្ជី, https://www.riigiteataja.ee/en/ (ទស្សនាចុងក្រោយថ្ងៃទី២០ ឧសភា ២០២៤)។

[217] UN-GGIM, https://ggim.un.org/UN-IGIF/ (ទស្សនាចុងក្រោយថ្ងៃទី២០ ឧសភា ២០២៤)។

[218] Thailand Board of Investment, "Data Center and Cloud Service in Thailand" [មជ្ឈមណ្ឌលទិន្នន័យ និងសេវាកម្មក្លោដនៅថៃ], https://www.boi.go.th/upload /content/Infopack_CloudandDataCenter.pdf (ទស្សនាចុងក្រោយថ្ងៃទី២០ ឧសភា ២០២៤)។

[219] CBRE, https://www.cbre.com/services/property-types/data-center (ទស្សនាចុងក្រោយថ្ងៃទី២១ ឧសភា ២០២៤)។ *[ដំណើរការអនឡាញរាប់ចាប់ពីការចុះបញ្ជី ដល់ការផ្ទេរកម្មសិទ្ធិដីធ្លីនៅព្រះរាជាណាចក្រដាណឺម៉ាក **បន្ថយពី៤០ថ្ងៃ មកត្រឹមតែ៤ថ្ងៃ។**]*

រីឯប្រទេសអាល្លឺម៉ង់ និងចក្រភពអង់គ្លេស ពេញនិយមទម្រង់ការចុះបញ្ជីដីធ្លីដំបូងមានលក្ខណៈដាច់ដោយដុំ។ ក្នុងប្រទេសកាណាដាអនុវត្តតាមទម្រង់ទាំងពីរនេះ និងប្រទេសចិនកំពុងដំណើរការប្រព័ន្ធចុះបញ្ជីដីធ្លីដំបូងដាច់ដោយដុំ។ ប្រទេសទាំងនេះ ភាគច្រើនសុទ្ធសឹងតែប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ជាជំនួយដល់ការចុះបញ្ជីអនឡាញទៅតាមប្រភេទផ្សេងៗពីគ្នា។ ប្រទេសនីមួយៗមានប្រវត្តិបទដ្ឋានគតិយុត្ត សមត្ថភាពរដ្ឋបាល និងគោលនយោបាយ ដែលមានភាពសមស្របនៃភាពជាក់លាក់ និងច្បាស់លាស់។[220] "បើគ្មានការអនុវត្តបច្ចេកវិទ្យាទេ អត្ថិភាពនៃឯកសារជាច្រើនក្នុងទម្រង់រូបវន្ត ប្រើប្រាស់ត្រឹមក្នុងវិស័យដីធ្លី ដោយមិនសន្សំសំចៃ ធ្វើឱ្យខាតបង់ជាង ១០០លានអឺរ៉ូ ឬស្មើនឹង១០២លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ។"[221]

ការសិក្សាគិតគូរទាំងការខាតបង់ផ្នែកហិរញ្ញវត្ថុយ៉ាងច្រើន នាំឱ្យបង្វែរពីការពិនិត្យទិដ្ឋភាពការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ ដល់ការពិចារណាទិដ្ឋភាពទាំងនៅក្នុងតំបន់អាស៊ី (៣.១.២.១) និងក្នុងតំបន់អឺរ៉ុប (៣.១.២.២)។

តើការប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេនគួរតែនាំឱ្យមានការរៀបចំឡើងវិញ និង/ឬជំនួសឱ្យពិចារណាលើការចុះបញ្ជីដីធ្លីតាមបែបប្រពៃណីដែរឬទេ?

#### ៣.១.២.១. ក្នុងតំបន់អាស៊ី

តំបន់ប៉ែកអាស៊ីបានលើកយកករណីសិក្សាពីរគឺ សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសនូវែលសេឡង់ ជាប្រទេសឈានមុខក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការចុះបញ្ជីដីធ្លី។

**ក.សាធារណរដ្ឋប្រជាមានិតចិន** (People's Republic of China)

បទប្បញ្ញត្តិបណ្ដោះអាសន្នស្ដីពីការចុះបញ្ជីអចលនទ្រព្យ ត្រូវដាក់ឱ្យប្រើប្រាស់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៥។ នៅក្នុងខេត្ត Shaanxi បានអនុវត្តពេញលេញ និងជាខេត្តគំរូរបស់ប្រទេសចិនក្នុងការបញ្ចប់ការចុះបញ្ជីដីធ្លីតាមប្រព័ន្ធអនឡាញ។ តាមទស្សនៈប្រជាជនចិន ការចុះបញ្ជីដីតាមបែបឌីជីថល ជាការងារចាំបាច់របស់រដ្ឋាភិបាលចិន ក្នុងការធានាប្រសិទ្ធភាព និងទំនុកចិត្តកម្មសិទ្ធិដីធ្លីរបស់ប្រជាជន។ ការទទួលបានអត្តសញ្ញាណមួយស្របច្បាប់បែបឌីជីថល ក្រៅពីអត្តសញ្ញាណប្រើប្រាស់រាល់ដង គឺអាចធានាដល់ការចុះបញ្ជីលំនៅឋាន ឬអចលនវត្ថុដែលមានន័យថា ចក្ខុវិស័យកិច្ចការពារសិទ្ធិអ្នកប្រើប្រាស់អនឡាញ អាចការពារស្របតាមច្បាប់ មិនត្រឹមតែអាចធានាសុវត្ថិភាពប្រតិបត្តិការលើអចលនទ្រព្យ និងកាត់បន្ថយការក្លែងបន្លំប៉ុណ្ណោះទេ ប៉ុន្តែ បង្កើនផលិតភាពស្របច្បាប់ការបង្កើត និងស្វែងរកព័ត៌មានម្ចាស់កម្មសិទ្ធិករអចលនវត្ថុជាសាធារណៈផងដែរ។ "ការគ្រប់គ្រងដីធ្លីដំបូងអាចពិបាក ពិព្រោះប្រជាជនចិនមានចំនួនច្រើនជាង[១.៤៣ពាន់លាននាក់(២០២៤)] និងផ្ទៃដីធំប្រមាណ១១.៤៦៦.៦០០$km^2$ ដែលដីធ្លីមួយចំនួនធំ នៅសល់ច្រើនមិនទាន់វាស់វែង (Huanle He, ២០១៤)។" [222]

[220] អាចរកបានបឋមនៅ ៖ https://www.researchgate.net/publication/329137308 (ឯកសារឯកជន)។

[221] Joao Fragoso Januario and Carlos Oliveira Cruz, "Social and Financial Sustainability of Real Estate Investment: Evaluating Public Perceptions towards Blockchain Technology" [និរន្តរភាពសង្គម និងស្ថេរភាពហិរញ្ញវត្ថុនៃការវិនិយោគអចលនទ្រព្យ៖ វាយតម្លៃពីការយល់ឃើញជាសាធារណៈពីបច្ចេកវិទ្យាប្លុកឆេន], *Research Gate* (Portugal) DOI.org.10.3390 (2023): 8។

[222] Huanle He, "China's Land Registration: Situation, Challenges and Efforts" [ការចុះបញ្ជីដីធ្លីនៃសធារណរដ្ឋប្រជាមានិតចិន៖ ស្ថានភាព យន្តការ និងផលប៉ះពាល់], *FIG Congress* (Kuala Lumpur Malaysia) 7227 (2014): 4។

គិតត្រឹមឆ្នាំ២០២៣ ប្រទេសចិនបានចុះបញ្ជីដីធ្លីបង្ហើយបញ្ចប់ដោយដំណាក់កាលសរុប៧៩០លានក្បាលដី។[223] ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីដំបូងក្នុងប្រទេសចិនរួមមាន៖ ១.ការគូសផែនទីភូមិសាស្ត្រ និងការវាស់វែង គឺរូបភាពត្រូវបានចាប់យកពីអាកាស និងផ្កាយរណបដែលច្បាស់ល្អ និងប្រើដើម្បីបង្កើតផែនទីឌីជីថលលម្អិតពីក្បាលដី។ បច្ចេកទេសគឺប្រើ GPS ទំនើបចុងក្រោយ និងការស្កេនឡាស៊ែរ (Laser)។ ២.មូលដ្ឋានទិន្នន័យព័ត៌មានរដ្ឋបាលសុរិយោដី គឺរាល់ទិន្នន័យទាក់ទងនឹងដីធ្លី រួមទាំងកំណត់ត្រាកម្មសិទ្ធិ សិទ្ធិប្រត្យក្ស និងប្រតិបត្តិការនានាត្រូវបានចងក្រងបង្រួបបង្រួមជាថ្លុងមួយលក្ខណៈមូលដ្ឋានទិន្នន័យឌីជីថលទូទាំងប្រទេស។ មូលដ្ឋានទិន្នន័យនេះត្រូវបានបង្ហោះជាសាធារណៈដល់ភាគីពាក់ព័ន្ធ គឺអាចចូលប្រើ និងធ្វើបច្ចុប្បន្នភាពតាមអ៊ីនធឺណិតបាន។ ៣.ប្រព័ន្ធចុះបញ្ជីដីធ្លីតាមអ៊ីនធឺណិត គឺដំណើរការត្រូវធ្វើជាឌីជីថល ដែលអនុញ្ញាតឱ្យម្ចាស់ដីអាចដាក់ពាក្យដោយភ្ជាប់ឯកសាររណប និងធ្វើបច្ចុប្បន្នភាពកំណត់ត្រាដីធ្លីរបស់ប្រជាពលរដ្ឋតាមរយៈវិបផតថលអនឡាញ។ ៤.ការប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន គឺរដ្ឋាភិបាលចិនក្នុងតំបន់មួយចំនួន កំពុងបន្តអភិវឌ្ឍជាមួយការប្រើប្រាស់បច្ចេកវិទ្យានេះ រួមទាំង AI, GIS, dApp ដែលប្រជាពលរដ្ឋចិនពេញនិយម ជឿជាក់ ដើម្បីបង្កើនសុវត្ថិភាព និងតម្លាភាពនៃកំណត់ត្រាចុះបញ្ជីដីធ្លី។[224]

**ខ.ប្រទេសនូវែលសេឡង់** (New Zealand)

បទប្បញ្ញត្តិការចុះបញ្ជីដីធ្លីគ្រប់គ្រងដោយច្បាប់ស្តីពីការផ្ទេរកម្មសិទ្ធិដីធ្លីឆ្នាំ២០១៧ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឆ្នាំ២០០២។ ច្បាប់នេះបានចូលជាធរមាននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ និងបាននិរាករណ៍ច្បាប់ផ្ទេរដីធ្លីឆ្នាំ១៩៥២។ កម្មសិទ្ធិដីធ្លីប្រទេសនេះ គឺផ្អែកលើទម្រង់ចុះបញ្ជីដីធ្លីហៅថា Torrens Title (Maõri) ដែលជាការចុះបញ្ជីកម្មសិទ្ធិដីធ្លីសាធារណៈ។[225] ស្ថិតក្រោមប្រព័ន្ធនេះ ក្បាលដីភាគច្រើនមានបណ្ណកម្មសិទ្ធិផ្ទាល់ខ្លួនដែលបង្ហាញពីទំហំ និងទីតាំងនៃដីដាក់លាក់ កត់ត្រាព័ត៌មានលម្អិតអំពីកម្មសិទ្ធិ និងផលប្រយោជន៍ផ្សេងទៀតដែលពាក់ព័ន្ធ។ ប្រទេសនូវែលសេឡង់បានបំប្លែងទម្រង់ការចុះបញ្ជីដីធ្លី ទៅជាទម្រង់អេឡិចត្រូនិក ដែលធ្វើឡើងតាមរយៈ "ព័ត៌មានដីធ្លីនូវែលសេឡង់ (LINZ - Land Information New Zealand)" ដោយប្រជាជន អាចស្វែងរកសេវាកម្មនៅលើបណ្តាញសាធារណៈ Land-online។[226]

ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីដំបូងក្នុងប្រទេសនូវែលសេឡង់រួមមាន៖ ១.ការវាស់វែង និងការធ្វើផែនទីសុរិយោដី គឺប្រើប្រាស់បច្ចេកទេសវាស់កម្រិតខ្ពស់ រួមភ្ជាប់ទាំង GPS, ការស្កេនឡាស៊ែរ និងបច្ចេកវិទ្យា Drone ដើម្បីបង្កើតផែនទីឌីជីថលដែលមានភាពត្រឹមត្រូវ។ ២.ការចុះបញ្ជីដីធ្លីឌីជីថល គឺប្រើថ្នាល Land-online នៃប្រព័ន្ធអនឡាញ

---

[223] Reuters, "China completes landmark national real estate registration system," *Macro Matter*, ២០២៣, https://www.reuters.com/markets/asia/china-completes-landmark-national-real-estate-registration-system-2023-04-25/ (ទស្សនាចុងក្រោយថ្ងៃទី២៣ ឧសភា ២០២៤)។ និងសៀវភៅ៖ https://digichina.stanford.edu/work/translation ។

[224] Danyue Wang, "The Information Management of Real Estate Registration Under the Background of Big Data" [ការគ្រប់គ្រងព័ត៌មាននៃការចុះបញ្ជីអចលនវត្ថុក្រោមប្រភពទិន្នន័យធំ ទិន្នន័យគោល], *Academic Journal of Science and Technology* ISSN:2771-3032|Vol.3, No.3 (2022): 5។

[225] ទម្រង់ចុះបញ្ជីបែប Torrens Title កើតចេញពីទម្រង់បែបអាណានិគមអង់គ្លេស, ក៏មាននៅប្រទេសកាណាដា និងអូស្ត្រាលីផងដែរ។

[226] បណ្តាញតភ្ជាប់៖ https://www.linz.govt.nz/guidance/landonline-support (ទស្សនាចុងក្រោយថ្ងៃទី២៣ ឧសភា ២០២៤)។

មូលដ្ឋានទិន្នន័យឌីជីថលមានលក្ខណៈថ្នាក់ជាតិ អាចរក្សាទុករាល់កំណត់ត្រាទាក់ទងនឹងដីធ្លី រួមទាំងកម្មសិទ្ធិ ប្រតិបត្តិការ និងវិវាទនានា។ ៣.ថ្នាល e-Plan ជាបណ្ដុំការវាស់វែងឌីជីថល ដែលអនុញ្ញាតឱ្យបណ្ដាអ្នកវាស់វែង ដែលមានអាជ្ញាបណ្ណអាចចូលរួមសហការ និងដាក់ស្នើផែនការវាស់វែងតាមអេឡិចត្រូនិក។ វិធីនេះ គឺអាចលុប បំបាត់តម្រូវការសម្រាប់ផែនការវាស់វែងផ្អែកលើក្រដាស និងសម្រួលដំណើរការចុះបញ្ជីដីធ្លីដំបូង។ នៅកម្ពុជា ក៏មានអាជ្ញាបណ្ណសម្រាប់អ្នកវាស់វែង ផងដែរ។[227] ៤.ព័ត៌មានកម្មសិទ្ធិដីធ្លីស្វ័យប្រវត្តិ ថ្នាល Landonline នេះអាចស្វែងរកព័ត៌មានភ្លាមៗនៃបណ្ណកម្មសិទ្ធិ និងកំណត់ត្រាដីធ្លី។ បច្ចេកវិទ្យា ei-GIS, XML, BIM, AI, Blockchain, IPFS (Inter Planetary File System), NSDI, VLBI ក៏ពេញនិយមប្រើប្រាស់ក្នុងប្រទេសនេះ ផងដែរ។[228]

### ៣.១.២.២. ក្នុងតំបន់អ៊ឺរ៉ុប

តំបន់ប៉ែកអ៊ឺរ៉ុប បានលើកយកករណីសិក្សាពីរដូចគ្នាគឺ សាធារណរដ្ឋអេស្តូនី និងសហព័ន្ធស្វីស ជាប្រទេសដែលឈានមុខ និងចែកចាយម៉ូដែលគំរូក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការចុះបញ្ជីដីធ្លី។

#### ក.សាធារណរដ្ឋអេស្តូនី (Republic of Estonia)

បទប្បញ្ញត្តិច្បាប់ស្តីពីការចុះបញ្ជីដីធ្លីចែងអំពីនីតិវិធី និងការថែរក្សាសម្រង់ដីធ្លីនៃរដ្ឋអេស្តូនីចូលជាធរមានថ្ងៃទី១៥ មីនា ២០១៩។ ជំនាន់កំណែទម្រង់អេឡិចត្រូនិកដំបូងនៃការចុះបញ្ជីដីធ្លីមានតាំងពីឆ្នាំ១៩៩៤ ដោយវិវត្តន៍ដំណាក់កាលបន្ទាប់ឆ្នាំ២០១០ និងផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ ដែលរដ្ឋាភិបាលអេស្តូនីតម្រូវឱ្យរាល់ឯកសារដីធ្លីទាំងអស់ ផ្លាស់ទៅជាទម្រង់អេឡិចត្រូនិកទាំងស្រុង។[229] ក្រមរដ្ឋប្បវេណីអេស្តូនី, ច្បាប់ស្តីពីការអនុវត្តអចលនទ្រព្យ, ច្បាប់ស្តីពីកម្មសិទ្ធិអាផាតមិន (Apartment), ច្បាប់ស្តីពីកាតព្វកិច្ច, និងយន្តការពិសេសនានា បានចង្អុលបង្ហាញជាក់លាក់ វិធីសាស្ត្រត្រួតពិនិត្យព័ត៌មានសុរិយោដី ក្នុងលក្ខខណ្ឌបើកម្មសិទ្ធិករ ឬជាអ្នករកស៊ីកម្រៃជើងសារ (កម្ពុជាហៅថា អ្នកគួកជេ) អាចឆែកមើលព័ត៌មានបានជារៀងរាល់ថ្ងៃ ដោយគ្រាន់តែទូទាត់ជាប្រចាំខែជាការស្រេច តម្លៃត្រឹមតែ១ផោន ឬ១ដុល្លារអាមេរិក/លើក។[230] ប្រទេសនេះមានភាពចាស់ទុំលើការអនុវត្តវិស័យដីធ្លី ដោយបង្កើតប្រព័ន្ធឆ្លាស់ហៅថាប្រព័ន្ធ X-Road ដោយមានសារការី(អន្តរការីកណ្តាល) និងអាជ្ញាធរសុរិយោដី រីឯប្រទេសកម្ពុជាគឺហៅថា CamDX។[231] ការចូលប្រើប្រាស់ទិន្នន័យនៅលើប្រព័ន្ធអចលនវត្ថុដែលបានចុះបញ្ជីអនឡាញដោយសាមីបុគ្គលរួចហើយនោះ គឺអាចផ្តល់សិទ្ធិឱ្យអ្នកដទៃ ឬតតិយជនពិនិត្យមើល

---

[227] ដូច២៩, ទំ.៩។ ពាក្យថា សមកាលកម្ម (Synchronization) សំដៅទៅដល់ការធ្វើបច្ចុប្បន្នកាលទីតាំងទិន្នន័យ ដែលស្ថិតនៅកន្លែងផ្សេងៗគ្នាឱ្យក្លាយជាមូលដ្ឋានទិន្នន័យតែមួយ ក្នុងខណៈពេលតែមួយ ឬស្គាល់ជាទូទៅថាជា ការធ្វើបច្ចុប្បន្នកម្ម ឬការផ្លាស់ទៀងទាត់។

[228] ei-GIS, https://www.linz.govt.nz/guidance/land-registration , (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។

[229] ប្រភពបឋមនៅក្នុង៖ https://www.riigiteataja.ee/en/eli/525032019009/consolide និង https://www.rik.ee/en/e-land-register/e-land-register-portal (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។

[230] សេវាកម្មឆែកព័ត៌មានតាមអេឡិចត្រូនិក, https://www.baltic-legal.com/estonian-land-register-eng.htm (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។

[231] ការចុះបញ្ជីកម្មសិទ្ធិលើអេឡិចត្រូនិក, https://kinnistusraamat.rik.ee/Avaleht.aspx?lang=Eng (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។ *នៅទូទាំងសហភាពអ៊ឺរ៉ុប អ្នកប្រើប្រាស់ក៏អាចឆែកមើលព័ត៌មានសុរិយោដីអេឡិចត្រូនិកតាមរយៈការស្នើសុំ ELRN* https://www.elra.eu ។

ឯកសារព័ត៌មានចាំបាច់មួយចំនួនជាឌីជីថល និង/ឬសាមីខ្លួន ក៏អាចមើលទិន្នន័យនៅលើអចលនវត្ថុដែលបានចុះបញ្ជីផ្សេងទៀត ផងដែរ តាមរយៈ X-Road។ ដើម្បីប្រើប្រាស់បាន អ្នកប្រើប្រាស់ត្រូវចូលដោយប្រើអត្តសញ្ញាណបុគ្គលឌីជីថល ឬលេខសម្គាល់ទូរសព្ទដៃ ឬស្មេនជីវមាត្រ ជាអាទិ៍។ ការចុះបញ្ជីដីធ្លីរបស់ប្រទេសអេស្តូនី ហៅថា KRIS ជាប្រព័ន្ធឌីជីថលចុះបញ្ជីដីធ្លីទំនើបបំផុតមួយនៅក្នុងពិភពលោក។ KRIS ក៏អាចចូលប្រើដើម្បីពិនិត្យមើលកម្មសិទ្ធិដីធ្លី ស្វែងរកដីសម្រាប់លក់ទិញ (ធុរកិច្ចអេឡិចត្រូនិក) និងការចុះបញ្ជីប្រតិបត្តិការដីធ្លី។[232]

ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីដំបូងក្នុងសាធារណរដ្ឋអេស្តូនីរួមមាន៖ ១.សុរិយោដីអេឡិចត្រូនិក និងចុះបញ្ជីដីធ្លីជាប្រព័ន្ធសុរិយោដីឌីជីថលពេញលេញ ដែលស្គាល់ថាជា e-Cadastre របស់ក្រុមប្រឹក្សាភិបាលដែនដី ឬហៅថាសភាអេឡិចត្រូនិក (e-Parliament) អេស្តូនី។ ២.ការបញ្ចូលទិន្នន័យភូមិសាស្ត្រ គឺ e-Cadastre សម្រង់សុរិយោដីប្រភពទិន្នន័យភូមិសាស្ត្រផ្សេងៗ ដូចជារូបភាពពីលើអាកាស ផែនទីសណ្ឋានដី និងបណ្ដាញឧបករណ៍ប្រើប្រាស់ ដែលផ្តល់ជាផែនទីឌីជីថលនៃក្បាលដីទូទាំងប្រទេស។ ៣.ថ្នាលផ្លាស់ប្តូរទិន្នន័យ X-Road ដែលមានសុវត្ថិភាព ដែលអនុញ្ញាតឱ្យមូលដ្ឋានទិន្នន័យរួម និងប្រព័ន្ធព័ត៌មានរបស់រដ្ឋាភិបាលផ្សេងៗ អាចទំនាក់ទំនងគ្នាទៅវិញទៅមក ក៏បានជួយដល់កំណត់ត្រារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដូចជាពន្ធលើអចលនទ្រព្យ អត្តសញ្ញាណបុគ្គលឌីជីថល និងអត្តសញ្ញាណបណ្ណជាតិឌីជីថល។ ៤.ប្លុកឆេន បានត្រួសត្រាយផ្លូវក្នុងការប្រើប្រាស់ជាចម្បងសម្រាប់ការចុះបញ្ជីដីធ្លី។ ៥.អត្តសញ្ញាណអេឡិចត្រូនិក ឬ e-ID និងហត្ថលេខាឌីជីថល គឺបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងប្រទេសអេស្តូនីជាអត្តសញ្ញាណបណ្ណបែបឌីជីថល និងស្កេនជីវមាត្រ គឺបានជួយសម្រួលដល់ដំណើរការចុះបញ្ជីដីធ្លីតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ ម្ចាស់ដីក៏អាចចុះហត្ថលេខាឌីជីថល និងដាក់ឯកសារទាក់ទងនឹងដីធ្លីដោយមិនចាំបាច់មានឯកសារជាក្រដាសឡើយ។ បច្ចេកទេស XML, Big Data, AIs មានលក្ខណៈពិសេសដល់លំហូរការងារដោយស្វ័យប្រវត្តិកម្មនៃរដ្ឋាភិបាលអេឡិចត្រូនិក និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ការធ្វើបច្ចុប្បន្នភាព និងការកែប្រែជាបន្តបន្ទាប់នៃកំណត់ត្រាឆ្លាតវៃលើប្រព័ន្ធព័ត៌មានដីធ្លី។[233]

### ខ.សហព័ន្ធស្វីស (Swiss Confederation-Switzerland)

បទប្បញ្ញត្តិប្រទេសស្វីស អាចចាត់ទុកថាជាប្រទេសដែលមានច្បាប់ស៊ីវិលតឹងរ៉ឹង។[234] ការគ្រប់គ្រងនៅលើអចលនទ្រព្យ កំណត់ដោយច្បាប់ជាលាយលក្ខណ៍អក្សរក្នុងកម្រិតសហព័ន្ធ ដូចក្រមរដ្ឋប្បវេណី, ក្រមកាតព្វកិច្ច, ច្បាប់ស្តីពីការលក់ទិញអចលនទ្រព្យដោយជនបរទេស (ហៅថា Lex Koller) ដែលគ្របដណ្តប់អនុវត្តបំណុលច្បាប់ក្ស័យធននិងបទបញ្ញត្តិស្តីពីការចុះបញ្ជីដីធ្លី។ ច្បាប់ Lex Koller បានដាក់កម្រិតលើការលក់ទិញលំនៅឋាន

---

[232] រដ្ឋបាលសុរិយោដីនៃសាធារណរដ្ឋអេស្តូនី, https://www.kohus.ee/en/estonian-courts/estonian-court-system/county-courts/tartu-maakohus/land-registry-and-registration (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។

[233] សេចក្តីថ្លែងការណ៍ UN ស្តីពីប្រព័ន្ធភូមិសាស្ត្រ, https://ggim.un.org (ទស្សនាចុងក្រោយថ្ងៃទី២៦ ឧសភា ២០២៤)។ និងប្រភពមួយទៀត៖ https://thedocs.worldbank.org/en/doc/165711456838073531-0050022016/original/WDR16BPEstonianeGovecosystemVassil.pdf ។ បន្ថែមពី *កិច្ចសន្យាឆ្លាតវៃ (Smart Contract), ប្រព័ន្ធក្លោដ និងប្រព័ន្ធ evarium* ។

[234] Baker McKenzie, "Real Estate Law," https://resourcehub.bakermckenzie.com/en/resources/global-corporate-real-estate-guide/europe-middle-east-and-africa/switzerland/topics/real-estate-law (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

និងអចលនទ្រព្យចំពោះជនបរទេស ខណៈពេលដែលការលក់ទិញក្រោមរូបភាពវិនិយោគ ឬទុនពាណិជ្ជកម្ម មិនត្រូវរឹតបន្តឹងក្រោមច្បាប់ Lex Koller ឡើយ។ មានការមិនពេញចិត្តមួយចំនួន ចំពោះច្បាប់នេះ ប៉ុន្តែ សភាស្វីសបានសម្រេចចិត្តរក្សាច្បាប់ Lex Koller នេះ ជាវិធានការដ៏មានប្រសិទ្ធភាពតែមួយគត់ដើម្បីកាត់បន្ថយតម្រូវការខ្លាំងពេក និងកាត់បន្ថយហានិភ័យទីផ្សារអចលនទ្រព្យលំនៅឋាន ដោយឈ្មួលទុច្ចរិត។[235] កម្ពុជាគួររៀនសូត្រពីច្បាប់នេះ ជាពិសេស ចំពោះបទប្បញ្ញត្តិស្តីពីចំណែកសហកម្មសិទ្ធិ, លំនៅឋាន, និងបុរីនៅកម្ពុជា។

ការចុះបញ្ជីដីស្វីនៅសហព័ន្ធស្វីស ក៏មានផែនការបែងចែកដីជាឡូត៍ៗ ផងដែរ។[236] រដ្ឋមួយដែលអព្យាក្រឹត្យមិនចូលបក្សសម្ព័ន្ធមួយនេះ មានភាពជឿនលឿនខ្លាំងស្ទើរគ្រប់វិស័យដោយផ្អែកលើបច្ចេកវិទ្យា។[237] ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីដំបូងក្នុងសហព័ន្ធស្វីសរួមមាន៖ ១.ការវាស់វែងសុរិយោដី និងការធ្វើផែនទីដោយស្វ័យប្រវត្តិ គឺជារដ្ឋមានប្រព័ន្ធសុរិយោដីឌីជីថលភាពត្រឹមត្រូវខ្ពស់ និងទាន់សម័យ រួមទាំងការស្កេនពី GPS និងឡាស៊ែរ ដើម្បីគូសផែនទីក្បាលដីយ៉ាងជាក់លាក់ដោយ https://www.geo4me.ch/en/surveyors/swiss។ ២.e-Grunbuch នៃការចុះបញ្ជីដីធ្លីឌីជីថល ជាមូលដ្ឋានទិន្នន័យឌីជីថលកណ្តាល ដែលរក្សាទុករាល់កំណត់ត្រាទាក់ទងនឹងដីធ្លី រួមទាំងសិទ្ធិកម្មសិទ្ធិ ប្រតិបត្តិការ និងការជាប់គាំងបញ្ហាណាមួយដោយប្លុកឆេន។ ៣.បញ្ជូនឯកសារតាមអេឡិច-ត្រូនិក អនុញ្ញាតឱ្យមានការបញ្ជូន បង្ហោះ ទទួលសារតាមអេឡិចត្រូនិក និងដំណើរការឯកសារណេបប្រតិបត្តិការដីធ្លី ដូចជាការផ្ទេរកម្មសិទ្ធិ ជាដើម។ ៤.ប្រព័ន្ធអន្តរព័ត៌មានភូមិសាស្ត្រ GIS ជាសំណុំទិន្នន័យភូមិសាស្ត្រផ្សេងៗ រួមទាំងផែនទីសណ្ឋានដី រូបភាពពីលើអាកាស និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលប្រើយ៉ាងទូលំទូលាយនៃក្បាលដី គាំទ្រដល់ការធ្វើផែនការ និងការគ្រប់គ្រងប្រើប្រាស់ប្លង់គោលកាន់តែប្រសិទ្ធភាព។ ៥.e-gov និងការចូលប្រើប្រាស់សេវាកម្មសាធារណៈ ជាវិបផតថលអនឡាញដែលអនុញ្ញាតឱ្យម្ចាស់ដី និងសាធារណជនទូទៅអាចចូលប្រើប្រាស់ព័ត៌មាន និងសេវាកម្មទាក់ទងនឹងដីធ្លី ដូចជាការស្វែងរកអចលនទ្រព្យ និងការសាកសួរអំពីកម្មសិទ្ធិជាដើម។ ៦.ហត្ថលេខាអេឡិចត្រូនិក និងអត្តសញ្ញាណបុគ្គលឌីជីថល គឺប្រព័ន្ធកំណត់អត្តសញ្ញាណអេឡិចត្រូនិកកម្រិតខ្ពស់ និងនីត្យានុកូលកម្មនៃហត្ថលេខាឌីជីថល ដើម្បីដំណើរការប្រតិបត្តិការឌីជីថលស្របច្បាប់ក្នុងដំណើរការចុះបញ្ជីដីធ្លី។ ប្រព័ន្ធចុះបញ្ជីដីឌីជីថលរបស់ប្រទេសស្វីសត្រូវបានចាត់ទុកថាជាគំរូអភិបាលកិច្ចប្រព័ន្ធទំនើប និងមានប្រសិទ្ធភាពបំផុតមួយក្នុងពិភពលោក។[238]

---

235 Canton Du Valais, "Prestation du Registre Foncier" [សេវាកម្មចុះបញ្ជីដីធ្លី], https://www.vs.ch/web/srf/regis tre-foncier (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

236 News+ Events Feed, "PSP Swiss Property AG" [អចលនទ្រព្យសហព័ន្ធស្វីស AG], *EAS,* ២០២៤, https://www.eqs-news.com/news/adhoc/psp-swiss-property-achieves-solid-operating-results-and-improves-the-ebitda-guidance-for-the-2024-business-year/2048323 (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

237 Corinne Ari, "Offering Best Digital Conditions: Switzerland Celebrates National Digital Day" [ការផ្តល់ជូនលក្ខខណ្ឌឌីជីថលល្អបំផុត៖ ប្រារព្ធទិវាឌីជីថលជាតិស្វីស], ២០១៧, https://www.s-ge.com/en/article/news/20174-ict-digitalday?ct (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

238 Geo4me, https://www.geo4me.ch/en/geoinformatics/territorial-information-system-gis/ (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

## ៣.២. វិធានការសុវត្ថិភាពអេឡិចត្រូនិក

"បណ្តាញប្លុកឆេន អាចចាត់ទុកថាជាសៀវភៅបញ្ជីចែកចាយ តម្កល់ទុកកំណត់ត្រាប្រតិបត្តិការ ផ្ទៀងផ្ទាត់សមកាលកម្ម ប្រកបដោយសុវត្ថិភាព និងជាអចិន្ត្រៃយ៍ក្នុងបរិមាណភាគីអន្តន (n) (Krishnapriya and Greenshma,២០២០)។"[239] លិខិតទម្រង់ការចុះបញ្ជីនិងកំណត់ត្រាសុរិយោដី ធ្លាប់រក្សាទុកជាលិខិតផ្លូវការក្នុងទម្រង់ជាឯកសារក្រដាស ដែលអាចកើតមានបញ្ហាបាត់បង់ បំផ្លាញ និងការកែប្រែឯកសារចាំបាច់ ក៏ដូចការរក្សាទុកជាអចិន្ត្រៃយ៍, និង/ឬ១០-២០ឆ្នាំ។[240] ចំពោះគោលបំណងទាំងនេះ គឺការរួមចំណែកដោះស្រាយបញ្ហាជាច្រើនត្រូវធ្វើឡើងដោយអ្នកស្រាវជ្រាវផ្សេងៗគ្នា ដើម្បីរកវិធីសាស្ត្រលើដំណើរការចុះបញ្ជីដីធ្លីបែបប្រពៃណី ដោយជំនួសឱ្យប្រើបច្ចេកវិទ្យាប្លុកឆេន។ ការផ្ទេរលិខិតទម្រង់ព័ត៌មាន និងឯកសាររណបជាទម្រង់អាណាឡូក ទៅជាទម្រង់ឌីជីថលគឺកម្ពុជាគួរតែពិចារណាកង្វល់នេះ។

ទន្ទឹមនេះ វេទិកាដំណើរការលំហូរការងារស្វ័យប្រវត្តិកម្មរបស់រាជរដ្ឋាភិបាល សម្រាប់ផ្តល់សេវាសាធារណៈក៏បានដាក់ឱ្យប្រើប្រាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាព https://flow.gov.kh ដើម្បីសម្រួលទៅដល់គុណភាពរយៈពេលការងារ។ ស្រដៀងទៅនឹង Konica Minolta ដែលពេញនិយមក្នុងអភិបាលកិច្ចប្រទេសថៃ។[241] ម្យ៉ាងវិញ ថ្នាលផ្ទុកឯកសារសាធារណៈផ្លូវការកម្ពុជា https://go.gov.kh/#/ គឺអាចប្រើប្រាស់បានសម្រាប់តែមន្ត្រីសាធារណៈ ដើម្បីការពារពីការវាយប្រហារសន្តិសុខសាយប័រយថាហេតុ និងមានតួនាទីអាចផ្សព្វផ្សាយ ចែករំលែក និងវិភាគ ផងដែរ។ តើការរក្សាទុកក្រដាស និងកត់ត្រាដោយដៃនៅតែបន្តដែរឬទេ? ឬដើម្បីបង្ការខ្លាចមានបញ្ហាគាំងប្រព័ន្ធឌីជីថល ឬអ៊ីនធឺណិត? ប្រាកដណាស់! ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា គួរតែដើរសន្ទឹមៗ ដោយត្រូវព្យាយាមសម្របប្រជាពលរដ្ឋឱ្យប្រើប្រាស់សេវាសាធារណៈ៥០/៥០ (ប្រើប្រាស់ប្រព័ន្ធអនឡាញផង និងតាមទម្លាប់ចាស់ដដែរផង ចំពោះប្រជាពលរដ្ឋមិនទាន់យល់ជ្រាបឌីជីថល ឬក៏បែងចែកតំបន់[គិតគូរ] គឺមិនខុសពីការប្រើប្រាស់ធនាគារទូទាត់ឌីជីថលនោះទ្បើយ)។ មួយវិញទៀត ការបង្កើតផតថលនៃទម្រង់បែបបទ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ឱ្យប្រើប្រាស់មិនគិតថ្លៃដោយសុវត្ថិភាព https://form.gov.kh ដែលមានសារៈប្រយោជន៍ និងស្រដៀងមុខងារខ្លះៗដូចនឹង Google Form និងប្រព័ន្ធ INA-GovTech របស់សាធារណរដ្ឋឥណ្ឌូនេស៊ី។[242] ការគិតគូរពីបរិស្ថានសង្គម និងបរិស្ថានសុរិយោដី-ឌីជីថល ជាបញ្ហាមួយជ្រុងគួរដោះស្រាយ។ ដូចនេះ គឺចាំបាច់ត្រូវមានការបង្កើត កែតម្រូវ និងសម្របសម្រួលឱ្យមានគំរូយន្តការដែលពាក់ព័ន្ធនឹងឯកសារ។

239 Krishnapriya S, and Greenshma Sarath, "Securing Land Registration using Blockchian" [កិច្ចធានាការចុះបញ្ជីដីធ្លីដោយប្រើប្រាស់ប្លុកឆេន], *Elsevier* (India) 171-1708-1715 (2020)។

240 សេចក្តីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា៨៧ *[ការរក្សាទុកជាអចិន្ត្រៃយ៍ សម្រាប់ប្លង់សុរិយោដី សៀវភៅគោលបញ្ជី សៀវភៅចុះបញ្ជីសិទ្ធិ ជាអាទិ៍, រក្សាទុក២០ឆ្នាំ សម្រាប់បញ្ជីឈ្មោះកម្មសិទ្ធិករ ទម្រង់បែបបទទិន្នន័យក្បាលដី សម្រង់សុរិយោដី ជាអាទិ៍, រក្សាទុក១០ឆ្នាំ សម្រាប់សាលកបត្របង្រួមនិងបំបែកក្បាលដី លិខិតលក់ផ្តាច់ ជាអាទិ៍]*។

241 ซอฟต์แวร์การจัดการและอนุมัติ เอกสารออนไลน์ [លំហូរការងារស្វ័យប្រវត្តិកម្ម], https://onestopitservices.konicaminolta.co.th/th/e-approval-workflow-benefits/ (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។

242 KPL, https://kpl.gov.la/En/detail.aspx?id=82969 (ទស្សនាចុងក្រោយថ្ងៃទី២៧ ឧសភា ២០២៤)។ *ដូចករណីស្វ័យប្រវត្តិកម្មទិន្នន័យគយ យកគំរូពី ASYCUDA និង e-Customes (ស្វីស) នៃបញ្ជរជាតិតែមួយ។*

| កម្មវត្ថុ | ឆ្លើយតប |
| --- | --- |
| កាត់បន្ថយប្រើប្រាស់ក្រដាសគ្រប់ប្រភេទ (A4, A3, A0...) | កាត់បន្ថយការបំពេញឯកសារច្រើនសារពីប្រជាពលរដ្ឋ ធុរជន មន្ត្រី ជាអាទិ៍<br>កាត់បន្ថយការព្រីនឯកសារច្រើនលើសលុប និងរាល់ឯកសារមិនចាំបាច់<br>កាត់បន្ថយការប្រើប្រាស់សម្ភារៈការិយាល័យផ្សេងៗ<br>បរិវេណផ្ទុក និងតម្កល់ឯកសារ លែងជាបញ្ហាព្រួយបារម្ភ |
| ទទួលព័ត៌មានរហ័សតាមរយៈ TelegramBOT ឬ SarikaBOT នៃបណ្តាញមជ្ឈការ វិមជ្ឈការ | ការផ្តល់ ទទួលព័ត៌មានរហ័សដល់អង្គភាពមានសមត្ថកិច្ច ជាអន្តរប្រតិបត្តិ<br>អាចចូលពិនិត្យសំណុំឯកសារ របាយការណ៍ ទិន្នន័យ ព្រឹត្តិបត្រ និងវិធាន<br>អាចផ្ញើការជូនដំណឹងបឋម ពិសេស និងផ្លូវការ<br>សម្រួលឯកសារត្រួតពិនិត្យ កែតម្រូវ សមកាលកម្ម និងសម្រេចពីថ្នាក់ដឹកនាំ |
| ការសម្រួលធុរកិច្ចរបស់អង្គភាព | សម្រួលចរន្តការរដ្ឋបាលស្ថាប័ន និងពន្លឿនរយៈពេលការអនុវត្ត (Dynamic)<br>បណ្តាញសាធារណៈ និងប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិកមានលក្ខណៈប្រមូលផ្តុំ<br>ងាយស្រួលជាស់តឿន ពិនិត្យលទ្ធភាព និងឆ្លើយតប |
| ការពង្រីកវិសាលភាពប្រព័ន្ធ | ងាយស្រួលស្នើសុំរដ្ឋបាលតាមរយៈប្រព័ន្ធ ដោយស្នើសុំបេសកកម្ម, បន្ទប់ប្រជុំ, លិខិតអញ្ជើញ, លិខិតបទដ្ឋានគតិយុត្តដទៃទៀត<br>ភ្ជាប់បណ្តាញរហ័សជាមួយប្រព័ន្ធសំខាន់ៗនិងបង្កើតលេខចំណាំ (Unique ID)<br>បណ្តាញសាធារណៈរបស់ក្រសួង ស្ថាប័នដទៃ ងាយស្រួលការទទួល និងផ្តល់គ្រប់ទម្រង់នៃចរន្តការរដ្ឋបាលទៅវិញទៅមកនិងជាអន្តរការី (EcoSystem)<br>កត់ត្រាទិន្នន័យ និងគ្រប់គ្រងមន្ត្រីរាជការក្រសួង ស្ថាប័នតាមប្រព័ន្ធឌីជីថល |
| ឃ្លាំងឯកសារអេឡិចត្រូនិក | រក្សាទុកសំណុំឯកសារក្នុងប្រព័ន្ធឌីជីថល ជាអចិន្ត្រៃយ៍<br>ផលិតរបាយការណ៍សង្ខេបពីចំនួនឯកសារចេញ-ចូលរបស់ស្ថាប័ន<br>ងាយស្រួលវិភាគ តាមដាន ស្វែងរក និងកត់សម្គាល់ |

តារាងទី១៣. គំរូអភិបាលកិច្ចនៃរដ្ឋបាលអេឡិចត្រូនិក

ដើម្បីពន្លឿនប្រសិទ្ធភាពលើការចុះបញ្ជីដីធ្លីបង្ហើយ ត្រូវគាំពារលំហូរសុវត្ថិភាពឯកសារសាធារណៈ (៣.២.១) និងមធ្យោបាយទូទាត់ប្រាក់ (៣.២.២) ដែលជាប្រភពនៃចំណូលថវិកាជាតិ។

តើអភិក្រមបែបចូលរួម កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ឬនៅ ជាពិសេសការចូលរួមអន្តរប្រតិបត្តិស្ថិតក្រោមអភិបាលកិច្ចរបស់រដ្ឋាភិបាលឌីជីថល?

### ៣.២.១. សុវត្ថិភាពឯកសារសាធារណៈ

ឯកសារសាធារណៈមួយផ្នែក គឺជាព័ត៌មានសម្ងាត់ជាតិ។ ឯកសារព័ត៌មានសម្រង់សុរិយោដី ជាលិខិតគតិយុត្តអាចបញ្ជាក់អំពីទ្រព្យមូលធនរបស់ប្រជាពលរដ្ឋ។ ពេលខ្លះការអនុវត្តរុញដាក់គ្នា ឬជាន់សមត្ថកិច្ចគ្នា ឬពីដៃមួយ ទៅដៃមួយទៀត អាចសបង្ហាញពីការចាត់ចែង និងការគ្រប់គ្រងស្ថានភាពការងារនៅមានកម្រិត។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ ក្រសួង ដ.ន.ស មានមន្ត្រីសរុប២.៨៤៥រូប ក្នុងនោះស្ត្រី៥៥៤រូប។[243] រាជរដ្ឋាភិបាល គឺ

[243] ដូច១៩០, ទំ.១-២។ [ក្នុងនោះមន្ត្រីក្របខណ្ឌសរុប២.០១២រូប (ស្ត្រី៤១៦រូប) និងទីស្តីការក្រសួងមន្ត្រីសរុប៧៤៨រូប(ស្ត្រី១៦៨រូប)]។

បានដាក់ចេញសេចក្តីណែនាំ និងត្រូវពិនិត្យមើលរចនាសម្ព័ន្ធមន្ត្រីជាន់គ្នា និងអតីតមន្ត្រីដែលបានបណ្តេញចេញ ប៉ុន្តែ ដឹងពីប្រព័ន្ធផ្ទៃក្នុង។[244] ក៏ដូចជា ការផ្តល់សេវាសាធារណៈ និងបំពេញមុខងារដែលមិនត្រូវបន្ថែមទម្ងន់បែបបទ និងនីតិវិធីដែលមានស្រាប់នៅតាមអង្គភាព ក្រសួង ស្ថាប័ន។[245] បរិការណ៍នេះ ធ្វើឡើងដើម្បីការពាររាល់ឯកសារសាធារណៈ ដែលកកស្ទះយូរឆ្នាំ និង/ឬត្រូវបានលួចយកពីអតីតមន្ត្រីសាធារណៈនៃក្រសួងសាមីផង ឬ ហេកគ័រ (Hacker) ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទ្រព្យសម្បត្តិជាតិ។[246] ការទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺថ្នាក់ដឹកនាំ រួមទាំងមន្ត្រីទាំងអស់របស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រ-ហាក់ប្រហែលលើ៖ ១.ការតាក់តែង, ២.ការអនុវត្តលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងស្របតាមបទបញ្ញត្តិពាក់ព័ន្ធ និង៣. ការថែរក្សារចនាសម្ព័ន្ធប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។[247] ការត្រួតពិនិត្យឯកសាររូបវន្ត ក៏គួរត្រូវប្រុងប្រយ័ត្នខ្ពស់។

កាលពីថ្ងៃទី២០ ឧសភា ២០២៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានកិច្ចសហការឱ្យមានប្រព័ន្ធតាមដានវឌ្ឍន-ភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ G-PSF Tracking System លើកទី១៩ ដែលអាចស្វែងរកទិន្នន័យលម្អិតស្តីពីវឌ្ឍនភាពការងារគ្រប់កម្រិត (តាមក្រសួង ស្ថាប័នទទួលបន្ទុក និងអនុវត្ត, ក្រុមការងារតាមវិស័យ...) និងគាំទ្រការបង្កើត Dashboard layout system ដែលអាចវិភាគ និងតាមដានកិច្ចការក្នុងវិស័យរដ្ឋ និងឯកជន។[248] ទៀតសោត គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលកម្ពុជា ក៏បានបង្កើតប្រព័ន្ធគ្រប់គ្រងគម្រោងបច្ចេកវិទ្យាព័ត៌មាន https://pe.digitaleconomy.gov.kh/login ផងដែរ។ កត្តានេះហើយ អាចជាជ្រុងមួយដោះស្រាយបញ្ហាឯកសារផ្ទៃក្នុង។ ករណីនៅព្រះរាជាណាចក្រម៉ាឡេស៊ី គឺហៅថាប្រព័ន្ធ MyDIGITAL។[249]

### ៣.២.១.១. ហត្ថលេខា និងចេញបណ្ណទម្រង់ឌីជីថល

យោងតាមរបាយការណ៍ ខណៈពេលដែលសេដ្ឋកិច្ចឌីជីថលតាមបណ្តាប្រទេសបានធ្វើទំនើបកម្មលើការចុះបញ្ជីដីធ្លីក្នុងរយៈពេល៥ឆ្នាំចុងក្រោយ កំណើនតម្រូវការអចលនទ្រព្យកើន៣ដងជាងប្រទេសនៅបន្តពឹងផ្អែករក្សារបៀបកំណត់ត្រាចាស់ និងរក្សាបណ្ណកម្មសិទ្ធិក្នុងទម្រង់ក្រដាស(Edi & Siti, ២០២១)។[250] រាល់ក្នុងទម្រង់លិខិតយថាភូត ភាគច្រើនឃើញមានការប្រើប្រាស់ជាកំណត់សម្គាល់ដូចជា ហត្ថលេខា ត្រាខៀវ ឬក្រហម ភ្ជាប់ជាមួយ

[244] សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការពិនិត្យឡើងវិញនិងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន, លេខ០១សណន, ២១ ឧសភា ២០២៤។

[245] សារាចររបស់រាជរដ្ឋាភិបាលស្តពីការរៀបចំ និងការកែសម្រួលរចនាសម្ព័ន្ធក្រសួង ស្ថាប័ន, លេខ០៨សរ, ១១ មិថុនា ២០២៤។

[246] ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន, លេខ១០១២ សហវ.ប្រក, ៣១ ធ្នូ ២០២១។

[247] ក្របខណ្ឌសវនកម្មកំណត់ដោយគណៈកម្មាធិការនៃអង្គការគាំទ្ររបស់ស្នងការទ្រើដវេ (COSO), https://www.coso.org/guidance-on-ic (ទស្សនាចុងក្រោយថ្ងៃទី៣០ ឧសភា ២០២៤)។

[248] CDC, https://cdc.gov.kh/km/ (ទស្សនាចុងក្រោយថ្ងៃទី៣០ ឧសភា ២០២៤)។

[249] Ekomomic, https://www.ekonomi.gov.my/sites/default/files/2021-02/malaysia-digital-economy-blueprint.pdf (ទស្សនាចុងក្រោយថ្ងៃទី៣០ ឧសភា ២០២៤)។

[250] Edi Mulyanto, and Siti Ummu Adillah, "Legal Protection of Land Rights Certificate Holders in Certificate Blocking Event by Land Office" [ការការពារស្របច្បាប់នៃអ្នកកាន់កាប់វិញ្ញាបនបត្រកម្មសិទ្ធិដីធ្លី ក្នុងហេតុការណ៍បំបិទសិទ្ធិវិញ្ញាបនបត្រដោយការិយា-ល័យភូមិបាល], *ResearchGate* DOI:10.30659/sanlar.3.2 (2021): 597-612។

គោត្តនាមនិងនាម ដែលមានកាលបរិច្ឆេទ និងទីតាំងជាក់លាក់។ កាលណាឃើញលក្ខណៈបែបនេះ នៅកម្ពុជាគឺចាត់ទុកថាជាលិខិតផ្លូវការ។[251] ការអនុវត្តបច្ចុប្បន្ន ភាគច្រើននៅតែចូលចិត្តប្រើហត្ថលេខា "សើម" នេះជាធម្មតាពោលគឺហត្ថលេខាដែលចុះដោយផ្ទាល់ដៃ។ បើបកស្រាយពី ហត្ថលេខាអេឡិកត្រូនិច ឬហត្ថលេខាឌីជីថល គឺពុំទាន់បានប្រើប្រាស់ទូលំទូលាយក្នុងប្រទេសកម្ពុជានៅឡើយទេ ដោយសារកត្តាចំណេះដឹងជាក់ស្តែង និងកង្វះខាតលិខិតបទដ្ឋានគតិយុត្តទាក់ទិនការប្រើប្រាស់ហត្ថលេខាឌីជីថល ស្របពេលមានអនុក្រឹត្យតែមួយគត់។[252] ហត្ថលេខាអេឡិកត្រូនិក ឬហត្ថលេខាឌីជីថលអាចៈ ១.បញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវ និងជាក់លាក់, ២.បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិកត្រូនិក, ៣.បញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទការចុះហត្ថលេខាឌីជីថល។[253] រីឯហត្ថលេខាស្កេន ពុំមានច្បាប់កំណត់ជាក់លាក់ទេ និងដែលបានមកពីរូបភាពឌីជីថលហត្ថលេខាដែលសរសេរដោយដៃ។ ហត្ថលេខាស្កេន បានមកពីការស្កេនឯកសារក្រដាសដើម រួចបំប្លែងទៅជាទម្រង់ឌីជីថល។ ហត្ថលេខាដោយដៃរួចស្កេន គឺគ្មានតម្លៃគតិយុត្ត ដោយសារហេតុផលមួយចំនួន ដូចជាៈ ១.មិនអាចបញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខី, ២.បញ្ជាក់ការយល់ព្រមរបស់ហត្ថលេខីចំពោះកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាឬឯកសារនោះ និង៣.ងាយស្រួលក្លែងបន្លំ ជាអាទិ៍។ ក្នុងន័យជាភស្តុតាង ហត្ថលេខាស្កេនគឺមានតម្លៃត្រឹមជាហត្ថលេខាថតចម្លង។ ហត្ថលេខាអេឡិចត្រូនិក គឺអាចបង្កើតបញ្ជាក់អំពីកំណត់អត្តសញ្ញាណបុគ្គលរបស់អ្នកចុះហត្ថលេខាដែលទទួលស្គាល់ដោយមន្ត្រីសាធារណៈ និងអាចធានាពីសុចរិតភាព។[254] បន្ថែមពីលើនេះ អាចប្រើប្រាស់ការស្កេនជីវមាត្រ ដូចជាស្កេនក្រយៅដៃ និងប្រស្រីភ្នែក បើទោះបីចង់កេងប្រវ័ញ្ចលើអត្តសញ្ញាណ ឬឈ្មោះខ្មោច (បុគ្គលមរណភាព) ក៏មិនអាចទៅរួចដែរ។

វិញ្ញាបនបត្រ ឬបណ្ណ ដែលសម្គាល់ពីបុគ្គលភាពគតិយុត្តលើការកាន់កាប់សិទ្ធិកម្មសិទ្ធិចំពោះអចលនវត្ថុ គឺជាមធ្យោបាយធានាស្របច្បាប់ បញ្ជាក់ពីភស្តុតាងនៃកម្មសិទ្ធិករ ទិន្នន័យរូបវន្ត និងសម្រង់អត្តសញ្ញាណកម្មសុរិយោដី ដែលអាចជៀសវាងពីការក្លែងបន្លំ ការរារាំងសិទ្ធិ និងការតតាំងនៃកម្មសិទ្ធិករ។ អានុភាពនៃការចុះបញ្ជីចំពោះបណ្ណកម្មសិទ្ធិ លុះត្រាតែមានឈ្មោះកម្មសិទ្ធិករ វៀរលែងតែក្នុងករណី ការលុបចេញពីបញ្ជីដែលប្តូរកម្មសិទ្ធិករថ្មី។[255]កាលពីពេលថ្មីៗនេះ ឃើញមានប្រជាពលរដ្ឋម្នាក់អាចរក្សាទុកបណ្ណកម្មសិទ្ធិតាំងពីសម័យអាណានិគមបារាំងចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុឆ្នាំ១៩៣០-១៩៣២ ដែលមានអាយុកាល៩៤ឆ្នាំ។ កាលប្រជុំធ្វើសេចក្តីព្រាងច្បាប់ភូមិបាលថ្មី មន្ត្រីជាន់ខ្ពស់នៃក្រសួង ដ.ន.ស ថាបើថ្ងៃអនាគតអាចឱ្យប្រជាពលរដ្ឋប្តូរប្រើប្រាស់ និងឱ្យតម្លៃបណ្ណជាទម្រង់អេឡិចត្រូនិក ឬឌីជីថល គឺពិតជាល្អប្រសើរណាស់។ បច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរទទួលយកបណ្ណ គឺតែងតែយកអ៊ុតផ្លាស្ទិករឹង ដាក់ទូដែក ចាត់ទុកថាបណ្ណក្រដាសដូចមាស១០តម្លឹងចឹង។ ពិព្រោះ យល់ថាខ្លាចបាត់ ខូចខាត និងចោរលួចយកទៅផ្ទេរកម្មសិទ្ធិ។ ក្រសួង ដ.ន.ស ក៏មានប្រសាសន៍ថា "ត្រូវការពេលដោះស្រាយ

[251] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, មាត្រា៦។

[252] សេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិហិរញ្ញវត្ថុស្តីពីសិក្ខាសាលាផ្សព្វផ្សាយស្តីពីថ្នាលគ្រឹះឌីជីថលកម្ពុជា, ៨ កញ្ញា ២០២២។

[253] ដូច១០៥, មាត្រា៩។

[254] ក្រមរដ្ឋប្បវេណីនៃសាធារណរដ្ឋបារាំង, មាត្រា១៣៦៧។

[255] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៣៧។ និងសេចក្តីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា១៤៩។

បញ្ហានេះ”។ កត្តាហេតុផលចាំបាច់ក្នុងការផ្លាស់មកប្រើបរិវត្តកម្មឌីជីថលនៃទម្រង់បណ្ណអេឡិចត្រូនិក អាចធានាចេញបណ្ណកម្មសិទ្ធិលឿនជាងមុន។[256]

### ៣.២.១.២. ថ្នាលផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកសារសុវត្ថិភាពឌីជីថល ( Verify.gov.kh )

បច្ចុប្បន្ន ប្រទេសកម្ពុជា និយមយកឯកសារទៅធ្វើ អត្រានុកូលកម្ម នៅតាមអង្គភាពអាជ្ញាធរមានសមត្ថកិច្ច ដូចជា ឃុំ សង្កាត់ និងការិយាល័យច្រកចេញ-ចូលតែមួយ ដែលត្រូវចំណាយរង់ចាំទទួលបង្កាន់ និងរយៈពេល៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ ទើបអាចប្រើការបាន។ យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ បានអនុញ្ញាតនៅថ្នាក់វិមជ្ឈការ គឺកាត់បន្ថយយកឯកសារបញ្ជាក់ និងទទួលប្រាក់កម្រៃសេវានៅការិយាល័យច្រកចេញ-ចូលតែមួយ។ ព្រមទាំងក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថលថ្មីដែលអាចកាត់បន្ថយការក្លែងបន្លំ, ទុតិយតា (ចេញបណ្ណលើកទី២) លើសញ្ញាបត្រនៃថ្នាក់ទុតិយភូមិ និងតាមបណ្ដាឧត្តមសិក្សា ហៅថា "ថ្នាលផ្ទៀងផ្ទាត់ និងបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារឌីជីថល" https://verify.gov.kh ។ ឧទាហរណ៍. សញ្ញាបត្រថ្នាក់បណ្ឌិតដែលបានភ្ជាប់តាមថ្នាលនេះ គឺអាចដឹងថាបុគ្គលនោះ ពិតជាបានបញ្ចប់ការសិក្សាយ៉ាងពិតប្រាកដ។[257]

ថ្នាលនេះ ត្រូវបានបង្កើតឡើងដោយប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន អាចកាត់បន្ថយឧបសគ្គបានយ៉ាងច្រើនចំពោះការបោះពុម្ពឯកសារក្រដាស ការការពារក្នុងទម្រង់ដែលមានសុវត្ថិភាព ផ្អែកលើគោលការណ៍ (Security, Scallability, Performance-SSP)។ រាល់ទិន្នន័យអ្នកប្រើប្រាស់ គឺមិនត្រូវបានបោះពុម្ពផ្សាយនៅលើប្លុកឆេនទេ។ មានតែលេខកូដឌីជីថលតែមួយគត់ដែលត្រូវបានរក្សាទុកលើប្លុកឆេន ដើម្បីបញ្ជាក់ថាឯកសារគឺមានភាពត្រឹមត្រូវ។ បច្ចុប្បន្ន ថ្នាលនេះមានមុខងារផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារ តាមរយៈ ឃ្យូ.អ.កូដស្តង់ដា។ ប្រសិនបើ ឃ្យូ.អ.កូដ ត្រឹមត្រូវ (មិនត្រូវបានកែសម្រួល) ថ្នាលនេះនឹងបង្ហាញឯកសារដើម ដើម្បីឱ្យអ្នកប្រើប្រាស់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរវាងឯកសារដើម និងឯកសារដែលបានបង្ហោះដោយផ្ទាល់។ ករណី បើឯកសារត្រូវបានដកហូត (Revoked)មានន័យថាក្រសួង ស្ថាប័នសាមីដែលចេញឯកសារនោះ ត្រូវបានលុបចោល និងគ្មានសុពលភាព។ ថ្នាលនេះ ក៏ទទួលពានឌីជីថលអាស៊ានឆ្នាំ២០២៤ កាលពីថ្ងៃទី១ កុម្ភៈ ២០២៤។ ក្រសួង ដ.ន.ស ក៏បានចុះ MOU និងត្រៀមដាក់ឱ្យប្រើប្រាស់នៃឃ្យូ.អ.កូដស្តង់ដានៅលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ស៊េរីថ្មី)។

---

[256] Scott Beyer, "Why Land Titles Need to Go Digital" [ហេតុអ្វីបណ្ណកម្មសិទ្ធិដីធ្លីត្រូវការឌីជីថល], *Governing*, ២០២២, https://www.governing.com/next/why-land-titles-need-to-go-digital (ទស្សនាចុងក្រោយថ្ងៃទី៣ មិថុនា ២០២៤)។ និងមួយទៀត Annisa Weningtyas, and others, "The Concept of Indefeasible Title in Electronic Land Certificates as an Initiative to Prevent Land Mafia" [គោលគំនិតនៃខ្លឹមសារ មិនអាចប្រកែកបានចំពោះវិញ្ញាបនបត្រកម្មសិទ្ធិដីធ្លីអេឡិចត្រូនិក ដែលជាគំនិតផ្តួចផ្តើមទប់ស្កាត់ពីការរំលោភដីធ្លី], *ReseachGate* DOI 10.53639/ijssr.v5i1.188 (2024)។

[257] ត្រូវបានបង្កើតឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល របស់រាជរដ្ឋាភិបាលកម្ពុជា ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

### ៣.២.២. មធ្យោបាយទូទាត់ប្រាក់

យោងតាមរបាយការណ៍ការចំណូលចុះបញ្ជីរបស់ក្រសួង ដ.ន.ស គិតត្រឹមឆមាសទី១ ឆ្នាំ២០២៣ ចំណូលរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្តប្រមូលបាន២៩២.៧៧៤.២០៨.៩០៥ រៀល ក្នុងនោះគឺសេវាសុរិយោដីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធចំនួន១៦.០១០.៥៨៥.៨០៥រៀល និងចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ២៤.៥៨៧.៩៧៣.១០០រៀល ក៏ដូចជាសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូ-និកដែលទទួលកម្រៃឆែកព័ត៌មាន២០.០០០រៀល/លើក ប្រមូលបាន៨.៣៧៦.២០០រៀល។

យោងតាមប្រកាសអន្តរក្រសួងលេខ៣៥៦សហវ.ប្រក, អនុក្រឹត្យស្តីពីសេវារដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត, និងប្រកាសអន្តរក្រសួងរបស់ខាងក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុស្តីពីការផ្តល់ប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមអេឡិចត្រូនិក គឺពុំបានបិទសិទ្ធិពីរបៀបរបប ឬមធ្យោបាយនៃការទូទាត់កម្រៃសេវាសាធារណៈឡើយ។ ទៀតសោត ការទូទាត់កម្រៃសេវាការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុគួរអាចប្រើវិធីសាស្ត្រដោយសាច់ប្រាក់ផ្ទាល់ផង ឬដោយប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ (ប្រព័ន្ធធនាគារឌីជីថល) ដែលបានកំណត់តម្លៃទុកជាក់លាក់។[258]

#### ៣.២.២.១. ប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ

ក្រោយពីគាំពារ និងប្រយុទ្ធប្រឆាំងជំងឺកូវីត១៩ ដោយជោគជ័យ កម្ពុជាគឺបានផ្លាស់ប្តូរបរិបទសឹងតែ១៨០° លើការប្រើប្រាស់មធ្យោបាយទូទាត់ប្រាក់។ ជាពិសេស យុវជនខ្មែរ និងក្នុងតំបន់ទីប្រជុំជន គឺនិយមប្រើការទូទាត់បែបធនាគារឌីជីថល ឬស្កេនឃ្យូអរកូដ ក្រោយមកទើបមានប្រើយ៉ាងទូលំទូលាយទាំងគ្រប់វ័យ តំបន់ និងប្រភេទ ហើយនេះជាទស្សនវិស័យមួយ បង្ហាញថា "កម្ពុជា គឺអាចនឹងសម្រេបឌីជីថលដោយមិនដឹងខ្លួន"។ បច្ចេកវិទ្យាហរិញ្ញវត្ថុ មានច្រើនប្រភេទ ប៉ុន្តែ ពិភពលោកទទួលស្គាល់ច្រើនបំផុតគឺ បច្ចេកវិទ្យាហ្វីនតិច (Fin-Tech) ដែលមានវត្តមានតាំងពីសតវត្សរ៍ទី១៩ មកម្ល៉េះ។ បច្ចេកវិទ្យានេះ អាចសម្រេបអន្តរកម្មបានគ្រប់មជ្ឈដ្ឋានជាមួយបច្ចេក-វិទ្យាដទៃទៀត ដូចជាប្លុកឆេន, AI, Metamask, និង Bitcoin ជាអាទិ៍។ ភាគច្រើន ស្គាល់តាមរយៈវិស័យធនា-គារ ដោយការទូទាត់សងប្រាក់ជាតួលេខសិប្បនិម្មិត ឬតួលេខឌីជីថល វិលជុំនៃប្រព័ន្ធហរិញ្ញវត្ថុ។[259]

កម្ពុជា គិតត្រឹមឆ្នាំ២០២៣ យោងទៅតាមរបាយការណ៍ធនាគារជាតិនៃកម្ពុជាមានទំហំ៤៩២ប៊ីលានដុល្លារជាទំហំប្រាក់ដែលបានផ្ទេរ ទូទាត់ និងចំនួនប្រតិបត្តិការសរុប១.៧៨៦លានដង ក្នុងនោះមានការវិនិយោគផ្ទាល់បរទេសចំនួន១៩៧.៨ទ្រីលានដុល្លារអាមេរិក ឬស្មើ+៧,៨%។[260] បណ្តាក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ នៅកម្ពុជាបានរួមចំណែកអភិវឌ្ឍពីវិធីសាស្ត្រឱ្យកាន់តែងាយស្រួល រហ័សផងដែរដូចជា KHQR Code, បាគង (Bakong), ABA, ACELEDA, Kess Innovation Plc ជាអាទិ៍។ រួមផ្សំនឹងបច្ចេកវិទ្យា CamDL ដែលរាជរដ្ឋាភិបាលកម្ពុជាបង្កើតថ្ងៃទី១៣ វិច្ឆិកា ២០២១ បានជំរុញពីបណ្តាញប្លុកឆេនឆ្លាស់ដែលយកមកប្រើប្រាស់ រវាងការទទួលស្គាល់

---

[258] ដូច១៩០, ទំ.៤, និងច្បាប់ភូមិបាល២០០១, មាត្រា៣០។

[259] Cfte.edu, https://courses.cfte.education/blockchain-and-defi-projects/ (ទស្សនាចុងក្រោយថ្ងៃទី៩ មិថុនា ២០២៤)។

[260] Fintech: https://digitaleconomy.gov.kh/fintech [២០២១] (ទស្សនាចុងក្រោយថ្ងៃទី១៦ មិថុនា ២០២៤)។

អត្តសញ្ញាណបុគ្គលឌីជីថល និងបណ្ដាញមុខងារសេវាសាធារណៈឌីជីថល https://camdl.gov.kh ។

### ៣.២.២.២. កំណត់ត្រាពន្ធដារ

គិតមកត្រឹមខែកក្កដា ឆ្នាំ២០២៤ ខេត្តកណ្ដាល និងខេត្តកំពង់ចាម គឺបានត្រៀមចុះបញ្ជីដីធ្លីបង្ហើយរួចរាល់។ តើការចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុតាមប្រព័ន្ធអនឡាញ ឬឌីជីថល មានផលប្រយោជន៍ខាងផ្នែកពន្ធដារដែរឬទេ? រាល់សម្រង់សុរិយោដីដែលបញ្ជាក់ពីសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ គឺក្រសួង ដ.ន.ស ត្រូវប្រគល់គ្រប់ទម្រង់ព័ត៌មានរបស់កម្មសិទ្ធិករជូនអគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រមូលពន្ធផ្សេងៗជាថវិកាជាតិ ទាក់ទិននឹងអចលន-ទ្រព្យផ្សេងៗ។ ដូចនេះ ប្រសិនបើការគ្រប់គ្រង និងក្ដោបកាប់ ឬកត្តាវិវាទក្នុងដំណាក់កាលចុះបញ្ជីនេះឆកល្វែង គឺធ្វើឱ្យមានភាពយឺតយ៉ាវដល់ផែនការថវិកាជាតិបម្រុងឆ្នាំបន្តបន្ទាប់ និងខាតប្រយោជន៍សាធារណៈ។

រាជរដ្ឋាភិបាលកំពុងដាក់ចេញសេចក្ដីព្រាងសៀវភៅណែនាំស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលទទួលបានការលើកលែងពន្ធប្រថាប់ត្រា (SOP) ស្របតាមបទប្បញ្ញត្តិស្ដីពីពន្ធដារនិងការបញ្ជូនសំណុំឯកសារដើម្បីចុះបញ្ជី និងកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ។ នេះគឺជាយុទ្ធសាស្ត្រមួយ ដែលរៀបចំថ្លឹងក្នុងការគ្រប់គ្រងចំណូលសារពើពន្ធ វិធានការលើកទឹកចិត្តផ្នែកសារពើពន្ធ និងការលើកទឹកចិត្តប្រជាពលរដ្ឋឱ្យមកចូលរួមការចុះបញ្ជីដីធ្លីបង្ហើយ ដែលជាយន្តការដោះស្រាយផ្នែកពន្ធដារដល់ការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុតាមប្រព័ន្ធអនឡាញ។

ទន្ទឹមនឹងការស្រូបយកប្រយោជន៍សាធារណៈ អគ្គនាយកដ្ឋានពន្ធដារ បានបន្តអភិវឌ្ឍន៍បច្ចេកទេសនៃការទូទាត់កម្រៃពន្ធទៅតាមប្រភេទ ដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ការសម្រួលនីតិវិធី តាមរយៈប្រព័ន្ធអន-ឡាញ អាចឱ្យប្រើប្រាស់ធ្វើប្រតិបត្តិការតាមរយៈ dApp នៃឧបករណ៍ឆ្លាតវៃ (ទូរសព្ទដៃ ថេប្លេត កុំព្យូទ័រ ជាអាទិ៍) របស់អ្នកប្រើប្រាស់បាន ដូចជា កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration, ប្រព័ន្ធបង់រហ័ស (e-Quick Payment) ជាអាទិ៍ ដោយអនុញ្ញាតតាមរយៈការស្កេនបាកូដបង្កាន់ដៃ ឬបាកូដស្ដង់ដារ ឬឃ្យូអរកូដនៃវិញ្ញាបនបត្រសម្គាល់សិទ្ធិ ដែលម្ចាស់កម្មសិទ្ធិករអាចប្រើប្រាស់ទៅតាមគ្រប់មធ្យោបាយ។[261] ក្នុងនោះ ការបង់ពន្ធទាក់ទិននឹងអចលនទ្រព្យដូចជា ១.ពន្ធលើអចលនទ្រព្យ ០,១%/ឆ្នាំ (មាត្រា១៤៧-១៥៤), ២.ពន្ធលើដីធ្លីមិនបានប្រើប្រាស់២%/ឆ្នាំ (មាត្រា.១៧៣-១៨០), ៣.ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ១០%នៃថ្លៃឈ្នួលអចលនទ្រព្យ (មាត្រា.១៣៩-១៤៦), ៤.ពន្ធប្រថាប់ត្រា៤%នៃតម្លៃអចលនទ្រព្យ (មាត្រា.១៥៥-១៦៤), និង៥.ពន្ធលើចំណេញមូលធនអចលនទ្រព្យ២០% (មាត្រា.១៦៧[៤])។[262] តួយ៉ាងគឺ រាជរដ្ឋាភិបាលកម្ពុជា ក៏បានដាក់ចេញវិធានការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអចលនទ្រព្យ ដូចជា ការលើកលែងពន្ធលើអចលនទ្រព្យតាមតំបន់មួយចំនួន និងការលើកលែងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទដែលមានតម្លៃក្រោម ឬស្មើតម្លៃ៧ម៉ឺនដុល្លារអាមេរិក និងបង្កើនរយៈពេលបង់ពន្ធកញ្ចប់សម្រាប់ក្រុមហ៊ុនអ្នកអភិវឌ្ឍលំនៅឋាន។[263]

---

[261] បណ្ដាសេវាកម្មអេឡិចត្រូនិកពន្ធដារនានា (ភ្ជាប់ជាមួយនីតិវិធីអនឡាញ), https://www.tax.gov.kh/km/e-service (ទស្សនាចុងក្រោយថ្ងៃទី១៦ មិថុនា ២០២៤)។

[262] ច្បាប់ស្ដីពីសារពើពន្ធ, លេខ នស/រកម/០៥២៣/០០៤, ១៦ ឧសភា ២០២៣។ *លើកលែងទណ្ឌកម្ម-អចលនទ្រព្យត្រឹមខែកក្កដា ២០២៤។*

[263] សេចក្ដីបំភ្លឺរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ៣៤៧១អពដ, ២៦ កញ្ញា ២០២៣ ការបន្តកំណែទម្រង់រដ្ឋបាលសារពើពន្ធ។

# ជំពូកទី៤

# វាយតម្លៃការអនុវត្ត
# តាមប្រព័ន្ធអនឡាញ

# ជំពូកទី៤
# វាយតម្លៃការអនុវត្តតាមប្រព័ន្ធអនឡាញ

អំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជា ប្រៀបបានជាទារកទើបតែរៀនចេះដើរដំបូង ដោយចាប់ផ្តើមធ្វើបរិវត្តកម្មឌីជីថល និងនវានុវត្តន៍បន្តិចម្តងៗ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃវិធានឌីជីថល ទាមទារឱ្យមានសេណារីយ៉ូប្រតិបត្តិទុកមុនទាំងបង្ការ ទប់ស្កាត់ និងបង្ក្រាប គឺមិនខុសពីការអនុវត្តផ្ទាល់ឡើយ។ ពាក្យមួយរបស់អង្គការសហប្រជាជាតិលើកឡើងថា "ភស្តុតាងបានបង្ហាញច្បាស់ថាការវិនិយោគលើការបង្ការ គឺជារឿងចាំបាច់"។ ការអនុវត្តអាចទៅរួចបាន ក៏លុះត្រាតែមានប៉ារ៉ាម៉ែត្រសមាមាត្រ រួមទាំងបច្ចេកទេស និងបទដ្ឋានគតិយុត្ត។ ដោយសារភាពថ្មីថ្មោង និងទំនើបកម្មទាក់ទិននឹងបច្ចេកវិទ្យាជាតម្រូវការចំពោះមុខ ពិសេសកត្តាកម្រិតយល់ដឹង ភាពស្ទាក់ស្ទើរ និងបន្តការជជែកដេញដោលលើវិស័យសាធារណៈ ដែលធ្វើឱ្យមានលក្ខណៈស្មុគស្មាញលើគំរូអភិបាលកិច្ចវិមជ្ឈការឌីជីថល។

ជាអំណោះតរៀងមក ជៀសវាងការឆកល្វែងត្រង់កន្លែងណាមួយ គប្បីសិក្សាអំពីសក្តានុពលចំពោះវេទិកាឌីជីថល (៤.១) និងសន្តិសុខសាយប័រ (៤.២)។

## ៤.១. សក្តានុពលចំពោះវេទិកាឌីជីថល

បច្ចេកវិទ្យាឌីជីថល អាចចាត់ទុកថាជា "**ឌីជីថលបៃតង**"។ នៅក្នុងបរិយាកាសឌីជីថល បើទោះបីការបង្កើតកែតម្រូវ ឬលុបក្នុងទម្រង់ណាមួយក៏ដោយ គឺប្រព្រឹត្តទៅតែក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប៉ុណ្ណោះ (Podshivalov, ២០២២)។[264] វឌ្ឍនភាពបច្ចេកវិទ្យា ភាគច្រើនមានឥទ្ធិពលលើគ្រប់វិស័យដែលនាំមកភាពវិជ្ជមាន និងដំណោះ-ស្រាយនូវអ្វីដែលមនុស្សពុំអាចធ្វើដោយផ្ទាល់បាន ប៉ុន្តែ ក៏ពុំគួរភ្លេចថា ការវិវត្តបច្ចេកវិទ្យាតែងតែលេចឡើងវិធីថ្មីៗដែលអាចខ្វះចន្លោះពីវិសាលភាពគ្រប់គ្រងដោយច្បាប់ពាក់ព័ន្ធ។ ភាពច្នៃប្រតិដ្ឋផ្អែកលើឌីជីថលូបនីយកម្ម ក្នុងទំនាក់ទំនងផ្លូវច្បាប់គឺអាចមានលក្ខណៈស្មុគស្មាញក្នុងការកំណត់ក្របខណ្ឌគតិយុត្ត ដោយសារទាមទារឱ្យមានការបង្កើត វិសោធនកម្ម និរាករ ដោយចងភ្ជាប់ទៅនឹងស្ថានភាពបច្ចេកវិទ្យាឌីជីថល។ ឧទាហរណ៍ លំហសាយប័រ (Cyberspace) ការរំលោភលើដែនអាកាសតាមរយៈបណ្តាញឥតខ្សែ។ កម្ពុជា ក៏ធ្លាប់ និងងាយរងគ្រោះដោយសារការវាយប្រហារព័ត៌មានវិទ្យាក្នុងលំហសាយប័រ ផងដែរ ដោយសារកម្ពុជានៅមានកម្រិត មិនទាន់យល់អ្វីទៅជាសុវត្ថិភាពឌីជីថល។ សង្គមទាំងមូលអាចនឹងប្រឈមមុខបញ្ហាផ្នែកនិរន្តរភាពជាច្រើនមាន កំណើនប្រជាជនគ្រោះមហន្តរាយ កង្វះតម្រូវការ និងកង្វះធនធានដីធ្លី បើគ្មានដំណោះស្រាយឌីជីថល។

តើមានសក្តានុពលគ្រប់គ្រាន់ឬនៅ ចំពោះគុណសម្បត្តិនិងគុណវិបត្តិនៃការកសាង និងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ដែលជារបត់ថ្មីដល់ពលរដ្ឋកម្ពុជា?

ទស្សនទានដល់ការសិក្សា បានលើកបង្ហាញពីសុចរិតភាពអ្នកប្រើប្រាស់ និងកាន់កាប់អចលនវត្ថុ (៤.១.១)

[264] Tikhon P. Podshivalov, "Improving implementation of the Blockchain technology in real estate registration" [ការកែលម្អអនុវត្តបច្ចេកវិទ្យាប្លុកឆេនក្នុងការចុះបញ្ជីអចលនទ្រព្យ], *Elsevier* (Russia) Volume 33 Issue 2, (October, 2022): 13។

និងផលវិជ្ជមាននិងផលប៉ះពាល់លើប្រព័ន្ធឌីជីថល (៤.១.២) ជាសក្ខីភាពក្នុងការអនុវត្តវិស័យដីធ្លី។

### ៤.១.១. សុចរិតភាពអ្នកប្រើប្រាស់ និងកាន់កាប់អចលនទ្រព្យ

ការប្រតិបត្តិអ្វីមួយដោយភាពត្រឹមត្រូវ គ្មានឧបករណ៍ស្តង់ដារអ្វីមួយដែលអាចយកមកវាស់វែងជាក់លាក់បានឡើយ។ ប៉ុន្តែ ប្រតិបត្តិកើតចេញពីអត្តនោម័តរបស់បុគ្គល ត្រូវស្ថិតក្រោមវិសាលភាពនៃច្បាប់។ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា គឺបានបញ្ញត្តិពីអត្តនោម័តបុគ្គលចំពោះសុចរិតភាពតាមផ្លូវច្បាប់ ឬហៅថាឋានៈនៃកំហុសជា៥ប្រភេទ ដោយអាចការពារផលប្រយោជន៍ចំនួន២ប្រភេទដូចជា៖ ១.សុចរិតតែគ្មានកំហុស (ដោយពុំបានដឹង), និង ២.សុចរិតតែមានកំហុស, រីឯពុំគួរការពារគឺ ៣.សុចរិតតែមានកំហុសធ្ងន់ធ្ងរ, ៤.ទុច្ចរិត និង៥.អាក្រក់ទុច្ចរិត។ ហេតុនេះកិច្ចការចំពោះមុខ គឺពន្លឿនការចុះបញ្ជីដីធ្លីបង្ហើយ។ ពិព្រោះ វិវាទភាគច្រើនស្តែងឡើងពីរូបភាព៖ ១.ប្រភេទការចូលទៅកាន់កាប់ដីអ្នកដទៃមានបណ្ណកម្មសិទ្ធិ, ២.បញ្ហាបណ្ណកម្មសិទ្ធិត្រួតគ្នា, ៣.លិខិតផ្ទេរកាន់កាប់ប្រើប្រាស់ដីធ្លីត្រួតគ្នា, ៤.សំណើសុំចេញបណ្ណកម្មសិទ្ធិលើដីរដ្ឋក្នុងដែនគម្របព្រៃឈើឆ្នាំ២០០២ និងតំបន់ការពារធម្មជាតិ, ៥.ការទប់ស្កាត់ចេញបណ្ណកម្មសិទ្ធិមិនសមហេតុផល, ៦.សំណើសុំអន្តរាគមន៍ដោះស្រាយបញ្ចប់វិវាទលើក្បាលដីពុំទាន់ចុះបញ្ជី, ៧.ចេញបណ្ណវិវាទមិនស្គាល់ព្រំដី និងច្រឡំភូមិសាស្ត្រ, ៨.វិវាទដីជាន់ប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការរំលោភលើដីចំណីសាធារណៈ ជាអាទិ៍។

ក្នុងករណីមានវិវាទនាពេលខាងមុខ បណ្ណដែលបានចុះបញ្ជីរួចរាល់ ទោះបីបណ្ណប្រភេទក្រដាសក្តី ឬទម្រង់ឌីជីថលក្តី គឺទទួលបានអាទិភាពលើបណ្ណដែលមិនបានចុះបញ្ជី។ ក្នុងប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិក និងប្រទេសបារាំង ការមិនចុះបញ្ជីកម្មសិទ្ធិ មិនប៉ះពាល់ដល់ភាពស្របច្បាប់នៃប្រតិបត្តិការនោះទេ ប៉ុន្តែក្នុងករណីមានជម្លោះប្រតិបត្តិការដែលមិនបានចុះបញ្ជី គឺមានអាទិភាពទាបបើប្រៀបធៀបជាមួយបណ្ណដែលបានចុះបញ្ជី។ នៅក្នុងប្រទេសមួយចំនួនទៀត រួមទាំងប្រទេសឥណ្ឌា បណ្ណដែលមិនបានចុះបញ្ជីមិនមានតម្លៃភស្តុតាង ដែលធ្វើឱ្យចាំបាច់សម្រាប់ភាគីក្នុងការចុះបញ្ជីកម្មសិទ្ធិទេ ប្រសិនបើដីមួយរកឃើញថាបានលក់ពីរដងហើយបានចុះបញ្ជីតែមួយ នោះអ្នកទាមទារសិទ្ធិលើដីតាមរយៈបណ្ណចុះបញ្ជី នឹងឈ្នះករណីវិវាទរវាងអ្នកទាមទារទាំងពីរ (Josip, Doris and other, ២០២២)។[265] ប៉ុន្តែ ប្រទេសទាំងនេះ ក៏មិនបដិសេធបញ្ហាការចុះបញ្ជីដើម្បីកាត់បន្ថយវិវាទនោះដែរ គឺមានយន្តការចុះបញ្ជីផ្សេងៗជាច្រើនពង្រឹងលើបទដ្ឋានគតិយុត្តចំពោះអ្នកកាន់កាប់ដីធ្លី ដើម្បីគ្រប់គ្រងអាសយដ្ឋានជាក់លាក់លើក្បាលដីទូទាំងប្រទេស។ ដំណើរការរៀបចំអាសយដ្ឋានលើក្បាលដីនីមួយៗ អាចដឹងពីកម្មសិទ្ធិករច្បាស់លាស់ ក៏ជាផ្នែកមួយអាចងាយស្រួលជួយដល់ខាងប្រៃសណីយ៍ ដែលផ្តល់សេវាដឹកជញ្ជូន និងចែកចាយបញ្ញើប្រៃសណីយ៍ដល់ទីលំនៅកម្មសិទ្ធិករផ្ទាល់ (Sarri, G.Tzouras and other, ២០២៤)។[266]

---

[265] Josip Križanović. Doris Pivac and other, “Review of Land Administration Data Dissemination Practices: Case Study on Four Different Land Administration System Types” [ការពិនិត្យឡើងវិញនៃការអនុវត្តផ្សព្វផ្សាយទិន្នន័យរដ្ឋបាលដីធ្លី៖ ករណីសិក្សាលើប្រភេទប្រព័ន្ធគ្រប់គ្រងដីធ្លីចំនួនបួនផ្សេងគ្នា], *MDPI* (Croatia) DOI.Org/10.3390/land10111175 (2021)។

[266] Paraskevi Sarri, Panagiotis G.Tzouras and other, “Incorporating Land Use and Transport Interaction Models to Evaluate Active Mobility Measures and Interventions in Urban Areas: A case study in Southampton, UK” [ការដាក់បញ្ចូលគំរូអន្តរកម្មនៃការប្រើប្រាស់ដីធ្លី និងការដឹកជញ្ជូន ដើម្បីវាយតម្លៃលើវិធានការចល័តសកម្ម និងអន្តរាគមន៍ក្នុងតំបន់ទីក្រុង៖ ករណីសិក្សានៅ Southampton នៃចក្រភពអង់គ្លេស], *Elsevier* (UK) Volume105 DOI.Org/10.1016/j.scs.105305 (2024): 108។

នៅកម្ពុជាបើស្ថិតក្នុងករណីបែបខាងលើនេះ ពិតប្រាកដណាស់មិនចង់ឱ្យកើតមានបញ្ហាទេ ជ្រើសរើសចុះបញ្ជីជាកត្តាចម្បង មិនថាអ្នកកាន់កាប់ស្ថិតក្នុងប្រភេទអត្តនោម័តណាទេ ត្រូវចុះបញ្ជីរួចសិន សឹមជជែកគ្នាតាមក្រោយ។ ជាក់ស្តែងដូចករណីបដិសេធការស្នើសុំចុះបញ្ជីដីធ្លី ដែលធ្វើឡើងដោយការរំលោភដីសាធារណៈរបស់រដ្ឋ ប៉ុន្តែ គឺព្យាយាមស្នើសុំទៅតាមហេតុផលរួមមាន កេរ្តិ៍ពីដូនតា, តាំងលំនៅប្រកបជីវភាព (ក្រីក្រ), ស្នាក់នៅ និងអាស្រ័យផលចំការយូរមកហើយ ជាអាទិ៍។ ប្រជាពលរដ្ឋខ្លះទៀតយល់ថា ដោយសារតែអចលនវត្ថុនោះគ្មានម្ចាស់ មិនបានដឹងថាជាកម្មសិទ្ធិរបស់រដ្ឋ។[267] ភារកិច្ចចម្បងរបស់រដ្ឋបាលសុរិយោដី គឺត្រូវតែកំណត់ និងកត់ត្រារាល់ទំនាក់ទំនងរវាងមនុស្សនិងអចលនវត្ថុ និងធានាបានថាទិន្នន័យអំពីកម្មសិទ្ធិអចលនទ្រព្យមានភាពទាន់សម័យ។

តើបុគ្គលភាពគតិយុត្តគួរមានទំនួលខុសត្រូវអ្វីចំពោះអំពើដែលកើតចេញពីចេតនាទុច្ចរិត ដើម្បីតែទាញយកផលប្រយោជន៍ណាមួយ?

### ៤.១.១.១. កិច្ចធានាភាពអះអាងកម្មសិទ្ធិអចលនវត្ថុ

បញ្ហាធ្លាក់ចុះនៃសីលធម៌សង្គម ស្របពេលបច្ចេកវិទ្យាក្នុងសង្គមកំពុងអភិវឌ្ឍន៍។[268] អំពើឆ្លៀតឱកាស តែងកើតមានឡើងក្នុងសង្គមកម្ពុជាស្របពេលអក្ខរកម្មរបស់ប្រជាពលរដ្ឋមានកម្រិតទាប ជនទុច្ចរិតតែងតែប្រើប្រាស់គ្រប់វិធីដើម្បីឆបោក ក្លែងបន្លំលើកម្មសិទ្ធិអចលនវត្ថុ។ ក្នុងនោះមើលឃើញថា ជារឿយៗរាល់វិវាទដីធ្លី គឺបង្កប់នូវវិការៈគ្រប់មធ្យោបាយ ដើម្បីទាញផលប្រយោជន៍លក្ខណៈបុគ្គល និងក្រុម។ វិការៈតាមផ្លូវច្បាប់នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ចំពោះការបង្ហាញឆន្ទៈបានចែង៨ចំណុចគឺ ១.ការភាន់ច្រឡំ, ២.ការឆបោក, ៣.ព័ត៌មានមិនពិត, ៤.ការរំលោភលើស្ថានភាព, ៥.ការគម្រាមកំហែង, ៦.ការកេងចំណេញហួសហេតុ, ៧.ឋបនីយផ្លូវចិត្ត, និង៨.ការបង្ហាញឆន្ទៈមិនពិត។[269] ករណីខ្លះឃើញដាក់បណ្តឹងរហូតដល់តុលាការកំពូល ដែលស្នើសុំបញ្ជាក់ពីសិទ្ធិកម្មសិទ្ធិ ទំហំ ទាមទារសំណងលើលំនៅឋាន ដីធ្លីនិងអគារ ជាអាទិ៍។ ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះ-រាជាណាចក្រកម្ពុជាបានបែងចែកបណ្តឹងរដ្ឋប្បវេណី៣ប្រភេទ៖ ១.បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក (ប្រគល់វត្ថុ, សងប្រាក់, ឱ្យធ្វើសកម្មភាព ឬមិនធ្វើសកម្មភាព...), ២.បណ្តឹងទាមទារឱ្យបញ្ជាក់ (បញ្ជាក់ភាពត្រឹមត្រូវលើឯក-សារ, កម្មសិទ្ធិករ, ទទួលស្គាល់...), និង៣.បណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត (ផ្លាស់ប្តូរទំនាក់ទំនងបុគ្គលក្លាយជាសន្តតិជន, ព័ត៌មានកម្មសិទ្ធិករ...)។[270]

ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីដូចជា៖ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល (សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សេវភាព សិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ), សិទ្ធិប្រាតិភោគប្រត្យក្ស (ហ៊ីប៉ូតែក សិទ្ធិឃាត់ទុក ឯកសិទ្ធិ បញ្ចាំ និងសិទ្ធិប្រាតិភោគដោយអនុប្បទាន), ក៏ដូចជាទិដ្ឋភាពលើការរឹបអូសបណ្តោះអាសន្ន,

---

[267] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៦១។

[268] អ៊ិត សាន, "ផលវិបាកនៃការធ្លាក់ចុះសីលធម៌," *ថ្មីៗ*, ២០២០, https://thmeythmey.com/?page=detail&id =22167 (ទស្ស-នាចុងក្រោយថ្ងៃទី១ កក្កដា ២០២៤)។

[269] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា៣៤៦-៣៥៣ និងមាត្រា២៣៣។

[270] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, (ពីពេលនេះតទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា២០០៦)។

ផ្ទេរសិទ្ធិអចលនវត្ថុមិនទាន់ចុះបញ្ជី ជាអាទិ៍ គឺសុទ្ធសឹងតែបុគ្គលអាចអះអាងពីសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ។[271] ករណីលទ្ធកម្មនៃកម្មសិទ្ធិអចលនវត្ថុ តែងកើតមានឡើងដោយសារតំបន់ខ្លះបន្តកាន់កាប់ភោគៈដីស្រែចំការតាំងពីសម័យសង្គមរាស្ត្រនិយម សម័យប៉ុលពតរហូតមកជាកេរ្តិ៍មរតកនៅសេសសល់។[272] ដោយសារកង្វះការយល់ដឹង ព័ត៌មាន ឬមិនបានដឹងថាច្បាប់ភូមិបាល២០០១ បដិសេធរាល់កម្មសិទ្ធិមុនសម័យកាល និងទទួលស្គាល់តែភោគៈស្របច្បាប់ ទើបកើតមានបាតុកម្មដីធ្លីជារឿយៗ។ ប៉ុន្តែ បើជជែកអំពីអាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ ជនដែលបានកាន់កាប់ដោយសន្តិវិធី និងដឹងឮជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិអំឡុងពេល២០ឆ្នាំ ឬជននោះសុចរិតគ្មានកំហុសអំឡុងពេល១០ឆ្នាំ អាចធ្វើលទ្ធកម្មបានស្របច្បាប់ ឬលទ្ធកម្មពិសេសនៃភោគៈ។[273] ចំនែកឯកម្មសិទ្ធិនៃដីដុះ និងដីកោះ កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី តែងមានជម្លោះជានិច្ចរាល់ពេលដែលធ្វើអស្សាមិករណ៍ និងរៀបផែនការអភិវឌ្ឍន៍ក្នុងតំបន់នោះ។[274] ទំនាក់ទំនងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត រាល់សិទ្ធិកាន់កាប់ត្រូវភ្ជាប់ទុកនៃវត្ថុតាមការជាក់ស្តែងទោះចំពោះក្តី ឬប្រយោលក្តី ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ទើបកម្មសិទ្ធិករអាចត្រូវសន្មតទទួលស្គាល់ស្របច្បាប់។[275] សិទ្ធិទាមទារឱ្យការពារការកាន់កាប់ដូចជាការប្រគល់វត្ថុមកវិញ ការរារាំង សំណងការខូចខាតនិងអ្នកកាន់កាប់ពិសេស គួរមានបញ្ជាក់បណ្ណសម្គាល់សិទ្ធិត្រឹមត្រូវ និងមានវិធានការដោះស្រាយសមស្រប។[276] ម្យ៉ាងវិញទាំងម្ចាស់កម្មសិទ្ធិសម្បទានិក និងបងប្អូនជនជាតិដើមភាគតិច តែងតែកង្វល់រឿងសម្បទានដី និងដីកប់សព ឬដីព្រៃអារក្ស ដែលចេះតែយកទៅចុះបញ្ជីទាំងកម្មសិទ្ធិឯកជន និងកម្មសិទ្ធិដីរដ្ឋ។[277] វណ្ណកម្មនេះក្រសួង ដ.ន.ស គួរតែគិតគូរជាមុនជៀសវាង នៅពេលបើកឱ្យដំណើរការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុតាមប្រព័ន្ធអនឡាញរួច នៅប្រទាំងប្រទើសមិនទាន់ច្បាស់។ ពីមុនឈ្លោះគ្នាព្រោះដីឡើងថ្លៃ បច្ចុប្បន្នដីចុះថោកខ្ជិលឈ្លោះគ្នា ប៉ុន្តែ បើមានវិបត្តិលើសិទ្ធិកម្មសិទ្ធិគឺមានតែបាតុកម្មនៅមុខក្រសួង ជាដរាប។

ក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថល មុននឹងឈានដល់ការចុះបញ្ជីអនឡាញ ត្រូវពិនិត្យទិដ្ឋភាពខាងលើឱ្យបានគ្រប់ជ្រុងជ្រោយ ដោយសារបញ្ហាសព្វថ្ងៃការបកស្រាយបទប្បញ្ញត្តិដោយតុល្យភាពចំពោះសកម្មភាពនៅលើវេទិកាឌីជីថល អាស្រ័យតែចំពោះគោលការណ៍ច្បាប់សារធាតុ ក្រមរដ្ឋប្បវេណី និងដាក់បន្ទុកការទទួលខុសត្រូវ

[271] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៣២ និង១៣៤។ និងសេចក្តីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា១៨២-១៩៦។ និងដូច១៨៨ (វិធីការបំពេញនិទ្ទេសចុះបញ្ជី, ប្រការ១០...) និងប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ប្រក.ដនស/១១, ចុះថ្ងៃទី៣ ឧសភា ២០១១។

[272] ដដែល, មាត្រា១៦០។

[273] ដដែល, មាត្រា១៦២-១៧៨។ និងច្បាប់ភូមិបាល២០០១, មាត្រា២៩-៤៦។

[274] ក្រមរដ្ឋប្បវេណីកម្ពុជា២០០៧, មាត្រា១៧៩-១៨៦។

[275] ដដែល, មាត្រា២២៧-២៣៥។

[276] ដដែល, មាត្រា២៣៦-២៤៣។

[277] ច្បាប់ភូមិបាល២០០១, មាត្រា៤៨។ និងសេចក្តីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា៧០(១)។ ប្រភពមួយទៀត វ៉ា សុភានុត, "អង្គការសង្គមស៊ីវិលស្នើឱ្យក្រសួងរៀបចំដែនដីបញ្ចូលចំណុចសំខាន់ៗមួយចំនួនក្នុងសេចក្តីព្រាងច្បាប់ភូមិបាលថ្មី," *ខេមបូចាព័ត៌មាន*, ២០២៤, https://khmer.cambojanews.com/civil-society-organizations-request-the-ministry-of-land-mana gement-to-put-some-important-points-in-the-new-draft-land-law/ (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។

តែម្យ៉ាងចំពោះអ្នកប្រើប្រាស់ ការព្រួយបារម្ភពីសុវត្ថិភាពទិន្នន័យបុគ្គល គឺនៅមិនទាន់គ្រប់គ្រាន់ឡើយ។ ទិដ្ឋភាពពិតដូចជាតាមរយៈការឆបោក ក្លែងបន្លំដោយផ្ទាល់ឬតាមប្រព័ន្ធបច្ចេកវិទ្យា និងអាចវិវត្តន៍ដល់ការធានាលក់ទិញអចលនវត្ថុតាមប្រព័ន្ធពាណិជ្ជកម្មអនឡាញ ជាអាទិ៍ ដែលបានឆ្លុះបញ្ចាំងដល់រាជរដ្ឋាភិបាលគួរតែគិតគូរពីសន្តិសុខសាយប័រ។[278] ចាំបាច់ត្រូវមានវិធានការរួម និងនីតិវិធីសង្គ្រោះ។ វិធានការរួម ជាសកម្មភាពរកអ្នកទទួលខុសត្រូវ ស៊ើបអង្កេត វាយតម្លៃនិងការវិនិច្ឆ័យចំពោះរាល់ការអះអាងកម្មសិទ្ធិអចលនវត្ថុទាំងឡាយណា ដែលផ្ទុយនឹងច្បាប់។ នៅកម្ពុជា មានសវនកម្មផ្ទៃក្នុង អាជ្ញាធរសវនកម្មជាតិ និងអធិការកិច្ចភូមិបាល(ថ្មី) ដែលគួរយកចិត្តទុកដាក់តាមដាន។[279] អធិការកិច្ចភូមិបាលនេះ ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ និងស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[280] មន្ត្រីអធិការកិច្ចភូមិបាល ពិតជាមានសារៈសំខាន់ដល់ការចុះបញ្ជីអនឡាញ ប៉ុន្តែ គួរជ្រើសមន្ត្រីដែលមានគុណវុឌ្ឍិបច្ចេកវិទ្យាឌីជីថល។ រីឯនីតិវិធីសង្គ្រោះវិញ បើចំពោះក្រសួង ស្ថាប័នត្រូវមានប្រព័ន្ធសន្តិសុខមួយរឹងមាំ ផ្តល់ទំនុកចិត្ត ដែលអាចធានាដល់សិទ្ធិកម្មសិទ្ធិលើប្រព័ន្ធអនឡាញដោយប្រការណាមួយ, ចំពោះប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន ត្រូវពង្រាយបញ្ជូនមន្ត្រីជំនាញឌីជីថលរបស់ខ្លួននៅតាមមជ្ឈមណ្ឌល ឬខាងការិយាល័យណាមួយនៅថ្នាក់មូលដ្ឋាន អាចជួយដល់ប្រជាពលរដ្ឋដែលមិនទាន់សម្របឌីជីថល ពិការភាព ឬក្រុមងាយរងគ្រោះជាកម្មសិទ្ធិករ។

អនុលោមតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា រាល់ការប៉ះពាល់កម្មសិទ្ធិ ឬសិទ្ធិស្របច្បាប់ផ្សេងទៀតលើអចលនវត្ថុជាបទល្មើសព្រហ្មទណ្ឌ។[281] បទល្មើសទាំងនោះ អាចរួមមាន៖ ជនណាដែលបានក្លែងបណ្ណយកទៅប្រើប្រាស់ផ្លូវការ ទោះក្នុងរូបភាពណាក៏ដោយ (អះអាងកម្មសិទ្ធិខុសច្បាប់, លក់ទិញត្រួតគ្នា...)[282], ជនណាក្លែងបន្លំ ប្រើលិខិតក្លែង ក្លែងបន្លំឯកសារសាធារណៈ ឬប្រើប្រាស់ឯកសារសាធារណៈក្លែង[283], ជនណាដែលបំភាន់មន្ត្រីសុរិយោដី ឬអាជ្ញាធរចុះបញ្ជីដីធ្លី[284], ជនណាប្រើប្រាស់អំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតទោះជាមិនទាន់បានធ្វើបណ្ណ ឬកំពុងមានទំនាស់ក៏ដោយ[285], គ្មានករណីឱ្យប្រើប្រាស់កម្លាំងឯកជន ធានាដល់ការគោរពបណ្ណកម្មសិទ្ធិ ឬសេចក្តីសម្រេចតុលាការ[286], ជនណាបានលួចលក់ ឬបញ្ចាំអចលនវត្ថុដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន និង/ឬ ហ៊ានប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬលិខិតបញ្ជាក់ក្លែងក្លាយណាមួយដែល

[278] ករណីបទល្មើសបច្ចេកវិទ្យាមួយផ្នែក ពីនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា (ន.ប.ប.ប) នៃក្រសួងមហាផ្ទៃ។

[279] សេចក្តីព្រាងច្បាប់ភូមិបាល២០២៣, មាត្រា១១១។

[280] ដដែល, មាត្រា១១១(២)។

[281] ច្បាប់ភូមិបាល២០០១, មាត្រា២៤៧ថ្មី-២៥០។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។ និងច្បាប់វិសោធនកម្មក្រមព្រហ្មទណ្ឌ, លេខ នស/រកម/០២១៨/០០៣, ២៧ កុម្ភៈ ២០១៨, (ពីពេលនេះតទៅហៅថា ក្រមព្រហ្មទណ្ឌកម្ពុជា២០០៩)

[282] ច្បាប់ភូមិបាល២០០១, មាត្រា២៥១។

[283] ក្រមព្រហ្មទណ្ឌកម្ពុជា២០០៩, មាត្រា៦២៦-៦៣០។

[284] ច្បាប់ភូមិបាល២០០១, មាត្រា២៥២។

[285] ដដែល, មាត្រា២៥៣ថ្មី។

[286] ដដែល, មាត្រា២៥៤។

ផ្ទុយពីម្ចាស់កម្មសិទ្ធិករ[287], ជនណាប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ និងបានលើកចេញ ឬរំកិល ឬបំផ្លាញចោលបង្គោលស៊ីម៉ង់ត៍ដៅចំណុចឋានលេខានិងផ្លាកសញ្ញាសុរិយោដី ឬក៏មិនរាងចាល[288], ជនណាបានប្រើប្រាស់បច្ចេកវិទ្យាជ្រែតជ្រែក ឬចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យដោយអំពើទុច្ចរិតណាមួយ ឬលុបបំបាត់ ឬកែប្រែ ឬធ្វើឱ្យខូចខាតទិន្នន័យក្នុងប្រព័ន្ធ[289], ជនណាដែលបង្កើតឧបសគ្គ ដែលរារាំងដល់ដំណើរការ ឬបញ្ចូល ឬលុបបំបាត់ ឬកែប្រែដោយទុច្ចរិតទិន្នន័យនៅក្នុងប្រព័ន្ធប្រព្រឹត្តកម្មស្វ័យប្រវត្តិ[290], ជនណាចូលរួមទៅក្នុងប្រមូលផ្តុំក្រុម ឬសន្និដ្ឋិភាព ដែលបង្កើតឡើងដើម្បីរៀបចំប្រព្រឹត្តបទល្មើស[291] ជាអាទិ៍ និងរាល់បទល្មើសថ្មីៗពាក់ព័ន្ធនឹងបច្ចេកវិទ្យាដទៃទៀត ដែលមិនទាន់មានចែង។

### ៤.១.១.២. កិច្ចធានាដោយរដ្ឋ និងក្រុមការងារបច្ចេកទេសឌីជីថល

រាជរដ្ឋាភិបាល ត្រូវតែធានាដល់សង្គតិភាព និងចីរភាព។ ការផ្តល់ទំនុកចិត្តដល់ពលរដ្ឋ ទទួលយកតម្រូវការពលរដ្ឋ និងឆ្លើយតបរាល់វិធានការ គឺជាគន្លឹះអាទិភាពដែលត្រូវមានក្នុងការអនុវត្តបរិវត្តកម្មឌីជីថល។ តាមទ្រឹស្តីនៃការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល (DPI-Digital Public Infrastruture) ត្រូវគិតគូរគ្រប់ជ្រុងចំពោះអ្នកប្រើប្រាស់បណ្តាញឌីជីថល ជាពិសេស កម្មវត្ថុលើការកាន់កាប់ដីធ្លីនេះ ដោយរដ្ឋាភិបាលឌីជីថលត្រូវតែកំណត់អត្តសញ្ញាណកម្មឱ្យបានជាក់លាក់រាល់ការប្រើប្រាស់ ១.អត្តសញ្ញាណ (ID), ២.ការទូទាត់ (Payment) និង៣.ទិន្នន័យ (Data) របស់អ្នកប្រើប្រាស់។ ទាំងនេះជាតម្លៃភស្តុតាង ដែលអាចបញ្ជាក់ថា ការអនុវត្ត ការប្រើ-ប្រាស់ផលិតផលសាធារណៈឌីជីថល (DPG-Digital Public Goods) ប្រកបដោយគុណភាព។[292] កាលណាបើនិយាយពីបរិវត្តកម្មឌីជីថល គឺមិនមែនជាបន្ទុកទាំងស្រុងលើរាជរដ្ឋាភិបាល ឬក្រុមការងារឌីជីថលនោះឡើយ, ប៉ុន្តែប្រជាជនគ្រប់រូបក៏គួរចូលរួមជាមួយគ្នាផងដែរ ប្រែក្លាយជាពលរដ្ឋឌីជីថល។ ដោយសារកង្វះមូលធនមនុស្សឌីជីថល និងមន្ត្រីសាធារណៈជំនាញឌីជីថល កម្ពុជាគួរប្រើទម្រង់ Hybrid ប្រើមូលធនមនុស្សឌីជីថលក្នុងស្រុកឱ្យអស់ពីលទ្ធភាព និងជួលពីក្រុមអ្នកបច្ចេកទេសបរទេស មកជួយអភិវឌ្ឍន៍ធនធានឌីជីថល។ មួយវិញទៀត គឺបច្ចេកវិទ្យាបានត្រុណមពីការបង្កើតអេប (App) ដែលឱ្យប្រើប្រាស់គោលបំណងទាញយកព័ត៌មានឯកជន សារសម្ងាត់ឯកជន របាយការណ៍ឯកជន ឬរបៀបរបបការរស់នៅឯកជន ដែលបង្កើតដោយរដ្ឋាភិបាល គឺដាច់ខាតមិនត្រូវឱ្យកើតមានឡើយ។ នៅប្រទេសជឿនលឿន អេបប្រភេទនេះ គឺត្រូវតែបង្កើតដោយនីតិបុគ្គលវិស័យឯកជន លុះត្រាតែមានបញ្ហា ឬបទល្មើសអ្វីមួយទើបនីតិបុគ្គលសាធារណៈរបស់រដ្ឋាភិបាលមានវិធានការ។ ហេតុផលគឺៈ

[287] ដដែល, មាត្រា២៥៥។ និងក្រមព្រហ្មទណ្ឌកម្ពុជា២០០៩, មាត្រា៦៣៦។

[288] ច្បាប់ភូមិបាល២០០១, មាត្រា២៥៩ និង២៦០។

[289] ក្រមព្រហ្មទណ្ឌកម្ពុជា២០០៩, មាត្រា៤២៧។

[290] ដដែល, មាត្រា៤២៨ និង៤២៩។

[291] ដដែល, មាត្រា៤៣០-៤៣២។

[292] UNDP, "Digital Public Goods for the SDGs," ២០២៣, https://www.undp.org/publications/digital-public-goods-sdgs និងប្រភពខាង UN: https://www.un.org/techenvoy/content/digital-public-goods (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។ ពាក្យថា ផលិតផលសាធារណៈឌីជីថល (Digital Public Goods)គឺរាល់ប្រភេទបច្ចេកវិទ្យាទាំងឡាយណាដែលយកមកអនុវត្តសមស្របនិរន្តរ៍ភាព និងជួយទៅដល់សេវាសាធារណៈឌីជីថល ស្របតាមតម្រូវការរបស់ប្រជាជាពលរដ្ឋ, ដោយអង្គការសហប្រជាជាតិ, https://www.un.org/techenvoy/content/digital-public-goods (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។

១.ពលរដ្ឋត្រូវការឯកជនភាវូបនីយកម្ម, ២.រដ្ឋាភិបាលអាចប្រើប្រាស់ខុសពីគោលបំណង, ៣.ពុំមានទំនុកចិត្តលើសារសម្ងាត់, ៤.ប្រជាធិបតេយ្យ ជាអាទិ៍។[293] ដូចនេះ រដ្ឋាភិបាលមានកាតព្វកិច្ចធ្វើបរិវត្តកម្មឌីជីថល រាល់អ្វីដែលពាក់ព័ន្ធដល់ការបម្រើសេវាសាធារណៈ ប៉ុណ្ណោះ (អនាគតអាចលើសពីតម្រូវការ)។

ក្រៅពីការធានាដល់បច្ចេកវិទ្យា និងព័ត៌មានទិន្នន័យនៃអត្តសញ្ញាណបុគ្គល រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើតឱ្យមានការរៀបចំ និងការប្រព្រឹត្តទៅនៃសភាអេឡិចត្រូនិក (e-Parliament) មួយដែលប្រតិបត្តិដោយក្រុមហ៊ុនឯកជន។ សមាជិកសភាអេឡិចត្រូនិក ចាំបាច់ត្រូវតែមិនមែនជាមន្ត្រីមកពីបណ្តាក្រសួង ស្ថាប័ន ដើម្បីប្រាកដថាឱ្យការអនុវត្តមានតម្លាភាព សុក្រឹតភាព និងឯករាជ្យភាពនៅក្នុងប្រព័ន្ធនៃស្វ័យប្រវត្តិកម្មឌីជីថល។ គំរូម៉ូដែលនៃសភាអេឡិចត្រូនិកបរទេស បង្កើតឡើងដើម្បីជំនួយដល់ការបោះឆ្នោតជាតិ, កំណែទម្រង់ និងពន្លឿនអនុម័តលើបច្ចេកវិទ្យាឌីជីថល, បទដ្ឋានគតិយុត្តពាក់ព័ន្ធឌីជីថល, និងជំរុញយន្តការប្រព័ន្ធឌីជីថល ជាអាទិ៍។[294] ក្នុងនោះក៏អាចបង្កប់គោលបំណងចំនួន៥ដើម្បី៖ ១.ដំឡើង និងដំណើរការប្រព័ន្ធឌីជីថលសមស្រប និងសុវត្ថិភាព (ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល), ២.ព័ត៌មានសភាឌីជីថល, ៣.អភិវឌ្ឍន៍ជំនាញឌីជីថលជួយដល់សមាជិក និងមន្ត្រីសភា, ៤.កាលានុវត្តន៍ និងអនុវត្តយុទ្ធសាស្ត្រផ្លូវការនៃការចូលរួមពីសំណាក់ពលរដ្ឋ, និង៥.អនុវត្តលក្ខខណ្ឌដែលបង្ការទុកជាចាំបាច់ សម្រាប់ការដាក់ឱ្យដំណើរការសភាអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាព។[295] ករណីសភាអេឡិចត្រូនិកនៃសភាអឺរ៉ុប បង្កើតឡើងតាំងពីឆ្នាំ២០០៨ដែលធ្វើឱ្យដំណើរការនីតិប្បញ្ញត្តិកម្រិតអឺរ៉ុប មានកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសគណៈកម្មការអឺរ៉ុប ជឿនលឿនខ្លាំងខាងផ្នែកបច្ចេកវិទ្យា។ សភាអឺរ៉ុប គឺបង្កើតគំរូសភាអេឡិចត្រូនិក មានម៉ូដែលបច្ចេកវិទ្យាដូចជា៖ ICT, XML, EPS, AT4AM &LEX, DiSP, QP web Form, Cat4Trad ។ល។[296] រាជរដ្ឋាភិបាលកម្ពុជា គួរតែពិចារណាពីកត្តាទាំងនេះ បំពេញភាពខ្វះខាត។

ប្រទេសកម្ពុជា នៅពុំមានបទដ្ឋានគតិយុត្តដែលបំពេញភាពខ្វះចន្លោះ និងករណីយកិច្ចគ្រប់គ្រាន់នៅឡើយទេ រាប់ចាប់តាំងពីអ្នកប្រើប្រាស់ ក្រុមអ្នកបច្ចេកទេស អាជ្ញាធរពាក់ព័ន្ធឌីជីថល អង្គភាព/អង្គការឌីជីថល ក្រសួង ស្ថាប័នបង្កើតសេវាសាធារណៈឌីជីថល និងរដ្ឋាភិបាលឌីជីថល ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការគិតគូរទុកជាមុន ព្យាករ វាយតម្លៃ និងពិនិត្យគ្រប់សកម្មភាពដែលដំណើរការឌីជីថល គឺជារឿងចាំបាច់បំផុត ដែលអាចជៀសវាងពីការវាយប្រហារឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឬសន្តិសុខសាយប័រ (៤.២)។

---

[293] Hacker News, "Why is there no government built social media?," [ហេតុអ្វីពុំមានបណ្តាញសង្គមដែលបង្កើតដោយរដ្ឋាភិបាល?], https://news.ycombinator.com/i tem?id=36601228 (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។

[294] Vivien Sierens and Thijs Vandenbussche, "From Mediator to Crisis Manager: The Evolving Relationship Between Council Presidencies and the European Parliament in Times of Crisis" [ពីអ្នកសម្របសម្រួលដល់អ្នកគ្រប់គ្រងវិបត្តិ៖ ទំនាក់ទំនងពីការវិវត្តន៍រវាងគណៈប្រធានក្រុមប្រឹក្សា និងសភាអឺរ៉ុបក្នុងគ្រាមានវិបត្តិ], *ResearchGate* (EU) DOI.10.1007/978-3-031-44788-4 (2024): 7។

[295] Patrick Kabuyablythe. Michelle Antonellikafu and Kofi Tsikata, "e-Parliament Systems and the Future of Parliaments" [ប្រព័ន្ធសភាអេឡិចត្រូនិក និងអនាគតនៃសភា], *World Bank Blogs*, ២០២២, https://blogs.worldbank.org/en/governance/e-parliament-systems-and-future-parliaments (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។

[296] WFD and EU, "Connected Parliaments: harnessing digital dividends to increase transparency and citizen engagement" [សភាតភ្ជាប់៖ ការទាញយកប្រយោជន៍ភាគលាភពីប្រព័ន្ធឌីជីថល ដើម្បីបង្កើនតម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ], https://www.wfd.org/sites/default/files/2022-06/wfd-connected-parliaments.pdf (ទស្សនាចុងក្រោយថ្ងៃទី២ កក្កដា ២០២៤)។

### ៤.១.២. ផលវិជ្ជមាន និងផលប៉ះពាល់លើប្រព័ន្ធឌីជីថល

ការវាយតម្លៃលើប្រព័ន្ធអនឡាញ និងការដាក់ឱ្យអនុវត្តចំពោះសេវាសាធារណៈឌីជីថល អាចជាអាវុធមុខពីរ ប្រសិនបើការអនុវត្តនោះមិនទាន់គ្រប់គ្រាន់ ឬឈ្វេសប្រហែស ឬការមើលស្រាលចំពោះដំណោះស្រាយឌីជីថលគ្រប់រូបភាពនានា។

ក្នុងន័យនេះបានពិនិត្យលើទិដ្ឋភាពកើតចេញពីកត្តាមនុស្ស និងសង្គម (៤.១.២.១) និងបរិស្ថានសុវិយោដី-ឌីជីថល (៤.១.២.២)។

#### ៤.១.២.១. កត្តាមនុស្ស និងសង្គម

ការចំណាយលើការអភិវឌ្ឍបរិវត្តកម្មឌីជីថល គឺជាឧបសគ្គលើថវិកាជាតិ និងថវិកាមូលធនមនុស្សឌីជីថល រួមទាំងការព្រួយបារម្ភលើការអនុវត្តខុសគោលដៅ។ ការបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លីទំនើប អាចផ្តល់ការតបស្នងមកវិញដូចជា៖ ១.បង្កើនតម្លាភាព និងកាត់បន្ថយអំពើពុករលួយ, ២.ពង្រឹងសុវត្ថិភាពកាន់កាប់ និងការការពារសិទ្ធិអចលនទ្រព្យរបស់ប្រជាជន, ៣.សម្រួលប្រតិបត្តិការដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យអចលនទ្រព្យ, ៤.បង្កើនការប្រមូលចំណូល និងពន្ធនានាសម្រាប់រាជរដ្ឋាភិបាល, ៥.ប្រសិទ្ធភាពការធ្វើផែនការទីក្រុង ការគ្រប់គ្រង និងការប្រើប្រាស់ដីកាន់តែប្រសើរ, ៦.បង្កើនទំនុកចិត្តខ្ពស់ដល់ពលរដ្ឋ និងទំនុកចិត្តសាធារណៈនៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ជាអាទិ៍។ ក្នុងនោះមានគោលបំណងជួយដល់សង្គម និងសេដ្ឋកិច្ចជាតិតាមរយៈ៖ ១.បង្កើនភាពងាយស្រួលជាងមុននៅលើកំណត់ត្រាដីធ្លីពីគ្រប់ទិសទី លើកកម្ពស់តម្លាភាព និងកាត់បន្ថយតម្រូវការដែលធ្លាប់តែតម្រូវទៅជួបដោយផ្ទាល់ និងសរសេរលើក្រដាសដដែលៗ, ២.អនុវត្តត្រឹមត្រូវ ជៀសវាងកំហុសនានាជាមួយនឹងប្រព័ន្ធឌីជីថលក្នុងការបញ្ចូលទិន្នន័យ ធ្វើបច្ចុប្បន្នភាព និងធ្វើសមកាលកម្ម, ៣.ពង្រឹងសុវត្ថិភាពលើកំណត់ត្រាឌីជីថល ដោយមិនងាយទទួលរងការខូចខាត ការបាត់បង់ ឬការរំខាន ធានាបានភាពត្រឹមត្រូវចំពោះទិន្នន័យកម្មសិទ្ធិដីធ្លី និងអចលនទ្រព្យ, ៤.ដំណើរការលឿនជាមុន រហ័ស កាត់បន្ថយការចំណាយពេល ដោយការលើលំហូរការងារដោយស្វ័យប្រវត្តិ និងការបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណិត, ៥.បង្វែកំណត់ត្រាក្រដាសដែលមានស្រាប់ គឺត្រូវតែស្កេន និងបំប្លែងទៅជាទម្រង់ឌីជីថលវិញធានាតម្លាភាព និងពេញលេញនៃទិន្នន័យ, ៦.ការជំរុញអភិវឌ្ឍវេទិកាឌីជីថល មូលដ្ឋានទិន្នន័យ និងវិបផតថលអនឡាញ, ៧.ដំណើរការវិស្វកម្មឡើងវិញពីវិធានទំនៀមទម្លាប់, ៨.សមាហរណកម្ម និងអន្តរប្រតិបត្តិការ ដោយប្រព័ន្ធចុះបញ្ជីដីធ្លីតាមប្រព័ន្ធឌីជីថល គួរតែរួមបញ្ចូលគ្នាជាមួយភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ និងមូលដ្ឋានទិន្នន័យផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យមានការផ្លាស់ប្តូរព័ត៌មានដោយរលូន, ៩.ការបណ្តុះបណ្តាលអ្នកប្រើប្រាស់និងសម្របខ្លួនឌីជីថល ត្រូវតែមានអ្នកពាក់ព័ន្ធ រួមទាំងមន្ត្រីរដ្ឋាភិបាល និងប្រជាពលរដ្ឋ ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធឌីជីថលថ្មី, និង១០.ទទួលយកការផ្លាស់ប្តូរម៉ូដែលឌីជីថលការចុះបញ្ជីដីធ្លីពីបណ្តាប្រទេសនានា ទាំងក្នុងកម្រិតអាស៊ាន ទាំងកម្រិតតំបន់ និងពិភពលោក។[297]

[297] Barikisa Owusu Ansah. Winrich Voss and other, "A systematic review of the institutional success factors for blockchain-based land administration" [ការត្រួតពិនិត្យឡើងវិញជាប្រព័ន្ធនៃកត្តាជោគជ័យរបស់ស្ថាប័នសម្រាប់ការគ្រប់គ្រងរដ្ឋបាលដីធ្លីដែលមានលើប្លុកឆេន], *Elsevier* (Germany) Volume125, DOI.org/10.1016/j.landusepol.106473 (2022)។

| **ចំណុចខ្លាំង** | **ចំណុចខ្សោយ** |
| --- | --- |
| ១.មិនពិបាកធ្វើដំណើរផ្ទាល់ ឬតម្រង់ជួររង់ចាំទទួលសេវា<br>២.ប្រមូលផ្តុំទិន្នន័យ វិភាគ វាយតម្លៃតាមស្ថានភាពសង្គម<br>៣.ឆ្លើយតបវិធានការសង្គ្រោះបានភ្លាមៗ នៅតាមចំណុចដៅ តំបន់វិនិច្ឆ័យ តំបន់គោលដៅ តំបន់និរន្តរាយ<br>៤.បង្កើនតម្លាភាព សុក្រឹត្យ ទំនុកចិត្ត និងគណនេយ្យភាព<br>៥.អភិបាលកិច្ចតាមបែបចូលរួម និងទាន់សម័យកាល<br>៦.ងាយស្រួលការសម្រេចចិត្តត្រឹមត្រូវ និងភ្លាមៗ<br>៧.ងាយពន្លឿនពីការសម្របខ្លួនឌីជីថល និងសុវត្ថិភាព<br>៨.កាត់បន្ថយពេលវេលា និងចំណាយថវិកាច្រើនពេក<br>៩.យុគសម័យឌីជីថល គ្រប់យ៉ាងពលរដ្ឋអាចប្រតិបត្តិការសេវាសាធារណៈក្នុងដៃ (ឧបករណ៍ឆ្លាតវៃ)របស់ខ្លួន គ្រប់ទីកន្លែង គ្រប់ពេលវេលា និងគ្រប់ស្ថានភាព (សេរី-តម្រូវការ)<br>១០.សេវាសាធារណៈឌីជីថល ជាអន្តរកម្មនៃគ្រប់ក្រសួងស្ថាប័នស្ថិតក្នុងបណ្តាញតែមួយ ឬថ្នាំងតែមួយ ឬបណ្តាញសាធារណៈរវាងអភិបាលកិច្ចវិមជ្ឈការតែមួយ<br>១១.លំហូរបែបបទតែមួយលើក ឬមួយដង អាចប្រើប្រាស់លើសេវាធារណៈឌីជីថលតាមគ្រប់តម្រូវការ<br>១២.សេវាសាធារណៈទូទាំងប្រទេសឈានដល់ការប្រើលើបច្ចេកវិទ្យាឌីជីថល ជំរុញដល់សង្គម និងសេដ្ឋកិច្ចជាតិ | ១.ប្រជាពលរដ្ឋអាចយល់ថាការប្រើប្រាស់តាមអ៊ីនធឺណិតចំណាយថវិកាច្រើន ពុំមានលទ្ធភាពបង់ថ្លៃសេវាបន្ថែម<br>២.ពិការភាព និង/ឬអសមត្ថជនប្រើប្រាស់សេវាឌីជីថល<br>៣.តែងមានផ្នត់គំនិត "រាល់ចម្លើយ គឺសុទ្ធតែបែបនោះ"<br>៤.ប្រជាជនមិនទាន់មានទំនុកចិត្តពេកទេ ជាពិសេស ចែកចាយទិន្នន័យបុគ្គល ឬទិន្នន័យឯកជនសម្ងាត់<br>៥.អក្ខរកម្មអប់រំ អក្ខរកម្មហិរញ្ញវត្ថុ និងអក្ខរកម្មឌីជីថល នៅមានកម្រិតទាប ពិបាកទទួលយកអ្វីដែលថ្មី<br>៦.ឧបសគ្គការចំណាយថវិកាជាតិ និងបំណុលសាធារណៈ<br>៧.ប្រជាជនមិនពេញនិយមពេកនៅលើប្រព័ន្ធបច្ចេកវិទ្យា ពិព្រោះ តែងតែមានទម្លាប់ត្រូវការពេលវេលាសម្របខ្លួន<br>៨.កង្វះមូលធនមនុស្សឌីជីថលក្នុងស្រុក គឺអាចធ្វើឱ្យយឺតយ៉ាវដល់ការអភិវឌ្ឍមូលធនឌីជីថល (ប្រសិនបើមិនខ្វះដៃ)<br>៩.ប្រសិនបើផ្លាស់ប្តូរនៃបរិវត្តកម្មឌីជីថលទាំងស្រុង គឺគ្មានលទ្ធផលល្អសម្រាប់ពលរដ្ឋកម្ពុជាឡើយ ត្រូវតែអត់ធ្មត់ប្រើ **យុទ្ធសាស្ត្រ៥០/៥០** (ដោយផ្ទាល់ផង អនឡាញផង) ទើបទទួលលទ្ធផលល្អ និងប្រើការអស់ពីលទ្ធភាព<br>១០.ទម្រង់អភិបាលកិច្ចរបស់រដ្ឋ តែងមានផ្នត់គំនិតលើអ្វីក៏ដោយត្រូវការពេលវេលាយូរតិច ថវិកាច្រើន ប្រើវិធីសាំញ៉ាំ |
| **កាលានុវត្តភាព** | **ការគំរាមកំហែង** |
| ១.បង្កលក្ខណៈសាមញ្ញ ភាពងាយស្រួល និងរហ័ស<br>២.គួរបន្ថែមវិធីសាស្ត្រលើថ្នាលស្ទង់មតិពីប្រជាជនលើការចំណាយថវិកាជាតិផ្សេងៗឱ្យបានត្រឹមត្រូវ (បើអាច)<br>៣.គួរបន្ថែមវិធីសាស្ត្រលើថ្នាលដែលប្រជាជនអាចផ្តល់ជាយោបល់ផ្សេងៗ ចំពោះសេវាសាធារណៈដោយផ្ទាល់ និងអនឡាញឱ្យកាន់ប្រសើរ (បើអាច)<br>៤.ប្រជាជនដែលមិនទាន់ជ្រាប ឬមិនទាន់សម្របឌីជីថល រដ្ឋាភិបាលគួរពង្រាយមន្ត្រីជំនាញរង់ចាំណែនាំ តាមច្រកណាមួយ ឬតាមឃុំសង្កាត់ ជាពិសេស តំបន់ជនបទ<br>៥.រាជរដ្ឋាភិបាលត្រូវបន្តការគាំទ្រ និងជំរុញសេវាអនឡាញគ្រប់សេវាសាធារណៈរបស់រដ្ឋ (វិស័យឯកជនអាចចូលរួម)<br>៦.អាចឈានទៅដល់ការផ្លាស់ប្តូរទិន្នន័យជាសកល គឺក្នុងកម្រិតស្តង់ដារអន្តរជាតិ | ១.កង្វះមូលធនមនុស្សឌីជីថលក្នុងការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ជាគ្រោះថ្នាក់សង្គមបែបយុគសម័យឌីជីថល<br>២.ប្រើបច្ចេកវិទ្យាជាឈ្នាន់អំពើអាក្រក់ទុច្ចរិត<br>៣.អាជ្ញាធរត្រូវតែមានបច្ចេកវិទ្យាខ្លាំង ជាងឧក្រិដ្ឋជន<br>៤.ពេលខ្លះអាជ្ញាធរកម្ពុជា តាមមិនទាន់ល្បិចឧក្រិដ្ឋជនក្នុងការប្រតិបត្តិលើបច្ចេកវិទ្យា (ជាក់ស្តែង)<br>៥.បង្ការចាំបាច់ បើវិស័យរដ្ឋ ឬវិស័យឯកជនប្រើប្រាស់លើទិន្នន័យខុសគោលដៅ<br>៦.នៅពេលរងការវាយប្រហារលើសន្តិសុខសាយប័រ យឺតយ៉ាវពេក ទម្រាំឈានដល់ដោះស្រាយ<br>៧.ហានិភ័យខ្លាំងចំពោះប្រជាជនដែលមិនទាន់សម្របលើឌីជីថល ងាយចាញ់បោក និងងាយជឿទុកចិត្ត<br>៨.មិនបានសិក្សាឈ្វេងយល់ពីវិធានការការពារឌីជីថល |

តារាងទី១៤៖ ភាពខ្លាំង និងភាពខ្សោយចំពោះមនុស្ស-សង្គមលើប្រព័ន្ធឌីជីថល

### ៤.១.២.២. បរិស្ថានសុរិយោដី-ឌីជីថល

ជាប្រវត្តិសាស្ត្ររបស់កម្ពុជា ក្នុងការរៀបចំ និងប្រព្រឹត្តទៅនៃបរិវត្តកម្មឌីជីថលក្នុងវិស័យដីធ្លី។ កាលានុវត្តន៍ និងវឌ្ឍនភាពឌីជីថល កម្ពុជាបាននឹងកំពុងត្រៀមខ្លួន និងអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយបន្តិចម្តងៗគ្រប់សេវាសាធារណៈទាំងអស់នៅទូទាំងប្រទេស។ សេវាសាធារណៈទូទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) កំពុងបម្រើជូនប្រជាពលរដ្ឋទាំងថ្នាក់មជ្ឈការ វិមជ្ឈការ និងសហវិមជ្ឈការមាន**សរុប៤៩៦មុខ** ក្នុងនោះស្ថិតក្រោមរដ្ឋបាលរបស់ក្រសួង១៩៨មុខ, សេវាធ្វើប្រតិភូកម្មទៅដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីទូទាំងរាជធានី ខេត្ត២២០មុខ និងសេវានៅតាមការិយាល័យតាមច្រកចេញ-ចូលតែមួយក្រុង ស្រុក ខណ្ឌ៧៨មុខ។[298] ក្រសួង ដ.ន.ស ពុំទាន់ដាក់ឱ្យដំណើរការសេវាសាធារណៈលើប្រព័ន្ធអនឡាញ គ្រប់សេវានៅឡើយទេ។ ត្រូវការពេលវេលា និងផែនការថវិកាដើម្បីដោះស្រាយ។ ការព្រួយបារម្ភពីសន្តិសុខ និងសុវត្ថិភាពលើទ្រព្យសម្បត្តិអចលនទ្រព្យនៅតែមានកង្វល់ក្នុងចិត្តចំពោះប្រជាជនគ្រប់រូប នាពេលបរិវត្តកម្មឌីជីថលពេញលេញ។ យ៉ាងណាមិញរាជរដ្ឋាភិបាលកម្ពុជាបានគូសបញ្ជាក់ថា សន្តិសុខនិងសុវត្ថិភាព ជាសមត្ថភាពដែលបុគ្គលម្នាក់ៗអាចចូលរួមយ៉ាងសកម្មក្នុងការរៀបចំបរិស្ថានឌីជីថលប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ។ តាមរយៈសមត្ថភាព[ឌីជីថល]ទាំងនេះ បុគ្គលម្នាក់ៗអាចចូលប្រើប្រព័ន្ធអនឡាញប្រកបដោយទំនុកចិត្ត អាចការពារខ្លួន និងអ្នកដទៃពីគ្រោះថ្នាក់នានា និងចូលរួមចំណែកក្នុងការបង្កើតនូវបទពិសោធន៍ឌីជីថលប្រកបដោយវិជ្ជមាន និងបរិយាបន្នសម្រាប់មនុស្សគ្រប់រូប។[299]

ការប្រើប្រាស់ក្រដាសគ្រប់ប្រភេទក្នុងកិច្ចការរដ្ឋបាលគ្រប់វិស័យសាធារណៈ ត្រូវតែកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់ ដោយផ្លាស់ប្តូររបៀបរបបការប្រើប្រាស់លើទម្រង់ឌីជីថលវិញ។ ការប្រើប្រាស់ក្រដាស គឺមានតែវិស័យ២ប៉ុណ្ណោះសំខាន់ខ្លាំង ដែលគួរតែបន្តការប្រើប្រាស់ និងឱ្យទូលំទូលាយ ១.**វិស័យអប់រំ** (ការសិក្សាទូទៅ, ផែនការបង្រៀន, ការស្រាវជ្រាវ, កំណែទម្រង់ការអប់រំ ជាអាទិ៍), និង២.**វិស័យយុត្តិធម៌** (ការត្រួតពិនិត្យសំណុំរឿង, កំណត់ហេតុ របាយការណ៍ ការវាយតម្លៃ ឬទិន្នន័យស៊ើបអង្កេត, ភស្តុតាង, អភិរក្សបណ្ណសារនៃសំណុំរឿង ជាអាទិ៍)។ ក្រសួង ស្ថាប័នមួយចំនួន ឃើញថានៅបន្តបង្កើតទម្រង់បែបបទឯកសារដោយបំពេញការងារដដែលៗ មិនមានសង្គតិភាព និងចាស់គំរិលហួសសម័យកាល។ ការគិតគូរយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើរឿងបរិស្ថានជាគំនិតចម្បងមួយ ដោយសារតែក្រដាសសរសេរដោយដៃផលិតចេញពីសំបករុក្ខជាតិ ព្រៃឈើ និងកាកជ័រកៅស៊ូនានា ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិរបស់កម្ពុជា។ កម្ពុជាមានឆន្ទៈ និងប្តេជ្ញាចូលរួមកាត់បន្ថយឧស្ម័នកាបូន ដោយតែងតែប្រារព្ធទិវាបរិស្ថានជាតិនិងបរិស្ថានពិភពលោកជារៀងរាល់ឆ្នាំ នាថ្ងៃទី៥ មិថុនា ១៩៩៦ ដល់ថ្ងៃទី៥ មិថុនា ២០២៤ និងទើបតែដាក់ឱ្យអនុវត្តក្រមបរិស្ថាន និងធនធានធម្មជាតិ ថ្ងៃទី២០ កក្កដា ២០២៤។[300] ការវិភាគទុកពីនិរន្តរភាពនិងចក្ខុវិស័យរយៈពេលវែង ជាបញ្ហាមួយមិនគួររំលង។

---

298 គិតត្រឹមខែកក្កដា ឆ្នាំ២០២៤។

299 ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, "ក្របខណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន (អ.ឌ.ប.ព)៖ លើកកម្ពស់ការកសាងពលរដ្ឋឌីជីថល ដើម្បីសេដ្ឋកិច្ចនិងសង្គមកិច្ចឌីជីថលដ៏រស់រវើក," ២០២៤។

300 ក្រមបរិស្ថាន និងធនធានធម្មជាតិ,លេខ នស/រកម/០៦២៣/០០៧, ២៩ មិថុនា ២០២៣, មាត្រា៥៧, និងមាត្រា១០៤-១២០។

| ចំណុចខ្លាំង | ចំណុចខ្សោយ |
| --- | --- |
| ១.អាចអភិក្រមទូទាំងរដ្ឋាភិបាល នៃផ្ទៃក្នុងគ្រប់ស្ថាប័នរដ្ឋ<br>២.គោលដៅវេទិការួម ជាអន្តរប្រតិបត្តិការរួមនៃរដ្ឋាភិបាលឌីជីថល និងអាចតាមដានលំហូរដំណើរការលើប្រព័ន្ធ<br>៣.អភិបាលកិច្ចតាមបែបចូលរួម និងដំណោះស្រាយរួម<br>៤.មូលដ្ឋានទិន្នន័យដីធ្លី មានភាពទាន់សម័យ<br>៥.កសាងប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដី ដែលមានផ្ទុកទិន្នន័យមិនកំណត់បរិមាណ<br>៦.ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល គឺអាចគាំទ្រលើឧបករណ៍ និង/ឬផលិតផលសាធារណៈឌីជីថលបានច្រើនប្រភេទ និងសំបូរបែប<br>៧.គ្រប់ដណ្តប់ទិន្នន័យសុរិយោដីទូទាំងប្រទេសផ្ទុកនៅក្នុងម៉ាស៊ីនមេរបស់ក្រសួង និងបញ្ជូនអន្តរកម្មទៅកាន់ក្រសួង ស្ថាប័ន អង្គភាពដទៃ បម្រើដល់ប្រយោជន៍សាធារណៈ<br>៨.ជំនួយពីបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងប្លុកឆេនច្រើន<br>៩.មន្ត្រីរដ្ឋបាលសុរិយោដីអាចបំពេញការងារនៅនឹងកន្លែង<br>១០.ងាយស្រួលត្រួតពិនិត្យ និងអនុម័តតាមអនឡាញ<br>១១.សមកាលកម្មនៃបច្ចុប្បន្នភាពទិន្នន័យភ្លាមៗ<br>១២.បង្កើត "**គោលការណ៍តែមួយដង តែអាចគ្រប់យ៉ាង**" | ១.ដកចេញអភិក្រមដែលផ្តោតលើតែក្រសួង ឬមុខងារ ឬក៏នាយកដ្ឋានណាមួយពេក ព្រោះជា "**ហានិភ័យអនាគត**"<br>២.មន្ត្រីរដ្ឋបាលសុរិយោដីនៅកំពុងតែបណ្តុះបណ្តាលលើវិធានទំនៀមទម្លាប់នៅឡើយ<br>៣.នៅកង្វះមន្ត្រីបច្ចេកទេសមកអនុវត្តលើអនឡាញ<br>៤.មើលស្រាលពីការរៀបចំ និងប្រព្រឹត្តទៅប្រព័ន្ធឌីជីថលតាមរយៈការឆ្វេសប្រហែស មើលរំលងជ្រុងតាមផ្នែក...<br>៥.ពុំទាន់មានលក្ខណៈគ្រប់គ្រាន់លើការគ្រប់គ្រងអ្នកប្រើ-ប្រាស់នៅឡើយ<br>៦.ពុំទាន់មានវិធានការជំនួយដល់ជនពិការ និងអសមត្ថ-ជន ដែលត្រូវការទទួលសេវា<br>៧.បន្តរក្សាកម្មវិធីជំនាន់ចាស់ ដោយមិនបានវិវត្តន៍<br>៨.ទម្លាប់ផ្នត់គំនិត "គិតមួយជំហាន ដើរមួយជំហាន" និង "បើមានបញ្ហាចាំគិតទៀត មិនចង់ស្មុគស្មាញ"<br>៩.ការគូស ការកំណត់ព្រំនិងចុះវាស់ក្បាលដី មិនទាន់បានបញ្ចប់ទូទាំងប្រទេស<br>១០.អំពើពុករលួយ "ថ្លៃទឹកតែ" និងរង់ចាំតែជំនួយបរទេស |
| **កាលានុវត្តភាព** | **ការគំរាមកំហែង** |
| ១.រាងអចលនទ្រព្យបម្លែងជាទ្រព្យសកម្មឌីជីថល ត្រូវភ្ជាប់ទៅនឹងវត្ថុក្នុងពិភពពិត ដោយមិនត្រឹមតែតំណភ្ជាប់ជាមួយស្ថាប័នយុត្តាធិការប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវមានតំណភ្ជាប់នៃលំហូរសកម្មភាពបុគ្គលរបស់កម្មសិទ្ធិករ<br>២.បន្តការកសាង ការអភិវឌ្ឍ និងទាញធាតុចូលចំពោះគំរូម៉ូដែលបច្ចេកវិទ្យាផ្សេងៗ បម្រើឱ្យបង្កើនសេវាសាធារណៈឌីជីថលបន្ថែមទៀត។ គួរតែបង្កើនម៉ាស៊ីនបញ្ជរ KIOSK។<br>៣.គួរបង្កើនជម្រើស ប្រភេទ និងកម្មវិធីផ្សេងៗរបស់ក្រសួងតាមតម្រូវការបន្ថែមរបស់អ្នកប្រើប្រាស់<br>៤.គួរបង្កើតថ្នាលលក់ទិញអចលនទ្រព្យនៅលើប្រព័ន្ធអន-ឡាញ ដោយរដ្ឋបាលសុរិយោដីជាអន្តរការីកណ្តាល<br>៥.គួរអភិវឌ្ឍន៍ និងអាចដឹងពីព័ត៌មានកម្មសិទ្ធិករតតិយជន (អ្នកជិតខាង) នៃព្រំដីជាប់គ្នារវាងកម្មសិទ្ធិករនៅលើបណ្ណអេឡិចត្រូនិក | ១.ខ្វះខ្នាយ ប្រហែស ឬឆកល្វែងលើប្រព័ន្ធណាមួយ<br>២.ងាយរងការវាយប្រហារសន្តិសុខសាយប័រ ដែលធ្វើឱ្យមានការខូចខាត ប្រែប្រួល ផ្លាស់ប្តូរទិន្នន័យព័ត៌មានដីធ្លីជាយថាហេតុណាមួយ<br>៣.សហប្រតិបត្តិការ ទប់ស្កាត់ និងបង្ក្រាបឱ្យបានរាល់បទល្មើសបច្ចេកវិទ្យា ដែលហានិភ័យដល់ទ្រព្យសម្បត្តិដីធ្លី<br>៤.យុទ្ធសាស្ត្រការប្រើប្រាស់ដីធ្លី ពុំទាន់មានលទ្ធផលល្អ<br>៥.ផែនការប្លង់សុរិយោដី និងនគរូបនីយកម្ម មិនទាន់បានប្រទាក់ក្រឡាគ្នានៅឡើយ អំឡុងពេលបរិវត្តកម្មឌីជីថល<br>៦.ពុំទាន់មានការពង្រឹងលើវិធានការសង្គ្រោះដីធ្លី<br>៧.បន្តកើតមានបទល្មើសរំលោភដីធ្លីនៅតាមតំបន់ ដែលអាចធ្វើឱ្យសេវាសាធារណៈឌីជីថល មានភាពយឺតយ៉ាវ<br>៨.វិធានការដោះស្រាយឌីជីថលលើបញ្ហាសុរិយោដី (គ្មាន)<br>៩.នៅមានកម្រិតនៃកង្វះមធ្យោបាយផ្សព្វផ្សាយ និងអប់រំ |

តារាងទី១៥៖ ភាពខ្លាំង និងភាពខ្សោយចំពោះបរិស្ថានសុរិយោដីលើប្រព័ន្ធឌីជីថល

## ៤.២. សន្តិសុខសាយប័រ

កាលណាលើកអំពីសាយប័រ គឺបានគិតដល់ភ្លាមអំពីសុវត្ថិភាពព័ត៌មានវិទ្យា។ វិធានការលើសាយប័រ គឺជាយន្តការរបត់មួយថ្មីសម្រាប់សង្គមកម្ពុជា អំពីវិធីសាស្ត្រការពារពីការវាយប្រហារឧក្រិដ្ឋកម្មសាយប័រ ឬសង្គ្រាមសាយប័រ ដែលប៉ះពាល់ដល់ការខូចខាតទិន្នន័យ ព័ត៌មាន របាយការណ៍ដែលបានផ្ទុក និងប្រើប្រាស់ក្នុងប្រព័ន្ធឌីជីថលនៃព័ត៌មានវិទ្យា។ កម្ពុជា ក៏ទើបតែបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថល និងបានបើកអង្គប្រជុំលើកទី ១ កាលពីថ្ងៃទី៣ មីនា ២០២៤ ដើម្បីសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ទើបតែរៀបចំពិនិត្យ ពិភាក្សា និងការកែសម្រួលលើសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ ដើម្បីបន្ទាន់ពីស្ថានការណ៍ចំពោះព័ត៌មានទិន្នន័យជាតិ។[301] ការព្រួយបារម្ភតែងកើតមានពីខាងសំណាក់ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់អ៊ីនធឺណិត ជាពិសេស លើការប៉ះពាល់សិទ្ធិប្រើប្រាស់ឌីជីថល។[302]

ការឆ្លើយតបនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលថ្មីៗ ជាពិសេសបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (Generative AI) ដែលនាំឲ្យមានការជំរុញនវានុវត្តន៍និងបង្កើនផលិតភាព នាំឲ្យមានកំណើននៃលំហូរទិន្នន័យឯកជនពលរដ្ឋ និងការប្រើប្រាស់ ដោយសារតែទិន្នន័យទាំងនោះគឺត្រូវឆ្លងកាត់លើការត្រួតពិនិត្យពីអាជ្ញាធរ និងច្រកផ្លូវអ៊ីនធឺណិត បង្កជាការព្រួយបារម្ភដល់ការយកប្រៀបផ្នែកព័ត៌មានសម្ងាត់ ពាណិជ្ជកម្ម ការបំពានឯកជនភាពរបស់ពលរដ្ឋ និងគំរាមកំហែងសន្តិសុខសាយប័រ ជាអាទិ៍។[303] ការរៀបចំបទប្បញ្ញត្តិឌីជីថល ដែលបន្ស៊ីទៅនឹងតម្រូវការពលរដ្ឋឌីជីថលគឺជាកម្មវត្ថុចាំបាច់ធានាដល់សិទ្ធិប្រើប្រាស់ឌីជីថល ទ្រព្យសកម្មហិរញ្ញវត្ថុឌីជីថល សិទ្ធិឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ។[304] កត្តានេះ បរិបទកម្ពុជា គួរបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំពីភាពត្រឹមត្រូវនៃការសិក្សាថ្មី ឬកែប្រែគោលនយោបាយដែលមានស្រាប់ទៅដល់មូលធនមនុស្សឌីជីថល ដើម្បីការពារពីការប្រើប្រាស់ឧបករណ៍ ឬកម្មវិធីដំណើរការបញ្ញាសិប្បនិម្មិតដោយគ្មានការទទួលខុសត្រូវ ឬគ្មានក្រមសីលធម៌ប្រើប្រាស់ ជាពិសេស ការក្លែងបន្លំ ឬផ្តល់ព័ត៌មានបោកប្រាស់នានា។[305]

---

[301] Semtararath, "ចូលរួមកិច្ចប្រជុំដើម្បីប្រកាសសមាសភាពនិងផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់ គ.ស.ឌ," *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍*, ២០២៤, https://mptc.gov.kh/2024/05/ (ទស្សនាចុងក្រោយថ្ងៃទី៣ កក្កដា ២០២៤)។

[302] ស៊ុន ណារិន, "អ្នកជំនាញបារម្ភអំពីសេចក្តីព្រាងច្បាប់«ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មាន»," *VOA*, ២០២៤, https://khmer.voanews.com/a/experts-fear-cambodian-cybercrime-law-could-aid-crackdown/7570396.html (ទស្សនាចុងក្រោយថ្ងៃទី៣ កក្កដា ២០២៤)។

[303] Paul Wagner and William Mapp, "Identifying Information Technology (IT) and Cybersecurity Executives' Competencies to Support Comprehensive Cybersecurity Programs" [ការកំណត់អត្តសញ្ញាណបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសមត្ថភាពអង្គប្រតិបត្តិសន្តិសុខអ៊ីនធឺណិត ដើម្បីគាំទ្រឱ្យទូលាយលើកម្មវិធីសុវត្ថិភាពអ៊ីនធឺណិត], *ResearchGate* (EU) DOI.10.34190/eccws2317 (2024)។

[304] Уголовный кодекс россии [ក្រមព្រហ្មទណ្ឌនៃសហព័ន្ធរុស្ស៊ី], ១ មករា ១៩៩៧, ក្នុងជំពូកទី២១ មាត្រា១៥៨, https://www.wipo.int/edocs/lexdocs/laws/en/ru/ru080en.pdf (ទស្សនាចុងក្រោយថ្ងៃទី៣ កក្កដា ២០២៤)។

[305] Sok Sarin and Heng Kimkong, "Generative AI In Higher Education: The Need To Develop Or Revise Academic Integrity Policies To Ensure The Ethical Use Of AI In Cambodia" [បញ្ញាសិប្បនិម្មិតក្នុងកម្រិតការអប់រំជាន់ខ្ពស់៖ តម្រូវការអភិវឌ្ឍន៍ ឬការកែសម្រួលគោលនយោបាយនៃសុចរិតភាពការសិក្សាដើម្បីធានាបានក្រមសីលធម៌លើការប្រើប្រាស់បញ្ញាសិប្បនិម្មិតនៅកម្ពុជា], *មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា CDC/J*, ២០២៤, https://www.cd-center.org/wp-content/uploads/2024/07/P124_2 0240702_V6IS1_EN.pdf (ទស្សនាចុងក្រោយថ្ងៃទី៣ កក្កដា ២០២៤)។

ប្រសិនបើក្រោយពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដាក់ឱ្យអនុវត្តបរិវត្តកម្មឌីជីថលផ្លូវការ តើសន្តិសុខព័ត៌មានវិទ្យា អាចធានាការពារទិន្នន័យកម្មសិទ្ធិអចលនវត្ថុបានដែរឬទេ?

ដើម្បីអាចការពាររងពីការវាយប្រហាររបស់ក្រុមចោរព័ត៌មានវិទ្យា ឬដោយបុគ្គល ឬក្រុមហេកគ័រ ដែលអាចប៉ះពាល់ដល់ដំណើរការសេវាសាធារណៈឌីជីថល គឺត្រូវគិតគូរអំពីវិធានការសង្គ្រោះសន្តិសុខព័ត៌មានកម្មសិទ្ធិអចលនវត្ថុ (៤.២.១) និងលទ្ធផលតេស្តមតិសាធារណជន (៤.២.២) ដែលអាចបញ្ជាក់អំពីទំនុកចិត្តរបស់អ្នកប្រើប្រាស់។

### ៤.២.១. វិធានការសង្គ្រោះសន្តិសុខព័ត៌មានកម្មសិទ្ធិអចលនវត្ថុ

ការកសាងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ ពុំមែនជារឿងងាយស្រួល។ សន្តិសុខអ៊ីនធឺណិត ក្លាយជាបញ្ហាសំខាន់ដោយសារមានការកើនឡើងពីការគំរាមកំហែង ការចាប់ជំរិត និងការប្លន់យកទ្រព្យសម្បត្តិលើប្រព័ន្ធអ៊ីនធឺណិត ប៉ះពាល់ធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិប្រជាជន ធុរកិច្ច និងរដ្ឋាភិបាល (Joshi, ២០២៤)។[306] ជៀសវាងពីកត្តាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់គួរតែមានវិធានការៈ ១.បង្កើត/បង្កើនក្រុមអ្នកជំនាញការពារសន្តិសុខសាយប័រ (បំបែកជាក្រុមទៅតាមប្រភេទ និងពណ៌), ២.កិច្ចសហការជាមួយវិស័យឯកជន, ៣.បម្រុងថវិកាលើការកសាងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ និង៤.សមត្ថកិច្ចទទួលខុសត្រូវពាក់ព័ន្ធ។ ក្រុមអ្នកការពារសន្តិសុខសាយប័រ (Cybersecurity Team) ចំពោះកម្ពុជាបច្ចុប្បន្ន អាចនឹងពិបាកបន្តិច ដោយសារកត្តាអក្ខរកម្មឌីជីថលនៅមានកម្រិតទាប មានតែ "ខ្ញុំដៃបរទេសជួយរៀបចំ"។[307] ជាយោបល់ រាជរដ្ឋាភិបាលកម្ពុជា គួរបន្ថែមកិច្ចសហការជាមួយក្រុមហ៊ុនសន្តិសុខបច្ចេកវិទ្យា Unit42, Crowdstrike ដែលជាក្រុមហ៊ុនខ្លាំង ស្តង់ដារពិភពលោក និងអាចធានាដល់ប្រព័ន្ធសន្តិសុខទិន្នន័យជាតិ។ នៅកម្ពុជា ធ្លាប់ទទួលរងគ្រោះជាច្រើន គ្រាន់តែព័ត៌មានពុំសូវមានភាពពេញនិយមសម្រាប់ពលរដ្ឋ។ ករណីនៅសាធារណរដ្ឋឥណ្ឌូនេស៊ី គឺរងគ្រោះរហូតដល់ការខូចខាតលើមជ្ឈមណ្ឌលទិន្នន័យជាតិ ប៉ះពាល់ដល់សេវាសាធារណៈឌីជីថល ជាពិសេស សេវាអាកាសយានដ្ឋាន ធនាគារ និងអចលនទ្រព្យ។[308] ការត្រៀមថវិកាជាតិកសាងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ គឺជាសំណួរនិងគ្មានចម្លើយ ពិព្រោះ "ភាពសំខាន់និងកម្រិតធ្ងន់ធ្ងរនៃការវាយប្រហារតាមរយៈសាយប័រ គឺខុសៗគ្នាទៅតាមទម្រង់ និងបរិបទនៃការវាយប្រហារនីមួយៗដែលជះឥទ្ធិពលទៅដល់ការបម្រុងសាច់ប្រាក់សម្រាប់ផ្នែកសន្តិសុខសាយប័រ ប៉ុន្តែ គឺតម្រូវការត្រៀមខ្លួនជានិច្ចរបស់រដ្ឋាភិបាលនីមួយៗ។"[309]

---

[306] Aditya Joshi, "Study of Cybersecurity of Laws and Regulations" [សិក្សាអំពីបទប្បញ្ញត្តិ និងច្បាប់ស្តីពីសន្តិសុខសាយប័រ], *ResearchGate* (Mumbai, India) DOI.10.36676/ijl.v2.i3.27 (2024): 7-14។

[307] ការណែនាំពីឧក្រិដ្ឋវិទ្យាបច្ចេកវិទ្យាពីក្រសួងមហាផ្ទៃ និងប្រភេទក្រុម ពណ៌នៃក្រុមអ្នកការពារសន្តិសុខសាយប័រ។

[308] Stefanno Sulaiman and Stanley Widianto, "Indonesia president orders audit of data centres after cyberattack," *Reuters,* ២០២៤, https://www.reuters.com/technology/cybersecurity/bulk-indonesia-data-hit-by-cyberattack-not-backed-up-officials-say-2024-06-28/ (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។

[309] Himanshu, "Cybersecurity Law: Challenges and Legal Frameworks for Protecting Digital Assets and Privacy Rights" [ច្បាប់ស្តីពីសន្តិសុខសាយប័រៈ បញ្ហាប្រឈម និងក្របខណ្ឌច្បាប់សម្រាប់ការពារទ្រព្យសម្បត្តិឌីជីថល និងសិទ្ធិឯកជនភាព], *ResearchGate* DOI.10.36676/ijl.v2.i2.05 (2024): 18-22។

ការរៀបចំបទប្បញ្ញត្តិ និងគោលការណ៍លើសន្តិសុខសាយប័រគួរគិតគូរលើ៖ ១.ការពារទិន្នន័យ និងសិទ្ធិលើឯកជនភាព, ២.វិធានការជូនដំណឹងពីការវាយប្រហារ, ៣.គ្រប់គ្រងហានិភ័យនិងសមកាលកម្ម, ៤.សិទ្ធិនិងកាតព្វកិច្ចលើការទទួលខុសត្រូវ, ៥.ការឆ្លើយតបឧបទ្ទវហេតុ ភាពអាសន្ន និងការស្តារឡើងវិញ, ៦.លំហូរទិន្នន័យឆ្លងព្រំដែន, ៧.អនុលោមការសម្រប និងនិរន្តរភាព, និង៨.កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងនោះ គួរតែមានទំនាក់ទំនងការពារពីអង្គការអន្តរជាតិដូចជា៖ UN, NATO, ITU, OAS, ENISA, APEC, CICTE ជាអាទិ៍។

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| ១.ធានាដល់ការការពារទ្រព្យសកម្មឌីជីថលផ្សេងៗ របស់ប្រជាជនជាពិសេសកម្មសិទ្ធិអចលនទ្រព្យ និងប្រាក់តម្កល់ទុកនៅធនាគារ ជាអាទិ៍<br>២.ដំណើរការដោយរលូន ល្បឿនលឿន មិនអាក់អួល ឬជាឧបសគ្គដល់សេវាសាធារណៈឌីជីថល<br>៣.មានភាពងាយស្រួលផ្តល់សេវាដល់ប្រជាជនគ្រប់ពេលវេលា គ្រប់ទីកន្លែង<br>៤.ស្ថិរភាព និងចីរភាពដល់ព័ត៌មានទិន្នន័យឌីជីថល<br>៥.សុវត្ថិភាពខ្ពស់ដល់មជ្ឈមណ្ឌលទិន្នន័យជាតិ<br>៦.បង្កើនទំនុកចិត្តមួយកម្រិតទៀតដល់ប្រជាជន ក្នុងការជំរុញលើការប្រើប្រាស់សេវាសាធារណៈឌីជីថល | ១.ត្រូវការថវិកាជាតិខ្ពស់ពេកនៃការចំណាយនៅលើប្រព័ន្ធសន្តិសុខសាយប័រ<br>២.ចំនួនមន្ត្រីជំនាញសាយប័រក្នុងស្រុក មានតិចតួចពេក<br>៣.ពាក្យមួយថា "ចេះមិនដល់ ឆ្ងល់មិនកើត" ជាពិសេសគឺអាជ្ញាធរជាតិពាក់ព័ន្ធ<br>៤.កាលៈទេសៈតម្រូវ ប៉ុន្តែមើលរំលងស្ថានការណ៍<br>៥.កង្វះការស្រាវជ្រាវជាតិទៅលើបរិបទពាក់ព័ន្ធ<br>៦.ខ្វះខ្នាយ មិនប្រុងប្រយ័ត្ន និងអំពើពុករលួយក្នុងប្រព័ន្ធព័ត៌មានវិទ្យា<br>៧.ប្រសិនបើខូចខាត ពុំទាន់មានវិធានសំណងរដ្ឋប្បវេណី<br>៨.កង្វះច្រើនពីបទដ្ឋានគតិយុត្ត និងការពន្លឿន |
| **កាលានុវត្តភាព** | **ការគំរាមកំហែង** |
| ១.បន្តបង្កើនហេដ្ឋារចនាសម្ព័ន្ធសន្តិសុខសាយប័រ<br>២.បង្កើនចំនួនក្រុមអ្នកការពារសន្តិសុខសាយប័រ (គឺប្រៀបដូចទៅនឹងកងកម្លាំងសាធារណៈ ដូច្នោះដែរ)<br>៣.ពិចារណាពីបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ដែលកត្តាខ្លះគឺអាចមហន្តរាយដល់សង្គម និងសេដ្ឋកិច្ចជាតិ<br>៤.បង្កើនទៅលើទំនាក់ទំនងការទូតបច្ចេកវិទ្យា និងការទូតសេដ្ឋកិច្ច<br>៥.បន្តបណ្តុះបណ្តាលមូលធនមនុស្សលើសន្តិសុខសាយប័រ ជាពិសេស បទប្បញ្ញត្តិគោលដៅ និងវិធានការសង្គ្រោះ<br>៦.រាជរដ្ឋាភិបាល ត្រូវបង្កើនសូចនាករ អាទិភាពគន្លឹះ និងគោលការណ៍អនុវត្ត<br>៧.គួរបង្កើតគណៈកម្មការសវនកម្មបច្ចេកវិទ្យាជាតិ និងអាជ្ញាធរអភិបាលកិច្ច<br>៨.បង្កើតកម្មវិធីការប្រកួតប្រជែង និងលើកទឹកចិត្តស្រាវជ្រាវពីបច្ចេកវិទ្យាសាយប័រ ដល់សិស្ស និស្សិត និងបណ្តាអ្នកស្រាវជ្រាវជាន់ខ្ពស់ | ១.ប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតជាឈ្នាន់បម្លែងទៅជាអាវុធយុទ្ធភណ្ឌសង្គ្រាមបច្ចេកវិទ្យា លំហអសន្តិសុខនិងឧក្រិដ្ឋកម្មសាយប័រ ឈានដល់ការបង្កើតកងកម្លាំងបច្ចេកវិទ្យាឌីជីថលពិសេស ជាដើមហេតុចលាចលអ៊ីនធឺណិត<br>២.ពុំបានព្យាករទុកមុនពីនិន្នាការសុវត្ថិភាពសាយប័រ<br>៣.ការផ្ទុះពីមេរោគចាប់ជំរិត (ransomware) ដែលសំដៅរាល់ទ្រព្យសកម្មនានានៅក្នុងប្រព័ន្ធឌីជីថលដូចជា អចលនទ្រព្យ សហគ្រាស ពាណិជ្ជកម្មគ្រប់ទំហំ និងធនាគារ<br>៤.ក្រុមចោរបច្ចេកវិទ្យា ប្រើប្រាស់វិធីសាស្ត្របញ្ឆោពីចម្ងាយ គឺមានន័យថា បើអ្នកប្រើប្រាស់មិនបានប្រុងប្រយ័ត្ន ទោះបីមិនបានប៉ះពាល់លើ ឬទុកចោលឧបករណ៍ឆ្លាតវៃ ក៏អាចមានហានិភ័យបាត់បង់ព័ត៌មាន និងទិន្នន័យបុគ្គល ផងដែរ និងពិបាកការចាប់ទីតាំង ឬឧបករណ៍ណាមួយដែលកំពុងប្រព្រឹត្តបទល្មើសនោះ<br>៥.ការឃ្លាំមើល និងចាប់សញ្ញាមិនប្រក្រតីណាមួយនៅលើបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត |

| | |
|---|---|
| ៩.បង្កើនយន្តការផែនការរំកិលនៃការបម្រុងទុកថវិកាជាតិ លើការការពារប្រព័ន្ធឌីជីថល<br>១០.បង្កើតយន្តការពិសេស តាមការចាំបាច់<br>១១. បង្កើតនីតិវិធីគាំពារ នៅពេលគាំងបច្ចេកវិទ្យាម្តងៗ | ៦.ការបែកធ្លាយទិន្នន័យពីសំណាក់រដ្ឋាភិបាលផ្ទាល់ ឬធុរ-ជន ឬអ្នកប្រើប្រាស់ដោយប្រការណាមួយ<br>៧.កត្តាបច្ចេកវិទ្យារបស់អាជ្ញាធរ អន់ជាងចោរព័ត៌មានវិទ្យា<br>៨.អាស្រ័យលើវិវត្តន៍ស្ថានការណ៍សង្គម |

តារាងទី១៦៖ ភាពខ្លាំង និងភាពខ្សោយចំពោះសន្តិសុខសាយប័រលើប្រព័ន្ធឌីជីថល

ប្រសិនបើគ្មានទំនុកចិត្តកម្មសិទ្ធិលើការធ្វើបរិវត្តកម្មឌីជីថល, ហេតុអ្វីប្រជាពលរដ្ឋខ្មែរ ទុកចិត្តលើការទូទាត់តាមប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលមានទំហំកម្មវត្ថុលើសពីរាប់លានដុល្លារអាមេរិក?

ចាំបាច់គួរមានវិធីសាស្តការការពារសុវត្ថិភាពដល់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល(៤.២.១.១) និងយន្តការអប់រំ និងផ្សព្វផ្សាយ (៤.២.១.២)។

### ៤.២.១.១. ការការពារសុវត្ថិភាពដល់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល

កំហុសភាគច្រើន ដែលនាំឱ្យមានការបែកធ្លាយទិន្នន័យបុគ្គល ឬរងការវាយប្រហារពីចោរព័ត៌មានវិទ្យា គឺកើតចេញពីកំហុសផ្ទាល់ខ្លួន(សុចរិតគ្មានកំហុស) ៩៥%ដោយមិនបានប្រុងប្រយ័ត្ន។[310] ក្នុងនោះអាចកើតឡើងដោយសារប្រជាពលរដ្ឋពេញនិយមតភ្ជាប់បណ្តាញអ៊ីនធឺណិតសាធារណៈឥតខ្សែ (Public-W WIFI) ដែលគ្មានប្រភពច្បាស់លាស់ VPN, WPA2-3, URL និងដោយជ្រែតជ្រែកចូលប្រព័ន្ធឧបករណ៍ឆ្លាតវៃផ្ទាល់របស់អ្នកប្រើ-ប្រាស់ដូចជា៖ ការវាយប្រហារសាយប័រ Cyber Attack Quishing ជាបច្ចេកទេសតាមរយៈការស្កេនឃ្យូ អរ កូដ, ស្កេនតាមទីតាំង (Location) និងការទូទាត់ប្រាក់ដោយឈ្វេសប្រហែស[311], មេរោគ Deepfake គឺអាចចាប់យកសញ្ញាក្លែងព័ត៌មានជីវមាត្រ (ទម្រង់មុខ សម្លេង ក្រយៅដៃ...)[312], មេរោគ Pagasus តាមរយៈការតម្លើងកម្មវិធីប្រើប្រាស់ផ្តេសផ្តាស[313], មេរោគ Adware ដែលរំខានដល់ឧបករណ៍ឆ្លាតវៃ និងតែងភ្ជាប់មកជាមួយការលោតផ្សាយពាណិជ្ជកម្ម ជាពិសេសលើការផ្សាយលក់ទិញអចលនទ្រព្យមិនពិតប្រាកដ ដោយសហភាពអឺរ៉ុបបានប្តឹងក្រុមហ៊ុន Meta ពីការមិនគោរពវិធានច្បាប់ Bloc's Landmark Antitrust នៃសេវាកម្ម Ad-supported[314], លើករណីញឹកញាប់គឺ Spam លើការទូទាត់បច្ចេកវិទ្យាហិរញ្ញវត្ថុធនាគារ ឆបោក ក្លែងបន្លំប្រាក់ និងការបោកប្រាស់ Scam ព័ត៌មានគណនីបង្ហាញពីទឹកប្រាក់ក្លែងក្លាយ ឬការចុចចូលតំណភ្ជាប់មិនស្គាល់ប្រភពពិត ជាអាទិ៍។

[310] Steve Smith, "10 Cyber Security Facts for 2023" [ហេតុការណ៍សន្តិសុខសាយប័រទាំង១០ឆ្នាំ២០២៣], *Devry University*, ២០២៣, https://www.devry.edu/blog/cyber-security-facts.html (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។

[311] Quishing, https://sosafe-awareness.com/glossary/quishing/ (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។

[312] Deepfakes, https://www.theguardian.com/technology/2020/jan/13/what-are-deepfakes-and-how-can-you-spot-them (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។ *ប្រភេទ Juice Jacking បច្ចេកទេសអនាមិកផ្តល់ឧបករណ៍ជំនួយឱ្យអ្នកប្រើប្រាស់។*

[313] Pegasus Hack, https://apnews.com/article/jordan-hacking-pegasus-spyware-nso-group-99b0b1e4ee256e0b4df055f926349a43 (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។ *[ករណីចោរបច្ចេកវិទ្យា ប្រគល់វត្ថុប្រើប្រាស់ចម្លែកៗ ដល់អ្នកប្រើប្រាស់]*

[314] CNBC, https://www.cnbc.com/2024/07/01/meta-accused-of-failing-to-comply-with-eu-antitrust-rules.html (ទស្សនាចុងក្រោយថ្ងៃទី៦ កក្កដា ២០២៤)។

ជារឿយៗកាលណាបើជួបបញ្ហារួច អាចចេះគិតទុកមុន ពិចារណា គឺតែងតែមានដំណោះស្រាយល្អជានិច្ច។ ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីជូនដំណឹង និងសារាចរណែនាំ ក៏ដូចជាគ្រប់សេនាធិការនានា ដល់ការការពារលើទិន្នន័យបុគ្គល, ឯកជនភាពបុគ្គល, សន្តិសុខទិន្នន័យ, មូលដ្ឋានទិន្នន័យជាតិ, និងរាល់ទ្រព្យសកម្មឌីជីថល។[315] កាលៈទេសៈតម្រូវការធ្វើបរិវត្តកម្មឌីជីថល ទាំងរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ចាំបាច់ត្រូវចេះទាញផលប្រយោជន៍ពីបច្ចេកវិទ្យា។ "ក្រៅពីកិច្ចធានាពីរដ្ឋាភិបាល ពលរដ្ឋគ្រប់រូបគឺត្រូវយល់ច្បាស់អំពីវិធានការពារពីបច្ចេកវិទ្យា និងអនុវត្តតាមបញ្ញត្តិបច្ចេកវិទ្យាប្រកបដោយក្រមសីលធម៌ និងស្មារតីទទួលខុសត្រូវ។"[316]

### ៤.២.១.២. យន្តការអប់រំ និងផ្សព្វផ្សាយ

កិច្ចការជំរុញឧគ្ឃោសនាស័ព្ទដោយផ្ទាល់តែម្យ៉ាង គឺពុំមានប្រសិទ្ធភាពទេ។ ស្របតាមគោលនយោបាយនៃរដ្ឋាភិបាលឌីជីថល ត្រូវមានភារកិច្ចយ៉ាងណាដើម្បីបញ្ជ្រាបប្រជាពលរដ្ឋខ្មែរ ផ្លាស់បរិបទមកជា **ពលរដ្ឋឌីជីថល** និងទទួលព័ត៌មាន ឬការជូនដំណឹងបែបឌីជីថល។ វិធីសាស្ត្រផ្សព្វផ្សាយឌីជីថល មានច្រើនរបៀប បែបបទ និងប្រភេទ។ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ផ្សព្វផ្សាយ ក្រៅពីក្នុងបណ្តាញសង្គមនានា គឺធ្វើតាម-រយៈគេហទំព័រផ្លូវការរបស់រាជរដ្ឋាភិបាលដូចជា៖ វេទិការដ្ឋាភិបាលឌីជីថល https://dgf.gov.kh , សមាគមឌីជី-ថលកម្ពុជា (DCC) https://dcc.gov.kh/login , និងថ្នាលទិន្នន័យរាយការណ៍សូចនាករស្ថិតិជាតិ (CamStat) https://camstat.nis.gov.kh ជាអាទិ៍។

វិធានការការពារទិន្នន័យបុគ្គល ជាពិសេស អត្តសញ្ញាណអនឡាញ(Online Credentials) ជាកត្តាសំខាន់ក្នុងដំណើរការសេវាសាធារណៈឌីជីថលទៅលើកម្មសិទ្ធិអចលនវត្ថុ ពិព្រោះ អាចគេចចេញពីកំណត់ត្រាដីធ្លីលើបុគ្គលក្លែងក្លាយ, ក្លែងអត្តសញ្ញាណសិទ្ធិនិងប្រភេទ, និងផ្លាស់ប្តូរព័ត៌មានកម្មសិទ្ធិករ។ វិធីសាស្ត្រសាមញ្ញៗ នៅពេលប្រជាពលរដ្ឋចាប់ផ្តើមប្រើប្រាស់សេវាអនឡាញគឺត្រូវ៖ ១.ចេះរក្សាពីសុវត្ថិភាពលើអ៊ីនធឺណិត និងសម្គាល់ពីការបោកប្រាស់បច្ចេកវិទ្យា, ២.បង្កើតលេខកូដសម្ងាត់ឱ្យរឹងមាំតាមការណែនាំ និងឧស្សាហ៍ផ្លាស់ប្តូរ (បើចាំបាច់), ៣.ត្រូវបន្ថែមរបាំងការពារសុវត្ថិភាពទិន្នន័យផ្ទាល់ខ្លួន 2FA-Two Fator Authentication បន្ថែមមួយជាន់ទៀតពីការទទួលសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់, ៤.មិនត្រូវបង្ហាញលេខសម្ងាត់ផ្ទាល់ខ្លួនទៅតតិយជន និងឧស្សាហ៍សំអាតទំហំផ្ទុកទិន្នន័យក្នុងឧបករណ៍ឆ្លាតវៃ, ៥.គោរពវិធាន CVE System ដែលជាវិធានងាយរង-គ្រោះ និងការបង្ហាញទូទៅតាមដំណាក់កាល នៅពេលអ្នកប្រើប្រាស់ពុំបានចាប់អារម្មណ៍អំឡុងពេលខុសប្រក្រតីនៃការបញ្ចូលព័ត៌មានផ្ទាល់ខ្លួន និងផ្ញើឯកសារណេបផ្លូវការទៅកាន់មន្ត្រីសាធារណៈ, គោរពវិធាន Capcha ក្រៅពីបង្កើតលេខកូដសុវត្ថិភាព និងព័ត៌មានជីវមាត្រ គឺអ្នកប្រើប្រាស់ត្រូវតែបំពេញតួពាក្យ ឬលេខខ្លីៗ ដែលក្រោយពីបញ្ជាក់សន្ទានកម្ម ដើម្បីឱ្យប្រព័ន្ធសេវាសាធារណៈអាចដឹងថាអ្នកប្រើប្រាស់មិនមែន Robot, និងឧស្សាហ៍តាម-ដានពីការជូនដំណឹងផ្សព្វផ្សាយរាល់កម្មវិធី ឬសេវាសាធារណៈឌីជីថលមួយណាដែលកំពុងប្រើប្រាស់។

---

[315] ច្បាប់អគ្រានុកូល២០២៣, មាត្រា១៥៩-១៦២។

[316] IIdar Begishev, "Review of the Monograph "Law of the Digital Environment" [ការពិនិត្យឡើងវិញនៃម៉ូណូក្រាម៖ ច្បាប់ស្តីពីបរិស្ថានឌីជីថល], *ResearchGate* (RUSSIA) DOI.10.21684/2412-2343-2023-10-1 (2023): 186-194។

### ៤.២.២. លទ្ធផលស្ទង់មតិសាធារណជន

លទ្ធផលនៃការស្ទង់មតិពីប្រជាពលរដ្ឋ បានផ្តល់ធាតុចូលសំខាន់ៗមួយចំនួនគួរឱ្យកត់សម្គាល់ ទាក់ទងនឹងការធ្វើបរិវត្តកម្មឌីជីថលលើការចុះបញ្ជីកម្មសិទ្ធិអចលនវត្ថុ។ នៅក្នុងចំណោម៤០គ្រួសារដែលបាន អង្កេតនៅ៥រាជធានី ខេត្ត[317] នាខែកក្កដា ឆ្នាំ២០២៤ លទ្ធផលបង្ហាញថាសមភាពយេនឌ័រលើភាព ជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យ គឺស្ថិតត្រឹមតែ៣៥% ប៉ុណ្ណោះ ធៀបនឹងកម្មសិទ្ធិករជាបុរស។ ចំណែកទំនាស់ដីធ្លីមាន៤១,៦៥%។ គួរកត់សម្គាល់ថា ភាគច្រើនប្រជាពលរដ្ឋមានទម្លាប់មិនសូវ ចូលចិត្តបំពេញឯកសារចុះបញ្ជីដីធ្លីដោយខ្លួនផ្ទាល់ ដោយហេតុតែខ្លាចខុស មិនចង់ឱ្យមានភាពស្មុគស្មាញ និងចំណាយពេលវេលាយូរ។ ជាក់ស្តែង ក្នុងចំណោមប្រជាជនដែលបានធ្វើអង្កេតខាងលើមានតែ១៥% ប៉ុណ្ណោះ ដែលបានបំពេញឯកសារដោយខ្លួនឯង។ តារាងខាងក្រោមបង្ហាញលទ្ធផលលម្អិតពីការស្ទង់មតិខាងលើ។ ទាក់ទងនឹងកម្រងសំណួរនៃការអង្កេត សូមមើលឧបសម្ព័ន្ធស្តីពីការស្ទង់មតិសាធារណជន។

| **កម្មវត្ថុ** | **ភាគរយគ្រួសារឆ្លើយតប**<br>(%) |
|---|---|
| ក.ភេទ (យេនឌ័រ=ស្ត្រីជាកម្មសិទ្ធិករ) | ៣៥% |
| ខ.ស្ថានភាពគ្រួសារ (មេគ្រួសារ) | ៧៣,៣៥% |
| គ.មានទំនាស់ដីធ្លី | ៤១,៦៥% |
| ឃ.បំពេញការស្នើសុំចុះបញ្ជីខ្លួនឯង | ១៥% |
| ង.ចុះបញ្ជីដោយផ្ទាល់<br>(ការិយាល័យ ដ.ន.ស.ភ /មន្ទីរ ដ.ន.ស.ស) | ៥៨,៣៥% |
| ច.ស្ថានភាពការចុះបញ្ជីផ្ទាល់ | ៥៣,៣៥% |
| ឆ.គិតគូរពីការចុះបញ្ជីអនឡាញ | ៩៣,៣៥% |
| ជ.ទំនុកចិត្តលើការចុះបញ្ជីអនឡាញ | ៧៣,៣៥% |

តារាង១៧៖ ការអង្កេត និងវាយតម្លៃមតិសាធារណជន

[317] រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងខេត្តព្រះសីហនុ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការផ្តល់សេវាសាធារណៈលើការចុះបញ្ជីដីធ្លីជោគជ័យ អាស្រ័យលើការប្តេជ្ញាចិត្តខ្ពស់ផ្នែកនយោបាយ។ ការចុះបញ្ជីលើកម្មសិទ្ធិអចលនវត្ថុ តែងតែកើតមានតម្រូវការ និងប្រែប្រួលជានិច្ចក្នុងសង្គមមូលធន។ ជាក់ស្តែង នៅកម្ពុជា គឺគិតមកដល់ម៉ោងនេះ ការចុះបញ្ជីដំបូងនៅមិនទាន់បានបញ្ចប់ទេ និងព្យាយាមការវាស់វែងចេញ បណ្តុបន្តបន្ទាប់នៃជំហានទី ០២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស)។ ល្បឿកនេះ ដើម្បីឱ្យស្របទៅតាមតម្រូវការ (កំណើនប្រជាជន, កាត់បន្ថយភាពក្រីក្រ, ស្តង់ដារនៃការរស់នៅ...) ចាំបាច់ និង ឯកជនភាវូបនីយកម្មពេញទីនៅកម្ពុជា ទាមទារឱ្យមានយុទ្ធសាស្ត្រ ផែនការនិងដំណោះស្រាយសមស្របពន្លឿន ដល់ការចុះបញ្ជីដីបង្ហើយ។

ការពឹងផ្អែកលើបច្ចេកវិទ្យាជំនួសឱ្យកិច្ចការរបស់មនុស្សទាក់ទងនឹងការចុះបញ្ជីដីធ្លីនៅកម្ពុជា ជាការចាំបាច់ សម្រាប់សតវត្សរ៍ទី២១។ កម្ពុជា ក៏បានចូលរួម និងបន្តអភិវឌ្ឍន៍លើផ្នែកបច្ចេកវិទ្យាតាមរយៈកិច្ចសហប្រតិបត្តិ-អន្តរជាតិ ដើម្បីត្រៀមខ្លួនឱ្យក្លាយទៅជាប្រទេសអភិវឌ្ឍន៍ និងប្រើប្រាស់បច្ចេកវិទ្យាទំនើប។ ការបញ្ជ្រាបបច្ចេក-វិទ្យាទៅក្នុងសេវាសាធារណៈរបស់រដ្ឋ ជាម៉ូឌុលមួយដែល អាចផ្លាស់ប្តូរស្ថានការណ៍ប្រជាជនឱ្យចូលចុះចំណោម ទាំងកម្រិតអាស៊ាន ក្នុងតំបន់ និងពិភពលោក។ ក្រោយពីទទួលរងវិបត្តិជំងឺសកលធ្ងន់ធ្ងរកូវីត១៩ រាជរដ្ឋាភិបាល កម្ពុជា បានទាញយកបច្ចេកវិទ្យាគំរូម៉ូដែលពីបរទេសជាច្រើន ជាពិសេស ពីបណ្តាសហភាពអឺរ៉ុប ដើម្បីឆ្លើយតប ផ្តល់សេវាសាធារណៈមួយចំនួនទៅដល់ប្រជាពលរដ្ឋពីចម្ងាយក្នុងអំឡុងពេលការបិទខ្ទប់មានការអប់រំ, ព័ត៌មាន, សុខាភិបាល, ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ។

បច្ចេកវិទ្យាមានអត្ថិភាពច្រើនទម្រង់ ប្រភេទ និងសំបូរបែបដោយមានតួនាទីរៀងៗខ្លួន អាស្រ័យលើតម្រូវការ ដែលចង់ទាញយកមកប្រើប្រាស់។ នៅកម្ពុជា ការទាញយកបច្ចេកវិទ្យាមកប្រើប្រាស់ក្នុងវិស័យដីធ្លី គឺពុំទាន់មាន ផលប្រយោជន៍សមប្រកបណាមួយទៅដល់កម្មសិទ្ធិករបានពេញលេញនោះទេ។ ភាពមិនច្បាស់លាស់ និងយឺត យ៉ាវលើសេវាសាធារណៈ គឺតែងតែបង្កឱ្យកើតមានជំងឺរលាកប្រស្រីភ្នែក និងដុំសាច់ក្នុងបំពង់កជានិច្ចដល់ប្រជា-ពលរដ្ឋ។ តួយ៉ាងដូចជា ការបន្ថែមវិវាទថ្មីលើវិវាទចាស់ វិវាទពុំទាន់ដោះស្រាយ និងវិវាទគ្មានដំណោះស្រាយ។ ជា សារវន្តនេះ វិស័យដីធ្លី ពិតជាត្រូវការវិធីសាស្ត្រនិងនីតិវិធីពីបច្ចេកវិទ្យា ដើម្បីឱ្យក្លាយជាម៉ូទ័រមួយចូលខ្លួនមកដោះ-ស្រាយលើបញ្ហាក្តីក្តាំងទាំងនេះ ជាពិសេស ការចុះបញ្ជីដំបូងលើកម្មសិទ្ធិអចលនវត្ថុ។ ការសិក្សាបច្ចេកវិទ្យាពីគំរូ ម៉ូដែលបរទេសពាក់ព័ន្ធវិស័យដីធ្លី គឺពុំមែនជារឿងងាយស្រួលនោះទេ ដែលយកមកអភិវឌ្ឍន៍បន្ថែមក្នុងស្រុក គឺ ព្យាយាមឱ្យមានការត្រិះរិះ វិភាគ និងពិចារណារាល់ប្រភេទថ្នាំណាមួយដែលសមស្របទៅនឹងប្រជាជនកម្ពុជា។

អត្តសញ្ញាណបុគ្គល និងការការពារទិន្នន័យបុគ្គល ឬឱ្យងាយយល់ គឺរាល់ព័ត៌មានអត្រានុកូលរបស់ប្រជា-ពលរដ្ឋ មិនខុសពីព័ត៌មានសម្រង់សុរិយោដី ដែលយកមកកត់ត្រាដោយដៃនៅលើក្រដាស អាចនឹងមានកំហុស ដោយអចេតនាពីមន្ត្រីកាន់កាប់បញ្ជី។ នេះត្រឹមជាបញ្ហាមួយ បើអនុវត្តបច្ចេកវិទ្យាក្នុងសេវាសាធារណៈ ចម្លើយគឺ បច្ចេកវិទ្យាឌីជីថល អាចដំណើរការដោយរលូនជាង ល្អជាង និងត្រឹមត្រូវជាងការប្រព្រឹត្តទៅដោយមនុស្ស។ ប៉ុន្តែ រាល់ដំណើរការបច្ចេកវិទ្យានេះ មិនមែនសុទ្ធតែវិជ្ជមានទាំងស្រុងទេ គឺទាមទារឱ្យមានវិធានការការពារនិរន្តរន៍។

# អនុសាសន៍

# អនុសាសន៍

គិតមកដល់ម៉ោងនេះ មនុស្សជាតិមិនអាចគេចផុតពីបញ្ញាសិប្បនិម្មិត (AI), បច្ចេកវិទ្យា ICT និងបច្ចេកវិទ្យាផ្សេងៗទៀតបានឡើយ ប៉ុន្តែ មនុស្សជាតិគឺអាចការការពារ និងទាញផលប្រយោជន៍ពីបច្ចេកវិទ្យាបានយ៉ាងមានប្រសិទ្ធភាព និងទំនួលខុសត្រូវ។ បរិបទនៅកម្ពុជា កំពុងរៀបចំ និងការប្រព្រឹត្តទៅលើរបៀបប្រើប្រាស់ថ្មីៗ សម្រប ពីបច្ចេកវិទ្យា និងនៅមិនទាន់អាចបែងចែកប្រភេទ ឬគោលដៅបានជាក់លាក់ ដោយសារអក្ខរកម្មឌីជីថល នេះបង្ហាញថា កម្ពុជាត្រូវការពេលវេលាច្រើនបន្ថែមទៀត ដើម្បីលត់ដំពីវិស័យអប់រំ។ ដោយសារកង្វះមូលធនមនុស្ស រាជរដ្ឋាភិបាលកម្ពុជា គួរជ្រើសរើសមន្ត្រីដោយគុណាធិបតេយ្យ ស្របតាមគុណវុឌ្ឍិ ដែលអាចបម្រើការដល់ផ្នែកបច្ចេកទេស-បច្ចេកវិទ្យាឌីជីថល។ គប្បីពង្រឹង និងបន្តដាក់ចេញគោលនយោបាយ បទប្បញ្ញត្តិពាក់ព័ន្ធ និងការអនុវត្តដែលបន្សុីទៅនឹងបរិវត្តកម្មឌីជីថល។ ទន្ទឹមនេះ បណ្តាក្រសួង ស្ថាប័នត្រូវមានស្មារតីឆន្ទៈ និងអភិក្រមបែបសហការអន្តរប្រតិបត្តិដល់ការពន្លឿនតាមផ្នែកនៃសេវាសាធារណៈ។ ក្រសួង ស្ថាប័ន គួរបន្តលើកទឹកចិត្ត និងជាកាតាលីករដល់ការស្រាវជ្រាវបច្ចេកវិទ្យាដែលសមស្របនឹងកម្ពុជា  និងបន្តទាញប្រមូលធាតុចូលដែលមានសារៈប្រយោជន៍ដល់សេវាសាធារណៈរបស់ខ្លួន ប្រកបដោយតម្លាភាព អព្យាក្រឹត និងប្រសិទ្ធភាព។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) គប្បីបន្តរៀនសូត្រ និងបណ្តុះបណ្តាលទៅដល់មន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋានដែលបំពេញមុខងារដល់ការចុះបញ្ជីដីធ្លី ក៏ដូចជាប្រជាពលរដ្ឋ ដែលមានតម្រូវ-ការលើការចុះបញ្ជីដីធ្លី ដោយព្យាយាមពន្យល់ អប់រំនិងផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថលបន្ថែម អំពីអក្ខរកម្មឌីជីថល សារៈសំខាន់បរិវត្តកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគ្រប់មធ្យោបាយ។ ការចុះបញ្ជីដីដំបូង ដោយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល គួរមានភាពច្បាស់លាស់លើការបង្កើត កែតម្រូវ ឬលុបពីដំណាក់កាលនីមួយៗដែលសំខាន់ និងបង្កដោយភាពងាយស្រួលទាំងអ្នកប្រើប្រាស់ និងមន្ត្រីកាន់កាប់បញ្ជី ដែលមានទម្រង់ឌីជីថល។ ដើម្បីឈានដល់ការចុះបញ្ជីដីធ្លីបង្ហើយ និងគ្មានវិវាទ គប្បីការរៀបចំប្រព័ន្ធមូលដ្ឋានទិន្នន័យ ត្រូវឱ្យមានសុវត្ថិភាពខ្ពស់ សណ្តាប់ធ្នាប់នៃអភិបាលកិច្ចឌីជីថល មិនត្រូវបង្ខំខ្លាំងពេកទាំងសមត្ថភាពនៅមានកម្រិត និងការប្រមូលផ្តុំនៃទិន្នន័យឱ្យមានលក្ខណៈប្រសើរឡើងទាំងការផ្តល់ ទទួល និងចែកចាយតាមសមត្ថកិច្ចដែលច្បាប់កំណត់។

រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនបទដ្ឋានគតិយុត្តដើម្បីការពារ  និងកែសម្រួលលើឥរិយាបថទាំងអ្នកបង្កើតគោលនយោបាយ, អ្នកស្រាវជ្រាវ, អ្នកអនុវត្ត, និងអ្នកប្រើប្រាស់លើប្រព័ន្ធឌីជីថលប្រកបដោយស្មារតីបុរេសកម្ម។ ដោយហេតុថា នៅពេលដែលក្រមសីលធម៌នៃការប្រព្រឹត្តទៅក្នុងបច្ចេកវិទ្យាកាន់តែខ្លាំង និងជឿនលឿន នោះវិបត្តិទទួលរងការវាយប្រហារពីបច្ចេកវិទ្យា ទាំងមិនបានព្រាងទុក អាចធ្វើឱ្យកម្ពុជាមានហានិភ័យបែបថ្មី ដែលពិបាកនឹងបរិយាយ។ ដោយមើលឃើញថា មិនត្រឹមតែហិរញ្ញវត្ថុនោះទេ គឺអចលនទ្រព្យ អាចក្លាយជាទ្រព្យសកម្មឌីជី-ថលនាពេលអនាគត នៅពេលដែលសេវាសាធារណៈឌីជីថលលើវិស័យដីធ្លី ទទួលបានជោគជ័យ។ កត្តានេះ គឺគ្រាន់តែបញ្ជាក់ស្មារតី ទាំងរាជរដ្ឋាភិបាល ទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស) ទាំងធុរជន និងទាំងប្រជាពលរដ្ឋ ត្រូវយល់ដឹងពីវិធីការពាររាល់ទិន្នន័យដែលជាកម្មវត្ថុនៅលើប្រព័ន្ធឌីជីថលរបស់ខ្លួនប្រកបដោយបរិយាបន្ន៕

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## កម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦។
ក្រមបរិស្ថាន និងធនធានធម្មជាតិ,លេខ នស/រកម/០៦២៣/០០៧, ២៩ មិថុនា ២០២៣។
ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/៣០, ៨ ធ្នូ ២០០៧។
ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល, លេខ នស/រកត/០៨២១/៥៦៤, ៧ សីហា ២០២១។
ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, លេខ នស/រកម/១១២០/០៣០, ១៤ វិច្ឆិកា ២០២០។
ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ២៤ ឧសភា ១៩៩៤។
ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២-០១១។
ច្បាប់ស្តីពីទូរគមនាគមន៍, លេខ នស/រកម/១២១៥/០១៧, ១៧ ធ្នូ ២០១៥។
ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, លេខ នស/រកម/០៣២៣/០០១, ១០ មីនា ២០២៣។
ច្បាប់ស្តីពីភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣១ សីហា ២០០១។
ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, លេខ នស/រកម/១១២១/០១៨, ១៨ វិច្ឆិកា ២០២១។
ច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ, លេខ នស/រកម/០២១៨/០០៣, ២៧ កុម្ភៈ ២០១៨។
ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១០២១/០១៤, ១៥ តុលា ២០២១។
ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩, ២ វិច្ឆិកា ២០១៩។
ច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៥២៣/០០៤, ១៦ ឧសភា ២០២៣។
ច្បាប់ស្តីពីស្ថិតិ, លេខ នស/រកម/១២១៥/០១៨, ២៤ ធ្នូ ២០១៥។
ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤, លេខ នស/រកម/១២២៣/០២២, ៧ ធ្នូ ២០២៣។
ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣។

## កម្រងអនុក្រឹត្យ

អនុក្រឹត្យស្តីពីការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងទិន្នន័យគាំពារសង្គម, លេខ៣៨អនក្រ.បក, ២០ កុម្ភៈ ២០២៤។
អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល, លេខ៤៤អនក្រ.បក, ១ មីនា ២០២៤។

អនុក្រឹត្យស្តីពីនីតិវិធីគ្រប់គ្រង និងអនុវត្តថវិកាសម្រាប់យុទ្ធនាការជំរុញការចុះបញ្ជីដីធ្លីលើកដំបូងដែលមានលក្ខណៈជាប្រព័ន្ធ, លេខ១៥៨អនក្រ.បក, ១៥ កក្កដា ២០២៤។

អនុក្រឹត្យស្តីពីការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា, លេខ២០៧អនក្រ.បក, ២៦ កក្កដា ២០២៣។

អនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់ថ្នាលផ្ទៀងផ្ទាត់ឯកសារ Verify.gov.kh, លេខ៥២អនក្រ.បក, ៣ មីនា ២០២៣។

អនុក្រឹត្យស្តីពីការបង្កើត និងបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ១៣៥អនក្រ.បក, ២២ មិថុនា ២០២៣។

អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល, លេខ១១៣អនក្រ.បក, ១ មិថុនា ២០២៣។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១៣៩អនក្រ.បក, ២៦ មិថុនា ២០២៣។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, លេខ៨១អនក្រ.បក, ១៩ មេសា ២០២២។

អនុក្រឹត្យស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល, លេខ២៥២អនក្រ.បក, ២២ ធ្នូ ២០២១។

អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត, លេខ២៨៧អនក្រ.បក, ៣១ ធ្នូ ២០២១។

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ, លេខ២៣អនក្រ.បក, ១៦ កុម្ភៈ ២០២១។

អនុក្រឹត្យស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, លេខ១៦៤អនក្រ.បក, ២៤ សីហា ២០២១។

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, លេខ២២០អនក្រ.បក, ១១ វិច្ឆិកា ២០២១។

អនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត, លេខ២៥អនក្រ.បក, ៩ មីនា ២០២០។

អនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, លេខ៨៤អនក្រ.បក, ១០ មិថុនា ២០២០។

អនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ១៨អនក្រ.បក, ៨ កុម្ភៈ ២០១៧។

អនុក្រឹត្យស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន, លេខ១១០ អនក្រ.បក, ២១ កក្កដា ២០១៧។

អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល, លេខ២៤៦អនក្រ.បក, ២៩ ធ្នូ ២០១៧។

អនុក្រឹត្យស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី, លេខ១៧ អនក្រ.បក, ១ កុម្ភៈ ២០១៦។

អនុក្រឹត្យស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្រ.បក, ៣១ ឧសភា ២០០២។ និងអនុក្រឹត្យស្ដីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១អនក្រ.បក, ៩ មិថុនា ២០១៦។

អនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ, លេខ១៨១អនក្រ.បក, ២៣ ធ្នូ ២០១៥។

អនុក្រឹត្យស្ដីពីនគរូបនីយកម្មរាជធានីក្រុង និងទីប្រជុំជន, លេខ៤២អនក្រ.បក, ៣ មេសា ២០១៥។ និងអនុក្រឹត្យស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី៣ មេសា ២០១៥ ស្ដីពីអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានីក្រុង និងទីប្រជុំជន, លេខ៧៦អនក្រ.បក, ៩ មិថុនា ២០១៥។

អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ, លេខ១០៨អនក្រ.បក, ១៨ មីនា ២០១៣។

អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ៧៧អនក្រ.បក, ៧ មិថុនា ២០១២។

អនុក្រឹត្យស្ដីពីការគ្រប់គ្រងបុរី, លេខ៣៩អនក្រ.បក, ១០ មីនា ២០១១។

អនុក្រឹត្យស្ដីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់, លេខ៧២អនក្រ.បក, ៥ ឧសភា ២០០៩។

អនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ, លេខ១១៨អនក្រ.បក, ៧ តុលា ២០០៥។

អនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ.បក, ៣១ ឧសភា ២០០២។

អនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ.បក, ២០ កក្កដា ១៩៩៩។

**កម្រងប្រកាស**

ប្រកាសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ស្ដីពីស្តង់ដារកម្ពុជា ផ្នែកឌីជីថលចំនួន៣ស្តង់ដារ, លេខ០៤៦ MISTI/០២១, ៥ កុម្ភៈ ២០២១។

ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការផ្ដល់ប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីការផ្ដល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក, លេខ១៤១៥សហវ.ប្រក, ២២ ធ្នូ ២០១៩។

ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការផ្ដល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក, លេខ១៤១៤សហវ.ប្រក, ២៤ ធ្នូ ២០១៩។

ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, លេខ៣៥៦សហវ.ប្រក, ២៦ មីនា ២០១៩។

ប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការផ្ដល់សេវាធារណៈរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, លេខ៤៩៨សហវ.ប្រក, ៨ ឧសភា ២០១៨។

ប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី, លេខ២១៥ប្រក/ដនស.មផ, ៩ កញ្ញា ២០០៥។ និងប្រកាសអន្តរ-ក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការកែសម្រួលប្រការ៩, លេខ១៥៩ប្រក/ដនស.មផ, ១៥ មិថុនា ២០១៦។

ប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលសហការចុះបញ្ជីដីរដ្ឋ និងកសាងផែនទីដីឯកភាពតែមួយសំដៅបង្កើនប្រសិទ្ធភាពការគ្រប់គ្រង ដីរដ្ឋ, លេខ១៧៨ដនស, ២៧ តុលា ២០១៤។

ប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ៥៩ប្រ.ក.ដ.ន.ស/១១, ៣ ឧសភា ២០១១។

ប្រកាសអន្តរក្រសួងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ និងការធ្វើចំណាត់ការដីរដ្ឋ, លេខ៤២ដនស.បក, ១០ មីនា ២០០៦។

ប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីការកំណត់ ចំនួន ឈ្មោះ និងព្រំប្រទល់ឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រ-កម្ពុជា, លេខ៤៩៣ប្រ.ក, ៣០ មេសា ២០០១។

ប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ, លេខ៧៦ប្រក/ដ.ន.ស, ១២ កញ្ញា ១៩៩៩។

**កម្រងសារាចរ**

សារាចរណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការអនុវត្តនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១៤ដនស/សរណន, ៣០ កញ្ញា ២០០៩។

សារាចរណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីគោលការណ៍ និងនីតិវិធីចុះបញ្ជីដីបំពេញបន្ថែម, លេខ០៦ស.ណ.ន, ៥ ឧសភា ២០០៦។

សារាចរណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ, លេខ០១ដនស/អកគដ/សរណន, ២១ កញ្ញា ២០០៥។

សារាចរណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោ-ដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ), លេខ០០១ដនស/សជ, ១៩ សីហា ២០០២។

**កម្រងសេចក្តីណែនាំ**

សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួងស្ថាប័ន, លេខ០១សណន, ២១ ឧសភា ២០២៤។

សេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់លិខិតរដ្ឋបាល តាមរយៈកម្មវិធីរដ្ឋបាលអេឡិច-ត្រូនិកពន្ធដារ, លេខ១១៩៣៦អពដ, ២១ មីនា ២០២៣។

សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការចុះបញ្ជីក្បាលដីទំនាស់ដែលត្រូវដោះស្រាយចប់ជាស្ថាពររួចហើយ, លេខ០២១ដនស/អសភ, ២៦ ឧសភា ២០១២។
សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី, លេខ១១ស.ណ.ន, ២១ កក្កដា ២០០៦។
សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីវិធានការធានាសុវត្ថិភាពនៃឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital, លេខ៩៥អ/សដភ, ២៣ ឧសភា ២០០៦។
សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការចុះបញ្ជីដីបន្ត, លេខ០២ដនស/សដ, ២៨ ឧសភា ២០០៤។

**កម្រងសេចក្តីជូនដំណឹង និងសេចក្តីសម្រេច**

សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីលទ្ធផលវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩, លេខ១២៧២សជណ.អកទ, ២២ វិច្ឆិកា ២០២៣។
សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការផ្ទៀងផ្ទាត់ទិន្នន័យអតីតមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ មន្ត្រីនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទដែលត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌ, លេខ៧៤សសរ, ១១ មេសា ២០២៤។
សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជំរុញ និងគាំទ្រសេដ្ឋកិច្ចឌីជីថល និងរៀបចំកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថល, លេខ៥១សសរ, ១១ កក្កដា ២០២៣។
សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុញ្ញាតឱ្យមជ្ឈមណ្ឌលធុរកិច្ចថ្មី "តេជោ" ជាប្រតិបត្តិករថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, លេខ១០១សហវ, ២៨ កក្កដា ២០២២។
លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីតម្រូវការនៃគំនូសប្លង់ទីតាំងដីសម្រាប់បំពេញបែបបទផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជី, លេខ១៩៧៤ដនស/អសដក, ១៦ សីហា ២០១៨។

**សេចក្តីព្រាងច្បាប់**

សេចក្តីព្រាងច្បាប់ស្តីពីភូមិបាល, ២៧ ធ្នូ ២០២៣។

**គោលនយោបាយ**

រាជរដ្ឋាភិបាលកម្ពុជា, គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២០២៤។
___, ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា២០២៤-២០៣៥, ខែមករា ឆ្នាំ២០២៤។
___, "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពៈ កសាង មូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, ខែសីហា ឆ្នាំ២០២៣។
___, ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០, ២៦ កក្កដា ២០២១។
កម្មវិធីនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៧, សម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ ២០២៣-២០២៨, រដ្ឋសភាជាតិ, ខែសីហា ឆ្នាំ២០២៣។
គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨របស់រាជរដ្ឋាភិបាលកម្ពុជា (រៀបចំដោយគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល), ខែកក្កដា ឆ្នាំ២០២៣។

គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥, អនុម័តថ្ងៃទី២៨ មករា ២០២២។
ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ របស់រាជរដ្ឋាភិបាលកម្ពុជា, ខែឧសភា ឆ្នាំ២០២១។
គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ឆ្នាំ២០២០-២០៣០, ១៣ ធ្នូ ២០១៩។
គោលនយោបាយ "ស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ" របស់រាជរដ្ឋាភិបាលកម្ពុជា, ២៤ តុលា ២០១៧។
គោលនយោបាយជាតិប្រជាជន២០១៦-២០៣០ របស់រាជរដ្ឋាភិបាលកម្ពុជា, ៤ មីនា ២០១៦។
គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី" របស់រាជរដ្ឋាភិបាលកម្ពុជា, ២៨ សីហា ២០១៥។
គោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យរបស់រាជរដ្ឋាភិបាលកម្ពុជា, ៣០ ឧសភា ២០១៤។
គោលនយោបាយជាតិស្តីពីលំនៅឋានរបស់រាជរដ្ឋាភិបាលកម្ពុជា, ៩ ឧសភា ២០១៤។
គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជារបស់រាជរដ្ឋាភិបាលកម្ពុជា, ៨ មេសា ២០១១។
គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី, ២៤ មេសា ២០០៩។
គោលនយោបាយស្តីពីការគ្រប់គ្រងដីរដ្ឋ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រុមការងារគ្រប់គ្រងដីរដ្ឋ, ២៣ វិច្ឆិកា ២០០៥។
ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី៖ ឯកសារបឋមរបស់រាជរដ្ឋាភិបាលកម្ពុជា, ៦ កញ្ញា ២០០២។

**ទិនានុប្បវត្តិ**

Chen, ChunXi, He Zhang, Kunli Jiang, and others. "Research on Evaluation Method of Real Estate Registration Data Quality" [ការស្រាវជ្រាវលើវិធីសាស្ត្រវាយតម្លៃគុណភាពនៃទិន្នន័យចុះបញ្ជីអចលនវត្ថុ]. *The International Archives of The Photogrammetry* Volume XLIII-B3-2021edition XXIV ISPRS (2021): 749។

Feng, Yougui, Xing, Zhurong, Ze, Han, and others. "Research on the new Method of Real Estate Integration Confirmation and Registration Based on small Program App" [ការស្រាវជ្រាវទៅលើវិធីសាស្ត្រថ្មីចំពោះអចលនវត្ថុលើការរួមបញ្ចូល ការបញ្ជាក់ និងការចុះបញ្ជីផ្អែកនៅលើកម្មវិធី៖ ថ្នាលតូច]. *Journal of Physics: Conference Series* (China) DOI:10.1088/1742-6596/1757/1/012167, ICCBD-AI (2020)។

Gertrude Pieper. "Developing a Land Registration System using a Compromise between the Implementation of International Standards and Adaptation to Local Circumstances: The Cambodian Experience" [ការបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លីដោយប្រើសម្របរវាងការអនុវត្តស្តង់ដារអន្តរជាតិ និងលក្ខណៈក្នុងតំបន់៖ បទពិសោធន៍កម្ពុជា]. *ResearchGate HK* (Netherland) TS8A (April, 2010)។

Hem, Sras. "The Land Registration Process in Cambodia: Background, Procedure, and Outcomes" [ដំណើរការចុះបញ្ជីដីធ្លីនៅកម្ពុជា៖ ប្រភព នីតិវិធី និងលទ្ធផល]. *J.Int.Stud.* 3 (2019): 5-31។

Jeffrey s, Brand. “Cambodia Property Law” [នីតិទ្រព្យសម្បត្តិកម្ពុជា]. Khmer Version4k, *Faculty of Public Management in Cooperation with The University of San Francisco Project to Strengthen the Faculty of Business,* (Phnom Penh) (1998)។

Kate Dalrymple. “Expanding Rural Land Tenures to Alleviate Poverty” [ការពង្រីកកាន់កាប់ដីធ្លីជនបទដើម្បីកាត់បន្ថយភាពក្រីក្រ]. *PhD Thesis* University of Melbourne (Australia) (2005)។

Li, Xuexiang, Bian, Fulin, and Shi, Yongge. “System Integration of Digital Real Estate-Management Based on Service” [ប្រព័ន្ធរួមបញ្ចូលនៃការគ្រប់គ្រងអចលនវត្ថុផ្អែកលើសេវាកម្មឌីជីថល]. *ELSEVIER* DO I:10.1016/j.phpro.2012.02.151, *Wuhan Hubei Province* (China) Physics Procedia 24, 10-12-1017 (2012)។

Mendi, Arif Furkan, and Alper Çabuk. “Blockchain Applications in Geographical Information Systems” [សំណើប្លុកឆេននៅក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ]. *Photogrammetric Engineering & Remote Sensing* Article January (2020)។

Milon, Biswas, Jabed Al Faysal. “LandChain: A Blockchain Based Secured Land Registration System” [LandChain ប្រព័ន្ធនៃការចុះបញ្ជីដីធ្លីដោយសុវត្ថិភាពផ្អែកលើប្លុកឆេន]. *Research Gate* (USA) DOI:10. 1109/ ICSCT53883.2021.9642505 (December, 2021)។

P, Tikhon Podshivalov. “Improving implementation of the Blockchain technology in real estate registration” [ការកែលម្អអនុវត្តបច្ចេកវិទ្យាប្លុកឆេនក្នុងការចុះបញ្ជីអចលនទ្រព្យ]. *Elsevier ScienceDirect* (Russia) Volume 33 Issue 2 (October, 2022)។

Panthukala, Chentan Anand, Supriya Chitari, Yeleboina Venkata Charan Teja, and others. “Online Land Registration using Blockchain” [ការចុះបញ្ជីដីធ្លីអនឡាញដោយប្រើប្រាស់ប្លុកឆេន]. *International Journal for Research in Applied Science & Engineering Technology (IJRASET)* (India) ISSN:2321-9653; IC Value: 45.98; SJ Impact Factor: 7.538. Volume 10 Issue VI June (2022)។

Park, Kwang Dong. “Digital Real-Estate Registration System in Korea for Supporting Legal Exchange” [ប្រព័ន្ធចុះបញ្ជីអចលនទ្រព្យឌីជីថលក្នុងប្រទេសកូរ៉េសម្រាប់គាំទ្រការផ្លាស់ប្តូរផ្លូវច្បាប់]. (South Korea) (30-10-2009)។

Rodima-Taylor, Daivi. “Digitalization land administration: The geographies and the temporalities of infrastructural promise”[ការគ្រប់គ្រងដីធ្លីឌីជីថលូបនីយកម្ម៖ ភូមិសាស្ត្រ និងកិច្ចព្រមព្រៀងនៃហេដ្ឋារចនាសម្ព័ន្ធបណ្ដោះអាសន្ន]. *Elsevier ScienceDirect* (US) Volume 122 p.140-151 (June, 2021)។

Sarath, Krishnapriya, and Greenshma Sarath. “Securing Land Registration using Blockchian” [កិច្ចធានាការចុះ បញ្ជីដីធ្លីដោយប្រើប្រាស់ប្លុកឆេន]. *Elsevier* (India) 171-1708-1715 (2020)។

Sumedh, Janbandhu, Dura j Saindane, Rohit Jadhav, and others. “Land Registration & Transfer of Entitlement using Blockchain” [ការចុះបញ្ជីដីធ្លី និងសិទ្ធិផ្លាស់ប្តូរដោយការប្រើប្លុកឆេន]. *International Journal for Research in Applied Science & Engineering Technology (IJRASET)* (India) ISSN:2 321-9653; IC Value: 45.98; SJ Impact Factor: 7.538. Volume 11 Issue III (Mar, 2023)។

Tembo, Emmanuel, and Boipuso Nkwae. “Land Registration in a Digital Environment” [ការចុះបញ្ជីក្នុងបរិយាកាសឌីជីថល]. *FIG Congress* (Botswana and Malaysia) 6786 (2014)។

Toyin, Lawal, Belay Alem, and Nawari Nawari. “Geospatial Blockchain for Land Registration and Cadastral Data Management using Geographical Information System - A Theoretical Framework”

[ប្លុកឆេនលើភូមិភាគសម្រាប់ការចុះបញ្ជីដីធ្លី និងការគ្រប់គ្រងទិន្នន័យរួមស៊ុវិយាដី ដោយការប្រើប្រាស់ព័ត៌មានភូមិសាស្ត្រ៖ ក្របខណ្ឌទ្រឹស្តី]. *ResearchGate* (USA) 368346802 (November, 2022)។

United Nation. "Seizing the of Opportunities of Safe, secure and Trustworthy Artificial Intelligence Systems for Sustainable Development" [ការចាប់យកនៃប្រព័ន្ធបញ្ញាសិប្បនិម្មិតដែលមានសុវត្ថិភាព និងទំនុកចិត្តសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព]. *General Assembly* 24-04670(E) 180324, A/78/L.49 (2024)។

Wang, Danyue. "The Information Management of Real Estate Registration Under the Background of Big Data" [ការគ្រប់គ្រងព័ត៌មាននៃការចុះបញ្ជីអចលនវត្ថុក្រោមប្រភពទិន្នន័យធំ ឬទិន្នន័យគោល]. *Academic Journal of Science and Technology* ISSN:2771-3032|Vol.3, No.3 (2022)។

World Bank. "Registering Property: The paths of Digitization" [ការចុះបញ្ជីអចលនទ្រព្យ៖ វិថីនៃការធ្វើឌីជីថល]. *eLibrary* DOI:10.1596/978-1-4648-0667-4, Published October (2015)។

**វេបសាយ និងបណ្ដាញសោតទស្សន៍ដោយឡែក (បានចង្អុលបង្ហាញលម្អិតតាមបណ្ដាក្រោមទំព័រ)**

Koem Bunthoeun. *ក្រុមហ៊ុន Google ប្រកាសគាំទ្រវេទិកាបច្ចេកវិទ្យា Cambodia Tech Catalyst 2024 ដែលរៀបចំលើកដំបូងនៅកម្ពុជា*. ២០២៤, https://business-cambodia.com/articles/cambodia-tech-catalyst-2024- (ទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២៤)។

World Bank. *Cambodia - Third Land Allocation for Social and Economic Development Project (LASED III): Fact Sheet (English)*. ២០២១, https://documents.worldbank.org/en/publication/ documents-reports/documentdetail/872911608199117198/cambodia-third-land-allocation-for-social-and-economic-development-project-lased-iii-fact-sheet (ទស្សនាចុងក្រោយថ្ងៃទី៩ ឧសភា ២០២៤)។

___. *Subnational studies: Registering Property.* *https://subnational.doingbusiness.org/en/data/exploretopics/registering-property/what-measured* [និងមានករណីសិក្សានៃព្រះរាជាណាចក្រដាណឺម៉ាក] (ទស្សនាចុងក្រោយថ្ងៃទី២៣ ឧសភា ២០២៤)។

ហ៊ុន ម៉ាណែត. សុន្ទរកថានៅក្នុងពិធីសន្និបាតប្រចាំឆ្នាំលើកទី៨០ របស់គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី-ប៉ាស៊ីហ្វិក(ESCAP) នាទីក្រុងបាងកក. ថ្ងៃទី២២ មេសា ២០២៤, https://dap-news.com/national/2024/04/22/409307/ (ទស្សនាចុងក្រោយថ្ងៃទី១២ ឧសភា ២០២៤)។

សែន ដាវីត. អត្រាអក្ខរកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់. *Khmer Times*, ២០២១, https://www.khmertimeskh.com/50808243 (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ហាប់ ផល្ធី. "បញ្ហានានាពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជាបច្ចុប្បន្ន ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០." រកបាននៅ៖ https:// phalthy.files.wordpress.com/2006/11/issues-related-to-lands-of-cambodia-history-of-land1.pdf (ទស្សនាចុងក្រោយថ្ងៃទី៥ វិច្ឆិកា ២០២៣)។

## វេបសាយ និងបណ្ដាញសោតទស្សន៍នានាពាក់ព័ន្ធរាជរដ្ឋាភិបាលកម្ពុជា និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល


Form KH, ឆ្នាំ២០២៣, https://form.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

Go gov.kh, ឆ្នាំ២០២៣, https://form.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

Techo Startup Center AI, ឆ្នាំ២០២៣, https://ai.techostartup.center/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

Verify.gov.kh, ឆ្នាំ២០២២, https://verify.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

កម្ពុជាមាតុភូមិខ្ញុំ, ឆ្នាំ២០២៣, https://cmhl.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCert), ឆ្នាំ២០១០-២០២៣, https://www.cam cert.gov.kh/ws-cybersecuritycybercrime/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល, ឆ្នាំ២០២៣, https://digitaleconomy.gov.kh/index (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, ឆ្នាំ២០២៣, https://dgc.gov.kh/about (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ថ្នាល CamDigiKey, ឆ្នាំ២០២០, https://camdigikey.gov.kh/kh (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជាCamDX, ឆ្នាំ២០២០, https://monitoring.camdx.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

និយ័តករទូរគមនាគមន៍កម្ពុជា, ឆ្នាំ២០២២, https://trc.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ប្រព័ន្ធផ្ដល់សេវាសាធារណៈឌីជីថល, ឆ្នាំ២០២២, https://service.mptc.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលធុរកិច្ចថ្មី"តេជោ", ឆ្នាំ២០១៨, https://techostartup.center/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

វេទិការដ្ឋាភិបាលឌីជីថល (DGF), ឆ្នាំ២០២៤, https://dgf.gov.kh (ទស្សនាចុងក្រោយថ្ងៃទី៣ មេសា ២០២៤)។

សេវាចុះឈ្មោះដែនជាតិ.kh, ឆ្នាំ២០២២, https://www.domain.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ឆ្នាំ២០២២, https://registrationservices.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

ស្វែងរកប្រព័ន្ធព័ត៌មានអំពីក្បាលដី, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ឆ្នាំ២០២៣, https://mlmupc.gov.kh/electronic-cadastral-services/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឆ្នាំ២០២៣, https://itd.mef.gov.kh/ (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

អគ្គនាយកដ្ឋានពន្ធដារ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឆ្នាំ២០២៣, https://www.tax.gov.kh ឬតាមរយៈ

https://t.me/gdtcambodianews (ទស្សនាចុងក្រោយថ្ងៃទី១២ តុលា ២០២៣)។

## សៀវភៅ និងឯកសារនានា

ALwaalan, Lateefa and other teams. “Industry Map: FinTech Ecosystem in Saudi Arabia” [ផែនទីសហគ្រាស៖ បច្ចេកវិទ្យាអេកូស៊ីស្ទែមហ្វីនតិចក្នុងអារ៉ាប់ប៊ីសាអូឌីត]. *Endeavor,* Saudi Arabia, 2022។

D-T Global Business Consulting. “Digital Transformation in Russia: Keeping Competitive” [ការផ្លាស់ប្តូរឌីជីថលក្នុងប្រទេសរុស្ស៊ី៖ បន្តការប្រកួតប្រជែង], Vienna Austria, 2019។

Digital Convergence USP2030. “Talking Interoperability: In focus Cambodia” [កិច្ចបរិយាយចំពោះអន្តរប្រតិបត្តិការ៖ ផ្តោតសំខាន់ក្នុងប្រទេសកម្ពុជា]. *Conference,* Phnom Penh Cambodia, 2022។

Gray, Catriona and Dr Robert H Wortham. “AI Governance and Assurance Global Trends 2023-24” [អភិបាលកិច្ចបញ្ញាសិប្បនិម្មិត និងការធានានិន្នាការកិច្ចសកលឆ្នាំ២០២៣-២០២៤]. *AI Assurance Club* Paper represents AI Global, 2024។

Ramamurthy, Bhargavi, ស៊ិក បូរ៉ក្ស, Per Ronnas និងសុខ ហាច. "ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០ការផ្តោតលើបញ្ហាដីធ្លី កម្លាំងពលកម្មនិងការចិញ្ចឹមជីវិតនៅជនបទ". ឯកសារពិភាក្សាលេខ២១, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ, ២០០២។

Taing, Nguonly. “Cambodia Data Exchange (CamDX).” *Dissemination Workshop on Cambodia Digital Government Policy 2022-2035,* Cambodia, 31 Mar 2022។

Techo Startup Center. “Startup Cambodia Insight 2023” [យល់ដឹងការបណ្តុះធុរកិច្ចថ្មីនៅកម្ពុជាឆ្នាំ២០២៣]. *Digital Platform: Ecosystem*, 2024។

___. “Year in Review 2023” [ទិដ្ឋភាពធុរកិច្ចថ្មីក្នុងឆ្នាំ២០២៣]. *Digital Platform*, 2024។

The Association of Southeast Asian Nations. “ASEAN Digital Masterplan 2025” [ផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥]. *Conference,* Jakarta Indonesia, 2021។

Thoin, Serge. “Watching Cambodia: Ten Paths to Enter the Cambodia Tangle” [ទស្សនីយភាពកម្ពុជា៖ មាគ៌ាទាំង១០ ដើម្បីជ្រៀតជ្រែកកម្ពុជា]. (1942), 1st edition, *White Lotus,* Bangkok Thailand, 1993។

UNECE, FAO, FIG. “Digital Transformation and Land Administration” [បរិវត្តកម្មឌីជីថល និងរដ្ឋបាលដីធ្លី]. *FIG Publication* No.80, Rome 2022។

WTO. “World Trades Statistical Review2023” [ទិដ្ឋភាពស្ថិតិពាណិជ្ជកម្មពិភពលោកឆ្នាំ២០២៣]. *Publication* 2023។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់. *បញ្ជីវាយនាមភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា*, ខែតុលា ឆ្នាំ២០២៣។

___. *សៀវភៅណែនាំប្រតិបត្តិស្តីអំពីការអនុវត្តគម្រោងបែងចែកដីធ្លី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*, ខែកញ្ញា ឆ្នាំ២០១០។

___. *សៀវភៅណែនាំបទដ្ឋានបច្ចេកទេសលំនៅឋានសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម និងប្រាក់ចំណូលទាប,* ២០១៨។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. *ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍,* ២០២២។

___. *ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣,* ខែកុម្ភៈ ឆ្នាំ២០២៤។

___. *ថវិកាសង្ខេបឆ្នាំ២០២២.* នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា, ២០២៣។

___. *ថវិកាសង្ខេបឆ្នាំ២០២៣.* នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា, ២០២៤។

___. *វិធាន និងនីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា.* CamDX៖ ២០២២។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍. *ឧស្សាហូបនីយកម្មកម្ពុជា៖ ចាប់យកភាពឈានទៅមុខនៃបច្ចេកវិទ្យាសម្រាប់សហគ្រាស,* ខែកក្កដា ឆ្នាំ២០២៣។

គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល. *ក្របខណ្ឌតាមដាន វាយតម្លៃសេដ្ឋកិច្ច និងធុរកិច្ចឌីជីថលនៅកម្ពុជា,* ២០២៣។

___. *ផែនការសកម្មភាព៣ឆ្នាំរំកិល ២០២៤-២០២៦៖ គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា,* ២០២៤។

ចម ប្រសិទ្ធ. *វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០២១.* ភ្នំពេញ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ៤ ឧសភា ២០២២។

ឆាន់ សាផាន. *របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ ២០២៣ និងលើកទិសដៅការងារបន្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់.* លេខ០២២ដនស/អរប/នរប/របា. ភ្នំពេញ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ៧ កក្កដា ២០២៣។

ជា សុផារ៉ា. *របាយការណ៍ស្តីពីសមិទ្ធផលសង្ខេបរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៨ - ដំណាច់ខែកញ្ញា ឆ្នាំ២០២២) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់.* លេខ០៥០ដនស/អរប/នរប/របា. ភ្នំពេញ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២៤ វិច្ឆិកា ២០២២។

___. *របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារបន្តឆ្នាំ២០២៣របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់.* លេខ០០២ដនស/អរប/នរប/របា. ភ្នំពេញ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ៩ មករា ២០២៣។

ថោ សេដ្ឋាណា."ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ." ក្រសួងមុខងារសាធារណៈ, បទបង្ហាញក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅបន្តការងារឆ្នាំ២០២៤, ខែមេសា ឆ្នាំ២០២៤។

ថេង ច័ន្ទសង្វារ. "ការងារសុរិយោដី." ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, បទបង្ហាញសម្រាប់សិស្សមេធាវីជំនាន់១៩, ២០២៣។

___. "ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតស្នាមរដ្ឋបាល." ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, បទបង្ហាញសម្រាប់វគ្គបណ្តុះបណ្តាលជូនជំនួយការ អ្នកហាត់ការ, ខែវិច្ឆិកា ឆ្នាំ២០២៣។

___. "សេចក្តីព្រាងច្បាប់ភូមិបាលថ្មី៖ត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣." ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, បទបង្ហាញសម្រាប់ទាញធាតុចូលពីនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ, ខែកុម្ភៈ ឆ្នាំ២០២៤។
ទ្រី ហ៊ាង. "វិវាទដីធ្លីនៅកម្ពុជា២០០១-២០០៩." និក្ខេបបទបណ្ឌិត, រាជបណ្ឌិត្យសភាកម្ពុជា, ២០១២។
ធនាគារជាតិនៃកម្ពុជា. *របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣,* ៣០ ខែមករា ឆ្នាំ២០២៤។
នាង ម៉ៅ. "រដ្ឋាភិបាលឌីជីថល." ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ស្លាយបទបង្ហាញ, ១៧ ធ្នូ ២០២១។
ព្រុំ ទេវី. *ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល៖ បទពិសោធន៍ និងបញ្ហាប្រឈមក្នុងការសិក្សាស្រាវជ្រាវ និង បង្ហាត់បង្រៀន,* រាជបណ្ឌិត្យសភាកម្ពុជា។
រាជរដ្ឋាភិបាល.*របៀបវារៈស្រាវជ្រាវជាតិ២០២៥.* ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ២០២៣។
___. *បរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធគាំពារសង្គមផែនការយុទ្ធសាស្ត្រ.* ក្រុមប្រឹក្សាជាតិគាំពារសង្គម, ២០២៤។
វង់សំអូន. *ការកំណត់បញ្ហាប្រធានបទសិក្សាស្រាវជ្រាវចេញពីភាពខ្វះចន្លោះក្នុងការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ.* រាជបណ្ឌត្យិសភាកម្ពុជា៖ ឯកសារផ្សព្វផ្សាយ, ខែមេសា ឆ្នាំ២០២៤។
សៀក វណ្ណា. "ចំណុចសំខាន់ៗនៃច្បាប់គ្រប់គ្រងអចលនវត្ថុ." ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ស្លាយបទបង្ហាញ, ១៨ វិច្ឆិកា ២០២៣។
សាន វឌ្ឍនា. "ការអប់រំឌីជីថល៖ បរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ." ក្រសួងអប់រំ យុវជន និង កីឡា, មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថលនិងការអប់រំពីចម្ងាយ, ២០២១។
សមាគមសាលាត្រាជូ. *ព្រឹត្តិបត្រច្បាប់សាលាត្រាជូ.* លេខទី៥, ខែមិថុនា ឆ្នាំ២០២៣។
អ៊ុកចាយ បញ្ញារ៉ា. "ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម២០១៧-២០២៦." អគ្គនាយកដ្ឋានអត្ត-សញ្ញាណកម្មនៃក្រសួងមហាផ្ទៃ, ស្លាយបទបង្ហាញ, ៣១ មីនា ២០២២។
អគ្គនាយកដ្ឋានពន្ធដាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. *ព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣,* លេខ ០៨, ខែតុលា-ធ្នូ ឆ្នាំ២០២៣។
___. *ផែនការយុទ្ធសាស្ត្រអគ្គនាយកដ្ឋានពន្ធដារឆ្នាំ២០២៤-២០២៨,* ២០២៤។
___. *សៀវភៅណែនាំកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ,* ២០១០។
___. *សៀវភៅណែនាំស្តីពីពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ,* ២០២១។
___. *សៀវភៅណែនាំស្តីពីពន្ធលើអចលនទ្រព្យ,* ២០១៣។
ហាប់ ផល្ញី. *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ១៩៨៥-២០១៥.* បោះពុម្ពលើកទី៥, ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០២២។
___. *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ២០១៦-២០២៣.* ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០២៣។
___. *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា.* ភ្នំពេញ. ព្រៃមៀម អ៊ែតវីថាយស៊ីង, ២០២១។
___. *វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា.* បោះពុម្ពលើកទី៤. ភ្នំពេញ, ២០២៣។
ហ៊ែល ចំរើន. "វិវាទដីធ្លីនៅកម្ពុជា." និក្ខេបបទបណ្ឌិត, សាកលវិទ្យាល័យប៉ារីស១ ប៉ង់តេអុង-សកបោន, ២០០៨។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ការស្រង់មតិសាធារណជន "Questionnaire survey R.M"

**ទីតាំង៖** ភូមិ……………… ឃុំ/សង្កាត់………………….. ស្រុក/ខណ្ឌ…………………..ខេត្ត/ក្រុង……………..

**កាលបរិច្ឆេទ៖** ថ្ងៃទី…………ខែ…………..ឆ្នាំ២០២៤

១. ភេទ

☐ ក. ប្រុស

☐ ខ. ស្រី

២. អាយុ

☐ ក. ១៨-២៩ឆ្នាំ

☐ ខ. ៣០-៣៩ឆ្នាំ

☐ គ. ៤០-៤៩ឆ្នាំ

☐ ឃ. ៥០-៥៩ឆ្នាំ

☐ ង. ចាប់ពី៦០ឆ្នាំឡើងទៅ

៣. តើអាសយដ្ឋានបច្ចុប្បន្ន អ្នករស់នៅទីណា?

☐ ក. រាជធានីភ្នំពេញ

☐ ខ. រស់នៅតាមខេត្ត

៤. នៅក្នុងគ្រួសារ អ្នកជា?

☐ ក. មេគ្រួសារ

☐ ខ. សមាជិកគ្រួសារ

៥. តើសមាជិកក្នុងគ្រួសាររបស់អ្នក មានចំនួនប៉ុន្មាននាក់?(ឧទាហរណ៍.បើមាន5នាក់សូមលោក លោកស្រីសរសេរថា 5)

……………………………………………………………………………………………………………

៦. តើអ្នក ឬចំនួនសមាជិកគ្រួសារអ្នកខាងលើនេះ មានដី ឬលំនៅឋាន ចំនួនប៉ុន្មានក្បាលដី? (ឧទាហរណ៍. បើមាន 2 ក្បាលដី សូមលោក លោកស្រីសរសេរថា 2)

……………………………………………………………………………………………………………

៧. តើដី ឬលំនៅឋានរបស់អ្នកបានចុះបញ្ជីអចលនវត្ថុ ឬចុះបញ្ជីវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង) ឬនៅ? (ឧទាហរណ៍. បើមាន 2 ក្បាលដីចុះបញ្ជី សូមលោក លោកស្រីសរសេរថា 2)

……………………………………………………………………………………………………………

៨. តើអ្នកធ្លាប់មានទំនាស់លើដីធ្លី ឬលំនៅឋាននោះដែរឬទេ?

☐ ក. ខ្ញុំមិនមានដីខ្លួនឯងទេ បច្ចុប្បន្ន

☐ ខ. ធ្លាប់មានទំនាស់ដីធ្លី

☐ គ. មិនធ្លាប់មានទំនាស់ដីធ្លីទេ

**៩. ការចុះបញ្ជីអចលនវត្ថុខាងលើនេះ តើអ្នកអញ្ជើញទៅស្នើសុំចុះបញ្ជីដោយខ្លួនឯងផ្ទាល់ឬយ៉ាងណា?**

☐ក. ខ្ញុំបានទៅចុះបញ្ជីខ្លួនឯង

☐ខ. ពឹងពាក់ឲ្យសមាជិកគ្រួសារណាម្នាក់ទៅចុះបញ្ជីឲ្យ

**១០. នៅពេលអ្នកអញ្ជើញទៅស្នើសុំចុះបញ្ជីអចលនវត្ថុ ចំពោះការបំពេញពាក្យស្នើសុំចុះបញ្ជី តើអ្នកបំពេញព័ត៌មានដោយខ្លួនឯងឬយ៉ាងណា?**

☐ក. ខ្ញុំបំពេញដោយខ្លួនឯង ឬសមាជិកគ្រួសាររបស់អ្នកណាម្នាក់ជួយបំពេញ

☐ខ. ខ្ញុំបានពឹងពាក់ឲ្យមន្ត្រីសុរិយោដីជួយបំពេញឲ្យ

**១១. តើអ្នកអញ្ជើញទៅចុះបញ្ជីអចលនវត្ថុ នៅទីណា?**

☐ក. ការិយាល័យច្រកចេញចូលតែមួយ នៅក្បែរស្រុក ខណ្ឌ ឃុំ សង្កាត់របស់ខ្ញុំ

☐ខ. អាជ្ញាធរឃុំ សង្កាត់ (មេឃុំ ចៅសង្កាត់ ឬស្មៀន)

☐គ. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ

**១២. តើអ្នកយល់ថា ដំណើរការសេវាចុះបញ្ជីអចលនវត្ថុរបស់មន្ត្រីទទួលបន្ទុក ផ្តល់សេវាជូនមានលក្ខណៈបែបណា?**

☐ក. ពេញចិត្ត

☐ខ. ពេញចិត្តផង មិនពេញចិត្តផង

☐គ. មិនពេញចិត្ត

**១៣. តើអ្នកយល់ថាការផ្តល់សេវាចុះបញ្ជីនេះ មានភាពលំបាកដែរឬទេ? ហេតុអ្វីបានជាអ្នកយល់ថាលំបាក តើការលំបាកនោះនៅត្រង់ដំណើរការមួយណា? តើអ្នកអាចផ្តល់មតិពិតប្រាកដមួយ ដើម្បីអាចកែតម្រូវស្ថាបនាក្នុងការចុះបញ្ជីអចលនវត្ថុនៅកម្ពុជា ឲ្យមានប្រសិទ្ធភាពទៅថ្ងៃខាងមុខបានដែរឬទេ?**

…………………………………………………………………………………………………

…………………………………………………………………………………………………

**១៤. តើអ្នកចង់ឲ្យមានដំណើរការសេវាចុះបញ្ជីអចលនវត្ថុតាមប្រព័ន្ធអនឡាញដែរឬទេ?**

☐ក. ល្អណាស់ គួរតែមាន

☐ខ. មិនចាំបាច់ មានក៏បាន អត់ក៏បាន

☐គ. មិនគួរមានទេ

**១៥. ប្រសិនបើមាន តើអ្នកមានជំនឿ ទុកចិត្ត ចូលរួមសាទរ ក្នុងការដាក់ឲ្យប្រើប្រាស់សេវាចុះបញ្ជីអចលនវត្ថុតាមប្រព័ន្ធអនឡាញរបស់ប្រព័ន្ធបច្ចេកវិទ្យារាជរដ្ឋាភិបាលដែរឬទេ?**

☐ក. ទុកចិត្ត ១០០%

☐ខ. ទុកចិត្តតិចតួច ច្រើនជាង ៥០%

☐គ. មិនទុកចិត្តសោះ